ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ឆ្អឹងសពជនរងគ្រោះ...
- ការិយាល័យពត៌មានសាធារណៈ

លេខ៩៨ ខែមករា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ៥២ ខែមេសា ឆ្នាំ២០០៤


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ ឆ្អឹងសពជនរងគ្រោះ ....................១

**ផ្នែកឯកសារ**

◆ ប៉ុល អ៊ឹម អតីតសិល្បការិនីភូមិភាគ៣០៤ ....................៣

◆ សាររបស់សមមិត្ត ខៀវ សំផន ....................៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ ....................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អ្នកស្រុកបាធាយៈ ដើម្បីគ្រួសារនិងសេរីភាព ....................១០

◆ វាផ្ទុំងនឹងបដិវត្តន៍របស់ខ្មែរក្រហម ....................១២

◆ ស៊ុំ សុខនៈ ខ្ញុំយល់ហើយសង្គ្រាម ....................១៤

◆ ជីវិតយាយ សែម ហាន នៅភូមិចាន់គង់ ....................១៧

◆ ការសិក្សាអំពីរូបថតរបស់ អ៊ឹង វណ្ណៈ ....................១៩

**ផ្នែកច្បាប់**

◆ តុលាការអន្តរជាតិនៅរ៉្វាន់ដារកឃើញថា ....................២០

◆ អំពើប្រល័យពូជសាសន៍ ....................២១

◆ ផលវិបាកនៃសង្គ្រាមចំពោះជាតិពន្ធនៅកូសូវ៉ូ ....................២៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការវិវត្តន៍ចុងក្រោយនៃតុលាការកាត់ទោសខ្មែរក្រហម ....................៣៣

◆ ការិយាល័យពត៌មានសាធារណៈ ....................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ស្រមោលបង ....................៤៨

◆ ទឹកភ្នែកម៉ែ ....................៥៨




លលាដ៍សពភេទប្រុស អាយុពី២០ទៅ៤០ឆ្នាំ

ស្នាមរបួសៈ គ្រាប់បាញ់ចូលពីផ្នែកខាងលើជ្រុងខាងស្តាំនៃលលាដ៍ក្បាលសំដៅចុះទៅក្រោមឆ្លងកាត់ខួរក្បាលរួចធ្លាយចេញតាមផ្នែកខាងឆ្វេងនៃគល់កញ្ចឹងក ។




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ:** យិន នាន, អៀ ម៉េងទ្រី, សុខា អ៊ីរ៉ែន, សុខ វណ្ណៈ, ផាត រចនា, ហេង សុខផាន់ណា, អែម សុខឃីម, ឡុង ដានី, ម៉ាកូ ម៉ាល់កូវីក, ដាយអាន់ អូរិនធ្លីធីរ, អាន់ថូនី ដកឃីន **អ្នកនិពន្ធនិងស្រាវជ្រាវ:** លី សុផល, សូ ហ្វារីណា **ជំនួយការនិពន្ធនាយក:** សាន់ កល្យាណ **និពន្ធនាយករង:** សួ ប៊ុនស៊ូ **អ្នកបកប្រែ:** អេង កុកថាយ **និពន្ធនាយកទូទៅ:** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ:** មាស ប៊ុនថាន

*សំបុត្រ៖*

# ឆ្អឹងសពជនរងគ្រោះមិនអាចទទួលបាននូវយុត្តិធម៌ឡើយ លុះត្រាតែការពិតដែលឆ្អឹងសពទាំងនេះលាក់ទុក ត្រូវបានលាតត្រដាង

លលាដ៍សពទាំងដប់ដែលបានថតយកមកតាំងបង្ហាញក្នុងពិព័រណ៍នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង គឺជាឆ្អឹងសពដែលបានរក្សាទុកនៅក្នុងសារមន្ទីរនេះតាំងពីឆ្នាំ១៩៧៩ ។ ឆ្អឹងទាំងនេះត្រូវបានជីកកកាយយកមកពីវាលពិឃាតជើងឯក (មានទីតាំងនៅជាយក្រុងភ្នំពេញភាគខាងត្បូង ជាកន្លែងដែលអ្នកទោសគុកទួលស្លែងត្រូវបានយកទៅប្រហារជីវិត) និងទីតាំងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ។ ពិព័រណ៍នេះមានគោលបំណងបង្ហាញអំពីតម្លៃនៃភ័ស្តុតាងកោសល្យវិច័យនៅក្នុងការបង្រួបបង្រួមឯកសារដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់របបខ្មែរ-ក្រហម ។ គោលបំណងទីពីរគឺដើម្បីអប់រំសាធារណជនអំពីប្រភេទនៃពត៌មានដែលអាចប្រមូលបានតាមលក្ខណៈវិទ្យា-សាស្ត្រចេញពីឆ្អឹងសពរបស់ជនរងគ្រោះ ដើម្បីយកទៅបង្ហាញនិងចងក្រងជាភ័ស្តុតាងនៃអំពើឃាតកម្ម ឬអំពើប្រល័យពូជសាសន៍ ។



*លលាដ៍សពភេទប្រុស អាយុពី៣០ ទៅ៥០ឆ្នាំ*
*ស្នាមរបួសៈ ប្រហោងលលាដ៍ក្បាលនៅផ្នែកខាងស្តាំបង្កឡើងដោយការវាយដោយឧបករណ៍ទាល ។ ស្នាមប្រេះនៅផ្នែកខាងក្រោយជ្រុងខាងឆ្វេងនិងសៀតផ្កាខាងឆ្វេងបង្កដោយការវាយដោយកម្លាំងខ្លាំងផ្សេងៗគ្នា ។*

ក្រុមកោសល្យវិច័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមជាមួយអ្នកឯកទេសកោសល្យវិច័យមួយក្រុមមកពីប្រទេសកាណាដា បានសិក្សាទៅលើលលាដ៍សពជាច្រើននិងបានសម្រាំងយកលលាដ៍សពចំនួនដប់មកវិភាគ ។ លលាដ៍សពទាំងអស់ត្រូវបានជ្រើសរើសផ្អែកទៅលើសភាពលលាដ៍ កម្រិតនៃភាពពុកផុយនិងភាពខុសគ្នានៃរូបរាងស្លាកស្នាមរបួស ។ លលាដ៍សពមិនបានជ្រើសរើសដោយចៃដន្យទេ ដូច្នេះយើងក៏មិនអាចសន្និដ្ឋានថា ពីព្រោះតែលលាដ៍មួយជាលលាដ៍ភេទស្រីនោះគឺមាន១០ភាគរយនៃជនរងគ្រោះរបបខ្មែរក្រហមជាស្ត្រីនោះទេ ហើយក៏មិនអាចប្រមាណថា ដោយសារលលាដ៍ចំនួន៤មានស្នាមគ្រាប់កាំភ្លើងនោះគឺមាន៤០ភាគរយនៃជនរងគ្រោះត្រូវបានសម្លាប់ដោយការបាញ់នឹងកាំភ្លើងនោះដែរ ។

ក្រុមអ្នកឯកទេសបានរកឃើញស្នាមរបួសបីប្រភេទនៅលើលលាដ៍សព ដែលនាំដល់ការស្លាប់បាត់បង់ជីវិតរបស់បុគ្គលនីមួយៗ÷

- ◆ លលាដ៍ចំនួនពីរមានស្នាមរបួសដែលបង្កដោយឧបករណ៍ទាលប៉ះទង្គិចដោយកម្លាំងខ្លាំង (ដូចជា ស្នូកកាំភ្លើង ញញួរ អន្ទង ឬ ដំបង) ។
- ◆ លលាដ៍ចំនួនបួនមានស្នាមរបួសដែលបង្កដោយឧបករណ៍មុតស្រួច (ដូចជាកាំបិតផ្គាក់ ចប ឬ ពូថៅ) ។
- ◆ លលាដ៍ចំនួនបួនមានស្នាមគ្រាប់កាំភ្លើង ។

ពីដំបូង មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងដាក់តាំងលលាដ៍សពជាសាធារណៈ ប៉ុន្តែក្រោយមកមានភាពចម្រូង-ចម្រាស់គ្នានៅក្នុងសង្គមកម្ពុជា អំពីភាពមិនសមរម្យនៃការធ្វើដូច្នេះ ។ ប្រជាជនខ្មែរមួយចំនួនមានអារម្មណ៍មិនសុខស្រួលចំពោះការយកលលាដ៍សពទៅដាក់នៅក្នុងប្រអប់បិទជិត ។ ទោះបីជាគ្មានព្រលឹងសណ្ឋិតនៅក្នុងឆ្អឹងទាំងនេះក៏ដោយ ក៏ប្រជាជនខ្លះនៅមានជំនឿថា មិនគួរណាយកឆ្អឹងទៅតម្កល់នៅក្នុងទីបិទជិតនោះទេ ពីព្រោះព្រលឹងមិនអាចទៅកាន់សុគតិភពបាន ។ ប្រជាជនខ្មែរ

តែងតែយកសពរបស់អ្នកស្លាប់ទៅបូជា ហើយតម្កល់អដ្ឋិធាតុនៅក្នុងស្តូបដើម្បីឲ្យព្រលឹងរបស់អ្នកស្លាប់អាចធ្វើដំណើរទៅចាប់ជាតិថ្មី ។ ព្រះករុណា សម្តេច ព្រះ នរោត្តម សីហនុ បានបញ្ជាក់អំពីការមិនសព្វព្រះហឫទ័យរបស់ព្រះអង្គ ចំពោះគំនិតដាក់តាំងបង្ហាញលលាដ៍សពជាសាធារណៈ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដូចប្រជាជនកម្ពុជាជាច្រើននាក់ដែរ ជឿជាក់ថាឆ្អឹងសពរបស់ជនរងគ្រោះមានតួនាទីសំខាន់នៅក្នុងសង្គមខ្មែរ ។ ឆ្អឹងសពទាំងនេះជាការដាស់តឿនដល់កូនខ្មែរជំនាន់ក្រោយឲ្យស្គាល់អំពីការឈឺចាប់និងការវិនាសរបស់ប្រទេសយើង ហើយនិងមានតួនាទីស្វែងរកយុត្តិធម៌ដល់មនុស្សរាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិត និងអ្នកដែលសេសសល់ពីសេចក្តីស្លាប់ ។ ឆ្អឹងសពគឺជាភស្តុតាងបង្ហាញពីបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តឡើងពីឆ្នាំ១៩៧៥ដល់១៩៧៩ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយការគោរពចំពោះព្រះរាជបំណងប្រាថ្នារបស់ព្រះមហាក្សត្រដែលមិនឲ្យដាក់តាំងលលាដ៍សពដោយចំហ យើងក៏បានយកលលាដ៍ទៅដាក់នៅក្នុងបន្ទប់ដោយឡែកមួយនៅក្នុងសារមន្ទីរទួលស្លែង ដែលអនុញ្ញាតឲ្យតែមន្ត្រីផ្លូវការចូលទស្សនា (ដូចជាព្រះរាជអាជ្ញារបស់តុលាការខ្មែរក្រហមជាដើម) ។ ជោគវាសនាចុងក្រោយរបស់លលាដ៍សពទាំងនេះគួរត្រូវសម្រេចយ៉ាងណាៗ គឺនៅក្រោយពេលដែលតុលាការខ្មែរក្រហមបានបញ្ចប់ ។

លលាដ៍សពត្រូវបានតម្កល់នៅលើទម្រដូចៗគ្នាធ្វើអំពីបន្ទះឈើតូចៗ និងស្តើងៗពីរជាន់មានទុកប្រឡោះប៉ុនចង្អុលដៃនៅជ្រុងទាំងបួននៃទម្រដើម្បីឲ្យមានខ្យល់ចេញចូលដល់លលាដ៍សពដែលបង្កភាពងាយស្រួលឲ្យព្រលឹងសពចេញចូលតាមបំណងប្រាថ្នា ។ ដើម្បីការពារលលាដ៍សព យើងបានយកប្រអប់កញ្ចក់រាងការេមកគ្របពីលើ រួចបិទភ្ជាប់ទៅនឹងទម្រដោយកាវបិទកញ្ចក់ ។ ប្រអប់កញ្ចក់អាចរើចេញវិញបានដោយគ្រាន់តែយកឡាមមកចៀរកាវបិទកញ្ចក់ចេញ ដូច្នេះយើងអាចសម្អាតឬផ្លាស់ប្តូរទីតាំងលលាដ៍បាន ។

**ឆាំង យុ**



លលាដ៍សពភេទស្រី អាយុពី៣៥-៥០ឆ្នាំ
ស្នាមរបួសៈ ស្នាមកាប់ចំពីលើក្បាលផ្នែកខាងស្តាំ ។



លលាដ៍សពភេទប្រុស អាយុពី២៥ទៅ៤៥ឆ្នាំ
ស្នាមរបួសៈ ស្នាមកាប់មិនធ្លាយទៅក្នុងដោយឧបករណ៍មុតទៅលើផ្នែកខាងក្រោយជ្រុងខាងឆ្វេងនៃលលាដ៍ក្បាល ។



លលាដ៍សពភេទប្រុស អាយុពី២៥ទៅ៤៥ឆ្នាំ
ស្នាមរបួសៈ ស្នាមប្រេះជាច្រើនខ្សែចេញពីចំណុចប៉ះទង្គិចនឹងឧបករណ៍ទាលដែលវាយដោយកម្លាំងខ្លាំងទៅលើផ្នែកខាងក្រោយជ្រុងខាងស្តាំនៃលលាដ៍ក្បាល ។

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ប៉ុល អ៊ឹម អតីតសិល្បការិនីភូមិភាគ៣០៤

ប៉ុល អ៊ឹម មានឈ្មោះដើម ប៉ុល ស៊ាងលី ហៅ ទូច កើតក្នុងគ្រួសារកសិករក្រីក្រនៅភូមិអូរពីរ ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ឪពុករបស់ អ៊ឹម ឈ្មោះ ប៉ុល ឡី និងម្តាយឈ្មោះ ជា កុត ។ អ្នកទាំងពីរប្រកបរបរជាអ្នកស៊ីឈ្នួលធ្វើស្រែនិងកាប់ខសដើម្បីចិញ្ចឹមជីវិត ។

ក្នុងឆ្នាំ១៩៦៨ ដោយជួបប្រទះនឹងការលំបាកក្នុងជីវភាពគ្រួសាររបស់ អ៊ឹម បានផ្លាស់ទីលំនៅមករស់នៅក្នុងភូមិស្រែវង្វួល ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដើម្បីស៊ីឈ្នួលនិងធ្វើស្រែប្រវាស់ដីអ្នកស្រុក ។ ក្រោយមក ឪពុកម្តាយរបស់ អ៊ឹម មានលទ្ធភាពទិញបានដីស្រែទំហំមួយហិកតា ។ អ៊ឹម រស់នៅជាមួយឪពុកម្តាយរហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧០ ទើបចូលបដិវត្តន៍តាមការអូសទាញរបស់ប្រធានភូមិឈ្មោះ ហុក ដែលលួងលោម អ៊ឹម ឲ្យចូលជាសមាជិកក្រុមសិល្បៈ ។ បន្ទាប់ពីបានរស់នៅជាមួយឈ្មោះ មុន ជាប្រធានសិល្បៈក្នុងភូមិអស់មួយរយៈមក នៅចុងឆ្នាំ១៩៧១ អ៊ឹម ត្រូវបានផ្លាស់មកនៅក្នុងសិល្បៈសេនាធិការភូមិភាគ៣០៤ដែលមាន ឃួន ជាប្រធាន ។ អ៊ឹម ពេញចិត្តនឹងការងារនៅក្នុងក្រុមសិល្បៈជាខ្លាំង ដោយសារ ឃួន យកចិត្តទុកដាក់បំពាក់បំប៉ន ទាំងផ្នែកសម្ភារ ម្ហូបអាហារ និងថ្នាំសង្កូវ ។ បន្តិចម្តងៗ អ៊ឹម កាន់តែមានភាពស្និទ្ធស្នាលជាមួយ ឃួន រហូតដល់ពេលមួយ អ៊ឹម ហ៊ានខូចសីលធម៌ជាមួយ ឃួន ។ អ៊ឹម ត្រូវបាន ឃួន អប់រំឲ្យស្រឡាញ់និងស្មោះស្ម័គ្រចំពោះក្រុមសេ.អ៊ី.អា ហើយស្អប់ខ្ពើមអង្គការ ។ ក្នុងក្រុមសិល្បៈ អ៊ឹម ហាត់រៀនច្រៀងនិងសម្តែងជាមួយយុទ្ធនារីជាច្រើនទៀតមានដូចជា អែម, ស្រុន, ខុំ, ខន, ម៉ៃ, និង រឿន នៅក្នុងផ្ទះដោយឡែក ដោយមានអាហារហូបចុកគ្រប់គ្រាន់ និងទទួលបានការយកចិត្តទុកដាក់ពី ឃួន យ៉ាងពិសេសជាងអ្នកដទៃ ។ លើសពីនេះទៅទៀត អ្នកទាំងនេះមិនចាំបាច់ធ្វើពលកម្មដូចអ្នកសិល្បៈដទៃទេ ។ ឃួន បានអួតសរសើរ អ៊ឹម នៅចំពោះមុខគណៈសិល្បៈ កែវ, ម៉ៃ និង កុំ ថាជាមនុស្សសកម្មប្រយុទ្ធ និងមានវណ្ណៈភាពល្អ ដូច្នេះ អ៊ឹម គួរតែបានមុខតំណែងសំខាន់នឹងគេ ។ អ៊ឹម កាន់តែមានការទុកចិត្ត ទុកថ្នើមចំពោះ ឃួន ខ្លាំងឡើងៗ ។ ម្យ៉ាងវិញទៀត ឃួន បានផ្តល់ឱកាសឲ្យ អ៊ឹម បង្កើនភាពស្និទ្ធស្នាល និងសាមគ្គីជាមួយ កែវ, ម៉ៃ និង កុំ ដើម្បីងាយស្រួលក្នុងការអូសទាញមនុស្សនៅក្នុងក្រុមសិល្បៈទាំងអស់ឲ្យចូលក្នុងក្រុមសេ.អ៊ី.អា ។ ដោយគោរពតាមការអប់រំរបស់ ឃួន, អ៊ឹម បានអូសទាញឈ្មោះ ផៃ និង សី ដោយនិយាយថា ឃួន មានការអាណិតអាសូរ ផៃ និង សី ជាខ្លាំង ហើយចង់ឲ្យ ផៃ និង សី មានមុខតំណែងត្រឹមត្រូវដូចអ្នកដទៃៗ ។

នៅក្នុងឆ្នាំ១៩៧២ អ៊ឹម, ម៉ម, កុំ, អែម, និង ម៉ៃ បានទៅចូលរួមអង្គប្រជុំនៅមន្ទីរ ម-២២ ដែលមាន ឃួន ជាប្រធាន កែវ ជាអនុប្រធាន និង ប៉ាត ជាសមាជិក ។ គោលបំណងនៃការបើកអង្គប្រជុំ គឺដើម្បីខ្ទេសនាម អ៊ឹម ចូលជាសមាជិកពេញសិទ្ធិក្នុងក្រុមសេ.អ៊ី.អា និងផ្តាំផ្ញើចំពោះអ្នកទាំងឡាយដែលមានវត្តមាននៅក្នុងអង្គប្រជុំត្រូវស្មោះត្រង់ចំពោះសេ.អ៊ី.អា ។ សមាជិកទាំងអស់ពុំចាំបាច់ខ្វល់ខ្វាយពីតំណែងនិងការងារទេ ព្រោះនឹងត្រូវបានផ្តល់ការងារនិងមុខនាទីសំខាន់ៗជាបន្តបន្ទាប់មិនខាន ។

នៅក្នុងខែ១០ ឆ្នាំ១៩៧២ ឃួន បានហៅ កែវ, ម៉ម, កុំ និង អ៊ឹម មកប្រជុំដាក់ផែនការថ្មី ។ ក្នុងពេលប្រជុំ ឃួន បានលើកសរសើរសមាជិកក្រុមថាធ្វើការបានល្អ ចេះរក្សាការសម្ងាត់ និងចេះសាមគ្គីគ្នា ។ សមាជិកទាំងអស់ក៏បានរាយការណ៍អំពីសកម្មភាពរបស់ខ្លួនដែលបានខិតខំអូសទាញសមាជិកក្នុងក្រុមសិល្បៈឲ្យចូលក្នុងក្រុមសេ.អ៊ី.អា ។ ឃួន ចេះតែបន្តដាក់ផែនការឲ្យសមាជិករបស់ខ្លួនបន្តការអូសទាញកម្លាំងនារីនៅក្នុងក្រុមសិល្បៈឲ្យចូលរួមធ្វើសកម្មភាពក្បត់នឹងអង្គការ ។ ឃួន បានណែនាំសមាជិកទាំងអស់អំពីវិធីកសាងកម្លាំងគឺត្រូវនិយាយថា ឃួន មានការអាណិតអាសូរចំពោះមិត្តៗនៅក្នុងក្រុមសិល្បៈជាខ្លាំង

ចង់លើកមុខលើកមាត់ឲ្យមានការងារនិងមុខនាទីត្រឹមត្រូវនឹងគេ ។

អ៊ីម បន្តលើកសរសើរ ដៃ និង សី អំពីការច្រៀងពីរោះ សម្តែងបានល្អមានរូបរាងស្រស់ស្អាត មានសាមគ្គីភាពទូលាយ គួបផ្សំការផ្គត់ផ្គង់ពីសំណាក់ ឃួន និងគណៈសិល្បៈទាំងឡាយ រហូតដល់ ដៃ និង សី មានការទុកចិត្តហើយយល់ព្រមចូល សេ.អ៊ី.អា ។

ដោយសារ អ៊ីម ធ្វើការបានល្អ ឃួន តែងតែចេញមុខការពារ អ៊ីម រាល់ពេលដែលមានបញ្ហា និងដកហូតតំណែងអ្នកទាំងឡាយណាដែលហ៊ាននិយាយប៉ះពាល់ដល់ អ៊ីម ។

នៅចុងឆ្នាំ១៩៧២ ក្រុមសិល្បៈសេនាធិការ៣០៤ត្រូវបែងចែកជាពីរក្រុម គឺក្រុមសិល្បៈភូមិភាគ៣០៤ និងក្រុមសិល្បៈពិសេសភូមិភាគ៣០៤ដែលគ្រប់គ្រងដោយ អែម ។ អ៊ីម បាននៅក្នុងក្រុមសិល្បៈពិសេស ហើយនៅក្នុងខែ១ ឆ្នាំ១៩៧៣ ក្រុមនេះត្រូវចុះទៅសម្តែងនៅតាមមូលដ្ឋាន ។ មុនពេលចេញទៅសម្តែង ឃួន តែងតែកោះហៅសមាជិកក្នុងក្រុមមកប្រជុំដាក់ផែនការថ្មីជានិច្ច ។ សមាជិកទាំងអស់ត្រូវបានទូន្មានឲ្យខិតខំបំផុសបំផុលសមាជិកដទៃទៀតនៅក្នុងក្រុមសិល្បៈកុំឲ្យមានជំនឿលើការមាគ៌ាដឹកនាំរបស់អង្គការ និងឲ្យឃើញថា បដិវត្តន៍កាន់តែយូរទៅកាន់តែក្រទៅនិងស្មុគស្មាញឡើង ។ ផ្ទុយទៅវិញ ត្រូវខំអប់រំក្រុមសិល្បៈទាំងពីរឲ្យទៅជាកម្លាំងតែមួយ សុទ្ធតែកម្លាំងប្រឆាំងនឹងបដិវត្តន៍ អស់ជំនឿលើបដិវត្តន៍ ។ ចំពោះ អ៊ីម, ឃួន បានដាក់ផែនការឲ្យអូសទាញ ហ៊ាន ដែលសម្តែងជាមួយគ្នានៅតាមមូលដ្ឋាន ។ អ៊ីម ធ្វើតាមការណែនាំរបស់ ឃួន គឺខូចសីលធម៌ជាមួយ ហ៊ាន បន្ទាប់មកក៏ចោទ ហ៊ាន ថាចាប់បង្ខំខ្លួន ។ ដោយមានអន្តរាគមន៍ពីសំណាក់ ឃួន សមាជិកដទៃទៀត នៅក្នុងក្រុមជឿថា ហ៊ាន បានប្រព្រឹត្តខុសចំពោះ អ៊ីម ពិតមែន ។ ដោយគ្មានផ្លូវដោះសារ ហ៊ាន ក៏បានចងកសម្លាប់ខ្លួន ។

ក្រោយមក ឃួន បានស្នើឲ្យ កែវ បញ្ជូនក្រុមសិល្បៈពិសេសមកសម្តែងជូនគណៈបញ្ជាការកងទ័ពនៅសមរភូមិតាំងក្រសាំង ។ នៅឆ្នាំ១៩៧៤ ឃួន បានផ្ញើសំបុត្រឲ្យ កែវ បញ្ជូនក្រុមសិល្បៈទៅត្រៀមរៀបចំសម្តែងដើម្បីទទួលសម្តេច សីហនុ នៅក្នុងខេត្តសៀមរាប ។ ក្នុងការសម្តែងលើកនេះ ការជ្រើសសិល្បករមកសម្តែងមានភាពតឹងរ៉ឹង គឺអ្នកដែលពុំមានលក្ខណៈសម្បត្តិល្អ មានរូបរាងមិនសមរម្យ នឹងត្រូវដកចេញ ។ ដោយសារមានភាពច្របូកច្របល់នៅក្នុងក្រុមសិល្បៈបណ្តាលមកពីការបែងចែកអ្នកសម្តែងល្អនិងមិនល្អ អ្នកមានរូបរាងស្អាតមិនស្អាត ។ ឃួន បានប្រកាសហៅសមាជិកប្រជុំដើម្បីប្រាប់ឲ្យផ្អាកការបំផុសបំផុលមហាជនមួយរយៈសិនក្នុងគោលបំណងចៀសវាងការប៉ះពាល់ដល់អត្តភាពភូមិភាគឧត្តរ ។ ក្នុងពេលហាត់សម្តែង ឃួន ចាត់តាំង ឲ្យ អ៊ីម ឲ្យធ្វើជាតួសំខាន់ ។ ឃួន បានអួតសរសើរប្រាប់មេបញ្ជាការនានាថា ភូមិភាគឧត្តរសម្តែងបានល្អណាស់ ជាពិសេសគឺ អ៊ីម រាំបានល្អជាងគេ ។ ដោយសារមោទនភាពចំពោះខ្លួនឯងដែលត្រូវបាន ឃួន ស្រឡាញ់ទុកចិត្ត អ៊ីម បាននិយាយអុជអាលអ្នកដែលសម្តែងមិនបានល្អនិងមានរូបរាងមិនស្អាត រហូតដល់អ្នកនោះបាក់ទឹកចិត្តមិនចង់សម្តែង និងដកខ្លួនចេញពីការសម្តែង ។ ក្រៅពីនេះ អ៊ីម បាន អួតអាងថា


ក្រុមសិល្បៈខ្មែរក្រហម

យួន ជ្រោមជ្រែងខ្លួនឲ្យមានការងារល្អនិងជិតស្និទ្ធជាមួយខ្លួនខ្លាំងណាស់ ។

បន្ទាប់ពីសម្តែងនៅខេត្តសៀមរាបចប់ កម្លាំងសិល្បៈត្រូវបានបញ្ជូនមកមន្ទីរ គ-១៥ ហើយក្រោយមកត្រូវបែងចែកជាបីផ្នែក ខ្លះទៅសមរភូមិ ខ្លះទៅមូលដ្ឋាន និងខ្លះទៀតទៅរៀនពេទ្យ ។ អ៊ឹម, ដៃ, លេង, សែន, មឿន និង ហ៊ាន ត្រូវបានអង្គការស្នើមកធ្វើការនៅក្រសួងវិទ្យុដែលហៅថាមន្ទីរ ស-៦ នៅខែ៨ ឆ្នាំ១៩៧៤ ។ មុនពេលផ្លាស់ចេញពីក្រុមសិល្បៈពិសេស យួន បានហៅ អ៊ឹម មកទូន្មានឲ្យប្រយ័ត្នប្រយែងរាល់កិច្ចការផ្សេងៗ ព្រោះនៅក្រសួងវិទ្យុពុំមានបណ្តាញរបស់សេ.អ៊ី.អាច្រើនទេ ។ យួន ក៏បានណែនាំ អ៊ឹម កុំរៀបការ ទោះបីជាអ្នកណាស្នើក៏ដោយ ព្រោះនឹងខូចប្រយោជន៍ច្រើនណាស់ ។ ការងារដែលអង្គការប្រគល់ឲ្យ អ៊ឹម ធ្វើនៅមន្ទីរ ស-៦ គឺជាំបាយជូន អ៉ិភា (អៀង ធីរិទ្ធ) និង អៀង សារី និងបង្ហាត់ច្រៀង លេងភ្លេង ថតសិល្បៈ និងឲ្យទទួលខុសត្រូវខាងពលកម្មក្នុងក្រសួង ។ អ៊ឹម បន្តបង្កបញ្ហាដោយធ្វើឲ្យរអាក់រអួលក្នុងការបង្រៀនសម្តែងសិល្បៈ អូសបន្លាយពេលវេលា និងបំបែកបំបាក់សាមគ្គីភាពដោយនិយាយពីនេះពីនោះ ម្តងត្រូវជាមួយអ្នកនេះ ម្តងត្រូវជាមួយអ្នកនោះ ។



មួយខែបន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញដោយខ្មែរក្រហម គឺក្នុងខែ៥ ឆ្នាំ១៩៧៥ អ៊ឹម ត្រូវបានផ្លាស់មកធ្វើការនៅក្នុងក្រសួងឃោសនាការជាមួយ កែវ, ម៉ម, រុន, សែន, មឿន, ឆន និង លឹម ។ កែវ បានណែនាំសមាជិករបស់ខ្លួនឲ្យរក្សាភាពធម្មតាសិន ព្រោះកន្លងមកមានបញ្ហាប៉ះពាល់សាមគ្គីប្រឫកប្របល់ច្រើនណាស់រវាងក្រុមសិល្បៈនិងអ្នកធ្វើការនៅក្រសួងឃោសនាការ ។ ប្រសិនបើសម្រុកធ្វើការបំផុសបំផុលបន្តទៀតក្រែងអង្គការមានការសង្ស័យ ដូច្នេះត្រូវរង់ចាំមើលសភាព-ការណ៍ស្រួលបន្តិចសឹមបន្តសកម្មភាពឡើងវិញ ។ ក្នុងពេលបង្ហាត់សិល្បៈនៅក្រសួងឃោសនាការ អ៊ឹម ឆ្លៀតនិយាយសរសើរពីអ្នកនេះអ្នកនោះដើម្បីឲ្យអ្នកហាត់សិល្បៈមានការពេញចិត្តនឹងខ្លួន ដូច្នេះខ្លួនអាចបង្កើនកម្លាំងក្បត់បន្ថែមទៀត ។ ក្រៅពីនេះ អ៊ឹម នៅតែបន្តទំនាក់ទំនងជាមួយសមាជិកក្នុងក្រុមចាស់ទោះបីជាឥឡូវនេះធ្វើការនៅក្រសួងដោយឡែកពីគ្នាក៏ដោយ ។ ដល់ខែ១២ ឆ្នាំ១៩៧៥ យួន បានបញ្ជូនកម្លាំងបន្ថែមមកធ្វើការជាមួយ អ៊ឹម នៅក្រសួងឃោសនាការ មានឈ្មោះ ម៉ៃ, ឆេន, សី, រ៉ន, គង់, ភី, យូន, ឆាត និង វ៉េត ។

ខែ១ ឆ្នាំ១៩៧៦ យួន បានកោះហៅសមាជិករបស់ខ្លួនមកប្រជុំនៅសង្កាត់ប្រាំងចំរេះ ដើម្បីពិភាក្សាអំពីដំណើរការបំផុសបំផុលនិងនិយាយប្រាប់ពីបណ្តាញផ្សេងៗដើម្បីងាយស្រួលទាក់ទងគ្នា ។

ខែ២ ឆ្នាំ១៩៧៦ ភាស់ ជាគណៈក្រសួងឃោសនាការបានហៅ អ៊ឹម មកប្រាប់ថា មានបុរសឈ្មោះ ម៉ន បានស្នើសម្ភពភាពដើម្បីយក អ៊ឹម ជាគ្រួសារ ។ ភាស់ បានពន្យល់ អ៊ឹម ថា ទោះបីជា អ៊ឹម មានគ្រួសារក៏មិនប៉ះពាល់ដល់ការសម្តែងសិល្បៈដែរ ឲ្យតែ អ៊ឹម ខំជម្នះ ។ អ៊ឹម បានបដិសេធយ៉ាងដាច់អហង្កា ប៉ុន្តែ ភាស់ នៅតែព្យាយាមរកហេតុផលដើម្បីឲ្យ អ៊ឹម ទទួលសំណើនេះ ។ អ៊ឹម ក៏យល់ព្រមប៉ុន្តែបានលួចផ្តល់ដំណឹងដល់ យួន

ដើម្បីឲ្យជួយ ។ ឃួន បានសរសេរសំបុត្រមក ភាស់ ដើម្បី អន្តរាគមន៍ក្នុងរឿងនេះ ។ ភាស់ ក៏បញ្ឈប់ការរៀបការរវាង អ៊ឹម និង ម៉ាន ប៉ុន្តែនៅក្នុងពេលដដែល ភាស់ បានរៀបចំ អ៊ឹម ជាមួយ ឡុង ដោយពុំទទួលយកការគេចវេះរបស់ អ៊ឹម តទៅទៀត ។ ក្រោយមក ឡុង ត្រូវបានលួចសម្លាប់ដោយសារ ឡុង និយាយ អំពីការខូចសីលធម៌រវាង ឃួន និងកូនក្រុម ។

បន្ទាប់ពីការស្លាប់របស់ ឡុង, ឃួន ត្រូវអង្គការចាប់ខ្លួន ហើយក្រុមសិល្បៈត្រូវចេញទៅសម្តែងនៅខេត្ត ទុកតែកម្លាំង តិចតួចនៅធ្វើការតាមមន្ទីរ មានដូចជា អ៊ឹម, ស៊ឹម, ឆេន, និង ឃី ប៉ុណ្ណោះ អ្នកឯទៀតត្រូវបញ្ជូនទៅធ្វើចម្ការ ។ បន្ទាប់ពី ឃួន ត្រូវចាប់ខ្លួន សមាជិកក្នុងក្រុមពុំហ៊ានបំផុសបំផុលទៀតទេ ។ នៅក្នុងខែ៩ ឆ្នាំ១៩៧៦ អ៊ឹម បានរៀបគ្រួសារម្តងទៀតជាមួយ ម៉ាន ក្រោមការរៀបចំរបស់ ភាស់ ដដែល ។ អ៊ឹម ចាប់ផ្តើមធ្វើ ការអូសទាញកម្លាំងបន្តទៀត រាល់ពេលដែលចេញទៅសម្តែងសិល្បៈ នៅទីកន្លែងផ្សេងៗ ។ ខែ១១ ឆ្នាំ១៩៧៦ អ៊ឹម ត្រូវបានបញ្ឈប់ ពីការសម្តែងសិល្បៈ ហើយធ្វើការងារថ្មីគឺនិពន្ធចម្រៀង និងវាយ អង្គុលីលេខនៅក្រសួងឃោសនាការ ។

នៅខែ១២ ឆ្នាំ១៩៧៦ អ៊ឹម, ដៃ និង សី ត្រូវបាន ភាស់ ជ្រើសរើសឲ្យទទួលភ្ញៀវចិនដែលមកថតភាពយន្តនៅប្រទេស កម្ពុជា ។ ភាស់ កាន់តែមានការទុកចិត្តនិងស្រឡាញ់ចំពោះអ្នក ទាំងបីជាខ្លាំង បណ្តាលឲ្យអ្នកទាំងបីកាន់តែហ៊ានធ្វើសកម្មភាព បំផុសបំផុលអ្នកនៅក្រសួងឃោសនាការថែមទៀត ។

ចាប់ពីខែ១ ឆ្នាំ១៩៧៧ ភាស់ បានប្រាប់ អ៊ឹម ឲ្យនិពន្ធ អត្ថបទអត្ថាធិប្បាយសម្រាប់ផ្សាយតាមវិទ្យុដោយពុំយកតាម អត្ថបទកាសែតរបស់អង្គការឡើយ ។ ចំពោះអត្ថបទកាសែត ដែលតម្រូវឲ្យអានចាក់ផ្សាយតាមវិទ្យុក៏ ភាស់ បញ្ជាឲ្យកែប្រែ ខ្លឹមសារមួយចំនួនដោយលើកហេតុផលថា កាសែតធ្វើសម្រាប់ ផ្ទៃក្នុង មិនអាចផ្សាយជាចំហទាំងស្រុងបានទេ ពាក្យមួយចំនួន ត្រូវតែកាត់ចេញ ឧទាហរណ៍ពាក្យថា "សម្រេចពី៣តោនទៅ៦ តោន" "វាយកម្ទាត់កម្មសិទ្ធិឯកជន" និង"សម្រួចគោលជំហរ សមូហភាពខ្ពស់" ។ល ។ ដោយសារតែហេតុនេះ ភាស់ ត្រូវ អង្គការចាប់ខ្លួន ។ បន្ទាប់ពីចាប់ខ្លួន ភាស់ អង្គការបានបញ្ជាឲ្យ យឹម ប្រជុំក្រុមអ្នកនិពន្ធហើយប្រាប់ថា អ្នកនិពន្ធទាំងអស់មិនមាន សិទ្ធិកែឬកាត់ចោលខ្លឹមសារអត្ថបទរបស់អង្គការដាច់ខាត ត្រូវតែ ផ្សាយវិទ្យុទាំងអស់ បើផ្សាយទៅមានហេតុផលយ៉ាងណាអង្គការ ជាអ្នកទទួលខុសត្រូវ ។

ថ្ងៃទី៧ ខែឧសភា ឆ្នាំ ១៩៧៧ អ៊ឹម ក៏ត្រូវអង្គការចាប់ខ្លួន បញ្ជូនមកមន្ទីរ ស-២១ ហើយត្រូវកម្ទេចនៅថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៧៧ ។

**ផាត រចនា**

# សាររបស់សមមិត្ត ខៀវ សំផន ឆ្នាំ១៩៧៨

ព្រះករុណាជាទីគោរព

ឬឯកឧត្តមជាទីគោរព

សន្និសីទរដ្ឋមន្ត្រីការបរទេសនៃប្រទេសមិនចូលបក្សសម្ព័ន្ធ នៅបែលក្រាតកាលពីចុងខែកក្កដា ១៩៧៨ បានបដិសេធ សកម្មភាពជ្រៀតជ្រែកនិងបំបាក់បំបែកចលនាយើង របស់មហា អំណាចចក្រពត្តិនិយមនិងវាតទីនិយមនិងបក្សពួក ។ ជាពិសេស សន្និសីទបានបដិសេធការប៉ុនប៉ងរបស់មហាអំណាចវាតទីនិយម និងបក្សពួកដែលចង់ប្រែក្លាយគោលការណ៍មិនចូលបក្សសម្ព័ន្ធ ហើយឲ្យចលនាមិនចូលបក្សសម្ព័ន្ធទទួលមនោគមវិជ្ជារបស់ពួក គេដើម្បីគេអូសទាញចលនានេះបំរើនយោបាយប៉ុករបស់ពួកគេ ។

ដោយធ្វើអីនៅបែលក្រាតមិនបាន មហាអំណាចវាតទីនិយម និងបក្សពួកនឹងដំណើរការតទៅទៀតនៅពេលប្រជុំកំពូលខាងមុខ ។ ពួកគេបំរុងនឹងយកថានៈរបស់គុយបាដែលនឹងទទួលសន្និសីទកំពូល នៃចលនាមិនចូលបក្សសម្ព័ន្ធលើកទី៦ និងធ្វើជាប្រធាននៃចលនា

ក្នុងរយៈ៣ឆ្នាំ ដើម្បីបន្តអនុវត្តផែនការរបស់គេអូសចលនាយើងទៅចូលបក្ខគេ ។

ប្រទេសជាសមាជិកនៃចលនាយើងស្ទើងទាំងអស់បានបញ្ចេញមតិដោយចំហនិងមិនចំហ សំដែងការព្រួយបារម្ភចំពោះអនាគតនៃចលនាយើង ។ ការព្រួយបារម្ភនេះមានហេតុផលត្រឹមត្រូវណាស់ ។ ភ័ស្តុតាងគ្រប់វិស័យ នយោបាយ យោធា សេដ្ឋកិច្ច ទូត ។ល ។ បង្ហាញច្បាស់ថា គុយបាចូលក្នុងបក្ខរបស់មហាអំណាចវាតទីនិយមហើយ ។ គុយបាលែងនៅជាប្រទេសមិនចូលបក្សសម្ព័ន្ធហើយ ។ កាលប្រជុំកំពូលលើកទី៥ នៅកូឡុំបូ ប្រទេសមិនចូលបក្សសម្ព័ន្ធមិនបានប៉ាន់ប្រមាណថាគុយបាក្បត់គោលការណ៍មិនចូលបក្សសម្ព័ន្ធដល់កំរិតដូចសព្វថ្ងៃនេះទេ ។

ប្រការមួយទៀតដែលគួរយកចិត្តទុកដាក់គឺយួនដែលដើរតួស៊ីរូងក្នុងចលនាមិនចូលបក្សសម្ព័ន្ធដូចគុយបាដែរ បានចូលក្នុងបក្ខនៃមហាអំណាចវាតទីនិយមជាចំហហើយ ។ យួនខិតខំដំណើរការជាមួយគុយបាដើម្បីអូសចលនាយើងទៅចូលខាងបក្ខមហារំលោភវាតទីនិយមក្នុងគោលបំណងសំរួលដល់អំពើឈ្លានពានវាតទីលេបទឹកដីកម្ពុជានិងយុទ្ធសាស្ត្រ“សហព័ន្ធឥណ្ឌូចិន”របស់វា និងដល់មហិច្ឆតាវាតទីតំបន់របស់វានៅអាស៊ី-អាគ្នេយ៍ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំយល់ដូចប្រទេសមិនចូលបក្សសម្ព័ន្ធដ៏កុះករថា បើទៅប្រជុំនៅឡាហាវ៉ាននោះនឹងលើកទឹកចិត្តដល់មហាអំណាចវាតទីនិយមនិងបក្សពួកមិនខាន ។ ក្នុងពេលប្រជុំនោះ ដោយពួកគេខ្វាចកម្លាំងដ៏មហិមានៃប្រទេសមិនចូលបក្សសម្ព័ន្ធ គុយបា យួន អាចធ្វើសម្បទានលើក្រដាសខ្លះ ។ នេះជាកល្បិចមួយរបស់មហាអំណាចវាតទីនិយមនិងបក្សពួក ។ ពីព្រោះសំខាន់ពួកគេដែលកំពុងឯកោ ខំសំរួលយ៉ាងណាឱ្យបានក្តាប់ចលនាមិនចូលបក្សសម្ព័ន្ធខាងចាត់តាំងសិន ។ កាលណាគុយបាបានធ្វើជាប្រធានចលនាហើយ ក្នុងរយៈបីឆ្នាំនេះមហាអំណាចវាតទីនិយមនិងបក្សពួកនឹងបំភ្លៃគោលការណ៍និងមូលដ្ឋាននយោបាយមិនចូលបក្សសម្ព័ន្ធ ហើយអូសចលនានេះទៅបំរើនយោបាយឈ្លានពាននិងវាតទីនៃបក្ខរបស់ពួកគេ ។ គុយបាខ្លួនឯងនឹងពង្រីកសកម្មភាពនៅអាហ្វ្រិកនិងមជ្ឈិមបូព៌ាក្នុងឋានៈជាកងទ័ពស៊ីឈ្នួល ។ ឯយួនក្នុងឋានៈជាប៉ុស្តិ៍ប៉មខាងមុខនៅអាស៊ី-អាគ្នេយ៍នៃមហាអំណាចវាតទីនិយម នឹងបង្កើនអំពើវាយលុក ឈ្លានពានកម្ពុជា ដើម្បីយកកម្ពុជាជាឈ្នាន់ឈានទៅវាតទីនៅតំបន់អាស៊ី-អាគ្នេយ៍ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រវាតទីនិយមលើសកលលោករបស់មហាអំណាចវាតទីនិយម ដូច្នេះកត្តាសង្គ្រាមលោកកាន់តែរីកធំឡើងទៀត ។

ហេតុនេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ក៏ដូចរដ្ឋាភិបាលប្រទេសមិនចូលបក្សសម្ព័ន្ធជាច្រើនឯទៀត សំរេចថាប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យក្តី ឬរដ្ឋមន្ត្រីទីមួយនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្តី នឹងមិនចូលរួមក្នុងការប្រជុំកំពូលនៃចលនាមិនចូលបក្សសម្ព័ន្ធទេ បើការប្រជុំនេះធ្វើនៅឡាហាវ៉ាន ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សូមស្នើចំពោះរដ្ឋាភិបាលព្រះករុណា ឬឯកឧត្តម កុំឱ្យមានប្រជុំកំពូលនៃចលនាមិនចូលបក្សសម្ព័ន្ធនៅឡាហាវ៉ាន ។ ហើយសូមស្នើថា ឬមួយជ្រើសរើសរដ្ឋធានីមួយទៀតដើម្បីប្រជុំកំពូល ឬមួយក៏ពន្យារពេលប្រជុំកំពូលទៅថ្ងៃក្រោយ ដូចរដ្ឋាភិបាលប្រទេសមិនចូលបក្សសម្ព័ន្ធមួយចំនួនបានស្នើរួចមកហើយ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំនឹងទាក់ទងជាមួយរដ្ឋាភិបាលប្រទេសមិនចូលបក្សសម្ព័ន្ធខំប្រឹងប្រែងតទៅទៀត ធ្វើយ៉ាងណាឱ្យធានាដល់គោលការណ៍នៃចលនាយើង និងដល់អនាគតនៃចលនាយើងក្នុងឋានៈជាកម្លាំងឯករាជនៅក្រៅបក្ខណាទាំងអស់ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំមានជំនឿជានិច្ចលើអនាគតដ៏ខ្លាំងក្លានៃចលនាមិនចូលបក្សសម្ព័ន្ធយើង ដែលផ្អែកលើឆន្ទៈឯករាជ្យមិនចូលបក្ខណា លើការតស៊ូនិងរបស់ប្រទេសមិនចូលបក្សសម្ព័ន្ធយើងដ៏កុះករ ។

សូមទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់បំផុតរបស់យើងខ្ញុំ ។

ភ្នំពេញ ថ្ងៃ...១៩៧៨

**ខៀវ សំផន**

ប្រធានគណៈប្រធានរដ្ឋ

កម្ពុជាប្រជាធិបតេយ្យ

(ឯកសារលេខ **D**០០១២៨)

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៣១៣ | សាប់ ភឿន | យុទ្ធជន | ពាណិជ្ជកម្ម | ១៧-១០-៧៦ | ៦-១២-៧៦ |
| ១៣១៤ | លាង ចាន់ថេន (ស្រី) | គ្រូបង្រៀន | រោងពុម្ព ក-២៨ | ១១-១០-៧៦ | ៦-១២-៧៦ |
| ១៣១៥ | អ៊ីង វាត់ឈីវ (ស្រី) | វេជ្ជបណ្ឌិត | ស្រុកបារាំង | ១២-១០-៧៦ | ៦-១២-៧៦ |
| ១៣១៦ | វិន សុភ័ណ (ស្រី) | ប្រពន្ធ យៀម សុកជា | ស្រុកបារាំង | ១០-១០-៧៦ | ៦-១២-៧៦ |
| ១៣១៧ | ត្រាំ គីមយូយ (ស្រី) | គ្រូបង្រៀន | តាខ្មៅ | ២៣-៩-៧៦ | ៦-១២-៧៦ |
| ១៣១៨ | ហ៊ូ ម៉ៃ ហៅ គុណ (ស្រី) | កម្មករថ្មី | ថាមពល | ២៣-១០-៧៦ | ៦-១២-៧៦ |
| ១៣១៩ | ញ៉ឹក ហ៊ិន ហៅ រ៉េន | អនុកងហា | ផ្សារក្រុង | ១២-៨-៧៦ | ៦-១២-៧៦ |
| ១៣២០ | ភួង អាន | ប្រជាជន | តំបន់៣៣ | ៤-៨-៧៦ | ៦-១២-៧៦ |
| ១៣២១ | កង លាប | វរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣២២ | ឆាន គ្រេះ ហៅ សេង | វរសេនាតូច | កងពល២៩០ | ?-៩-៧៦ | ៦-១២-៧៦ |
| ១៣២៣ | នៀម សុវ៉ាង ហៅ សុវណ្ណ | យុទ្ធជន | ប្រាំងចំរេះ | ?-៩-៧៦ | ៦-១២-៧៦ |
| ១៣២៤ | កាន់ ស៊ីម ហៅ ម៉ុន | កងហា | រោងចក្រកង់ឡាន | ៩-១០-៧៦ | ៦-១២-៧៦ |
| ១៣២៥ | ប៉ុញ ជីន | វរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣២៦ | គុន ភឿង ហៅ ឈាន | ឧស្សាហកម្ម | តំបន់៣៣ | ៧-១០-៧៦ | ៦-១២-៧៦ |
| ១៣២៧ | ហែម លុន ហៅ សុភឿន | វរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣២៨ | ព្រូ ស្រ៊ុន | កម្មករចាស់ | រោងចក្រប្រេងកន្ទក់ | ?-៩-៧៦ | ៦-១២-៧៦ |
| ១៣២៩ | ផែង ភាព | កម្មករថ្មី | រោងពុម្ព ក-២៨ | ១០-១០-៧៦ | ៦-១២-៧៦ |
| ១៣៣០ | កែវ គុង | អនុក្រុម | ដឹកជញ្ជូនជើងទឹក | ៩-១០-៧៦ | ៦-១២-៧៦ |
| ១៣៣១ | ម៉ក់ មៀន | កម្មករថ្មី | រទេះភ្លើង | ១៦-៩-៧៦ | ៦-១២-៧៦ |
| ១៣៣២ | ឡុង ឡេងឈីង | ប្រធានរោងចក្រ | ស្រុកបារាំង | ១២-១០-៧៦ | ៦-១២-៧៦ |
| ១៣៣៣ | ដៃ ជួន | មេក្រុម | តំបន់១៥ | ២៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៣៤ | ងួន ពេញ | វរសេនាធំ | កងពល២៩០ | ១-១០-៧៦ | ៦-១២-៧៦ |
| ១៣៣៥ | ហួត ឆេង | កម្មករចាស់ | រទេះភ្លើង | ១៤-៩-៧៦ | ៦-១២-៧៦ |
| ១៣៣៦ | មៀក ម៉េដា | កម្មករចាស់ | រោងចក្រ ក-២ | ១២-៨-៧៦ | ៦-១២-៧៦ |
| ១៣៣៧ | ប៉ុក ពក | ប្រជាជន | តំបន់២៥ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៣៨ | ហេង ហួន | សក្តិ១ | តាខ្មៅ | ១-៩-៧៦ | ៦-១២-៧៦ |
| ១៣៣៩ | ស៊ីង សេង | លោកសង្ឃ | យួន | ១៦-៩-៧៦ | ៦-១២-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១៣៤០ | ម៉ឺន លាត ហៅ វឿន | កងវរយ | ឃុំកង្គ | ៤-៩-៧៦ | ៦-១២-៧៦ |
| ១៣៤១ | សុក ជឿន | យុវជនកងចល័ត | តំបន់៣២ | ១៤-១០-៧៦ | ៦-១២-៧៦ |
| ១៣៤២ | សុក អឿន ហៅ ស អឿន | វរសេនាតូច | កងពល១៧០ | ៣០-៨-៧៦ | ៦-១២-៧៦ |
| ១៣៤៣ | ទឹម សារិន ហៅ តឹក | អាត់សាដង់ | តាឡី | ៣០-៨-៧៦ | ៦-១២-៧៦ |
| ១៣៤៤ | ណុប វ៉ន ហៅ ពា | យុទ្ធជនពាណិជ្ជកម្ម | កំពង់សោម | ២០-៦-៧៦ | ៦-១២-៧៦ |
| ១៣៤៥ | ភិន ភាព | យុទ្ធជន | រោងចក្រប្រេងកាត | ២៨-៦-៧៦ | ៦-១២-៧៦ |
| ១៣៤៦ | កោះ ឡាយ | កម្មករថ្មី | រ៉ោរទេះភ្លើងរមាស | ១០-៨-៧៦ | ៦-១២-៧៦ |
| ១៣៤៧ | សាត់ ហេ ហៅ ហៀក | អនុកងវរយ | ឃុំកង្គ | ?-៨-៧៦ | ៦-១២-៧៦ |
| ១៣៤៨ | ស សមិត្ត ហៅ ស្ទួត | មេក្រុម | កងពល១៧០ | ២៣-៩-៧៦ | ៦-១២-៧៦ |
| ១៣៤៩ | ម៉ុក សូវុធ | អគ្គការសហប្រជាជាតិ | អាមេរិក | ២៤-៩-៧៦ | ៦-១២-៧៦ |
| ១៣៥០ | សួស ចន | វរសេនាតូច | ឃុំកង្គ | ៦-៩-៧៦ | ៦-១២-៧៦ |
| ១៣៥១ | មាស លាន ហៅ សារី | យុទ្ធជន | កងពល១៦៤ | ៧-៥-៧៦ | ៦-១២-៧៦ |
| ១៣៥២ | ហ៊ីង ស៊ីផាត ហៅ គឹមសុត | សត្តិ២ | តាឡី | ៣១-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៣ | ប៉ូវ លីម ហៅ សិទ្ធ | វរសេនាតូច | កងពល១៧០ | ៣០-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៤ | អាន ឃាន់ | យុទ្ធជន | ផាមពល | ?-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៥ | ខៀវ វ៉ុម | ជាងផត | កងពល៥០២ | ៦-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៦ | សៅ ឆេង | ប្រជាជន | តំបន់២៥ | ១៨-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៧ | ឌុប យ៉ន ហៅ យ៉ុន | ព្រិទ្ធបាលឯក | តាឡី | ៣១-៨-៧៦ | ៦-១២-៧៦ |
| ១៣៥៨ | ឯក ភឿង ហៅ ភាព | មេក្រុម | ផ្សារក្រុង | ១២-៩-៧៦ | ៦-១២-៧៦ |
| ១៣៥៩ | កែប ថា ហៅ ម៉ុល | យុទ្ធជន | កងពល៣១០ | ?-៨-៧៦ | ៦-១២-៧៦ |
| ១៣៦០ | គុយ ជា | ទូត | រុស្ស៊ី | ២៣-៩-៧៦ | ៦-១២-៧៦ |
| ១៣៦១ | ប៉ាត់ សុកយ៉ាន | យុទ្ធជន | ដឹកជញ្ជូនជើងគោក | ១១-៩-៧៦ | ៦-១២-៧៦ |
| ១៣៦២ | សុក ឃីម | កម្មករចាស់ | រោងចក្រ គ-១០ | ៤-១០-៧៦ | ៦-១២-៧៦ |
| ១៣៦៣ | ហ៊ុល គាប | រទេះភ្លើង | បាត់ដំបង | ១៥-៩-៧៦ | ៦-១២-៧៦ |
| ១៣៦៤ | ផន ប៉េងស៊ាង | យុទ្ធជន | កងពល៥០២ | ១១-៩-៧៦ | ៦-១២-៧៦ |
| ១៣៦៥ | នួន ខុង ហៅ សារិន | កម្មករថ្មី | រោងចក្រ ក-២ | ៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៦៦ | មាន ជឿន | យុទ្ធជន | ផ្សារក្រុង | ១៤-៨-៧៦ | ៦-១២-៧៦ |
| ១៣៦៧ | អ៊ឹង រស់ស៊ីទួន | បើកឡានដឹកទំនិញ | វៀតណាម | ១៥-៩-៧៦ | ៦-១២-៧៦ |
| ១៣៦៨ | ព្រំ សឿន | អគ្គិសនី | មន្ទីរ ស-៨ | ៤-៨-៧៦ | ៦-១២-៧៦ |
| ១៣៦៩ | មាស អាន ហៅ អុល | កម្មករថ្មី | កំពង់សោម | ២៩-៩-៧៦ | ៦-១២-៧៦ |
| ១៣៧០ | ភួង បូជា | កម្មករចាស់ | អគ្គិសនី | ៤-៨-៧៦ | ៦-១២-៧៦ |

**(នៅមានត)**

# អ្នកស្រុកបាធាយៈ ដើម្បីគ្រួសារនិងសេរីភាព

ស្រុកបាធាយស្ថិតនៅក្នុងខេត្តកំពង់ចាម ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ស្រុកបាធាយបានក្លាយទៅជាតំបន់ប្រទាញប្រទង់គ្នារវាងកងទ័ពខ្មែរក្រហមនិងទាហានលន់ណុល ។ យុវជនយុវនារីជាច្រើនបានចូលបម្រើចលនាខ្មែរក្រហមក្នុងតួនាទីផ្សេងៗដែលហៅជារួមថា “កម្មាភិបាល” ។ ជាងបីទសវត្សរ៍បានកន្លងផុតទៅហើយ យុវជនយុវនារីដែលបានចូលបម្រើបដិវត្តន៍ភាគច្រើននៅតែបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ននេះមិនទាន់ឃើញវិលត្រឡប់មកភូមិស្រុកវិញនៅឡើយ ។ សព្វថ្ងៃឪពុកម្តាយ និងក្រុមគ្រួសារនៅតែទន្ទឹងរង់ចាំមើលផ្លូវកូន ខ្លះនៅមានសង្ឃឹម ខ្លះទៀតស្ទើរតែអស់សង្ឃឹម ។

ផ្លូវទៅកាន់ភូមិក្រដាសដែលកសាងឡើងដោយអង្គការក្រៅរដ្ឋាភិបាលមានសភាពរាបស្មើ ។ ផ្ទះដំបូលក្បឿងក្បាច់ចាស់ៗមើលទៅធ្វើឲ្យភូមិនេះមានលក្ខណៈលេចធ្លោជាងគេក្នុងចំណោមភូមិទាំងឡាយ ។ វាលស្រែមើលទៅឃើញតែជញ្ជ្រាំងស្រូវដែលអ្នកភូមិទើបនឹងច្រូតហើយថ្មីៗ និងគំនរចំបើងដែលខ្វាយចេញពីម៉ាស៊ីនកំពុងបោកបែន ។ អ្នកភូមិទាំងឡាយហាក់ដូចជាមានសុខភាពមាំមួននិងមានទឹកមុខសប្បាយរីករាយគ្រប់ៗគ្នា ។

នៅពេលយើងដើរតាមផ្លូវ យើងឃើញមីងម្នាក់កំពុងកូរស្ករ និងមានក្មេងៗនៅព័ទ្ធជុំវិញ ។ ឪពុកនិងប្តីៗបានចេញទៅធ្វើស្រែប្រាំងអស់ហើយ ។ នៅឯផ្លូវម្ខាងទៀត មីងម្នាក់បានប្រាប់យើងដូចគ្នាថា អ្នកភូមិខ្លះទៅស្រែ ។ គាត់ធ្វើស្រែបីដងក្នុងមួយឆ្នាំ ។ យើងបន្តដំណើរទៅផ្ទះមួយខាងមុខ ឃើញតាកំពុងលួសឫស្សី យាយកំពុងធ្វើត្រីទុកស្ល ។ នៅមុខផ្ទះមានស្រូវដែលហាលនៅលើកន្ទេលស្លឹកត្នោត ។ តាមដែលខ្ញុំសង្កេតមើលនៅក្នុងភូមិនេះ ក៏ដូចភូមិ៦ទៀតក្នុងស្រុកបាធាយដែរ គឺនៅក្នុងចិត្តអ្នកភូមិម្នាក់ៗមិនមែនសុទ្ធតែសប្បាយដូចៗគ្នាទេ ។ គាត់មិនទាន់បានទទួលចម្លើយនៅឡើយ ។ គាត់បានបាត់ប្តី កូន បងប្អូន បែកបាក់គ្រួសារ ។ គាត់នៅមានចម្ងល់និងមានទុក្ខក្នុងចិត្តរហូតមក ។ គាត់នៅតែរកហោរាទស្សន៍ទាយ សួរគេសួរឯង និងធ្វើដំណើរទៅរកញាតិឆ្ងាយៗទៀតផង ។ ប្រជាជនក្នុងភូមិបានទទួលយើងយ៉ាងរាក់ទាក់ ដោយគាត់សង្ឃឹមថានឹងទទួលបានដំណឹងល្អអំពីសាច់ញាតិរបស់គាត់ ។ ចំណែកអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលនៅរស់ឆ្ងល់ថាតើយើងមកធ្វើប្រវត្តិរូបបដិវត្តន៍ម្តងទៀត ឬក៏ប៉ូលិសតាមមកចាប់កំហុសឬយ៉ាងណា ។ ពេលនោះយើងបានបង្ហាញប្រវត្តិរូបអតីតអ្នកធ្លាប់បម្រើការនៅក្នុងរបបខ្មែរក្រហមដែលបានប្រមូលទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រាប់អំពីគោលបំណងរបស់យើងក្នុងការស្វែងរកពត៌មានបន្ថែមអំពីប្រវត្តិរូបនេះដើម្បីចងក្រងជាឯកសារប្រវត្តិសាស្ត្រសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ហើយយើងក៏បានចែកជូនទស្សនាវដ្តីស្វែងរកការពិតមួយចំនួនដល់ប្រជាជនដែលរស់នៅក្នុងស្រុកនោះផង ។

ក្រោយពីសំណេះសំណាលមកទើបយើងដឹងថា ទាំងអតីតកម្មាភិបាលដែលនៅរស់ ទាំងម្តាយឪពុកនិងសាច់ញាតិរបស់អ្នកទាំងនោះ សុទ្ធតែចង់បានសន្តិភាព សេរីភាព និងយុត្តិធម៌ ។

អ្នកភូមិទាំងនោះគិតថា យើងទៅជួបគាត់ប្រហែលជាមានដំណឹងល្អដែលគាត់កំពុងតែចង់ដឹង ។ យ៉ែម នួ នៅភូមិក្រដាសបានប្រាប់យើងថា គាត់បាត់បងប្រុសម្នាក់នៅក្នុងបដិវត្តន៍ ។ ដូចអ្នកភូមិផ្សេងទៀតដែរ គាត់ធ្លាប់រកគ្រូទាយ ប៉ុន្តែមិនទាន់បានដំណឹងនៅឡើយ ។ កាលពី៣ឆ្នាំមុនគាត់និងប្តីធ្លាប់ទៅរកបងនៅអន្លង់វែងតែរកមិនឃើញ ។ នៅផ្ទះទល់មុខគ្នា លោកតា ធុន ថន ក៏ធ្លាប់ឲ្យហោរាទស្សន៍ទាយអំពីដោគវាសនាកូនរបស់គាត់ដែលបានបាត់ខ្លួននៅក្នុងបដិវត្តន៍របស់ខ្មែរក្រហមដែរ ។ ហោរាបាន


លោកតា ធុន ថន

ទស្សន៍ទាយថា លោកតានឹងរកកូនប្រុសឃើញវិញនៅពេលដែលគាត់មានអាយុ៨០ឆ្នាំ ។ ពេលវេលាចេះតែកន្លងទៅ លោកតាលែងសង្ឃឹមថាកូនរបស់គាត់នៅរស់ទៀតហើយ ។ ប្រពន្ធរបស់គាត់ឈឺរ៉ាំរ៉ៃដោយសារតែនឹកកូនពេក ។ មីង ហម ហៀង នៅភូមិជាលា ឃុំជាលា មានគម្រោងនឹងទៅរកកូនដែរដោយសារអ្នកជិតខាងរបស់គាត់ដែលមានកូនធ្វើបដិវត្តន៍ជំនាន់ជាមួយគ្នាបានរកកូនឃើញវិញ ។ មីងបានសម្លឹងមើលមុខក្រុមអ្នកស្រាវជ្រាវយើង ហើយនិយាយថា “ម្នាក់នេះមុខដូចកូនខ្ញុំណាស់” ។


លោកយាយ ចាន់ សយ

យាយ ចាន់ សយ នៅភូមិទួលចាន់ក្នុងឃុំច្បារអំពៅ និយាយថាគាត់មិនជឿថាកូនគាត់នៅរស់ទេ ។ គាត់បានឲ្យហេតុផលថា “ឥឡូវស្រុកគេស្រួលបួលហើយ អាចទៅមកបាន កូនច្បាស់ជាវិលមករកម្តាយហើយប្រសិនបើនៅរស់នោះ” ។ យាយ ពឹង នៅ នៅភូមិតាំងក្រាំង ឃុំជាលា អស់សង្ឃឹមក្នុងការស្វែងរកកូនរបស់គាត់ហើយ ប៉ុន្តែគាត់នៅតែនឹកកូនរបស់គាត់ជានិច្ច ។ គាត់និយាយប្រាប់យើងថា “ពេលដែលខ្ញុំឃើញកូនអ្នកដទៃ ដូចជាពួកកូនៗមកអ៊ីចឹងឬដូចពេលបុណ្យចូលឆ្នាំ ក្មេងៗមកលេងជុំគ្នា ពេលនោះខ្ញុំនឹកឃើញកូនខ្ញុំហើយ” ។ ក្រោយពីបាត់កូនប្រុស យាយ ចាន់ សយ ក៏បាត់ប្តីរបស់គាត់ដែរ ។ ប្តីរបស់គាត់ត្រូវខ្មែរក្រហមចាប់ទៅនៅពេលបាយថ្ងៃត្រង់មិនដឹងយកទៅណា ។ គាត់ទៅវត្ត “អុជធូបរាល់ថ្ងៃសីល” បួងសួងឲ្យប្តី និងកូនរបស់គាត់បានវិលមកវិញ ។

អ្នកភូមិរស់នៅជាមួយនឹងអារម្មណ៍ហាក់ដូចជាបាត់បង់អ្វីមួយនិងខ្វះទីពឹងក្នុងចិត្ត ។ យាយ ពឹង នៅ នៅភូមិតាំងក្រាំង បានពន្យល់ថា “ខ្ញុំជាម្តាយ ខ្ញុំត្រូវតែពឹងលើកូនអ៊ីចឹងហើយ ។ ដល់បាត់កូនទៅខ្ញុំគ្មានអីសង្ឃឹមទៀតទេ” ។

ក្រោយពីការធ្វើបុណ្យទៅវត្តបួងសួងឲ្យញាតិបាត់ទៅ អ្វីដែលអ្នកភូមិគ្រប់គ្នាចង់បានសម្រាប់ខ្លួនឯងនិងកូនចៅទៅថ្ងៃមុខនោះគឺការរស់នៅដោយសុខសន្តិភាព សេរីភាព និងយុត្តិធម៌ ។ បងស្រី ហួន ឈាង នៅភូមិក្រដាស ដែលបានបាត់បងប្រុស បានពន្យល់ថា “ក្រោយរឿងរ៉ាវកន្លងទៅ ខ្ញុំគ្មានចង់បានអ្វីក្រៅពីរស់នៅស្រួលសេរីដូចសព្វថ្ងៃទេ គឺចង់ឲ្យអាចហូបអីដែលខ្ញុំធ្វើបាន ទៅណាមកណាបាន” ។ លោកតា ធុន ថន ក៏ចង់បានយុត្តិធម៌ដែរ គឺយុត្តិធម៌ដែលអាចឲ្យគាត់មានលុយគ្រប់គ្រាន់ធ្វើបុណ្យឲ្យកូនទាំងពីររបស់គាត់ ។ ខណៈយើងសួរយាយ ពឹង នៅ ថាតើគាត់ចង់បានអ្វីជាសំណង ឬមានអ្វីអាចជួយគាត់ផ្សះផ្សាបានឬទេ គាត់ឆ្លើយថា “ខ្ញុំនឹកកូនចង់បានកូនខ្ញុំជាងចង់បានរបស់” ។ ឆ្លើយតបនឹងសំណួរដូចគ្នានេះ យាយ ចាន់ សយ បាននិយាយថា “គ្មានអ្វីយកមកប្រៀបបានទេ ។ បាត់មនុស្សរបស់ខ្ញុំ កូន ប្តី ខ្ញុំបាត់ស្មារតី” ។ យួន យឿន អតីតកម្មាភិបាលខ្មែរក្រហមម្នាក់នៅភូមិជើងព្រៃ ឃុំជើងព្រៃក៏យល់ថាគាត់បានខាតបង់អស់ជិតមួយជីវិតឥតប្រយោជន៍ ហើយចង់ឲ្យកូនគាត់ “រស់នៅដោយសុខស្រួលដូចរាល់ថ្ងៃនេះ កុំឲ្យដូចគាត់កាលទៅធ្វើទាហានមានការលំបាក” ។ ហង់ ហួន អតីតកម្មាភិបាលម្នាក់ទៀតនៅភូមិភ្នំដិល នៅចាំបានពីហេតុផលចូលបដិវត្តន៍ ហើយក្រោយមកនៅតែមានការសោកស្តាយដូចគ្នា ។ “ពេលនោះខ្ញុំលង់ប៉ុណ្ណឹង ដល់ទៅគេមកណែនាំថាស្រឡាញ់ប្រជាជនថ្មី ស្រឡាញ់ប្រជាជនចាស់ កសាងភូមិឃុំដីកប្រឡាយ ខ្ញុំគិតថាវាសមហេតុផលទៅណា៎ ។ តាមពិតទៅជីវិតខ្ញុំលំបាកមិនអាចថ្លែងបាន ឈឺចាប់ណាស់” ។

ក្រុមគ្រួសារក៏ដូចកម្មាភិបាលផ្ទាល់ អាចពន្យល់បានពីមូលហេតុចូលបដិវត្តន៍ ប៉ុន្តែទាំងអស់គ្នាមិនអាចយល់បានថាបដិវត្តន៍មានបញ្ហាអ្វីបានជាប្តី កូន បងប្អូនកម្មាភិបាលដូចគ្នាត្រូវចោទថាក្បត់ ហើយបាត់ខ្លួន ។ ចម្លើយគឺអាស្រ័យលើតុលាការខ្មែរក្រហមនៅពេលខាងមុខដែលមាននាទីវែកញែក ប៉ុន្តែទាំងអតីតកម្មាភិបាលទាំងក្រុមគ្រួសារក៏ដូចជនរងគ្រោះដែលនៅរស់ទាំងអស់នេះ ជាអ្នកដែលអាចជួយបំភ្លឺនៅតុលាការ ។ ដំណើរស្រាវជ្រាវនៅស្រុកបាធាយកំពុងតែបន្ត ហើយកន្លងមកគឺមានអតីតកម្មាភិបាល៥នាក់ដែលនៅរស់ ។ សរុបនៅបណ្តាខេត្តដែលយើងបានចុះកន្លងមកមានអតីតកម្មាភិបាលនៅរស់ចំនួនជិត ៥០០នាក់ ។

**សឹម សុរិយ៉ា**

# ទន្ទេងនឹងបដិវត្តន៍របស់ខ្មែរក្រហម



ទេស អុល

ទេស អុល ហៅ ភ័ក្តិ មានស្រុកកំណើតនៅភូមិត្រពាំងឈូក ឃុំមេសជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ក្នុងចំណោមបងប្អូន២នាក់ អុល គឺជាកូនច្បង។ ប្អូនប្រុសរបស់ អុល ឈ្មោះ ប្រោក បានចេញទៅបម្រើបដិវត្តន៍ខ្មែរក្រហមក្រោយ អុល បាត់ខ្លួនមកទល់សព្វថ្ងៃនេះ ។

កាលពីកុមារ អុល រស់នៅជាមួយជីតាដែលជាទាហាននៅខេត្តព្រៃវែង ហើយបានចូលរៀនសាលានៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង។ អុល ឈប់រៀនត្រឹមថ្នាក់ទី៧ (ស្មើនឹងថ្នាក់ទី៥ បច្ចុប្បន្ន) ហើយត្រឡប់មកស្រុកកំណើតវិញ។ ខែ២ ឆ្នាំ ១៩៧៣ អុល ត្រូវបានចៅហ្វាយស្រុកស្ទឹងត្រង់ចុចឈ្មោះឲ្យចូលបម្រើទ័ពបដិវត្តន៍ខ្មែរក្រហម ។ អុល ទើបតែមានអាយុ ១៥ឆ្នាំ ចេញដំណើរទៅជាមួយយុវជនពីរនាក់ទៀតឈ្មោះ វុធ និង សេង ដែលរស់នៅក្នុងភូមិជាមួយគ្នា ។

នៅភូមិអូរលើ អុល បានចូលរួមវគ្គមហាសន្និបាតដែលអ្នកខុទ្ទេសនាមបានបង្រៀនយុវជនទាំងអស់ថា "កូនប្រុសមាននាទីតែមួយគត់គឺធ្វើទ័ព" ។ ប៉ុន្តែអង្គភាពរបស់ អុល បានទទួលបរាជ័យស្ទើរគ្រប់សមរភូមិ ហើយបាក់ទ័ពរប៉ាត់រប៉ាយ ។ ដោយមិនអាចទ្រាំទ្រនឹងការលំបាកបាន និងដោយគ្មានសង្ឃឹមថា អាចទទួលជ័យជម្នះលើទាហានលន់ណុលផង អុល បានលួចរត់គេចមកផ្ទះវិញ ។

ក្រោយមក អុល ចង់ចូលបម្រើការងារខាងពេទ្យ ដើម្បីចៀសពីការត្រូវបញ្ជូនទៅសមរភូមិមុខវិញ ។ ដោយសារ អុល ចេះភាសាបារាំងខ្លះៗ ដូច្នេះគាត់បានកុហកអ្នកធ្វើការនៅមន្ទីរពេទ្យស្រុកថាគាត់ចេះវិជ្ជាពេទ្យ ។

ពាក់កណ្តាលឆ្នាំ១៩៧៣ អុល ចូលធ្វើការនៅមន្ទីរពេទ្យស្រុក ។ ប្រហែលឆ្នាំ១៩៧៤ អុល ត្រូវបានផ្លាស់ឲ្យទៅប្រចាំការនៅសមរភូមិព្រែកក្តាម ។ ប្រចាំការនៅសមរភូមិបានមួយឆ្នាំ អុល ត្រូវផ្លាស់ទៅពេទ្យកងពល៣០៤របស់ភូមិភាគកណ្តាលទៀត រហូតមកដល់ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមទទួលជ័យជម្នះលើរបបលន់ណុល គាត់ក៏ផ្លាស់ទៅធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលាដែលជាមន្ទីរពេទ្យសម្រាប់កងទ័ព ។ អុល មាន ឋានៈជាប្រធានអគារ ។ មានគ្រូពេទ្យជាច្រើននាក់នៅមន្ទីរពេទ្យព្រះកេតុមាលាជាជនជាតិចិន ។ អំឡុងពេលធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលា អុល បានឃើញ ដួន ជឿន មកធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យជាញឹកញាប់ ហើយពេលខ្លះ អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ក៏បានមកត្រួតពិនិត្យមន្ទីរពេទ្យនេះដែរ ។

ចុងឆ្នាំ១៩៧៦ មានការភ្ញាក់ផ្អើលថា ប្រធានភូមិភាគឧត្តរ និងភូមិភាគកណ្តាលក្បត់ ។ អឿន ប្រធានកងពល៣០៤ ត្រូវចាប់ខ្លួនយកទៅដាក់មន្ទីរឃុំឃាំង ស-២១ ។ អុល ត្រូវចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងខ្សែក្បត់ហើយក៏ត្រូវចាប់ខ្លួនដែរ ។ នៅពេលចាប់ខ្លួន គាត់ត្រូវបានប្រាប់ថា អង្គការផ្លាស់ឲ្យទៅមន្ទីរអន្តរជាតិ ។ អុល ត្រូវបញ្ជូនទៅមន្ទីរ ស-២១ដែរ ប៉ុន្តែមិនទាន់បញ្ចូលក្នុងគុកភ្លាមទេ គឺត្រូវបញ្ជូនទៅដាក់នៅក្នុងការិយាល័យមួយនៃមន្ទីរ ស-២១ ។ អុល រង់ចាំនៅក្នុងការិយាល័យគុកអស់រយៈពេលដ៏យូរហើយត្រូវបង្អត់បាយមួយថ្ងៃ ។ ក្នុងថ្ងៃដដែលនោះ ប្រធានការិយាល័យគុកបានសួរចម្លើយ អុល ។ អ្នកសួរចម្លើយបានសួរ អុល ថា "មិត្តឯងមានបង្កប់ខ្សែយួនទេ?" អុល ឆ្លើយថា "ខ្ញុំអត់មានទេ ខ្ញុំគ្រាន់តែព្យាបាលជំងឺ មិនបានទទួលការ

បំពាក់បំប៉នយោបាយអ្វីទេ បើមេឲ្យខ្ញុំធ្វើអី ខ្ញុំធ្វើហ្នឹង» ។

រំលងបានមួយថ្ងៃ តាយាត អនុប្រធានមន្ទីរពេទ្យព្រះកេតុមាលាបានអះអាងថា អុល មិនជាប់ពាក់ព័ន្ធនឹងសកម្មភាពក្បត់ឡើយ ។ ដូច្នេះ អុល ត្រូវបានដោះលែង ប៉ុន្តែមិនបានបញ្ជូនមកធ្វើការនៅកន្លែងចាស់ទេ គឺត្រូវបញ្ជូនឲ្យទៅធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនៅខែ៥ឆ្នាំ១៩៧៧ ។ អុល ត្រូវជីកដីនិងរែកដីដាក់ឆ្នូនរំសេវសម្រាប់បំបែកថ្មភ្នំ ។ អុល បានឲ្យដឹងថា នៅពេលដាក់រំសេវបំបែកភ្នំយកថ្មម្តងៗ តែងតែមានមនុស្សស្លាប់ជាច្រើន ដោយសារថ្មធ្លាក់លើ ។ អ្នកដែលធ្វើការនៅព្រលានយន្តហោះមានរូបរាងស្គមកំព្រឹង ព្រោះរបបអាហារមានតែបបររាវមិនអាចបំប៉នរាងកាយដែលធ្វើការហួសកម្លាំងបានឡើយ ។ អុល ធ្វើការតាំងពីព្រឹករហូតដល់ម៉ោង១២យប់ ទើបបានដេករយៈពេល១ម៉ោង រួចត្រូវក្រោកធ្វើការបន្តទៀត ។ ប្រហែល ចុងឆ្នាំ១៩៧៧ អុល បានចូលរួមប្រជុំនៅព្រលានយន្តហោះដោយមានកម្មាភិបាលខាងនិរតីជាអ្នកដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំបានដាស់តឿនកម្មករទាំងអស់ខំឲ្យកសាងខ្លួនដើរឲ្យទាន់កង់ប្រវត្តិសាស្ត្រ ហើយកុំគិតមានគំនិតក្បត់ឲ្យសោះ ។

នៅខែ២ឆ្នាំ១៩៧៨ មានពត៌មានថាកងទ័ពវៀតណាមបានឈ្លានពានប្រទេសកម្ពុជា ។ អង្គការបានដក អុល ឲ្យទៅធ្វើការខាងពេទ្យវិញដោយប្រាប់ថា «មិត្តឯងកសាងខ្លួនបានហើយ» ។ អុល ចូលសមរភូមិជាមួយកងពលលេខ៤ វរសេនាតូចលេខ៣១ ។ ថ្ងៃមួយ អុល កំពុងតែរុំរបួសឲ្យកងទ័ព ស្រាប់តែគ្រាប់ផ្លោងធ្លាក់ចំកន្លែងដែល អុល ស្ថិតនៅ ហើយដះអម្បែងគ្រាប់ត្រូវឆ្អឹងជំនីរ ក្បាល និងភ្នែករបស់ អុល ។ អុល ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យជាំព្រីងដើម្បីទទួលការព្យាបាល ។ សម្រាកព្យាបាលក្នុងមន្ទីរពេទ្យបានរយៈពេលកន្លះខែ មុខរបួសរបស់ អុល មិនបានគ្រាន់បើសោះ ផ្ទុយទៅវិញកាន់តែធ្ងន់ធ្ងរឡើងៗ ។ អុល ត្រូវបញ្ជូនទៅមន្ទីរពេទ្យទាហាននៅទីក្រុងភ្នំពេញ ។ អុល មិនទាន់ជាសះស្បើយពីរបួសផង ខ្មែរក្រហមកៀរអ្នកជំងឺទាំងអស់ចេញពីមន្ទីរពេទ្យឆ្ពោះទៅខេត្តបាត់ដំបង ពីព្រោះកងទ័ពវៀតណាមបានវាយលុកចូលដល់ខេត្តស្វាយរៀងហើយ ។ ខ្មែរក្រហមបានប្រកូកប្រកាសថា «បើមិនចេញប្រយ័ត្នយួនអារ-ក» ។ អុល ធ្វើដំណើរតាមទូក ហើយបន្តដំណើរតាមរថភ្លើងមកឈប់ក្នុងព្រៃនៅក្នុងខេត្តបាត់ដំបង ។ ចុះពីរថភ្លើង ទាំងអស់គ្នាត្រូវធ្វើដំណើរកាត់ព្រៃបន្តទៀត ។ អុល មិនអាចដើរកាត់ព្រៃបានទេ ព្រោះឆាយនឹងធ្វើឲ្យរបួសរបស់គាត់ដរ ដូច្នេះគាត់សម្រេចចិត្តត្រឡប់មកផ្ទះវិញ ។

រហូតមកដល់បច្ចុប្បន្ន មុខរបួសនៅលើខ្លួននិងក្បាលរបស់ អុល នៅតែបន្សល់ស្លាកស្នាម ហើយស្លាកស្នាមទាំងនេះធ្វើឲ្យគាត់មិនអាចបំភ្លេចការលំបាកវេទនាដែលគាត់បានទទួលរងក្នុងអំឡុងពេលធ្វើការបម្រើបដិវត្តន៍ខ្មែរក្រហមឡើយ ។

អុល និយាយថា «ខ្ញុំវង្វេងនឹងបដិវត្តន៍របស់ខ្មែរក្រហម ។ ដំបូងគេឲ្យខ្ញុំប្រឹងប្រែងធ្វើការងារដើម្បីឲ្យទាន់ប្រវត្តិសាស្ត្រ ។ អស់ពីប្រឹងប្រែងចោទខ្ញុំថាជាខ្មាំងហើយបញ្ជូនទៅលត់ដំ ។ អស់ពីលត់ដំបញ្ជូនខ្ញុំទៅសមរភូមិប្រយុទ្ធ ។ ខ្ញុំមិនដឹងជានិយាយយ៉ាងណាឲ្យសមនឹងអំពើដែលខ្មែរក្រហមធ្វើមកលើខ្ញុំទេ» ។

ឪពុក អុល ឈ្មោះ នួន ចំណែកម្តាយ ឈ្មោះ គឹម ។ សព្វថ្ងៃគាត់ទាំងពីរនៅរស់នៅឡើយ ។ អុល រស់នៅជាមួយប្រពន្ធឈ្មោះ សុខ លាង និងកូន៣នាក់ ។ គាត់បាននិយាយរឿងរ៉ាវរបស់គាត់ប្រាប់ប្រពន្ធកូនរបស់គាត់ឲ្យបានដឹងពីបទពិសោធន៍នៃជីវិតរបស់គាត់នៅក្រោមរបបខ្មែរក្រហមដូចជារឿងរ៉ាវជួរចត់ការឈឺចាប់ និងការបាត់បង់ប្អូនប្រុសរបស់ខ្លួន ។ គាត់ទាមទារយុត្តិធម៌ដើម្បីសងនូវអ្វីដែលគាត់បានបាត់បង់ ។ អុល បន្ថែមថា «ដើម្បីទទួលបានយុត្តិធម៌ លុះត្រាតែមានតុលាការ» ។

**ស្វ ហ្សារីណា**

## ពាក្យស្លោកខ្មែរក្រហម

- **ប្តេជ្ញាតស៊ូកម្ចាត់កម្មសិទ្ធិបុគ្គលសួនតួ ខាងសម្ភារ និងខាងអំណាចឱ្យអស់រលីង ហើយពង្រឹងនិងពង្រីកកម្មសិទ្ធិសមូហភាពជាច់ខាត។**
- **ប្តេជ្ញាតស៊ូកម្ចាត់ជាច់ខាត នូវសីលធម៌ផ្សេងៗក្នុងការរស់នៅភ្លើតភ្លើន មានស្រីស្រាជាដើម។**

*(ដកស្រង់ចេញពីសៀវភៅ យស់ សុ)*

# ស៊ុំ សុខនៈ ខ្ញុំយល់ហើយសង្គ្រាម



ស៊ុំ សុខន

ចាប់ពីពេលដែលសេនាប្រមុខ លន់ណុល ធ្វើរដ្ឋប្រហារទម្លាក់ សម្តេច ព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាម ។ ដូចជាយុវជនមួយចំនួនដែរ សុខន បានឈប់រៀនត្រឹមថ្នាក់ទី៨ ហើយបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍តាមការអំពាវនាវរបស់ព្រះមហាក្សត្រ ដែលឲ្យកូនចៅប្រមូលកម្លាំងចូលព្រៃដើម្បីបង្កើតជារណសិរ្សតស៊ូរំដោះជាតិពី លន់ ណុល ។ បន្ទាប់ពីសង្គ្រាមដ៏ក្តៅគគុក អូសបន្លាយអស់រយៈពេល៥ឆ្នាំ ខ្មែរក្រហមបានទទួលជ័យជម្នះ ហើយបានអនុវត្តគោលនយោបាយសម្លាប់រង្គាលប្រជាជន និងបំផ្លិចបំផ្លាញអ្វីៗគ្រប់យ៉ាងដែលជាសំណល់នៃរបបមុន ដើម្បីកសាងសង្គមដ៏បរិសុទ្ធមួយពីភាពទទេស្អាត ។ សុខន មិនបានវិលត្រឡប់មកស្រុកកំណើតវិញឡើយ ។ ផ្ទុយទៅវិញគាត់ត្រូវបញ្ជូនទៅលត់ដំដោយធ្វើការងារធ្ងន់ធ្ងរហួសប្រមាណ ។ រហូតមកដល់សព្វថ្ងៃ សុខន នៅតែមិនអស់ចម្ងល់ថា ហេតុអ្វីបានជាអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យសម្លាប់ខ្មែរគ្នាឯងមិនរើសមុខយ៉ាងនេះ ។ សុខន និយាយថា “មុនដំបូងខ្មែរក្រហមធ្វើសង្គ្រាមដើម្បីរំដោះជាតិ ពេលរំដោះបានហើយមិនដឹកនាំគ្នាអភិវឌ្ឍន៍ប្រទេសទេ បែរជាអនុវត្តគោលនយោបាយខ្មែរសម្លាប់ខ្មែរទៅវិញ ។ ដល់ទីបញ្ចប់គ្មានថ្នាក់ដឹកនាំខ្មែរក្រហមណាម្នាក់ក្លាហានហ៊ានចេញមុខទទួលស្គាល់ការពិតសោះ បែរជាចោទដាក់គ្នាពីមួយទៅមួយ” ។

សុខន បានចូលបដិវត្តន៍នៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧១ ពេលដែលមានអាយុទើបតែ១៨ឆ្នាំ មិនទាន់យល់អ្វីដែលហៅថាការរំដោះជាតិ អ្វីដែលហៅថាសង្គ្រាមនៅឡើយ ។ សុខន និយាយថា “តាមការអំពាវនាវរបស់សម្តេចថា ធ្វើសង្គ្រាមច្បាំងនឹងចក្រពត្តិអាមេរិក ប៉ុន្តែដល់ពេលទៅច្បាំងគ្មានឃើញច្បាំងជាមួយអាមេរិកឯណាទេ គឺច្បាំងតែជាមួយខ្មែរគ្នាឯង” ។

សុខន បានទទួលការហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រទ័ពអស់រយៈពេលជាងមួយខែ ។ វគ្គហ្វឹកហ្វឺននេះបង្ហាត់ដោយជនជាតិវៀតណាមម្នាក់ឈ្មោះ តាវៀង ។

ឆ្នាំ១៩៧២-៧៣ សុខន ចូលប្រឡូកផ្ទាល់ក្នុងសមរភូមិប្រយុទ្ធជាច្រើនដូចជា ព្រែកដឹក ព្រៃទទឹង កងមាស ព្រៃឈរ កោះគ្រលង់ និងតាមផ្លូវជាតិលេខ៧ ។ សុខន បានរៀបរាប់ថា ជីវិតជាកងទ័ពជួបការលំបាកគ្រប់បែបយ៉ាង ។ ពេលចូលប្រយុទ្ធក្នុងសមរភូមិម្តងៗ មានការភ័យខ្លាចជាប់ជាប្រចាំ ។ ពេលយប់មិនដែលបានសម្រាកគ្រប់គ្រាន់ ជួនកាលត្រូវសត្វល្អិតខាំមិនហ៊ានស្រែកថ្ងូរ ។ ពេលខ្លះជាប់ដៃប្រយុទ្ធជាមួយទាហានលន់ណុល ៤-៥ថ្ងៃជាប់គ្នា កងទ័ពត្រូវដាច់ស្បៀងទទួលទានតែស្លឹកឈើ ។ កងទ័ពស្លាប់និងរបួសជារៀងរាល់ថ្ងៃ ។ រហូតដល់ឆ្នាំ១៩៧៤ កងរបស់ សុខន ត្រូវវាយចល័តទៅខាងព្រែកក្តាម ខ្នាគ្រហឹម ។ សុខន និយាយថា នៅខ្នាគ្រហឹមរយៈពេល៦ខែ កងទ័ពជួបនឹងការលំបាកខ្លាំងណាស់ ព្រោះជារដូវទឹកឡើងសុទ្ធតែទឹកព័ទ្ធជុំវិញ ពេលចាញ់បាក់ទ័ពម្តងៗរត់មិនរួចព្រោះគ្មានច្រករត់ ដូច្នេះកងទ័ពស្លាប់អស់ជាច្រើន ។ នៅក្នុងឆ្នាំ១៩៧៤-៧៥ សុខន ស្ថិតនៅក្នុងកងពល៣១០ដែលកំពុងតែរៀបចំកម្លាំងដើម្បីវាយសម្រុកចូលទីក្រុងភ្នំពេញ ។ មុខព្រួញ របស់ សុខន មានកងទ័ព៣០០នាក់ ប៉ុន្តែនៅតែវាយមិនឈ្នះទាហានលន់ណុល ព្រោះខាងទាហានលន់ណុលមានរថក្រោះជាច្រើនគ្រឿងនិងមានយន្តហោះថែមទៀត ។ កងទ័ពខ្មែរក្រហមទប់ទល់មិនជាប់បណ្តាលឲ្យដាច់ខ្សែត្រៀមស្លាប់កងទ័ពអស់ជាច្រើន ចំណែកអ្នកដែលនៅរស់បានបាត់ម្ចាស់ការរត់បែកផ្លូវគ្នា ។ សុខន រត់ទៅជាមួយយុទ្ធមិត្ត១៨នាក់ ។ ក្រុមរបស់គាត់ត្រូវទាហានលន់ណុលព័ទ្ធជាប់នៅមាត់បឹងមួយ អស់ច្រករត់តទៅទៀត ក៏នាំគ្នាចុះក្នុងទឹកបឹងបន្ទឹម

ត្រីមកបាំងនឹងព្រៃអញ្ចាញយកត្រកៀតមកគ្របក្បាលពួនសំងំ តាំងពីម៉ោង៧ព្រឹករហូតដល់ម៉ោង៨យប់ ។ ទាហានលន់ណុល ស្រែកថា បាញ់ៗ! ហើយក៏បាញ់រះសំដៅមកកន្លែងដែលក្រុមរបស់គាត់លាក់ខ្លួន ប៉ុន្តែសំណាងល្អមិនមាននរណាម្នាក់ស្លាប់ ឬរងរបួសឡើយ ។ បន្ទាប់ពីស្ងប់គ្រាប់កាំភ្លើង គាត់នាំគ្នាឆ្លងទៅត្រើយម្ខាងទៀតដោយហែលបន្ទឹមខ្លួនអែបគុម្ពត្រកៀត ។ ឡើងដល់លើគោក ទាំងអស់គ្នាមិនហ៊ានដើរជុំគ្នាជាក្រុមធំទេ គឺដើរបំបែកគ្នាជាក្រុមតូចៗ ។ សុខន បញ្ជាក់ថា ទោះបីនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ ក៏ម្នាក់ៗត្រូវតែប្រុងប្រយ័ត្ន មិនឲ្យបាត់កាំភ្លើងដែរ ព្រោះបើនរណាម្នាក់ធ្វើឲ្យបាត់កាំភ្លើង នឹងត្រូវថ្នាក់លើចោទថាយកកាំភ្លើងឲ្យខ្មាំង ហើយអ្នកនោះពិតជាមានទោសជាមិនខាន។ សុខន បន្ថែមថា «បើបាត់កាំភ្លើងដូចបាត់ជីវិត» ។ ការធ្វើដំណើរបានតែពេលយប់ប៉ុណ្ណោះ ពេលថ្ងៃត្រូវរកកន្លែងលាក់ខ្លួនព្រោះខ្លាចទាហានលន់ណុលឃើញ ។ សុខន ចំណាយពេលដើរអស់បួនយប់ទើបរកឃើញអង្គភាពដើម ប៉ុន្តែនៅសល់សមាជិកតែ៨នាក់ ចំណែក១០នាក់ទៀតមិនដឹងវង្វេងទៅទីណា ។ សុខន ត្រូវបានប្រធានអង្គភាពអនុញ្ញាតឲ្យឈប់សម្រាក៧ថ្ងៃ រួចក៏បញ្ជូនចូលសមរភូមិជាលើកទី២ ។ នៅពេលប្រយុទ្ធ សុខន ត្រូវរបួសជើងហើយមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ព-១ អស់រយៈពេល២០ថ្ងៃ ។

សុខន បានចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ។ គាត់បានឃើញទីក្រុងភ្នំពេញនៅមានសភាពប្របូកប្របល់នៅឡើយ ព្រោះប្រជាជនមិនទាន់ចេញអស់ពីទីក្រុង ។ ក្រោយពីប្រជាជនចេញពីទីក្រុងអស់ហើយ ទើបសេនាធិការប្រមែប្រមូលកងទ័ពមកពីគ្រប់កងពលជួបជុំគ្នាដើម្បីទទួលផែនការថ្មី ។

នៅឆ្នាំ១៩៧៦ អង្គការប្រមូលអាវុធ ហើយចាប់ផ្តើមរំសាយទ័ពមួយចំនួនធំ ។ អ្នកខ្លះត្រូវអង្គការចាត់តាំងទៅធ្វើជាកម្មករ អ្នកខ្លះទៅធ្វើស្រែ ។ ចំណែក សុខន ដែលមានរបួសជើង អង្គការបញ្ជូនទៅអង្គភាពកងទ័ពពិការ ធ្វើស្រែនៅបឹងបាយាប ។ សុខន បានបន្ថែមថា កាលណោះគាត់ធ្វើការ គ្មានពេលសម្រាក មិនដែលបានស្គាល់ថ្ងៃបុណ្យទានឬថ្ងៃសៅរ៍អាទិត្យសោះឡើយ ។

នៅក្នុងឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនតាំងពីគណៈភូមិភាគបូព៌ា រហូតដល់ប្រធានកងពល ប្រធានអនុសេនាតូច ដែលនៅក្រោមចំណុះភូមិភាគបូព៌ា ។ ចំណែកយុទ្ធជនធម្មតាមួយចំនួនត្រូវអង្គការចាត់តាំងឲ្យទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង និងមួយចំនួនទៀតបញ្ជូនទៅកន្លែងផ្សេង ។ សូម្បីតែ សុខន ដែលជាជនពិការក៏ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំងដែរ ។ ការងារនៅទីនោះដំបូងគឺកាប់រំលំដើមត្នោត និងដើមឈើផ្សេងទៀត ហើយគាស់យកគល់ចេញ ។ បន្ទាប់មកពេលដែលឡានដឹកដីពីភ្នំមកដាក់ យុទ្ធជនត្រូវនាំគ្នាបុកបង្ហាប់ដី ។ ការងារដំណើរការបានប្រមាណ៣ទៅ៤ខែក៏លេចចេញជារូបរាងព្រលានយន្តហោះ ។ ការងារបន្តទៀតគឺចាក់ថ្មធំៗក្រាលបាត បន្ទាប់មកចាក់ថ្មតូចៗ និងចុងក្រោយគឺចាក់បេតុង ។ សុខន បានត្អូញត្អែរថាការងារព្រលានយន្តហោះជួបការលំបាកខ្លាំងណាស់ ធ្វើតាំងពីម៉ោង៧ព្រឹករហូតដល់ម៉ោង១១យប់ បានសម្រាកតែពេលបាយមួយភ្លែតប៉ុណ្ណោះ ។ លើសពីនេះទៀត យុទ្ធជនត្រូវក្រោកតាំងពីម៉ោង៤ភ្លឺដើម្បីប្រជុំដកពិសោធន៍ ។ ទីនោះជាកន្លែងលត់ដំកសាងខ្លួន អង្គការវិន័យតឹងតែងបំផុត អ្នកណាធ្វើខុសតែបន្តិចនឹងត្រូវសម្លាប់ចោលដោយគ្មានសួរនាំរកខុសត្រូវអ្វីទាំងអស់ ។

សុខន បាននិយាយថា មានវិស្វករចិនជាច្រើននាក់មកធ្វើការនៅខេត្តកំពង់ឆ្នាំង មិនមែនធ្វើតែព្រលានយន្តហោះមួយមុខទេ គឺមានទាំងខាងសំណង់ស្ពានថ្នល់ផង ។ វិស្វករចិនធ្វើការមានម៉ោងសម្រាកមិនដូចកម្មករខ្មែរទេ សូម្បីតែការហូបចុកក៏ផ្សេងពីគ្នាដែរ ។ គ្មាននរណាម្នាក់ហ៊ាននិយាយអំពីស្ថានភាពរបស់ខ្លួនប្រាប់ជនជាតិចិនឡើយ ព្រោះកម្មករខ្មែរ មិនចេះភាសាចិន ហើយទោះបីជាចេះក៏មិនហ៊ាននិយាយដែរ ព្រោះខ្លាចអង្គការដឹងយកទៅសម្លាប់ចោល ។

នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សុខន បានឃើញវិស្វករចិនជ្រួលច្របល់ឡើងរថយន្តបើកសំដៅទៅខេត្តបាត់ដំបង អស់រលីងគ្មានសល់ម្នាក់ នៅសល់តែកម្មករខ្មែរ ។ បន្ទាប់មកស្រាប់តែឮថាយួនវាយចូលទីក្រុងភ្នំពេញហើយ ។ សុខន ភ័យផងអរផង នាំគ្នាចំនួន១០នាក់គេចខ្លួនចូលព្រៃ ។ យុទ្ធជនខ្លះ

ទៀត ត្រូវបានប្រធានអង្គភាពកៀរឡើងភ្នំ សំដៅទៅជាយដែនខ្មែរ-ថៃ ។ យុទ្ធជននិងយុទ្ធនារីមួយចំនួនមិនហ៊ានវិលត្រឡប់ទៅស្រុកកំណើតវិញទេ ព្រោះជឿពាក្យឃោសនារបស់អង្គការដែលថា "បើត្រឡប់ទៅស្រុកវិញ ប្រយ័ត្នយួនចាប់បានអារ-កប្ចុះពោះប្រកស្មោ" ដូច្នេះក៏សុខចិត្តចូលព្រៃតាមអង្គការ ។ សុខន និងយុទ្ធមិត្តនាំគ្នារត់ចូលព្រៃដាច់ស្បៀងអាហារ មកដល់អមលាំងបានឃើញព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់មួយ គឺកងទ័ពខាងនិរតីកំពុងតែសម្លាប់កងទ័ពខាងបូព៌ាជាច្រើនពាន់នាក់ ។ សុខន ឃើញសភាពការណ៍មិនស្រួល ក៏រំកិលខ្លួនចេញទៅកន្លែងផ្សេង ហើយសម្រេចចិត្តវិលត្រឡប់មកផ្ទះវិញ ទោះបីត្រូវយួនសម្លាប់ក៏ដោយចុះ ។ ពេលដែល សុខន មកដល់ផ្ទះនៅខែមិថុនា ឆ្នាំ១៩៧៩ ។ ឪពុកម្តាយបងប្អូនរបស់ សុខន សប្បាយចិត្តជាខ្លាំងដែលឃើញ សុខន នៅរស់រានមានជីវិត ហើយបានវិលត្រឡប់មកផ្ទះវិញ ។ ម្តាយរបស់ សុខន បានលាន់មាត់ថា "ឱកូនម្តាយ! កូនអាយុវែងណាស់" ។

បងប្អូនរបស់ សុខន បីនាក់ទៀតក៏បានចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ដែរ ប៉ុន្តែក្នុងចំណោមបងប្អូនទាំងបួននាក់ មានតែ សុខន ម្នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតបានវិលត្រឡប់មកស្រុកកំណើតរស់នៅជួបជុំក្រុមគ្រួសារវិញ ក្រៅពីនោះពីរនាក់បានស្លាប់ និងម្នាក់ទៀតបាត់ខ្លួន ។ បច្ចុប្បន្ននេះ សុខន មិនចង់បានសំណងជាសម្ភារចំពោះការដែលគាត់បានទទួលរងនិងបាត់បង់នោះទេ ។ អ្វីដែលគាត់ចង់បានគឺតុលាការយុត្តិធម៌មួយសម្រាប់កាត់ទោសអ្នកដឹកនាំរបបខ្មែរក្រហម ដើម្បីឲ្យប្រជាជនបានយល់ការពិតនិងបានស្ងប់អារម្មណ៍ ជាពិសេសឲ្យក្មេងៗជំនាន់ក្រោយយកមកសិក្សា និងពិចារណាកុំឲ្យទៅថ្ងៃអនាគតមានការខុសឆ្គងទៀត ។

**សុខ ខណ្ណៈ**

## មជ្ឈមណ្ឌលឯកសារកម្ពុជាៈ ដើម្បីការចងចាំនិងយុត្តិធម៌ ទេពិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៤ សមាគមអ្នកនិពន្ធខ្មែរសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំពិធីប្រគល់រង្វាន់ដល់ជ័យលាភី **"ទេពិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ"** ចំនួន៨រូប នៅសមាគមអ្នកនិពន្ធខ្មែរ ។ កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងអំពាវនាវដល់ប្រជាជនកម្ពុជាគ្រប់រូបឲ្យសរសេរអត្ថបទស្តីអំពីជីវិតផ្ទាល់ខ្លួន ដែលបានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ និងទស្សនៈផ្ទាល់ខ្លួនចំពោះប្រវត្តិសាស្ត្រនៃរបបនេះ ។

ដោយយល់ឃើញថា អត្ថបទដែលបានចូលរួមក្នុងកម្មវិធីនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនិងថែរក្សាប្រវត្តិសាស្ត្រ ដើម្បីការស្រាវជ្រាវនិងសិក្សារៀនសូត្រ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងបន្តកម្មវិធី **"ទេពិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ"** លើកទី២ ចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ២០០៤ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេស ឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮ និងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

ប្រធានបទខាងលើនេះ តម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិ-សាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរ នឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកកាន់សមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបុទុមវតី ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ, កម្ពុជា ឬតាមរយៈអ៊ីម៉ែល dccam@online.com.kh ។ សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥, ០១២ ៨៨៣ ០៧២ ។ សូមអរគុណ!

**ហ៊ុយ ខណ្ណៈ**
**អ្នកសម្របសម្រួលកម្មវិធី**

# ជីវិតយាយ សែម ហាន នៅភូមិចាន់គង់



សែម ហាន

រហូតមកដល់សព្វថ្ងៃនេះ យាយ សែម ហាន នៅតែនឹករឭកដល់កូនប្រុសដែលបានបាត់ខ្លួន នៅក្នុងបដិវត្តន៍ខ្មែរក្រហម ។ យាយហាន បានឲ្យដឹងថា «ខ្ញុំគ្មានចង់បានអ្វីក្រៅពីកូនប្រុសឡើយ ។ ឃើញគេមានកូនច្រើននៅជិតខ្លួនមើលទៅកក់ក្តៅ ។ ចំណែកខ្ញុំមានកូនតែ២នាក់ ដល់ខ្មែរក្រហមយកទៅម្នាក់ ខ្ញុំនៅតែ២នាក់កូនស្រីកណ្តោចកណ្តែងណាស់ ។ ខ្ញុំគិតពីកូនច្រើនពេក ទៅជាឲ្យខ្ញុំវង្វេងវង្វាន់ ភ្លេចភ្លាំងអស់ហើយ ។ ខ្ញុំគិតថាកូនប្រុសខ្ញុំវាស្លាប់ហើយបានជាវាគ្មានដំណឹងអ្វីមកផ្ទះសោះ» ។ ការបាត់បង់កូនប្រុសបានធ្វើឲ្យយាយហាន ពិបាកចិត្ត ហើយគួបផ្សំនឹងជីវភាពខ្វត់ខ្សោយទៀតផងនោះ បានធ្វើឲ្យសុខភាពយាយទ្រុឌទ្រោម និងមានជំងឺប្រចាំកាយ ។ យាយហាន តែងតែរំឭកប្រាប់ចៅៗជារឿយៗថា «បើឪពុកធំរបស់ឯងនៅរស់ វានឹងនៅជិតយាយគ្រាន់បាន២នាក់នឹងម្តាយរបស់ឯង» ។ នៅពេលមានពិធីបុណ្យប្រពៃណីខ្មែរម្តងៗ យាយហាន តែងតែឧទ្ទិសមគ្គផលដល់កូនប្រុសរបស់គាត់ជានិច្ច ។

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤កន្លងទៅនេះ ក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់ផ្ទះរបស់យាយ សែម ហាន ហើយបានបង្ហាញឯកសារប្រវត្តិរូបរបស់កូនយាយឈ្មោះ សែម សឿន ដែលជាអ្នកទោសនៅមន្ទីរឃុំឃាំង ស-២១(ទួលស្លែង) និងបានជួបសំណេះសំណាលជាមួយយាយអំពីប្រវត្តិរឿងរ៉ាវរបស់ សឿន និងជីវិតផ្ទាល់របស់យាយនៅក្នុងរបបខ្មែរក្រហម ។ យាយហាន បានឲ្យដឹងថា «ខ្ញុំរំភើបណាស់ ដោយបានដំណឹងពិតប្រាកដអំពីកូនប្រុស ទោះបីដំណឹងនោះបានធ្វើឲ្យខ្ញុំមានការរន្ធត់ក្នុងចិត្តដោយដឹងថាកូនខ្ញុំត្រូវខ្មែរក្រហមចាប់ដាក់គុកទួលស្លែងក៏ដោយ» ។

យាយ សែម ហាន អាយុ៧០ឆ្នាំ មានស្រុកកំណើតនិងរស់នៅក្នុងភូមិចាន់គង់ ឃុំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម មានចម្ងាយប្រមាណ១៥គីឡូម៉ែត្រប៉ែកខាងជើងផ្សារផ្អាវ ។ ផ្ទះយាយ ហាន តូចល្មមសង់ពីឈើប្រក់ក្បឿង ។ នៅក្នុងភូមិចាន់គង់ អ្នកភូមិភាគច្រើនបានសង់ផ្ទះតូចៗល្មមធ្វើពីឈើប្រក់ក្បឿងឬស្លឹកនៅតាមចន្លោះដីស្រែដែលជាកម្មសិទ្ធិរបស់ខ្លួន ។ នៅក្នុងភូមិចាន់គង់ មិនសូវមានដើមឈើធំៗទេ មានតែដើមត្នោតមួយៗ ។ ចំណែកនៅប៉ែកខាងជើងភូមិសុទ្ធតែវាលស្រែដែលលាតសន្ធឹងរហូតដល់ស្រុកជលគីរីនៃខេត្តកំពង់ឆ្នាំង ។ តាំងពីដើមរហូតមកបច្ចុប្បន្ន អ្នកភូមិចាន់គង់ធ្វើស្រែបានតែមួយរដូវប៉ុណ្ណោះ គឺនៅរដូវវស្សា ។ នៅរដូវប្រាំងចាប់ពីខែមីនាដល់ខែឧសភាពេលដែលទឹកត្រពាំងទឹកស្រះនៅក្នុងភូមិរីងអស់ អ្នកភូមិត្រូវធ្វើដំណើរកាត់វាលស្រែចម្ងាយ៨គីឡូម៉ែត្រទៅដងទឹកល្អក់ៗនៅតាមអូរយកមកកូរសាច់ជូរទុកឲ្យរង់ថ្លាសម្រាប់បរិភោគនិងប្រើប្រាស់ប្រចាំថ្ងៃ ។ មានពេលខ្លះក្នុងមួយថ្ងៃអ្នកភូមិមិនបានផឹកទឹកម្តងក៏មាន ។

យាយ សែម ហាន មានប្តីឈ្មោះ អ៊ូ សិត និងមានកូន២នាក់ ។ កូនប្រុសបងឈ្មោះ សែម សឿន និងកូនស្រីពៅ ឈ្មោះ សិត អ៊ិច ។ ប្តីយាយបានស្លាប់តាំងពីអាយុ៣០ឆ្នាំ ។ យាយហាន បានខិតខំធ្វើស្រែចិញ្ចឹមកូនទាំង២នាក់រហូតដល់កូនប្រុសរបស់យាយបានបួសរៀននៅវត្តតាព្រងហៅវត្តប្រើសមាសស្ថិតនៅក្នុងភូមិថ្មី ឃុំត្រប់ ។

អំឡុងឆ្នាំ១៩៧៣ ពេលមានការទម្លាក់គ្រាប់បែក ប្រជាជនដែលរស់នៅក្នុងភូមិចាន់គង់មានការភ័យខ្លាច ហើយបានរត់គេចចេញពីផ្ទះជាញឹកញាប់ ។ នៅខណៈពេលនោះ សឿន ក៏បានសឹកពីបួសមកធ្វើស្រែជាមួយម្តាយនិងប្អូនស្រីវិញ ។ រស់នៅផ្ទះមិនបានប៉ុន្មានផង ប្រធានភូមិបានស្នើឲ្យ សឿន និងយុវជននៅក្នុងភូមិធ្វើជាកងឈ្លបយាមការពារភូមិស្រុក ។ បន្ទាប់ពីធ្វើកងឈ្លបបានរយៈពេលមួយខែ សឿន ត្រូវបានរដ្ឋអំណាចភូមិចាន់គង់បញ្ជូនឲ្យទៅធ្វើកងទ័ពបន្តទៀត ។ យាយហាន មិនពេញចិត្តឲ្យកូនប្រុសចេញទៅធ្វើកងទ័ពខ្មែរក្រហមទេ ប៉ុន្តែ

យាយមិនហ៊ានប្រកែកនឹងរដ្ឋអំណាចភូមិ ។ យាយហាន បានឲ្យដឹងថា «ខ្ញុំបានត្រឹមតែយំប៉ុណ្ណោះ មិនដឹងធ្វើយ៉ាងម៉េចដើម្បីឃាត់កូនកុំឲ្យចេញទៅធ្វើកងទ័ពខ្មែរក្រហមបាន» ។ ខណៈពេលដែល សឿន ចេញទៅធ្វើកងទ័ព យុវជនផ្សេងទៀតដែលមានអាយុស្របាលៗនឹង សឿន ក៏ត្រូវខ្មែរក្រហមបង្ខំឲ្យចេញទៅធ្វើកងទ័ពស្ទើរតែទាំងអស់ដែរ ។

បន្ទាប់ចេញទៅធ្វើកងទ័ពខ្មែរក្រហមបានរយៈពេល៣ខែ សឿន និងមិត្តភក្តិចំនួន៣នាក់ទៀតដែលរស់នៅក្នុងភូមិចាន់គង់ជាមួយគ្នា បានលួចរត់ត្រឡប់មកនៅផ្ទះវិញ ។ បន្ទាប់មក សឿន បានចូលបម្រើការងារជាអ្នកលក់ដូរទំនិញនៅមន្ទីរពាណិជ្ជកម្ម ។ នៅចន្លោះពេលសម្រាកហូបបាយថ្ងៃនិងពេលល្ងាច គណៈឃុំគ្រប់បានបញ្ជាឲ្យ សឿន និងយុវជនយុវនារីនៅក្នុងមន្ទីរពាណិជ្ជកម្មឃុំគ្រប់ទាំងអស់ជួយបង្កបង្កើនផលដូចជា ដាំត្រសក់ ត្រកួន ស្ពៃ ដើម្បីផ្គត់ផ្គង់អង្គភាព ។

នៅពាក់កណ្តាល ឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហមបានវាយសម្រុកចូលទីក្រុងភ្នំពេញយ៉ាងស្រួចស្រាល់ ។ នៅក្នុងខណៈពេលនោះគណៈបញ្ជាការកងទ័ពខ្មែរក្រហមនៅតាមសមរភូមិនីមួយៗបានដើរប្រមូលកងទ័ពដែលរត់ចោលជួរទាំងអស់ឲ្យចូលទៅតាមអង្គភាពរៀងៗខ្លួនវិញ ។ សឿន និងមិត្តភក្តិដែលធ្លាប់បានរត់ចោលជួរ ក៏ត្រូវមេបញ្ជាមកប្រមូលយកទៅអង្គភាពវិញ ។

ក្រោយពេល សឿន ត្រឡប់ទៅអង្គភាពបានរយៈពេលប្រហែលកន្លះខែ មានអ្នកភូមិម្នាក់ទៅលេងកូនប្រុសនៅព្រែកក្តាម ក៏បានជួបនឹង សឿន ។

ក្រោយជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ សឿន ធ្លាប់បានមកលេងផ្ទះម្តង សម្រាកនៅផ្ទះបាន២យប់ ។ សឿន បាននិយាយប្រាប់ម្តាយនិងប្អូនស្រីថាអង្គភាពរបស់គាត់នៅទីក្រុងភ្នំពេញ ។ យាយ ហាន បាននិយាយជាមួយកូនថា គាត់ចង់ទៅលេងទីក្រុងភ្នំពេញ ប៉ុន្តែត្រូវ សឿន បដិសេធថា «កុំទៅអីម៉ែ! ភ្នំពេញធំហើយឆ្ងាយណាស់» ។ ចាប់តាំងពីពេលដែល សឿន ត្រឡប់ទៅភ្នំពេញវិញ យាយហាន មិនដែលបានទទួលដំណឹងអំពី សឿន ទៀតទេ ។ កូនចៅមួយចំនួនរបស់អ្នកភូមិចាន់គង់ដែលនៅរស់ បានមកលេងផ្ទះនិងផ្ញើដំណឹងមកឲ្យក្រុមគ្រួសារគ្រប់ៗគ្នា បាត់ដំណឹងតែ សឿន ។ យាយហាន គិតថាប្រហែលជា សឿន ស្លាប់ហើយ បានជាគ្មានលេចឮដំណឹងអ្វីសោះ ។

ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ យាយហាន ក៏ដូចជាអ្នកដទៃទៀតដែរ ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅតាមព្រៃជើងភ្នំក្បែរ ភូមិកំពោត និងភូមិភ្នំត្នោត ស្ថិតនៅក្នុងឃុំគ្រប់ ដើម្បីកាប់គាស់គល់ឈើ រានដីដាំដំណាំនិងធ្វើស្រែគ្មានពេលសម្រាក ។ របបហូបចុកគឺម្នាក់ទទួលបានបបរមួយវែកជាមួយសម្លម្ជូរត្រកួន ព្រលិត ឬសម្លដៃចេក ។ នៅក្នុងរយៈពេលនោះ កូនស្រីរបស់គាត់ត្រូវបានគណៈកងខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងកងចល័តលើកទំនប់ជីកប្រឡាយនិងធ្វើការងារនៅឆ្ងាយៗពីភូមិស្រុក ។

បន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ យាយហាន និងកូនស្រី (សិត អ៊ីច) បានវិលត្រឡប់មករស់នៅផ្ទះកំណើតរបស់ខ្លួន និងប្រកបរបរធ្វើស្រែដូចពីមុន ។ សព្វថ្ងៃ យាយហាន មានជំងឺប្រចាំកាយនិងរស់នៅពឹងពាក់ទៅលើកូនស្រីទាំងស្រុង ។ យាយហាន និយាយថា «បើកូនប្រុសខ្ញុំនៅរស់ប្រហែលជាអាចជួយសម្រាលការងារខ្ញុំបានច្រើន ខ្ញុំមិនយ៉ាប់យ៉ឺនដូចសព្វថ្ងៃនេះទេ ។ កូនប្រុសខ្ញុំវាមិនចេះដើរលេងទេ កាលពីវាមិនទាន់ចេញទៅធ្វើកងទ័ពខ្មែរក្រហម វាជួយធ្វើការងារជំនួសខ្ញុំបានច្រើនណាស់» ។ ជាចុងក្រោយយាយហាន បានបន្ថែមទៀតថា «ខ្ញុំចង់បានសាលាក្តីមួយដើម្បីជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ដើម្បីឲ្យខ្ញុំបានអស់ចិត្តថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់កូនប្រុសខ្ញុំ?»

**ឡុង ដានី**



សាច់ញាតិរបស់ យាយហាន កំពុងតែអានប្រវត្តិរូបរបស់ សឿន

# មរតកនៃរបបខ្មែរក្រហម
# ការសិក្សាអំពីរូបថតរបស់ អ៊ុំង វណ្ណៈ

យុវជនឈរនៅខាងឆ្វេងដៃក្នុងរូបថតនេះឈ្មោះ អ៊ុំង វណ្ណៈ រីឯយុវជនដែលឈរខាងស្តាំដៃឈ្មោះ លាង ទាំងពីរនាក់បាត់ខ្លួន។ រូបនេះថតនៅវត្តភ្នំ ទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៦ ។ វណ្ណៈ កើតនៅឆ្នាំ១៩៦០ នៅភូមិទឹកអណ្តូង ឃុំត្រពាំងសោ ស្រុកប្រាសាទសម្បូរ ខេត្តកំពង់ធំ។ ឪពុករបស់វណ្ណៈឈ្មោះ ពាង វីរ ម្តាយឈ្មោះ ទុន គាវ ។ វណ្ណៈ មានបងប្អូនចំនួន៩នាក់ ក្នុងនោះ៨នាក់ជាស្រី ។ វណ្ណៈ ជាមនុស្សដែលមានអត្តចរិតស្លូតបូត ស្ងៀមស្ងាត់ និងជួយយកអាសារអ្នកជិតខាង ។ កាលនៅកុមារ វណ្ណៈ មានចំណង់ចំណូលចិត្តផ្នែកគ្រឿងម៉ាស៊ីននិងគ្រឿងកង់ម៉ូតូ ។ ឪពុកម្តាយរបស់ វណ្ណៈ បានបញ្ជូនគាត់ឲ្យទៅរៀននៅសាលាវត្ត នៅក្នុងភូមិទឹកអណ្តូង ។ បន្ទាប់ពីបញ្ចប់ថ្នាក់បឋមសិក្សានៅក្នុងភូមិ វណ្ណៈ បានបន្តការសិក្សានៅទីរួមខេត្តកំពង់ធំរហូតចប់ថ្នាក់ទី៥ (ស្មើនឹងថ្នាក់ទី៨បច្ចុប្បន្ន) ។

នៅក្នុងសម័យសង្គ្រាមប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហម និងទាហានលន់ណុល វណ្ណៈ ឈប់រៀនហើយស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហមក្នុងឆ្នាំ១៩៧៣ ។ មិនយូរប៉ុន្មានបន្ទាប់ពីចូលខ្មែរក្រហមទទួលជោគជ័យលើរបបលន់ណុលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វណ្ណៈ ត្រូវបានខ្មែរក្រហមបញ្ជូនពីខេត្តកំពង់ធំឲ្យទៅទីក្រុងភ្នំពេញ ។ នៅពេលមកដល់ទីក្រុងភ្នំពេញ វណ្ណៈ បម្រើការងារជាជាងថតរូបប្រចាំនៅក្រសួងពាណិជ្ជកម្ម ។ វណ្ណៈ ត្រូវខ្មែរក្រហមចាប់ខ្លួន និងសម្លាប់ចោលនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ប្រាំខែបន្ទាប់ពីឪពុករបស់គាត់ឈ្មោះ ពាង វីរ ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ។



អ៊ុំង វណ្ណៈ    លាង

បើតាមឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា (I១០១៧៨) ពាង វីរ កើតនៅភូមិទឹកអណ្តូង ឃុំត្រពាំងសោ ស្រុកសន្ទុក ខេត្តកំពង់ធំ ។ ចាប់ពីឆ្នាំ១៩៧៣ ដល់ខែមេសា ឆ្នាំ១៩៧៥ ពាង វីរ ជាប្រធានមន្ទីរសេដ្ឋកិច្ចភូមិភាគឧត្តរ ។ បន្ទាប់ពីបញ្ជូនមកដល់ទីក្រុងភ្នំពេញគាត់បានក្លាយជាជាងជួសជុលម៉ាស៊ីនដេរនៃក្រសួងកាត់ដេររដ្ឋ ។ ពាង វីរ ត្រូវខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅក្រសួងកាត់ដេររដ្ឋ ហើយដាក់ឃុំឃាំងនៅផ្ទះយ បន្ទប់ធំលេខ៣ និងបន្ទប់តូចលេខ១១០ ។

**អៀ ម៉េងទ្រី**

# តុលាការអន្តរជាតិនៅរ៉្វាន់ដារកឃើញថា អគ្គនាយកសារព័ត៌មានល្មើសច្បាប់ពីបទប្រល័យពូជសាសន៍

នៅក្នុងសាលក្រមជាប្រវត្តិសាស្ត្រមួយ តុលាការឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់ប្រទេសរ៉្វាន់ដា បានកាត់ទោសអគ្គនាយកសារព័ត៌មានបីរូបពីបទបង្កឲ្យមានអំពើប្រល័យពូជសាសន៍ ។ ចុងចោទត្រូវបានរកឃើញថាមានទោសដោយសារបានប្រើប្រាស់ប៉ុស្តិ៍វិទ្យុនិងកាសែតរបស់ខ្លួនក្នុងការបញ្ឆេះឲ្យមានការស្អប់ខ្ពើមចំពោះជាតិពន្ធុទុតស៊ី ដែលមានចំនួនភាគតិចនៅក្នុងប្រទេស ដោយតម្រង់ផ្លូវនិងជួយជំរុញដល់ប្រតិបត្តិការសម្លាប់រង្គាលជាតិពន្ធុនេះឲ្យអស់ពីប្រទេសរ៉្វាន់ដា នៅឆ្នាំ១៩៩៤ ។

សេចក្តីសម្រេចរបស់តុលាការ ប្រកាសនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៣ ។ ចាប់តាំងពីការកកើតនៃតុលាការនូរឹមប៊ឺកនេះ គឺជាលើកទីមួយហើយដែលឧក្រិដ្ឋជនត្រូវបានកាត់ទោសពីបទការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំតាមរយៈការប្រើប្រាស់ប្រព័ន្ធសារព័ត៌មាន ។ លើសពីការកាត់ទោសអ្នកផ្សព្វផ្សាយរបស់របបណាហ្ស៊ីអាល្លឺម៉ង់ឈ្មោះ ជូលៀស ស្ត្រេច ឆឺរ នៅឆ្នាំ១៩៤៦ សាលក្រមនៅប្រទេសរ៉្វាន់ដាអាចជាគំរូផ្នែកច្បាប់ដ៏មានឥទ្ធិពលមួយនៅក្នុងការកំណត់ថា ស្ថាប័នសារព័ត៌មានអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថាប័នទាំងនោះបានណែនាំ ឬញុះញង់អ្នកស្តាប់និងអ្នកអានឲ្យអនុវត្តតាម ។

ចុងចោទទាំងបីរូបនៅក្នុងតុលាការរ៉្វាន់ដាដែលធ្វើឡើងនៅទីក្រុងអារូស្សា នៃតង់ហ្សានី គឺហ្វឺឌីណាន់ ណាហ៊ីម៉ាណា និង ហ្សង់បុស្កូ បារ៉ាយ៉ាវីហ្សា ទាំងពីរនាក់ជាសហនាយកនៃប៉ុស្តិ៍វិទ្យុ អ.ធី.អិល.អិម (វិទ្យុភ្នំមួយពាន់) និងហាស់សាន់ ង៉េហ្សេ ជាចាងហ្វាងកាសែតកាំងហ្គូរ៉ា ។ ណាហ៊ីម៉ាណា និង ង៉េហ្សេ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ចំណែកឯ បារ៉ា-យ៉ាវីហ្សា ត្រូវជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ក្នុងមូលហេតុថា គាត់ត្រូវបានរំលោភសិទ្ធិនៅក្នុងដំណាក់កាលដំបូងនៃការជាប់ឃុំ ។

ក្នុងពេលប្រកាសសាលក្រម ចៅក្រម ណាវ៉ាណេសឹម ភីឡាយ បានថ្លែងទៅកាន់ចុងចោទថា "អំណាចរបស់ប្រព័ន្ធសារព័ត៌មាននៅក្នុងការបង្កើតនិងបំផ្លាញតម្លៃជាមូលដ្ឋាននៃមនុស្ស នាំមកជាមួយវានូវការទទួលខុសត្រូវខ្ពស់ ។ ជនដែលគ្រប់គ្រងប្រព័ន្ធសារព័ត៌មានជាអ្នកទទួលខុសត្រូវចំពោះលទ្ធផលចុងក្រោយ" ។ គាត់បន្តថា "ចុងចោទទាំងបីរូបបានបង្កឲ្យមានការស្លាប់បាត់បង់ជីវិតជនស៊ីវិលគ្មានកំហុសរាប់ពាន់នាក់ដោយពុំចាំបាច់ប្រើប្រាស់អាវុធជាតិផ្ទុះ ឬអាវុធរូបវ័ន្តអ្វីទាំងអស់" ។

មានប្រជាជនប្រមាណ៨សែននាក់ ភាគច្រើនជាជាតិពន្ធុទុតស៊ី ហើយមួយចំនួនតូចជាតិពន្ធុហ៊ូទូដែលមិនជ្រុលនិយម ហើយព្យាយាមការពារជាតិពន្ធុទុតស៊ី ត្រូវបានសម្លាប់តែក្នុងរយៈពេលប៉ុន្មានខែនៅក្នុងប្រទេសរ៉្វាន់ដានៅឆ្នាំ១៩៩៤ ។ នៅក្នុងអំពើប្រល័យពូជសាសន៍នោះ វិទ្យុ អ.ធី.អិល.អិម តែងតែផ្សព្វផ្សាយពាក្យសម្តីបញ្ឆេះបញ្ឆូលឲ្យប្រជាជនសម្លាប់ជាតិពន្ធុទុតស៊ី ។ នៅក្នុងកម្មវិធីមួយ វិទ្យុដដែលបានប្រកាសថា "យើងត្រូវបញ្ចប់ពួកនេះ (ទុតស៊ី) ឲ្យអស់ បោសសម្អាតវាឲ្យអស់ពីផ្ទៃប្រទេស..." ។ វិទ្យុថែមទាំងផ្តល់ព័ត៌មានដល់អ្នកស្តាប់អំពីទីកន្លែងលាក់ខ្លួនរបស់ក្រុមទុតស៊ី ហើយពន្យុះឲ្យប្រជាជនតាមសម្លាប់មនុស្សដែលមានរៀបរាប់ឈ្មោះក្នុងវិទ្យុ ។ នៅក្នុងសៀវភៅដែលមានចំណងជើងថា "ខ្ញុំសូមប្រាប់ពិភពលោកឲ្យដឹងថាថ្ងៃស្អែកខ្ញុំនិងគ្រួសារនឹងត្រូវគេសម្លាប់ជាមួយគ្នា" អ្នកនិពន្ធ ហ្វីលីព ហ្គូរ៉េវិច បានសរសេរថា "សម្តីរបស់វិទ្យុ អ.ធី.អិល.អិម មានភាព "ច្បាស់លាស់មិនស្រពេចស្រពិល ហើយត្រូវបានប្រជាជនធ្វើតាម" ។

កាសែត កាំងហ្គូរ៉ា (មានន័យថា ចូរភ្ញាក់ឡើង) ដែលចេញផ្សាយពីរដងក្នុងមួយសប្តាហ៍ ត្រូវបានប្រើប្រាស់ដោយ ង៉េហ្សេ (ជាចាងហ្វាងនិងជាចៅកែ) ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការសម្លាប់រង្គាល ។ "សូមទុកឲ្យកំហឹងដែលឆេះឆំជាយូរមកហើយផ្ទុះ

ឡើងចុះ» ង៉ើហ្វេ បានសរសេរដូច្នេះនៅក្នុងកាសែតប៉ុន្មានថ្ងៃមុនពេលដែលអំពើប្រល័យពូជសាសន៍កើតឡើង ។ នៅក្នុងទំព័រទីមួយនៃកាសែតមានដាក់សំណួរមួយថា «តើអាវុធបែបណាដែលយើងគួរយកមកប្រើដើម្បីកម្ចាត់ពួកអ៊ិនហ្សិនហ្សី (មានន័យថាសត្វកន្លាត ពាក្យនេះត្រូវបានប្រើជាទូទៅសំដៅទៅលើជាតិពន្ធុទុតស៊ី) តែមួយដងនិងឲ្យចប់សព្វគ្រប់?» ។ សំណួរនេះត្រូវបានដាក់នៅក្បែររូបភាពផ្កាក់មួយ (នៅប្រទេសរ៉្វាន់ដា ផ្កាក់ត្រូវបានប្រើប្រាស់ជាអាវុធសម្រាប់ប្រល័យពូជសាសន៍) ។

អាលីសុន ដឺហ្វុច ជាបញ្ញាជនម្នាក់ដែលបានសិក្សាយ៉ាងទូលំទូលាយទៅលើអំពើប្រល័យពូជសាសន៍សម្រាប់អង្គការសង្កេតការសិទ្ធិមនុស្ស បានប្រាប់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍នៅសហរដ្ឋអាមេរិកថា «សាលក្រមរបស់តុលាការគឺជាសេចក្ដីវិនិច្ឆ័យវិសាមញ្ញមួយ ពីព្រោះវាទទួលស្គាល់ថា ប្រព័ន្ធសារព័ត៌មានអាចត្រូវបានប្រើប្រាស់ដើម្បីសម្លាប់មនុស្ស» ។ ផ្ទុយទៅវិញ ចន ហ្វុយ ដែលជាមេធាវីការពារក្ដី ង៉ើហ្វេ បានថ្លែងថា «នេះជាការសម្រេចចិត្តខុសទាំងស្រុង» ។ ហើយថា «រឿងក្ដីនេះនឹងត្រូវសើចចំអកពេញតុលាការនៅអាមេរិក» ។

ការចេញសាលក្រមបានបញ្ជាក់ថាមានភ័ស្តុតាងគ្រប់គ្រាន់ដែលធ្វើឲ្យចៅក្រមមានការពេញចិត្តនិងទទួលស្គាល់ថា ការផ្សាយសំឡេងនិងការបោះពុម្ពផ្សាយរបស់ចុងចោទបានរំលោភព្រំដែនតែមានលក្ខណៈការពារខ្លួនពីការញុះញង់ដាក់ស្តែងឲ្យសម្លាប់មនុស្ស ។

**អាន់ថូនី ដកឃីន**

# អំពើប្រល័យពូជសាសន៍

ដោយសារការគោរព ការស្គាល់ច្បាស់ និងការលើកមកនិយាយម្ដងហើយម្ដងទៀត អនុសញ្ញាស្ដីអំពីការបង្ការនិងការផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ បានចូលមកស្ថិតនៅក្នុងមនសិការនៃមនុស្សជាតិ ។

កម្លាំងសីលធម៌របស់អនុសញ្ញាប្រល័យពូជសាសន៍បែរជាផ្ទុយស្រឡះ ។ តាំងពីអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ត្រូវបានអនុម័តឡើង វាត្រូវបានកត់សម្គាល់លើសអ្វីៗទាំងអស់ចំពោះការបរាជ័យទាំងស្រុងរបស់រដ្ឋទាំងឡាយក្នុងការគោរពនិងធ្វើតាមបទបញ្ញត្តិនៅក្នុងអនុសញ្ញា ។

ទោះបីជាអនុសញ្ញានោះបានប្រមើល (ប៉ុន្តែមិនទាមទារ) ឲ្យមានការបង្កើតតុលាការអន្តរជាតិដើម្បីដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ក៏ដោយ ក៏រហូតដល់៤៥ឆ្នាំក្រោយទើបតុលាការព្រហ្មទណ្ឌអន្តរជាតិទីមួយត្រូវបានបង្កើតឡើង ។ ដែនសមត្ថកិច្ចរបស់តុលាការនោះត្រូវបានកំណត់នៅត្រឹមឧក្រិដ្ឋកម្មមួយចំនួនដូចជាអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងអតីតប្រទេសយូហ្គោស្លាវីតាំងពីឆ្នាំ១៩៩១ ។ មួយឆ្នាំក្រោយមក តុលាការស្រដៀងគ្នាហើយមានលក្ខណៈចង្អៀតចង្អល់ជាងនោះមួយទៀតត្រូវបានបង្កើតឡើងសម្រាប់ប្រទេសរ៉្វាន់ដា ។ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ គឺរយៈពេលកន្លះសតវត្សរ៍ ក្រោយពីមហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់អនុសញ្ញាអំពើប្រល័យពូជសាសន៍ ទើបសាលក្រមទីមួយដាក់ចេញដោយផ្អែកទៅលើអនុសញ្ញាប្រល័យពូជសាសន៍ដោយតុលាការអន្តរជាតិក្រោយពីការកាត់សេចក្ដីមួយ (ជនជាប់ចោទមួយផ្សេងទៀតបានសារភាពកំហុសចំពោះអំពើប្រល័យពូជសាសន៍) ។ នៅថ្ងៃនោះ តុលាការរ៉្វាន់ដាបានរកឃើញថា ហ្សង់ប៉ូល អាកាយេស៊ុ ល្មើសច្បាប់៩ករណីចំពោះសកម្មភាពរបស់គាត់នៅក្នុងអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាក្នុងឆ្នាំ១៩៩៤ ។

គ្មានរដ្ឋណាមួយបានពាំនាំរឿងក្ដីមួយនៅក្រោមដែនសមត្ថកិច្ចរបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍ទៅកាន់តុលាការពិភពលោកមុនឆ្នាំ១៩៩៣នោះទេ ហើយរឿងក្ដីនៅឆ្នាំ១៩៩៣ទៀតសោតស្ទើរមិនមែនជាទង្វើជាប្រវត្តិសាស្ត្រមួយនៅក្នុងកិច្ចប្រឹងប្រែងជំរុញឲ្យគោរពអនុសញ្ញាលើឆាកអន្តរជាតិដែរ ។ នៅឆ្នាំ១៩៩៣ រឿងក្ដីប្រល័យពូជសាសន៍ត្រូវបានប្ដឹងដោយ

រដ្ឋមួយ ដែលបានទទួលរងអំពើប្រល័យពូជសាសន៍ គឺប៊ូស្នៀ-ហឺហ្សេហ្គោវីណា ទល់នឹងរដ្ឋមួយដែលត្រូវចោទប្រកាន់ថាបានទទួលខុសត្រូវ គឺអតីតប្រទេសយូហ្គោស្លាវីមិនមែនប្តឹងដោយរដ្ឋទាំងឡាយដែលបានប្តេជ្ញាថានឹងជំរុញឲ្យមានការគោរពច្បាប់នៃមនសិការសកលលោកជួសមុខឲ្យជនរងគ្រោះលំបាកវេទនានៅក្រៅដែនដីប្រទេសទាំងនោះឡើយ ។

ផ្ទុយទៅវិញ នៅពេលដែលបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តឡើង ហើយផ្សព្វផ្សាយនៅក្នុងប្រព័ន្ធសារពត៌មានប្រចាំថ្ងៃ អ្នកជំនាញការច្បាប់សហរដ្ឋអាមេរិកត្រូវបានស្នើ «ឲ្យអនុវត្តទៅតាមច្បាប់ដើម្បីចៀសវាងអំពើប្រល័យពូជសាសន៍» ។ បើតាមសម្តីរបស់កាសែតញូវយ៉កថែម នៅពេលដែលជាតិពន្ធហ៊ូទូនៅប្រទេសរ៉្វាន់ដាកាប់សម្លាប់ជាតិពន្ធទុតស៊ីរាប់សែននាក់ រដ្ឋាភិបាលលោក គ្លីនតុន បែរជាណែនាំអ្នកនាំពាក្យរបស់លោកឲ្យចៀសវាងនិយាយថាអ្វីដែលកំពុងកើតឡើងជាអំពើប្រល័យពូជសាសន៍ ដោយមូលហេតុថាវាអាច «បញ្ឆេះឲ្យសាធារណជនប្រកាសទាមទារឲ្យចាត់វិធានការ» ។ ផ្ទុយទៅវិញ ក្រសួងការបរទេសនិងក្រុមប្រឹក្សាសន្តិសុខសហរដ្ឋអាមេរិក ត្រូវបានរាយការណ៍ថាបានណែនាំដល់អ្នកនាំពាក្យរដ្ឋាភិបាលអាមេរិកឲ្យនិយាយថា «អំពើប្រល័យពូជសាសន៍អាចកើតមាន» នៅក្នុងប្រទេសរ៉្វាន់ដា ។

រយៈពេលប្រាំទសវត្សរ៍នៃការមិនជំរុញឲ្យគោរពច្បាប់បានធ្វើឲ្យបទបញ្ញត្តិស្នូលនៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ស្ថិតនៅក្នុងភាពស្រពិចស្រពិលក្នុងកម្រិតមួយដែលធ្វើឲ្យអ្នកនយោបាយប្រឆាំងបិទបាំងការពិតកាន់តែងាយស្រួល ។ (ទោះជាយ៉ាងណា ការប្រើប្រាស់ភាពមិនច្បាស់លាស់នៃច្បាប់ដើម្បីបិទបាំងការពិត ជាការរំលោភទៅលើអនុសញ្ញាដែលតម្រូវឲ្យរដ្ឋជាសមាជិកមិនត្រឹមតែដាក់ទណ្ឌកម្មចំពោះអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារមិនឲ្យកើតមាននិងបញ្ឈប់អំពើប្រល័យពូជសាសន៍ដែលជាវិធានការមួយមិនចាំបាច់រង់ចាំការដឹងពិតថាអំពើប្រល័យពូជសាសន៍បានកើតឡើងនោះទេ) ។

និយមន័យនៃអំពើប្រល័យពូជសាសន៍ចែងនៅក្នុងអនុសញ្ញាគឺគួរឲ្យទុកចិត្តបាន ហើយត្រូវបានបញ្ចូលទាំងស្រុងទៅក្នុងលក្ខន្តិកៈច្បាប់នៃតុលាការយូហ្គោស្លាវីនិងរ៉្វាន់ដា ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ដែលនឹងត្រូវបង្កើតឡើងក្រោយពីរដ្ឋចំនួន៦០ បានផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម អនុម័តឡើងនៅខែកក្កដា ឆ្នាំ១៩៩៨ ។ ក្រោយពីបានបញ្ជាក់ថា អំពើប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋមួយនៅក្រោមច្បាប់អន្តរជាតិ ទោះត្រូវបានធ្វើឡើងនៅក្នុងពេលមានសន្តិភាពឬសង្គ្រាម អនុសញ្ញាប្រល័យពូជសាសន៍បានឲ្យនិយមន័យអំពើប្រល័យពូជសាសន៍ថា «រាល់ទង្វើណាមួយខាងក្រោមដែលបានប្រព្រឹត្តឡើងដោយមានចេតនាចង់បំបាត់ចោលទាំងស្រុងឬដោយផ្នែកនូវជនជាតិ ជាតិពន្ធ សញ្ជាតិ ឬសាសនិកក្រុមណាមួយ ទៅតាមទម្រង់ដូចជាៈ សម្លាប់សមាជិកក្រុម, បង្កឲ្យមានការឈឺចាប់លើរាងកាយឬសតិបញ្ញាដល់សមាជិកក្រុម, បង្កឡើងដោយចេតនានូវល័ក្ខខ័ណ្ឌជីវិតទៅលើក្រុមក្នុងគោលបំណងនាំមកនូវការបំផ្លិចបំផ្លាញជារូបវ័ន្តទាំងមូលឬដោយផ្នែក, ដាក់បង្ខំវិធានការណែនាំ ដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងក្រុម, ផ្ទេរកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត» ។

នៅក្នុងអនុសញ្ញាឆ្នាំ១៩៤៨ បទឧក្រិដ្ឋប្រល័យពូជសាសន៍មានទាំងសមាសធាតុរូបវ័ន្តនិងសមាសធាតុសតិបញ្ញា ។ សមាសធាតុរូបវ័ន្តរួមមានសកម្មភាពដែលបានចែងជាធរមាននៅក្នុងច្បាប់ដូចជាការសម្លាប់សមាជិកក្រុមសញ្ជាតិណាមួយ ។ សមាសធាតុទីពីរគឺទង្វើទាំងឡាយណាដែលត្រូវបានធ្វើឡើងក្រោមគោលបំណងបំផ្លាញទាំងស្រុងឬដោយផ្នែកនូវជនជាតិ ជាតិពន្ធ សញ្ជាតិ ឬក្រុមសាសនិកណាមួយ ។ នៅក្នុងសាលក្រមនៃរឿងក្តី អាកាយេស៊ុ តុលាការរ៉្វាន់ដាបានរកឃើញថា ការរំលោភជាតិពន្ធទុតស៊ីដោយមានផែនការត្រឹមត្រូវនៅក្នុងខេត្ត បានបង្កជាអំពើប្រល័យពូជសាសន៍ដែល «ធ្វើឲ្យមានការឈឺចាប់លើរូបរាងកាយឬសតិបញ្ញានៃសមាជិកក្រុម» ។

បន្ថែមទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្លួនឯង អនុសញ្ញាឆ្នាំ១៩៤៨បានចែងថា អំពើដែលរៀបរាប់បន្ទមកនេះនឹងត្រូវផ្តន្ទាទោសៈ ការឃុបឃិតគ្នាប្រព្រឹត្តអំពើប្រល័យពូជសាសន៍, ការញុះញង់ដោយផ្ទាល់ឬជាសាធារណៈឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍, ការព្យាយាមប្រព្រឹត្តអំពើប្រល័យ

ពូជសាសន៍ និងការចូលរួមដោយផ្ទាល់នៅក្នុងការប្រល័យពូជសាសន៍ ។

អ្វីដែលមិនបានរៀបរាប់នៅក្នុងអនុសញ្ញាគឺមានសារសំខាន់ដូចអ្វីដែលបានរៀបរាប់ ។ ទោះជាសេចក្តីព្រាងនៃអនុសញ្ញាបានរាប់បញ្ចូលក្រុមអ្នកនយោបាយ នៅក្នុងចំណុចដែលរៀបរាប់អំពីការតម្រូវឲ្យមានចេតនា វាត្រូវបានលុបចេញវិញនៅក្នុងសេចក្តីព្រាងចុងបញ្ចប់ ។ វាហាក់បីដូចជាមានរដ្ឋាភិបាលច្រើនពេកដែលច្បាស់ជានឹងទទួលរងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ប្រសិនបើការកម្ទេចដោយចេតនាទៅលើក្រុមអ្នកនយោបាយធ្លាក់ទៅក្នុងវង្វង់បទឧក្រិដ្ឋប្រល័យពូជសាសន៍ ។

អ្វីដែលមិនបានរាប់បញ្ចូលដែរនោះគឺអំពើប្រល័យពូជសាសន៍វប្បធម៌ ដែលមានន័យថា ការបំផ្លិចបំផ្លាញក្រុមមួយតាមរយៈការបញ្ចូលក្រុមនោះដោយបង្ខំទៅក្នុងវប្បធម៌មួយទៀត ។ ប្រវត្តិនៃការធ្វើសេចក្តីព្រាងបានបញ្ជាក់យ៉ាងច្បាស់ថា អនុសញ្ញាឆ្នាំ១៩៤៨ ត្រូវបានបង្កើតឡើងដើម្បីរាប់បញ្ចូលទាំងការបំផ្លិចបំផ្លាញទៅលើរូបរាងកាយនៃមនុស្សម្នាក់ ។ ការបញ្ជាក់ពីកិច្ចប្រឹងប្រែងតែមួយគត់ក្នុងការបញ្ចូលសញ្ញាណនៃការលុបបំបាត់វប្បធម៌ក្រុម គឺការរៀបរាប់នៅក្នុងអនុសញ្ញាអំពីការផ្ទេរកុមារ ដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត ។

នៅក្នុងផ្នែកនេះនិងផ្នែកផ្សេង និយមន័យពីអំពើប្រល័យពូជសាសន៍របស់អនុសញ្ញាគឺមានលក្ខណៈចង្អៀតចង្អល់ជាងគំនិតរបស់បញ្ញាជនប៉ូឡូញ រ៉ាហ្វែល ឡឹមគិន ដែលបានស្នើឡើងដំបូងនៅក្នុងសន្និសីទអន្តរជាតិមួយក្នុងឆ្នាំ១៩៣៣ថា សន្ធិសញ្ញាមួយគួរត្រូវបានបង្កើតក្នុងគោលបំណងធ្វើឲ្យការវាយប្រហារទៅលើក្រុមជនជាតិ សាសនា និងជាតិពន្ធ ក្លាយជាបទឧក្រិដ្ឋអន្តរជាតិ ។ រ៉ាហ្វែល ឡឹមគិន ដែលបានបម្រើការងារនៅនាយកដ្ឋានទទួលបន្ទុកផ្នែកសង្គ្រាមរបស់សហរដ្ឋអាមេរិក បានបង្កើតពាក្យប្រល័យពូជសាសន៍ (genocide) ពីពាក្យភាសាក្រិច genos មានន័យថាជនជាតិឬកុលសម្ព័ន្ធ និងពាក្យ cide ពីភាសាឡាតាំងមានន័យថា សម្លាប់ ។ នៅក្នុងសៀវភៅរបស់គាត់មានចំណងជើងថា «ការគ្រប់គ្រងរបស់សម្ព័ន្ធអាឡឺម៉ង់» បោះពុម្ពឆ្នាំ១៩៤៤ រ៉ាហ្វែល ឡឹមគិន បានសរសេរថា គំនិតដូចខាងលើអាចសរសេរជាពាក្យ ethnocide ពីភាសាក្រិច ethnos ជាតិ និងឡាតាំង cide មានន័យថា ប្រល័យជាតិពន្ធ ។

ទោះបីជា រ៉ាហ្វែល ឡឹមគិន បានរាប់បញ្ចូលទាំងការបំបាត់រូបរាងនៃក្រុមក៏ដោយ តាមការពិតនៅក្នុងគំនិតជាក់ស្តែងរបស់គាត់គឺចង់សំដៅទៅលើការប្រើប្រាស់វិធីសាស្ត្រប្រល័យពូជសាសន៍ក្នុងរូបរាងឃោរឃៅបំផុតប៉ុណ្ណោះៈ

«តាមរយៈពាក្យ genocide អំពើប្រល័យពូជសាសន៍ យើងសំដៅទៅលើការបំផ្លិចបំផ្លាញក្រុមជាតិពន្ធមួយ... ។ និយាយរួម អំពើប្រល័យពូជសាសន៍មិនមានន័យថាជាការបំផ្លិចបំផ្លាញដោយផ្ទាល់ទៅលើជាតិណាមួយទេ លើកលែងតែក្នុងករណីដែលអំពើប្រល័យពូជសាសន៍ត្រូវបានសម្រេចដោយការសម្លាប់រង្គាលទៅលើពលរដ្ឋនៃជាតិមួយ ។ ប្រល័យពូជសាសន៍គឺបញ្ជាក់អំពីផែនការសកម្មភាពផ្សេងៗ ធ្វើឡើងក្នុងបំណងបំផ្លិចបំផ្លាញមូលដ្ឋានគ្រឹះជីវិតនៃក្រុមជនជាតិនៅក្នុងប្រទេសមួយ ដើម្បីលុបបំបាត់ចោលក្រុមនោះទាំងស្រុង ។ គោលដៅនៃផែនការបែបនោះគឺការលុបបំបាត់ចោលនូវស្ថាប័ននយោបាយ សង្គម វប្បធម៌ ភាសា សតិអារម្មណ៍ជាតិ សាសនា និងសេដ្ឋកិច្ចនៃក្រុមជាតិពន្ធក្នុងប្រទេស រួមទាំងការធ្វើឲ្យបាត់បង់សន្តិសុខ សេរីភាព សុខភាព សេចក្តីថ្លៃថ្នូរ និងជីវិត របស់បុគ្គលទាំងឡាយជាសមាជិកនៃក្រុម... ។ អំពើប្រល័យពូជសាសន៍មានពីរដំណាក់កាលៈ ទីមួយ ការបំផ្លិចបំផ្លាញទម្រង់ជាតិនៃក្រុមដែលទទួលរងការជិះជាន់ ទីពីរ ការដាក់បញ្ចូលនូវទម្រង់ជាតិថ្មីដោយក្រុមអ្នកជិះជាន់ ។ ការដាក់បញ្ចូលនេះអាចធ្វើទៅលើប្រជាជនដែលទទួលការជិះជាន់ហើយត្រូវបានទុកឲ្យរស់ ឬធ្វើទៅលើតំបន់នោះក្រោយពីបានបំបាត់ប្រជាជនចេញពីតំបន់ឬត្រួតត្រាតំបន់នោះដោយប្រជាជននៃប្រទេសដែលដាក់ការជិះជាន់» ។

៤ឆ្នាំបានកន្លងផុតទៅមុននឹងបទឧក្រិដ្ឋដែល រ៉ាហ្វែល ឡឹមគិន បានលើកឡើងត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាអន្តរជាតិមូលដ្ឋានច្បាប់ពិតប្រាកដត្រូវបានបង្កើតក្នុងតុលាការទីក្រុងនូរ៉ឹមប៊ឺកនៅឆ្នាំ១៩៤៥ និងការកាត់ទោសក្រោយសង្គ្រាមផ្សេងទៀត ។ ទោះបីជាធម្មនុញ្ញទីក្រុងនូរ៉ឹមប៊ឺកមិនបានប្រើប្រាស់

ពាក្យប្រល័យពូជសាសន៍ ក៏និយមន័យនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិរបស់ធម្មនុញ្ញនោះមានអត្ថន័យស្រដៀងគ្នាជាច្រើនចំណុចទៅនឹងគំនិតរបស់ រ៉ាហ្វែល ឡឹមគិន ស្តីពីអំពើប្រល័យពូជសាសន៍ ។ ពាក្យប្រល័យពូជសាសន៍ត្រូវបានប្រើប្រាស់នៅក្នុងដីកាចោទប្រកាន់ប្រឆាំងនឹងឧក្រិដ្ឋជនសង្រ្គាមធំៗ ដែលត្រូវកាត់ទោសនៅក្នុងតុលាការទីក្រុងនូរឹមប៊ឺក ។ ឧក្រិដ្ឋជនទាំងនោះត្រូវបានចោទប្រកាន់ថា «បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយចេតនា និងមានផែនការច្បាស់លាស់ក្រោមទ្រង់ទ្រាយសម្លាប់រង្គាលក្រុមជនជាតិដែលជាជនស៊ីវិលរស់នៅក្នុងតំបន់ក្រោមការគ្រប់គ្រង ដើម្បីលុបបំបាត់ចោលក្រុមជនជាតិ សញ្ជាតិ ឬសាសនា» ។ ព្រះរាជអាជ្ញានៃតុលាការនូរឹមប៊ឺកបានលើកឡើងអំពីពាក្យប្រល័យពូជសាសន៍នៅក្នុងសវនាការចុងបញ្ចប់ ។ ពាក្យប្រល័យពូជសាសន៍ក៏ត្រូវបានលើកឡើងនៅក្នុងការកាត់សេចក្តីនៃតុលាការយោធាអាមេរិកជាច្រើនលើកនៅក្នុងទីក្រុងនូរឹមប៊ឺក ។

ក្រោយពីមានការកាត់ទោសឧក្រិដ្ឋជនសង្រ្គាមនៅទីក្រុងនូរឹមប៊ឺកភ្លាមៗ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចមួយបញ្ជាក់ថា អំពើប្រល័យពូជសាសន៍ «គឺជាបទឧក្រិដ្ឋមួយនៅក្រោមច្បាប់អន្តរជាតិ» ។ នៅក្នុងបុព្វកថាសេចក្តីសម្រេចឆ្នាំ១៩៤៦ បានពន្យល់ថា «ប្រល័យពូជសាសន៍ជាការបដិសេធសិទ្ធិរស់រានមានជីវិតរបស់ក្រុមទាំងឡាយនៃមនុស្សក្នុងទម្រង់ដូចនឹងអំពើមនុស្សឃាតដែលមានន័យថាជាការបដិសេធសិទ្ធិរស់រានមានជីវិតរបស់មនុស្សម្នាក់ដែរ» ។

ភាពចង្អៀតចង្អល់បន្តិចនៃអនុសញ្ញាឆ្នាំ១៩៤៨ ពិសេសការមិនរាប់បញ្ចូលក្រុមនយោបាយ និងការតម្រូវឲ្យមានចេតនាច្បាស់លាស់ បានធ្វើឲ្យមេដឹកនាំនយោបាយលើកឡើងថា តើអំពើប្រល័យពូជសាសន៍ដែលឋិតនៅក្នុងការសង្ស័យ អាចបំពេញតាមល័ក្ខខ័ណ្ឌដ៏តឹងរ៉ឹងរបស់អនុសញ្ញាបានឬទេ? តើជនបង្កសង្រ្គាមនៅអាន់ហ្វែលឆ្នាំ១៩៨៨ មានចេតនាក្នុងការសម្លាប់ជាតិពន្ធឃើត ប្រមាណ៥ម៉ឺននាក់ដែលបានស្លាប់ក្នុងសង្រ្គាមនោះឬទេ? បើតាមសម្តីរបស់បញ្ញាជនល្បីម្នាក់ តើវាជាបំណងប្រាថ្នារបស់មេដឹកនាំទាំងនោះដើម្បីកម្ចាត់ «ចលនាជាតិពន្ធឃើតដែលជាឧបសគ្គនយោបាយ»? តើជនដៃដល់ស៊ើបនៅប៊ូស្នៀមានគោលបំណងបំផ្លិចបំផ្លាញសាសនិកអ៊ីស្លាមនិងជាតិពន្ធក្រូអាត ឬក៏ជាតិពន្ធស៊ើប «គ្រាន់តែ» ទាមទារឲ្យមានការកាន់កាប់ផ្តាច់មុខទៅលើតំបន់មួយ?

ដូចដែលសំណួរទាំងនេះបានលើកឡើង ប្រភពសំខាន់នៃភាពស្រពិចស្រពិលឋិតនៅត្រង់អត្ថន័យនៃ «តម្រូវការឲ្យមានចេតនា» នៃអនុសញ្ញាឆ្នាំ១៩៤៨ ។ ទោះបីជាប្រវត្តិនៃការធ្វើសេចក្តីព្រាង គឺស្រពិចស្រពិលខ្លះៗ ខ្ញុំជឿថាវាជាកំហុសមួយដែលបកស្រាយថា «ចេតនា» ក្នុងអនុសញ្ញាដូចគ្នាទៅនឹង«មូលហេតុ» នៃបទឧក្រិដ្ឋ ។ ខ្ញុំជឿថា ជនដៃដល់ស៊ើបអាចកាប់សម្លាប់សាសនិកអ៊ីស្លាម ដើម្បីទទួលបាននូវការគ្រប់គ្រងទឹកដី មិនមែនបដិសេធចេតនាលុបបំបាត់ចោលសាសនិកអ៊ីស្លាមដើម្បីសម្រេចបាននូវគោលដៅពិតប្រាកដនោះទេ ។

អនុសញ្ញាអំពើប្រល័យពូជសាសន៍បានដាក់កំហិតករណីយកិច្ចទូទៅមួយទៅលើរដ្ឋជាសមាជិក «ឲ្យការពារមិនឲ្យកើតមាននិងដាក់ទោស» ទៅលើអំពើប្រល័យពូជសាសន៍ ។ ជនទាំងឡាយណាដែលបានជាប់ចោទពីបទប្រល័យពូជសាសន៍ នឹងត្រូវកាត់ទោសដោយរដ្ឋដែលអំពើប្រល័យពូជសាសន៍បានកើតឡើង ឬ «ដោយតុលាការអន្តរជាតិដែលមានអំណាចផ្លូវច្បាប់ទៅលើប្រទេសជាសមាជិកដែលទទួលស្គាល់ចំពោះយុត្តាធិការរបស់តុលាការនោះ» ។ ទោះបីជាអនុសញ្ញាប្រល័យពូជសាសន៍មិនបានរៀបរាប់អំពីល័ក្ខខ័ណ្ឌទីបីគឺការកាត់ទោសនៅក្នុងរដ្ឋទីបីក៏ដោយ បច្ចុប្បន្នគ្រប់រដ្ឋទាំងអស់អាចមានអំណាចផ្លូវច្បាប់ទៅលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ ទោះជាបទឧក្រិដ្ឋនោះបានកើតឡើងនៅទីណា ហើយជនរងគ្រោះនិងជនដៃដល់មានសញ្ជាតិអ្វីក៏ដោយ ។

បន្ថែមទៅលើការទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះអំពើប្រល័យពូជសាសន៍ អនុសញ្ញាប្រល័យពូជសាសន៍បានរៀបរាប់អំពីការទទួលខុសត្រូវរបស់រដ្ឋលើឆាកអន្តរជាតិចំពោះការរំលោភទៅលើកាតព្វកិច្ចរៀបរាប់នៅក្នុងអនុសញ្ញា ។ រដ្ឋជាសមាជិកអាចប្តឹងនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិដើម្បីចោទប្រកាន់ថារដ្ឋជាសមាជិកមួយទៀតមានការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ។ ការប្តឹងផ្តល់ទីមួយត្រូវបាន

ធ្វើឡើងប្រឆាំងនឹងប្រទេសយូហ្គោស្លាវី ដោយប្រទេសបូស្នៀ-ហឺហ្សេហ្គោវីណា នៅឆ្នាំ១៩៩៣ ហើយបច្ចុប្បន្ននៅតែមិនទាន់សម្រេចនៅឡើយ ។

មាត្រាទី៨នៃអនុសញ្ញារៀបរាប់អំពីវិធានការផ្សេងៗ មិនត្រឹមតែដើម្បីដាក់ទោសចំពោះអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីបញ្ឈប់អំពើនេះពេលវាកំពុងកើតឡើង មាត្រានេះបានចែងថា *«រាល់ភាគីដែលទទួលស្គាល់អនុសញ្ញាអាចស្នើឲ្យអង្គការសហប្រជាជាតិជាតិចាត់វិធានការ នៅក្រោមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដែលត្រូវបានចាត់ទុកថាមានភាពចាំបាច់សម្រាប់ការការពារនិងបញ្ឈប់អំពើប្រល័យពូជសាសន៍ ឬអំពើផ្សេងទៀត ដែលបានរៀបរាប់នៅក្នុងមាត្រាទី៣»* ។ រដ្ឋទាំងឡាយដែលជាសមាជិកនៃអនុសញ្ញាអាចទាមទារការផ្តល់អំណាចពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីប្រើប្រាស់កម្លាំងយោធាក្នុងការបញ្ឈប់អំពើប្រល័យពូជសាសន៍ដែលកំពុងកើតឡើងនៅក្នុងប្រទេសមួយផ្សេងទៀត ។

ចុងបញ្ចប់ ទោះបីជាសន្ធិសញ្ញាជាច្រើនដាក់កំហិតតែទៅលើរដ្ឋជាសមាជិកសន្ធិសញ្ញាក៏ដោយ ក៏នៅក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់នៅឆ្នាំ១៩៥១ តុលាការយុត្តិធម៌អន្តរជាតិបានសង្កេតឃើញថា ទ្រឹស្តីជាមូលដ្ឋានរបស់អនុសញ្ញាប្រល័យពូជសាសន៍ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលផ្សារភ្ជាប់គ្រប់រដ្ឋទាំងអស់ ។

## អំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រ

ទោះបីជា រ៉ាហ្វែល ឡឹមគិន បានបញ្ជាក់ថា ឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ីមានលក្ខណៈប្លែកជាមូលដ្ឋានពីឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងមុនសង្គ្រាមលោកលើកទីពីរ ក៏«ដំណោះស្រាយចុងក្រោយ» របស់ អ៊ីត្លែរ មិនមែនជាប្រតិបត្តិការសម្លាប់រង្គាលទីមួយដែលបំពេញទៅតាមនិយមន័យប្រល័យពូជសាសន៍របស់ រ៉ាហ្វែល ឡឹមគិន ដែរ ។ ការសម្លាប់រង្គាលដោយមានផែនការច្បាស់លាស់របស់ពួកយ៉ាំងធឺកទៅលើជនជាតិអាមេនៀន ពីខែមេសា ឆ្នាំ១៩១៥ គឺជាអំពើប្រល័យពូជសាសន៍ទីមួយប្រចាំសតវត្សរ៍ទី២០ ។ ជំរុញដោយការអើពើរបស់ពិភពលោកចំពោះការកាប់សម្លាប់ជនជាតិអាមេនៀនជាងមួយលាននាក់ អ៊ីត្លែរ ត្រូវបានរាយការណ៍ថា បានពន្យល់អ្នកនៅក្រោមបង្គាប់របស់ខ្លួនដោយសួរជាសំណួរថា «តើបច្ចុប្បន្ននរណាជាអ្នករកយុត្តិធម៌ឲ្យជនជាតិអាមេនៀន?»

នៅក្នុងចំណោមការសម្លាប់រង្គាលក្នុងទ្រង់ទ្រាយធំនាពេលបច្ចុប្បន្ន មានបញ្ញាជនមួយចំនួនបានយល់ស្របថា ការសម្លាប់ជាតិពន្ធុឃើតនៅក្នុងស្រុកជីស៊ីមនៅឆ្នាំ១៩៣៧-៣៨, ការកាប់សម្លាប់ជាតិពន្ធុហ៊ូទូដោយពួកទុតស៊ីនៅប្រទេសប៊ូរុនឌីនៅឆ្នាំ១៩៧២, ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥-៧៩, និងប្រតិបត្តិការអាន់ហ្វែលប្រឆាំងនឹងជាតិពន្ធុឃើតនៅអ៊ីរ៉ាក់ បំពេញតាមល័ក្ខខ័ណ្ឌផ្នែកច្បាប់នៃអំពើប្រល័យពូជសាសន៍ ។

នៅក្នុងចំណោមករណីទាំងនោះ គ្មានករណីណាមួយមានភាពស្មុគស្មាញក្នុងការបកស្រាយថាជាអំពើប្រល័យពូជសាសន៍ ជាងករណីប្រទេសកម្ពុជានោះទេ ។ ដោយសារទំហំនៃការបាត់បង់ជីវិតមនុស្សនៅកម្ពុជាគឺជិត២លាននាក់ក្នុងចំណោម៧លាននាក់ ត្រូវបានជឿថាបានស្លាប់បាត់បង់ជីវិតដោយសារនយោបាយរបស់ខ្មែរក្រហម មតិជាច្រើនបានកំណត់ថាបទឧក្រិដ្ឋរបស់ខ្មែរក្រហមជាអំពើប្រល័យពូជសាសន៍ ។ ដោយសារជនដៃដល់និងជនរងគ្រោះមួយភាគធំជាជាតិពន្ធុខ្មែរ ការសន្និដ្ឋានបែបនោះតម្រូវឲ្យមានការទាញហេតុផលច្បាប់ច្បាស់លាស់ ។ បញ្ញាជនខ្លះបានលើកអំពីពាក្យ «ប្រល័យពូជសាសន៍ខ្លួនឯង (auto genocide)» ដោយអះអាងថា ល័ក្ខខ័ណ្ឌនៃអំពើប្រល័យពូជសាសន៍ក្នុងអនុសញ្ញាឆ្នាំ១៩៤៨អាចត្រូវបានបំពេញ ទោះបីជាជនដៃដល់ព្យាយាមសម្លាប់ផ្នែកដ៏ធំមួយនៃក្រុមជាតិពន្ធុឬសញ្ជាតិខ្លួនឯងក៏ដោយ ។ អ្នកខ្លះបានទាញ ហេតុផលថា ជនរងគ្រោះភាគច្រើនត្រូវបានសម្លាប់ដោយសារមូលហេតុនយោបាយ ហើយបញ្ជាក់ថា ជនរងគ្រោះមួយចំនួន ដូចជាឥស្លាមនិងពុទ្ធសាសនិកត្រូវបានសម្រាំងយកទៅសម្លាប់ដែរ រួចទាញសរុបថា យ៉ាងហោចណាស់បទឧក្រិដ្ឋប្រឆាំងក្រុមទាំងនេះក៏មានលក្ខណៈប្រល័យពូជសាសន៍ដែរ ។

ការសម្លាប់រង្គាលខ្លះមានលក្ខណៈជាអំពើប្រល័យពូជសាសន៍ជាងការសម្លាប់រង្គាលផ្សេងទៀត ដូចជាការសម្លាប់ជនជាតិជ្វីហ្វ

នៅក្នុងសង្គ្រាមលោកលើកទីពីរ និងការសម្លាប់ជាតិពន្ធុទុតស៊ីនៅក្នុងប្រទេសរ៉្វាន់ដានៅឆ្នាំ១៩៩៤ ។ ចំណែកការសម្លាប់រង្គាលផ្សេងទៀតអាចជាអំពើប្រល័យពូជសាសន៍ ឬមិនមែនអាស្រ័យទៅតាមហេតុផលផ្សេងៗដែលលើកឡើង ។ នៅក្នុងអវត្តមាននៃដំណោះស្រាយក្នុងតុលាការឬការតាំងចិត្តផ្នែកនយោបាយ ស្ទើរតែរាល់ករណីអំពើប្រល័យពូជសាសន៍ទាំងអស់អាចចោទសួរបាន ។ ចុងចោទទីមួយដែលបានកាត់ទោសនៅក្នុងតុលាការប្រទេសរ៉្វាន់ដា បានទាញហេតុផលថា ការសម្លាប់រង្គាលនៅក្នុងប្រទេសរ៉្វាន់ដាត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ ដែលជាទម្រង់ដ៏ឃោរឃៅមួយនៃការធ្វើសង្គ្រាមស៊ីវិល ។ តុលាការប្រទេសរ៉្វាន់ដាបានឆ្លើយតបវិញថា «ជាមួយនឹងជម្លោះ ...អំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើងនៅក្នុងប្រទេសរ៉្វាន់ដានៅឆ្នាំ១៩៩៤ប្រឆាំងនឹងជាតិពន្ធុទុតស៊ី» ហើយថា ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែល «ប្រហែលត្រូវបានជួយជំរុញដោយជម្លោះ» មិនមែនមានន័យថា វាបដិសេធការពិតដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើងនោះទេ ។

ការពុំបានជំរុញឲ្យមានការគោរពអនុសញ្ញា និងកង្វះឆន្ទៈនៃសហគមន៍អន្តរជាតិអស់ជាច្រើនទសវត្សរ៍មកហើយ បានធ្វើឲ្យបញ្ញាជនបានត្រឹមតែទាញហេតុផលថាតើអំពើណាជាប់ឈ្មោះជាអំពើ«ប្រល័យពូជសាសន៍»ទៅតាមនិយមន័យច្បាប់ ។ ភាពមិនច្បាស់លាស់បង្កប់នៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍អាចត្រូវបានដោះស្រាយចេញតែក្នុងករណីដែលរដ្ឋទាំងឡាយមានឆន្ទៈក្នុងការទទួលស្គាល់ដោយត្រង់ៗថាអំពើប្រល័យពូជសាសន៍បានកើតឡើង ហើយជំរុញឲ្យគោរពតាមច្បាប់នៃមនសិការ ។

**ជាយអាន់ អ៊្វិនឆ្លីធីរ**

# ផលវិបាកនៃសង្គ្រាមចំពោះជាតិពន្ធនៅកូសូវ៉ូ

## *សេចក្តីផ្តើមៈ ប្រវត្តិខេត្តកូសូវ៉ូ*

ពីឆ្នាំ១៩៨៩ដល់១៩៩៩ កូសូវ៉ូបានជួបប្រទះនូវការគាបសង្កត់ដោយរដ្ឋស៊ែប៊ីយ៉ាងធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។ កូសូវ៉ូគឺជាខេត្តស្វយ័តមួយនៅក្នុងតំបន់ស៊ែប៊ី ដែលមានជម្លោះនឹងគ្នាជាយូរមកហើយ ហើយដែលប្រជាជន៩០ភាគរយនៃខេត្តនេះជាជាតិពន្ធអាល់បានី ។ ទោះបីជាមានអន្តរាគមន៍ម្តងហើយម្តងទៀតពីកងរក្សាសន្តិសុខស៊ែប៊ីនិងសហព័ន្ធយូហ្គោស្លាវីនៅកូសូវ៉ូក៏ដោយ ក៏ការបំបិទមិនឲ្យមានស្វយ័តភាពនៃខេត្តនេះមានទម្រង់ប្លែកមួយចំនួន ។ កម្មវិធីនយោបាយរបស់រដ្ឋា-ភិបាលស៊ែប៊ីថ្មីមិនបានធ្វើឡើងក្នុងគោលបំណងស្តាររបៀបរបបសង្គមនិងការពារមិនឲ្យមានការផ្តាច់ខ្លួន ដូចលើកមុនទេ ផ្ទុយទៅវិញ នយោបាយនេះនាំមកនូវការផ្លាស់ប្តូរដ៏គំហុកនៅក្នុងសង្គមស៊ែប៊ីនិងកូសូវ៉ូទាំងមូល ។ វិធានការបែបគាបសង្កត់របស់រដ្ឋាភិបាលស៊ែប៊ីទៅលើពលរដ្ឋអាល់បានីនៅកូសូវ៉ូ ប្រែប្រួលទៅតាមពេលវេលា ហើយនៅទីបញ្ចប់មានទម្រង់និងលក្ខណៈដូចរបបផ្តាច់ការបែបកុម្មុយនិស្តដែលធ្វើឡើងតាមរយៈអំពើភេរវកម្មផ្ទៃក្នុងដែលគាំទ្រដោយរដ្ឋ ។

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ ជនកុម្មុយនិស្តយូហ្គោស្លាវីបានជួបប្រទះនឹងជម្លោះផ្ទៃក្នុងយ៉ាងធ្ងន់ធ្ងរ វិបត្តិច្បាប់រដ្ឋធម្មនុញ្ញ វិបត្តិសេដ្ឋកិច្ចសង្គម និងអំពើភេរវកម្មប្រឆាំងប្រទេសយូហ្គោស្លាវីដោយពួកជ្រុលនិយមក្នុងស្រុកនិងមកពីខាងក្រៅ ។ នៅមុនការកកើតរបបស៊ែប៊ី រដ្ឋាភិបាលសហព័ន្ធនិងសាធារណរដ្ឋរបស់ប្រទេសយូហ្គោស្លាវីបានឆ្លើយតបជាញឹកញាប់ទៅនឹងបញ្ហាទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពនិងអំណាចរដ្ឋ តាមរយៈការពង្រាយកងសន្តិសុខរដ្ឋនិងនគរបាលដែលបង្ក្រាបពួកប្រឆាំងនយោបាយដោយអាថ៌កំបាំង ។ វិធានការផ្នែកច្បាប់និងសេដ្ឋកិច្ចបានក្លាយទៅជាយុទ្ធសាស្ត្រតែមួយគត់នៃប្រព័ន្ធមួយដែលមានភាពរំដើបរំជួលមិនឈប់ឈរ ។

នៅពេលដែលជនកុម្មុយនិស្តស៊ែប៊ីដឹកនាំដោយ ស្លូបូដាន់ មីឡូសេវិក ដណ្តើមអំណាចបានពីមេដឹកនាំពុំសូវផ្តាច់ការរបស់ស៊ែប៊ីនៅឆ្នាំ១៩៨៧ គោលបំណងសំខាន់និងបន្ទាន់បំផុតរបស់ក្រុមនោះគឺកម្ចាត់ចោលរាល់អ្វីៗដែលអាចជាមធ្យោបាយនៃ

ការប្រឆាំងនយោបាយ ព្រមទាំងធនធានសេដ្ឋកិច្ច មនុស្ស វប្បធម៌ និងសង្គម តាមរយៈការចេញច្បាប់គាបសង្កត់ក្នុងគោលដៅទប់ស្កាត់មិនឲ្យមានការបះបោរប្រឆាំងនឹងរបបថ្មី ។ ការកើនឡើងនៃរបបកុម្មុយនិស្តគឺជាលទ្ធផលនិងជាការឆ្លើយតបទៅនឹងការភ័យខ្លាចរបស់ជនកុម្មុយនិស្តចំពោះការកើតឡើងនៃកំណែទម្រង់បែបប្រជាធិបតេយ្យនិងទីផ្សារសេរីដែលអាចមានគ្រោះថ្នាក់ដល់អំណាចដឹកនាំរបស់ខ្លួន ។ មូលហេតុមួយទៀតគឺប្រជាជនស៊ែប៊ីភាគច្រើនព្រួយបារម្ភថា សាធារណរដ្ឋស៊ែប៊ីមានឋានៈទាបនៅក្នុងសហព័ន្ធយូហ្គោស្លាវី ដោយសារស្វ័យតភាពហួសព្រំដែននៃខេត្តកូសូវ៉ូនិងវ៉ូវ៉ូឌីណាដែលផ្តល់ដោយច្បាប់រដ្ឋធម្មនុញ្ញសហព័ន្ធយូហ្គោស្លាវីឆ្នាំ១៩៧៤ ។

រដ្ឋាភិបាលស៊ែប៊ីថ្មីបានរំលាយចោលសភារបស់កូសូវ៉ូនិងវ៉ូវ៉ូឌីណា បដិសេធចោលការដឹកនាំក្នុងតំបន់ ហើយអនុវត្តនូវកម្មវិធីដ៏ធំមួយក្នុងគោលបំណងធ្វើមជ្ឈការរាល់អំណាចនយោ-បាយតាមរយៈការកាន់អំណាចនីតិបញ្ញត្តិនិងនីតិប្រតិបត្តិផ្តាច់មុខដោយសភាស៊ែប៊ីនិងរដ្ឋាភិបាលនៅបែលក្រាដ ។ ដើម្បីអនុវត្តកម្មវិធីនេះបាន រដ្ឋាភិបាលស៊ែប៊ីបានធ្វើសមាហរណកម្មច្បាប់រដ្ឋធម្មនុញ្ញនៅអំឡុងឆ្នាំ១៩៨៨-៩០ ។

ជាតិពន្ធអាល់បានីនៅកូសូវ៉ូរាប់ម៉ឺននាក់ដែលជាប្រជាជនភាគច្រើននៅក្នុងខេត្តកូសូវ៉ូ ត្រូវរដ្ឋាភិបាលស៊ែប៊ីបណ្តេញចេញពីស្ថាប័នខុបត្ថម្ភដោយរដ្ឋាភិបាលនិងក្រុមហ៊ុនកាន់កាប់ដោយរដ្ឋ ។ កងកម្លាំងរក្សាសន្តិសុខស៊ែប៊ីបានគាបសង្កត់ទៅលើជាតិពន្ធអាល់បានីដែលជាប្រជាជនភាគច្រើននៅក្នុងខេត្តកូសូវ៉ូអស់រយៈពេលជាងមួយទសវត្សរ៍ ។

រដ្ឋាភិបាលស៊ែប៊ីមិនត្រឹមតែបានបង្កើតក្របខ័ណ្ឌផ្នែកច្បាប់និងរដ្ឋធម្មនុញ្ញថ្មីដើម្បីអនុញ្ញាតឲ្យខ្លួនបង្ក្រាបប្រជាជនអាល់បានីប៉ុណ្ណោះទេ ថែមទាំងបានបង្កើតប្រព័ន្ធសម្ងាត់មួយផ្អែកទៅលើការសម្រេចចិត្តជាសម្ងាត់និងសណ្តាប់ធ្នាប់មិនរៀបរាប់ជាលាយលក្ខណ៍អក្សរ ។ នេះជាមូលហេតុធ្វើឲ្យបាត់បង់ការគ្រប់គ្រងទៅលើអំណាចតុលាការនៃអង្គនីតិប្រតិបត្តិនិងនីតិបញ្ញត្តិ និងបង្កើតឡើងនូវមូលដ្ឋានសម្រាប់បដិសេធការចោទប្រកាន់ពីអំពើឃោរឃៅធ្វើឡើងដោយកងទ័ពស៊ែប៊ី ។ សកម្មភាពជាសម្ងាត់ទាំងនោះបានបង្កឲ្យមានការតក់ស្លុតនៅគ្រប់មជ្ឈដ្ឋាន ហើយបង្អាក់យន្តការឆ្លើយតបនិងការពារនៅក្នុងសង្គមស៊ីវិលនិងប្រជាជនទាំងអស់ ។

ការបង្កើតឡើងនូវរបបកុម្មុយនិស្តនៅក្នុងសាធារណរដ្ឋដ៏ធំបំផុតនៃសហព័ន្ធយូហ្គោស្លាវី បានបង្កឲ្យមានចលនាជាតិនិយមមិនមែនស៊ែប៊ី និងពួកផ្តាច់ខ្លួនប្រកាន់ជាតិពន្ធដែលឡើងកាន់អំណាចនៅក្នុងសាធារណរដ្ឋផ្សេងទៀត ។ មកដល់ឆ្នាំ១៩៩១ ប្រទេសយូហ្គោស្លាវីបានចាប់ផ្តើមបែកបាក់ក្រោមសម្ពាធរបស់មេដឹកនាំជាតិនិយមនៅក្នុងសាធារណរដ្ឋជាសមាជិក ។ ប្រឈមមុខនឹងការបែកបាក់ផ្នែករដ្ឋធម្មនុញ្ញនិងសង្គមសេដ្ឋកិច្ច ព្រមទាំងការព្យាយាមផ្តាច់ខ្លួន របបស៊ែប៊ីបានឆ្លើយតបដោយចាត់ទុករដ្ឋស៊ែប៊ីជាជំហរចុងក្រោយនៃសហព័ន្ធយូហ្គោស្លាវី ។ ក្នុងពេលជាមួយគ្នា រដ្ឋស៊ែប៊ីបានអនុវត្តដោយសម្ងាត់នូវកម្មវិធីមួយមានគោលបំណងបំពាក់អាវុធដល់ជាតិពន្ធស៊ែបនៅក្នុងប្រទេសក្រូអាតនិងបូស្នៀ-ហឺហ្សេហ្គោវីណា និងបំពាក់បំប៉នឲ្យក្រុមនេះប្រឆាំងនឹងរដ្ឋាភិបាលស្របច្បាប់នៃសាធារណរដ្ឋទាំងនោះ ។

សកម្មភាពបង្កជម្លោះនេះបានបង្កើនល្បឿននៃការបំបែកខ្លួន ។ មកដល់ពាក់កណ្តាលឆ្នាំ១៩៩១ បន្ទាប់ពីមានការប្រកាសឯករាជ្យភាពជាផ្លូវការដោយសភាជាតិនៃប្រទេសស្លូវេនី និងក្រូអាត ជម្លោះប្រដាប់អាវុធបានផ្ទុះឡើងនៅក្នុងសាធារណរដ្ឋទាំងពីរ ។ ក្នុងឆ្នាំ១៩៩២ ជម្លោះនៅក្នុងប្រទេសបូស្នៀ-ហឺហ្សេហ្គោវីណា កើតឡើងរវាងកងកម្លាំងរបស់សាធារណរដ្ឋទាំងនោះ និងកងកម្លាំងសហព័ន្ធគ្រប់ដណ្តប់ដោយស៊ែប៊ី និងកម្លាំងពីរទៀតគឺជាតិពន្ធស៊ែប៊ីនៅក្រូអាតនិងបូស្នៀ ដែលបំពាក់អាវុធនិងដឹកនាំដោយរបបស៊ែប៊ី ។ សហព័ន្ធយូហ្គោស្លាវីត្រូវរំលាយជាផ្លូវការនៅក្នុងឆ្នាំ១៩៩២ ក្រោយពីអង្គការសហប្រជាជាតិដាក់របាំងសេដ្ឋកិច្ចទៅលើសាធារណរដ្ឋស៊ែប៊ីនិងម៉ុងតេណេក្រូ ។ នេះជារដ្ឋសាធារណៈ តែពីរដែលនៅសេសសល់នៅក្នុងសហព័ន្ធយូហ្គោស្លាវី ។

នៅក្នុងសម័យច្របូកច្របល់នោះ ជនអាល់បានីនៅកូសូវ៉ូបានចាប់ផ្តើមអនុវត្តការប្រឆាំងតាមបែបអហិង្សាចំពោះការដឹកនាំបែបគាបសង្កត់របស់របបស៊ែប៊ី តាមរយៈការបង្កើត

ស្ថាប័នអប់រំ វប្បធម៌ សង្គម និងស្ថាប័នរដ្ឋ ដោយខ្លួនឯង ដើម្បីបម្រើជាតិពន្ធអាល់បានីនៅក្នុងតំបន់ ។ នៅឆ្នាំ១៩៩១ នៅក្នុងការបោះឆ្នោតជាសម្ងាត់បង្កើតឡើងដោយគណបក្សអាល់បានី ជាតិពន្ធអាល់បានីភាគច្រើនលើសលប់បានបោះឆ្នោតគាំទ្រឲ្យកូសូវ៉ូប្រកាសខ្លួនជារដ្ឋឯករាជ្យ ។ របបស៊ែប៊ីមិនទទួលស្គាល់ចំពោះប្រជាមតិនោះទេ ហើយចោទថា ការបោះឆ្នោតនោះល្មើសច្បាប់និងមានលក្ខណៈប្រឆាំង ។

ក្រោយពីមានការរំលោភសិទ្ធិមនុស្សនៅកូសូវ៉ូនិងការគាបសង្កត់ទៅលើជាតិពន្ធអាល់បានី សហគមន៍អន្តរជាតិបែរជាយកចិត្តទុកដាក់ទៅលើជម្លោះប្រដាប់អាវុធនៅបូស្នៀ-ហឺហ្ស៊ីហ្គោវីណាទៅវិញ ។ រដ្ឋាភិបាលស៊ែប៊ីនិងជនជាតិស៊ែប៊ីដែលជាបរិវារ ត្រូវបានសហគមន៍អន្តរជាតិចាត់ទុកថាឃោរឃៅនៅក្នុងអំឡុងជម្លោះប្រដាប់អាវុធពីឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៥ ។ នៅពេលមានសន្និសីទសន្តិភាពនៅដេតុនសម្រាប់បូស្នៀ-ហឺហ្ស៊ីហ្គោវីណានៅឆ្នាំ១៩៩៥ សហគមន៍អន្តរជាតិបានព្យាយាមធ្វើសម្បទានជាមួយរបបស៊ែប៊ីដែលត្រូវបានមើលឃើញថាមានការចាំបាច់សម្រាប់ការបញ្ឈប់ការប្រឈមមុខដាក់គ្នា ។ បញ្ហានៅក្នុងខេត្តកូសូវ៉ូនៅតែមិនទាន់ដោះស្រាយចេញ ហើយស្ទើរតែត្រូវបំភ្លេចចោលនៅក្នុងការពិភាក្សាអំពីសន្តិភាពដែលធ្វើឡើង ក្រោយពីមានការដកហូតរបាំងសេដ្ឋកិច្ចចេញពីស៊ែប៊ីនិងម៉ុងតេណេហ្គ្រូ នៅពេលដែលកិច្ចព្រមព្រៀងសន្តិភាពនៅដេតុនចាប់ផ្តើមដំណើរការ ។

នៅក្នុងខេត្តកូសូវ៉ូ វិធីសាស្ត្រដ៏ធំនិងមានប្រជាប្រិយភាពបំផុតរបស់គណបក្សនយោបាយអាល់បានីគឺការប្រឆាំងបែបអហិង្សានិងការព្យាយាមស្វែងរកដំណោះស្រាយដោយសន្តិវិធីជាមួយរបបដឹកនាំស៊ែប៊ី ។ វិធីសាស្ត្រទាំងពីរនេះទទួលជោគជ័យតិចតួចប៉ុណ្ណោះ ។

មកដល់ឆ្នាំ១៩៩៨ ដោយដឹងថាដំណោះស្រាយអហិង្សាមិនមានប្រសិទ្ធភាព និងដឹងទៀតថារបបស៊ែប៊ីគ្មានឆន្ទៈក្នុងការចរចាជាមួយមេដឹកនាំគណបក្សនយោបាយ ជនអាល់បានីបានបង្កឲ្យមានការប្រែប្រួលដ៏ធំនៅក្នុងសារជាតិនៃជម្លោះនៅកូសូវ៉ូ ។ កងទ័ពរំដោះទឹកដីកូសូវ៉ូដែលជាកងកម្លាំងប្រដាប់អាវុធជាតិពន្ធអាល់បានីរស់នៅក្នុងកូសូវ៉ូ និងដែលមានគោលបំណងដណ្តើមយកសន្តិភាពសម្រាប់ខេត្តកូសូវ៉ូតាមរយៈការតស៊ូអាវុធ បានបង្កើនការវាយប្រហារតាមបែបទាហានឈ្លបទៅលើទីតាំងប៉ូលិសស៊ែប៊ី នាយទាហានស៊ែប៊ី ជនជាតិស៊ែប៊ី និងជនទាំងឡាយដែលសង្ស័យថាជួយគាំទ្ររដ្ឋាភិបាលស៊ែប៊ី ។

រដ្ឋាភិបាលស៊ែប៊ីបានឆ្លើយតបទៅនឹងការវាយប្រហារនេះដោយបង្កើនវិធានការគាបសង្កត់ក្នុងគោលបំណងកាត់បន្ថយរាល់ការប្រឆាំងក្នុងចំណោមជាតិពន្ធអាល់បានី និងដាក់ពង្រាយកងរក្សាសន្តិសុខនៅទូទាំងខេត្តចាប់ពីឆ្នាំ១៩៩៨ ។ កងកម្លាំងរក្សាសន្តិសុខស៊ែប៊ីតែងតែតបតទៅនឹងការវាយប្រហារទៅលើទីតាំងរបស់ខ្លួនតាមរយៈការវាយប្រហារយ៉ាងឃោរឃៅទៅលើភូមិឋានរបស់ជាតិពន្ធអាល់បានី ។ នៅខែមីនា ឆ្នាំ១៩៩៨ ការវាយប្រហារដោយកងរក្សាសន្តិសុខទៅលើភូមិមួយនៅក្នុងទីក្រុងស្រេប្រេនីកា បណ្តាលឲ្យស្លាប់មនុស្សចំនួន៥៨នាក់ រួមទាំងមេដឹកនាំមួយរូបរបស់កងទ័ពរំដោះទឹកដីកូសូវ៉ូ និងសមាជិកគ្រួសាររបស់គាត់ស្ទើរតែទាំងអស់ ។ កងរក្សាសន្តិសុខស៊ែប៊ីបានបន្តគាបសង្កត់និងវាយប្រហារទៅលើភូមិជាច្រើនរបស់ជាតិពន្ធអាល់បានីនៅក្នុងតំបន់ដ្រិននិកា ដែលបណ្តាលឲ្យប្រជាជនជាច្រើននាក់ភៀសខ្លួនចេញពីលំនៅឋាន ។

ដោយមិនបានកាត់បន្ថយសកម្មភាពប្រឆាំងនិងបង្ក្រាបទៅលើការវាយឆ្មក់ អំពើឃោរឃៅរបស់កងកម្លាំងរក្សាសន្តិសុខស៊ែប៊ីបែរជាបង្កឲ្យមានការចងកំហឹងកាន់តែខ្លាំងពីជាតិពន្ធអាល់បានីចំពោះរដ្ឋាភិបាលស៊ែប៊ី ហើយធ្វើឲ្យប្រជាជននៅក្នុងខេត្តកូសូវ៉ូកាន់តែអាណិតអាសូរចំពោះកងទ័ពរំដោះទឹកដីកូសូវ៉ូទៅវិញ ។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ទីប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុវត្តសេចក្តីសម្រេចលេខ១១៦០ ដែលរិះគន់ការប្រើប្រាស់កម្លាំងទ័ពហួសហេតុរបស់រដ្ឋាភិបាលស៊ែប៊ីទល់នឹងជនស៊ីវិលនៅកូសូវ៉ូ ហើយសេចក្តីសម្រេចនោះបានដាក់របាំងមិនឲ្យនាំអាវុធចូលក្នុងប្រទេសស៊ែប៊ីនិងម៉ុងតេណេហ្គ្រូ ។

ទោះជាមានការប្រកាសពីសហគមន៍អន្តរជាតិឲ្យបញ្ឈប់ការប្រើប្រាស់អាវុធក៏ដោយ ក៏កងរក្សាសន្តិសុខស៊ែប៊ីនៅតែបន្តការវាយប្រហារកាន់តែឃោរឃៅនៅរដូវក្តៅនៅភាគខាងកើតខេត្ត

កូសូវ៉ូតាមបណ្តោយព្រំដែនអាល់បានី ក្នុងគោលបំណងបំផ្លាញផ្លូវដឹកជញ្ជូនសម្ភាររបស់កងទ័ពរំដោះទឹកដីកូសូវ៉ូមកពីភាគខាងជើងអាល់បានី ។ នៅក្នុងដំណាក់កាលនៃការវាយប្រហារនោះ មានជនអាល់បានីប្រមាណ៤ម៉ឺន៥ពាន់នាក់បានភៀសខ្លួនទៅប្រទេសអាល់បានីនិងម៉ុងតេណេក្រូ ។ ជនភៀសខ្លួនបានទទួលរងការវាយប្រហារជាប្រចាំពីកងរក្សាសន្តិសុខស៊ែប៊ី ហើយភូមិឋានដែលបោះបង់ចោលតែងត្រូវលួចទ្រព្យសម្បត្តិនិងដុតបំផ្លាញចោល ។

នៅក្រោមសម្ពាធរបស់សហគមន៍អន្តរជាតិ នៅទីបំផុតរដ្ឋាភិបាលស៊ែប៊ីបានយល់ព្រមបញ្ឈប់ប្រតិបត្តិការប្រឆាំងការវាយឆ្មក់ ហើយអនុវត្តបេសកកម្មឃ្លាំមើលដំណើរការដែលគ្រប់គ្រងដោយអង្គការសន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុបនៅក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ១៩៩៨ ។ ក៏ប៉ុន្តែ ទោះជាមានបទឈប់បាញ់គ្នាបែបនេះក៏ដោយ ក៏កងទ័ពស៊ែប៊ីនៅតែបន្តវាយប្រហារទៅលើជាតិពន្ធអាល់បានីដោយសម្ងាត់ក្នុងគោលបំណងកាត់បន្ថយការគាំទ្រកម្លាំងខុទ្ទាម ។ នៅក្នុងការវាយប្រហារមួយ កងរក្សាសន្តិសុខស៊ែប៊ីបានសម្លាប់ជនអាល់បានីចំនួន៤៥នាក់ នៅក្នុងភូមិមួយឈ្មោះ រ៉ាសាក់ ។ អំពើឃោរឃៅនេះបណ្តាលឲ្យមានការតវ៉ាជាខ្លាំងនៅលើឆាកអន្តរជាតិ ពិសេសនៅសហរដ្ឋអាមេរិក ហើយប្រកាសឲ្យអន្តរជាតិឆ្លើយតបជាបន្ទាន់ទៅនឹងអំពើឃោរឃៅរបស់កងទ័ពស៊ែប៊ី ។

នៅរដូវផ្ការីកឆ្នាំ១៩៩៩ សហគមន៍អន្តរជាតិ បានរៀបចំកិច្ចពិភាក្សាសន្តិភាពរវាងមេដឹកនាំនយោបាយអាល់បានីនិងគណៈប្រតិភូរបស់របបស៊ែប៊ី នៅប្រទេសបារាំង ។ ក្រោយពីការពិភាក្សាយ៉ាងក្តៅគគុក មេដឹកនាំអាល់បានីបានយល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពមួយដែលលើកឡើងដោយអ្នកចូលរួមអន្តរជាតិដែលមានវត្តមាននៅទីនោះ ប៉ុន្តែគណៈប្រតិភូស៊ែប៊ីបានបដិសេធ ហើយកិច្ចប្រឹងប្រែងដើម្បីសន្តិភាពក៏ត្រូវគាំងដំណើរ ។ ក្រោយការចរចា ក្រុមអ្នកសង្កេតការណ៍របស់អង្គការសម្រាប់សន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុបបានដកខ្លួនចេញពីខេត្តកូសូវ៉ូ ហើយកងរក្សាសន្តិសុខស៊ែប៊ីក៏ចាប់ផ្តើមបើកការវាយប្រហារជាថ្មីទៅលើទីតាំងជាច្រើននៅក្នុងទឹកដីកូសូវ៉ូ ដែលបណ្តាលឲ្យជនអាល់បានីរាប់ម៉ឺននាក់ចាកចេញពីផ្ទះនិងបោះបង់ចោលអាជីវកម្មដើម្បីស្វែងរកសុវត្ថិភាពនៅក្នុងទឹកដីថ្មី ។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ អង្គការណាតូបានបើកប្រតិបត្តិការទម្លាក់គ្រាប់បែកនៅស៊ែប៊ីនិងម៉ុងតេណេក្រូក្នុងគោលបំណងបង្ខំឲ្យរបបស៊ែប៊ីបញ្ឈប់អំពើឃោរឃៅហើយទទួលយកដំណោះស្រាយសន្តិភាពនៅលើតុចរចា ។ នៅក្នុងអំឡុងពេលទម្លាក់គ្រាប់បែកដោយអង្គការណាតូ កងរក្សាសន្តិសុខស៊ែប៊ីបានវាយប្រហារកាន់តែខ្លាំងក្លាទៅលើជនអាល់បានីនិងប្រព្រឹត្តអំពើឃោរឃៅដ៏រន្ធត់ ។

ចំនួននិងកម្រិតនៃអំពើឃោរឃៅទាំងនេះបានធ្វើឲ្យជនអាល់បានីរាប់រយនាក់ស្លាប់បាត់បង់ជីវិត ត្រូវចាប់ខ្លួន បណ្តេញចេញពីផ្ទះ និងបោះបង់ចោលមុខជំនួញ ។ កងរក្សាសន្តិសុខស៊ែប៊ី សហការជាមួយនឹងជាតិពន្ធស៊ែបនិងសមាជិកមួយចំនួនតូចនៃជាតិពន្ធផ្សេងទៀត បានឆក់ប្លន់ទ្រព្យសម្បត្តិនិងដុតបំផ្លាញផ្ទះសម្បែងរបស់ជាតិពន្ធអាល់បានី ។

នៅដើមខែមិថុនា ឆ្នាំ១៩៩៩ តំណាងអង្គការណាតូនិងកងកម្លាំងរក្សាសន្តិសុខស៊ែប៊ីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបច្ចេកទេសយោធានៅទីក្រុងគូម៉ាណូវ៉ូ ប្រទេសម៉ាសេដូនៀ ។ អាស្រ័យលើកិច្ចព្រមព្រៀងនោះ កងរក្សាសន្តិសុខស៊ែប៊ីបានបញ្ឈប់រាល់ប្រតិបត្តិការយោធា ហើយដកខ្លួនចេញពីខេត្តកូសូវ៉ូជាថ្នូរនឹងការបញ្ឈប់ការទម្លាក់គ្រាប់បែក ។ ចំណែករដ្ឋាភិបាលស៊ែប៊ីបានយល់ព្រមឲ្យមានការពង្រាយទាហានរបស់កងកម្លាំងកូសូវ៉ូដឹកនាំដោយអង្គការណាតូចំនួន៥ម៉ឺននាក់នៅក្នុងខេត្តដើម្បីរក្សាសន្តិភាព ។ ក្រោយពីការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងនោះ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចលេខ១២៤៤ស្តីអំពីកូសូវ៉ូ ដែលផ្តល់អំណាចឲ្យបេសកកម្មគ្រប់គ្រងបណ្តោះអាសន្នរបស់អង្គការសហប្រជា-ជាតិនៅកូសូវ៉ូដឹកនាំខេត្តនេះសម្រាប់រយៈពេលមួយមិនកំណត់ ។ សេចក្តីសម្រេចលេខ១២៤៤បានបន្តថែងថា ខេត្តកូសូវ៉ូនឹងឋិតនៅជាផ្នែកមួយនៃរដ្ឋស៊ែប៊ី ប៉ុន្តែមិនបានរៀបរាប់អំពីការបោះឆ្នោតដោយផ្ទាល់ដើម្បីសម្រេចអំពីអនាគតរបស់ខេត្តនេះ




ទេ ។

កងរក្សាសន្តិសុខស៊ើប៊ីបានដកថយពីកូសូវ៉ូ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ហើយកងទ័ពដែលដឹកនាំដោយអង្គការណាតូបានចូលមកដល់ក្នុងថ្ងៃជាមួយគ្នា ។ ជនអាល់បានីជាច្រើនបានត្រឡប់មកកូសូវ៉ូវិញ ហើយបានសងសឹកទៅលើជនជាតិស៊ើបនិងជាតិពន្ធុផ្សេងទៀតដោយឆក់ប្លន់ទ្រព្យសម្បត្តិ ដណ្តើមកាន់កាប់ ដុតនិងបំផ្លាញផ្ទះសម្បែង ។ ពួកឧក្រិដ្ឋកាសនិយមមួយចំនួនក៏បានចូលរួមនៅក្នុងសកម្មភាពនេះដែរ ។

ទោះបីជាមានការយល់ព្រមថាកងទ័ពរំដោះទឹកដីកូសូវ៉ូត្រូវដកហូតអាវុធនិងរំសាយខ្លួនជាបន្ទាន់ក៏ដោយ ក៏កងទ័ពនេះនៅតែមានសកម្មភាពដដែល ជាពិសេសនៅកន្លែងដែលកងរក្សាសន្តិសុខស៊ើប៊ីទើបនឹងដកថយភ្លាមៗ ហើយពុំទាន់មានអាជ្ញាធរដឹកនាំត្រឹមត្រូវ ។ កងទ័ពសេសសល់នេះបានឆែកឆេរផ្ទះសម្បែងរបស់ជាតិពន្ធុផ្សេងៗដោយខុសច្បាប់ ចាប់ខ្លួនជនដែលត្រូវសង្ស័យថាបានសហការជាមួយកងរក្សាសន្តិសុខស៊ើប៊ី ដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅតាមផ្លូវក្នុងភូមិនិងទីក្រុងដើម្បីបញ្ឈប់អ្នកដំណើរ និងធ្វើអំពើល្មើសច្បាប់ផ្សេងទៀតដូចជាលួចឆក់ប្លន់រុះរើនិងដុតផ្ទះសម្បែងនិងហាងនានា វាយធ្វើបាបក្រុមជាតិពន្ធុដទៃ បណ្តេញចេញពីផ្ទះនិងទីកន្លែងធ្វើការផាវមិនផ្តល់សិទ្ធិឲ្យជាតិពន្ធុដទៃប្រើប្រាស់សេវាសុខាភិបាលនិងសេវាសាធារណៈផ្សេងទៀត ប្រព្រឹត្តអំពើហិង្សានិងអំពើរំលោភសិទ្ធិមនុស្សជាច្រើនទៀត ។

មានជនមិនមែនអាល់បានីយ៉ាងហោចណាស់៩៣២នាក់បានបាត់ខ្លួនពីខែមិថុនា ឆ្នាំ១៩៩៩ ដល់ខែធ្នូ ឆ្នាំ២០០០ ។ ការស្រាវជ្រាវធ្វើឡើងដោយអង្គការមនុស្សធម៌បានបញ្ជាក់ថាជនជាតិស៊ើបបានបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ ពីខែមិថុនាដល់ខែកញ្ញា ឆ្នាំ១៩៩៩ គិតសរុបទាំងជាតិពន្ធុផ្សេងៗមានមនុស្សចំនួន៨៣៥នាក់បានបាត់ខ្លួន ។ កងទ័ពរំដោះទឹកដីកូសូវ៉ូបានដោះលែងមកវិញចំនួន១៨១នាក់ ២៤នាក់បានរត់រួចពីមន្ទីរឃុំឃាំង ១៣នាក់ត្រូវដោះលែងដោយកងទ័ពណាតូ ហើយ៦២នាក់ទៀតត្រូវសម្លាប់ចោលក្រោយពីចាប់ខ្លួន ។ មនុស្សចំនួន៥៩៣នាក់នៅមិនទាន់រកឃើញនៅឡើយ ។

អ្នកដែលបាត់ខ្លួនភាគច្រើនជាជនស៊ីវិល ។ ក្នុងចំណោមអ្នកបាត់ខ្លួនទាំង៥៩៣នាក់ មាន២៥៧នាក់ត្រូវចាប់ខ្លួនដោយកងទ័ពរំដោះកូសូវ៉ូហើយបាត់ដំណឹង ។ ចំណែក៦៣៣៦នាក់ទៀតបានបាត់ខ្លួនដោយពុំដឹងមូលហេតុ ។ ករណីបាត់ខ្លួនភាគច្រើនបានកើតឡើងនៅក្នុងទីក្រុងដែលកងរក្សាសន្តិសុខស៊ើប៊ីពុំសូវបានប្រព្រឹត្តអំពើហិង្សានៅក្នុងដំណាក់កាលប្រតិបត្តិការទម្លាក់គ្រាប់បែកដោយអង្គការណាតូ ។ ពីថ្ងៃទី១២ ខែមិថុនា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៩ មានមនុស្ស១២១នាក់បាត់ខ្លួននៅព្រីសរីន ក្នុងនោះមនុស្ស៥១នាក់ត្រូវចាប់ខ្លួនដោយកងទ័ពរំដោះកូសូវ៉ូហើយបាត់ដំណឹង ៤២នាក់បានបាត់ខ្លួនដោយពុំដឹងមូលហេតុ ៥នាក់ត្រូវសម្លាប់ក្រោយពីចាប់ខ្លួន ហើយ២៣នាក់ត្រូវដោះលែងមកវិញដោយការធ្វើអន្តរាគមន៍ពីកងទ័ពណាតូ ។ នៅទីក្រុងព្រីសទីណា ដំណាក់កាលជាមួយគ្នានោះជនមិនមែនអាល់បានីចំនួន១៤២នាក់បានបាត់ខ្លួន ក្នុងនោះ២៧នាក់ត្រូវដោះលែងវិញក្រោយពីចាប់ខ្លួនបានប៉ុន្មានថ្ងៃ ។ មកទល់នឹងថ្ងៃទី១ ខែកញ្ញា សាកសពចំនួន៧ត្រូវបានរកឃើញ ។ នៅទីក្រុងជីលែន មានមនុស្សចំនួន១២០នាក់បានបាត់ខ្លួន ៤៧នាក់ត្រូវបានដោះលែងបន្ទាប់ពីការសួរចម្លើយ ហើយ៨នាក់ទៀតត្រូវបានដោះលែងដោយសារអន្តរាគមន៍ពីកងទ័ពណាតូ ។ តាមរយៈព័ត៌មានដែលប្រមូលបានដោយអង្គការមនុស្សធម៌ ជាតិពន្ធុស៊ើបនិងរ៉ូម៉ាចំនួន៦៣នាក់បានបាត់ខ្លួននៅជ្យាកូវីកាក្នុងរយៈពេលពីរខែកន្លះ ។

១៨នាក់ត្រូវបានដោះលែងមកវិញក្នុងអំឡុងពេលប៉ុន្មានថ្ងៃបន្ទាប់ពីសួរចម្លើយ ២នាក់រត់រួច សាកសព៤ត្រូវបានរកឃើញ ហើយ៤១នាក់ទៀតនៅតែបាត់ខ្លួន ។ ការស្រាវជ្រាវរបស់អង្គការមនុស្សធម៌បានបង្ហាញថា នាយទាហានរបស់កងរក្សាសន្តិសុខស៊ើប៊ីជាច្រើននាក់បានបាត់ខ្លួនក្នុងដំណាក់កាលទម្លាក់គ្រាប់បែករបស់អង្គការណាតូនិងការវាយប្រហារជាមួយកងទ័ពរំដោះទឹកដីកូសូវ៉ូ ។ នៅក្នុងដំណាក់កាលជាមួយគ្នា ជនអាល់បានីចំនួន១៥០០នាក់បានបាត់ខ្លួនក្រោយពីត្រូវចាប់ឃុំឃាំង ។

ក្រោយថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៩ ការចាប់ពង្រត់និងការបាត់ខ្លួននៃជាតិពន្ធបានកើតឡើងក្នុងរឿងក្តីដាច់ដោយឡែក ។ នេះជាលទ្ធផលនៃការពិតដែលថាជាតិពន្ធស៊ើប៊ីរស់នៅក្នុងខេត្តកូសូវ៉ូភាគច្រើន និងសមាជិកជាច្រើននៃជាតិពន្ធផ្សេងទៀត បានភៀសខ្លួនចេញពីកូសូវ៉ូ ឬទៅពួននៅក្នុងជំរំដែលការពារដោយកងទ័ពណាតូ ។ តួលេខរបស់អង្គការមនុស្សធម៌បង្ហាញថា មានជនមិនមែនអាល់បានីចំនួន៩៧រូបបានបាត់ខ្លួនពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៩ ដល់ចុងខែធ្នូ ឆ្នាំ២០០០ ក្នុងនោះ៧២នាក់ត្រូវបាត់ដំណឹងឈឹង ។ ករណីនេះគឺពិតទាំងស្រុងចំពោះអំពើហិង្សានិងការរំលោភសិទ្ធិមនុស្សនៅក្នុងខេត្តកូសូវ៉ូ ។ ដោយសារជាតិពន្ធស៊ើបនិងជាតិពន្ធផ្សេងទៀតបានចាកចេញពីខេត្តកូសូវ៉ូស្ទើរតែទាំងអស់នោះ អត្រាការនៃបាត់ខ្លួនបានថយចុះ ។

## ស្ថានការណ៍បច្ចុប្បន្ន

អំពើឃោរឃៅក្នុងទ្រង់ទ្រាយធំធ្វើឡើងដោយកងរក្សាសន្តិសុខស៊ើប៊ី នៅក្នុងជម្លោះប្រដាប់អាវុធពីឆ្នាំ១៩៩៨ដល់ឆ្នាំ១៩៩៩ និងការទម្លាក់គ្រាប់បែករបស់អង្គការណាតូ រួមទាំងការគាបសង្កត់អស់រយៈពេលជាងមួយទសវត្សរ៍ដោយរបបស៊ើប៊ីទៅលើជាតិពន្ធអាល់បានី បានធ្វើឲ្យមានការប្រកាន់ពូជសាសន៍រវាងជាតិពន្ធអាល់បានីនិងជនជាតិស៊ើបនិងជាតិពន្ធផ្សេងទៀតដែលត្រូវបានចាត់ទុកថាបានសហការជាមួយមេដឹកនាំរបបស៊ើប៊ី ។ អំពើឃោរឃៅនិងកង្វះខាតឆន្ទៈនយោបាយរបស់រដ្ឋាភិបាលស៊ើប៊ីនៅឆ្នាំ២០០០ក្នុងការទទួលខុសត្រូវចំពោះអំពើឃោរឃៅពីអតីតកាលដែលបានប្រព្រឹត្តឡើងក្រោមមូលហេតុបម្រើប្រយោជន៍ប្រទេសស៊ើប៊ី បានធ្វើឲ្យទំនាក់ទំនងរវាងជាតិពន្ធនៅក្នុងខេត្តកូសូវ៉ូដែលធ្លាប់តែមិនសូវចុះសម្រុងគ្នានោះកាន់តែដុនដាបថែមទៀត ។ គោលជំហរនយោបាយមិនបត់បែនរបស់មេដឹកនាំរដ្ឋាភិបាលស៊ើប៊ីដែលទទួលខុសត្រូវចំពោះកិច្ចការកូសូវ៉ូ បានផ្តល់ផលវិបាកដល់ជាតិពន្ធស៊ើបនិងជាតិពន្ធផ្សេងទៀតនៅក្នុងខេត្តកូសូវ៉ូ ។ រឿងក្តីមនុស្សបាត់ខ្លួនទាំងសមាជិកនៃជាតិពន្ធអាល់បានីនិងស៊ើប ព្រមទាំងជាតិពន្ធផ្សេងទៀត បានបន្តបំពុលបរិយាកាសរួមរស់ជាមួយគ្នានិងផ្សះផ្សារវាងជនជាតិផ្សេងៗនៅក្នុងខេត្តកូសូវ៉ូ ដែលមានភាពចាំបាច់សម្រាប់ការនាំទៅរកភាពដើមវិញនៃទំនាក់ទំនងរវាងជាតិពន្ធខុសៗគ្នា និងការបណ្តុះលទ្ធិប្រជាធិបតេយ្យនៅក្នុងតំបន់ ។

ស្ថានភាពបច្ចុប្បន្នដែលប្រឈមមុខជាតិពន្ធទាំងឡាយនៅក្នុងខេត្តកូសូវ៉ូ គឺកង្វះការទុកចិត្តនិងភាពមិនច្បាស់លាស់ចំពោះអនាគត ។ ប្រជាជនទាំងអស់កំពុងរង់ចាំជនណាម្នាក់ដែលមានគោលដៅនយោបាយផ្សេងពីតម្រូវការជាក់ស្តែងនៃជាតិពន្ធទាំងអស់នៅក្នុងខេត្តកូសូវ៉ូ មកធ្វើការសម្រេចចិត្តដែលជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាជនកូសូវ៉ូក្នុងពេលបច្ចុប្បន្ននិងពេលអនាគត ។

តួនាទីមិនដាច់ស្រេចរបស់ខេត្តកូសូវ៉ូធ្វើឲ្យស្ថានការណ៍កាន់តែដុនដាប ។ អង្គការបេសកកម្មគ្រប់គ្រងបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ អង្គការសម្រាប់សន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុប និងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀតដែលមានវត្តមាននៅក្នុងខេត្ត ទាមទារឲ្យកូសូវ៉ូមានឋានៈអន្តរជាតិជាក់លាក់មួយ ពិសេសនៅក្នុងក្របខ័ណ្ឌយុរអង្វែងដែលទទួលបានការគោរពនិងការពារសិទ្ធិមនុស្សនិងសិទ្ធិជាពលរដ្ឋរបស់ជាតិពន្ធទាំងអស់ មុនពេលចាប់ផ្តើមចរចាអំពីឋានៈរបស់ខេត្តកូសូវ៉ូ ។

ដោយមូលហេតុនេះ មេដឹកនាំជាតិពន្ធអាល់បានីជាច្រើននាក់បានបញ្ចេញសំឡេងគាំទ្រមិនងាករេចំពោះសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋនៃជាតិពន្ធទាំងអស់ និងការវិលទៅរួមរស់នៅក្នុងសង្គមមួយដែលគោរពគ្នាទៅវិញទៅមក ហើយបន្ថែមទៀតថាការផ្សះផ្សានិងការរួមរស់ជាមួយគ្នាអាចធ្វើទៅបានលុះត្រាតែខេត្តកូសូវ៉ូទទួលបានឯករាជ្យភាព ។

សាធារណជនអាល់បានីទូទៅនៅតែរស់នៅក្នុងស្រមោលអន្ធកាលដ៏ធំធេងបន្សល់ពីអតីតកាលដែលពោរពេញទៅដោយអំពើឃោរឃៅនិងការបាត់ខ្លួនសមាជិកគ្រួសារដែលមិនអាចដោះស្រាយចេញ។ រដ្ឋាភិបាលស៊ែប៊ីបច្ចុប្បន្នបន្តបដិសេធមិនទទួលខុសត្រូវ ឬគ្រាន់តែព្យាយាមដោះស្រាយក្នុងកម្រិតតិចតួច ហើយតែងតែលើកអំពីករណីបាត់ខ្លួនរបស់ជនជាតិស៊ែបដែលចោទថាត្រូវបានចាប់ពង្រត់និងសម្លាប់ដោយក្រុមកងទ័ពរំដោះទឹកដីកូសូវ៉ូ។

ពេលដែលមកដល់ខេត្តកូសូវ៉ូជាលើកដំបូងនៅឆ្នាំ១៩៩៩ អង្គការរក្សាសន្តិភាពអន្តរជាតិបានឈរឱបដៃមើលសកម្មភាពឆក់ប្លន់ រុះរើនិងដុតផ្ទះសម្បែង ដែលធ្វើឡើងដោយជាតិពន្ធភាគច្រើន។ អង្គការអន្តរជាតិតែងត្រូវបានចោទប្រកាន់ថាប្រកាន់គោលជំហរអសកម្មនិងមិនអើពើនៅពេលជួបប្រទះនឹងទង្វើរំលោភសិទ្ធិមនុស្សនិងអំពើហិង្សាទៅលើជាតិពន្ធផ្សេងៗនៅកូសូវ៉ូ ដែលគ្រាន់តែធ្វើឲ្យជនជាតិទាំងអស់មានការស្អប់ខ្ពើមនិងមិនពេញចិត្តចំពោះវត្តមានសហគមន៍អន្តរជាតិដែលប្រកាសខ្លួនថាមកការពារជាតិពន្ធ។

ដោយមានបន្ទុកយ៉ាងធ្ងន់ធ្ងរចំពោះអស្ថិរភាពសង្គមសេដ្ឋកិច្ច និងនយោបាយ ដែលកើតមាននៅក្នុងសង្គមស៊ែប៊ី រដ្ឋាភិបាលថ្មីរបស់រដ្ឋស៊ែប៊ីបានរក្សាគោលនយោបាយមិនបត់បែនចំពោះបញ្ហាកូសូវ៉ូ។ សភាជាតិនិងរដ្ឋាភិបាលស៊ែប៊ីតែងតែប្រកាសជាផ្លូវការថា កូសូវ៉ូធ្លាប់ជាផ្នែកមួយមិនអាចញែកដាច់នៃអធិបតេយ្យភាពជាតិនិងបូរណភាពទឹកដីស៊ែប៊ី ហើយនឹងនៅតែជាផ្នែកមួយនៃស៊ែប៊ីជារៀងរហូត ដោយមិនខ្វល់ចំពោះបំណងប្រាថ្នារបស់ប្រជាជនភាគច្រើននៅក្នុងខេត្ត និងផលវិបាកនៃការថ្លែងបែបនោះចំពោះឋានៈនៃជនជាតិភាគតិចដែលបន្តរស់នៅទីនោះឡើយ ជាពិសេសគឺជនជាតិស៊ែប។ សកម្មភាពរបស់រដ្ឋាភិបាលស៊ែប៊ីនៅក្នុងខេត្ត ជាពិសេសមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ខេត្តកូសូវ៉ូ តែងតែផ្តោតការយកចិត្តទុកដាក់ទៅលើការរក្សាកូសូវ៉ូជាផ្នែកមួយនៃប្រទេសស៊ែប៊ីជាជាងដោះស្រាយតម្រូវការជាក់ស្តែងនៃជាតិពន្ធស៊ែបនិងជាតិពន្ធផ្សេងទៀត។

អ្នកនយោបាយទាំងសងខាងតែងតែពិចារណាអំពីបញ្ហារដ្ឋនិងនយោបាយអន្តរជាតិ ប៉ុន្តែជាតិពន្ធទាំងអស់ដែលអ្នកនយោ-បាយទាំងនេះតែងលើកយកទៅពិភាក្សាដូចជា ស៊ែប រ៉ូម៉ា អាស្កាលី អេហ្ស៊ីប ក្រូអាត និងជនមិនមែនអាល់បានី ត្រូវបានទុកឲ្យដោះស្រាយបញ្ហាសង្គមដោយខ្លួនឯង។ បញ្ហារួមមានការស្វែងរកនិងរក្សាការងារនៅក្នុងវិបត្តិសេដ្ឋកិច្ចក្រោយសង្គ្រាម ការប្តឹងយកទ្រព្យសម្បត្តិដែលរឹបអូសដោយជនអាល់បានីមកវិញតាមផ្លូវច្បាប់ ការស្វែងរកការអប់រំ សេវាសុខភាព និងតម្រូវការចាំបាច់ផ្សេងទៀតសម្រាប់គ្រួសារ និងការងារប្រចាំថ្ងៃសាមញ្ញបំផុតនោះគឺការងារស្រែចម្ការ ដោយមិនចាំបាច់ឲ្យមានការឃ្លាំមើលពីទាហានណាតូ និងកុំឲ្យមានការធ្វើបាបពីជនអាល់បានី។ ដូច្នេះ នៅពេលដែលការពិភាក្សាវែកញែកអំពីឋានៈផ្លូវច្បាប់នៃខេត្តកូសូវ៉ូចេះតែបន្ត ជាតិពន្ធទាំងអស់នៅក្នុងទឹកដីកូសូវ៉ូ នៅតែជាចំណាប់ខ្មាំងនៃជម្លោះអតីតកាលដែលគ្មាននរណាចង់ដោះស្រាយរកយុត្តិធម៌និងធ្វើឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយ។ ជាតិពន្ធទាំងនោះជាអ្នកទោសរបស់ស្ថានការណ៍សង្គមដ៏តឹងតែងដែលតែងយកមកពិភាក្សាប៉ុន្តែមិនដែលអនុវត្តជាក់ស្តែង។

**ម៉ាកូ ម៉ាល់កូវីក**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ការវិវត្តន៍ចុងក្រោយនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

***ក្នុងការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលនឹងដំណើរការនាពេលខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជាចង់ឲ្យបង្កើតសាលាក្ដីអន្តរជាតិ ប៉ុន្តែចង់ឲ្យមានចៅក្រមកម្ពុជាចូលរួមច្រើនជាងចៅក្រមបរទេស ។ តើការមានចៅក្រមខ្មែរក្នុងតុលាការអន្តរជាតិច្រើនជាងចៅក្រមបរទេសជាការគួរឲ្យបារម្ភខាងយុត្តិធម៌ដែរឬទេ?***

មុនពេលឈានដល់ការសម្រេចតាមផ្លូវគតិយុត្តិអំពីចំនួនចៅក្រមខ្មែរនិងចៅក្រមបរទេសនៅក្នុងដំណើរការកាត់ក្ដីមេដឹកនាំខ្មែរក្រហមដែលជាតុលាការអន្តរជាតិធ្វើឡើងក្នុងស្រុកជាពិសេសមុនពេលដែលសភាជាតិផ្ដល់សច្ចាប័នលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងមុនពេលដែលព្រះមហាក្សត្រឡាយព្រហស្ដលេខាលើច្បាប់នេះនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ មានការជជែកដេញដោលនិងវែកញែកគ្នាយ៉ាងខ្លាំងក្លាចាប់ពីឆ្នាំ១៩៩៧មក ។

ជាសង្ខេប យើងពិនិត្យឃើញមានទស្សនៈពីរចម្បង ។ ទស្សនៈទី១គឺការយកអធិបតេយ្យភាពជាធំ ។ អ្នកដែលផ្ដួចផ្ដើមនិងគាំទ្រទស្សនៈនេះគឺរាជរដ្ឋាភិបាលកម្ពុជា ។ ទស្សនៈទី២គឺយក "មតិភាគច្រើនដាច់ខាត (supermajority)" ជាចំណុចសំខាន់ដើម្បីដោះស្រាយភាពទាល់ច្រក ។ មតិភាគច្រើនដាច់ខាតនេះអាចជួយបានច្រើនគួរសមក្នុងដំណើរការជំនុំជម្រះក្ដី ហើយគំនិតបង្កើតរូបមន្តនេះចេញមកពីសហរដ្ឋអាមេរិក ។ ផ្អែកតាមរូបមន្តនេះ មតិភាគច្រើនមិនអាចផ្ដួលមតិភាគតិចបានទេ ។ មានន័យថា មតិភាគតិចក៏មានអំណាចស្មើនឹងមតិភាគច្រើនដែរហើយមតិភាគច្រើនមិនអាចមានសុពលភាពបានទេ ប្រសិនបើមិនទទួលយកមតិភាគតិចនៅក្នុងសេចក្ដីសម្រេចណាមួយរបស់សហចៅក្រម ។ ប្រសិនបើយកតាមរូបមន្តមតិភាគច្រើនតាមធម្មតា ពិតជាការចាញ់ប្រៀបខាងចៅក្រមខ្មែរជាមិនខាន ។ ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្ដែង ។ នៅក្នុងជំពូកទី៣ មាត្រាទី៩ និយាយអំពីសមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ សាលាដំបូងមានចៅក្រមវិជ្ជាជីវៈ៥រូប ក្នុងនោះមានចៅក្រមខ្មែរ៣រូបដែល១រូបធ្វើជាប្រធាន និងចៅក្រមបរទេស២រូប ។ ដូចនេះ ទោះបីជាចៅក្រមខ្មែរមានជំហរដូចគ្នា១០០ភាគរយ ក៏មិនអាចផាត់ចៅក្រមបរទេស២រូបឲ្យនៅក្រៅបញ្ជីបានដែរ ។ ដាច់ខាតរាល់សេចក្ដីសម្រេចត្រូវតែមានចៅក្រមបរទេស១រូបយ៉ាងតិចដើម្បីធ្វើឲ្យសេចក្ដីសម្រេចមានសុពលភាព ។ តាមពិត មាននីតិវិធីស៊ីជម្រៅតទៅមុខទៀត ប៉ុន្តែចំណុចសំខាន់គឺមតិភាគតិចមានតម្លៃស្មើនឹងមតិភាគច្រើន ។

ទោះបីជាមតិភាគតិចមានតម្លៃស្មើមតិភាគច្រើនដូចនេះក៏ពិតមែន ក៏នៅមានមតិរិះគន់មួយចំនួនសម្ដែងការព្រួយបារម្ភទៅលើការបែងចែកបក្ខពួកគ្នារវាងចៅក្រមនិងព្រះរាជអាជ្ញាបរទេសជាមួយចៅក្រមនិងព្រះរាជអាជ្ញាខ្មែរ ហើយការសម្រេចផ្សេងៗនឹងផ្អែកទៅលើសញ្ជាតិជាជាងផ្អែកទៅលើមូលដ្ឋាននៃអង្គហេតុនិងអង្គច្បាប់ ។ ពីព្រោះថា យោងតាមមាត្រាទី១១នៃច្បាប់កាត់ទោសខ្មែរក្រហម "អង្គជំនុំជម្រះវិសាមញ្ញ" វាក្យខ័ណ្ឌទី៤ អគ្គលេខាធិការអង្គការសហប្រជាជាតិរៀបចំបញ្ជីបេក្ខជនចៅក្រមបរទេស "ដែលមានចំនួនយ៉ាងតិច១២រូប" ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សាអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិ៩រូប និងចៅក្រមបម្រុងយ៉ាងតិច៣រូបចេញពីក្នុងបញ្ជីនោះ ។ ដូចនេះ ទាំងចៅក្រមពេញសិទ្ធិនិងចៅក្រមបម្រុង គឺសុទ្ធតែត្រូវឆ្លងកាត់យោបល់និងការសម្រេចរបស់រដ្ឋាភិបាលនិងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

តាមប្រសាសន៍របស់ឯកឧត្តម ឱម យិនទៀង នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៣ "ចៅក្រមខ្មែរឲ្យតែមានសមត្ថភាពអាចចូលរួមនៅក្នុងដំណើរការជំនុំជម្រះបាន មិនថាអាណិកជនខ្មែរឬខ្មែរដែលទទួលការអប់រំនៅក្នុងស្រុកនោះទេ" ។

ចំណែកឯខាងអង្គការលើកលែងទោសអន្តរជាតិចង់ឲ្យមាន

ការធានាឲ្យបានប្រាកដថាសាលាក្តីអន្តរជាតិនេះអាចជឿទុកចិត្តបាននិងផ្តល់យុត្តិធម៌យ៉ាងពិតប្រាកដដល់ជនរងគ្រោះកម្ពុជា ។

ដើម្បីនាំមកនូវយុត្តិធម៌ដែលគួរឲ្យជឿទុកចិត្តបាននិងអាចទទួលយកបានសម្រាប់ជនរងគ្រោះទូទៅនិងអ្នកដែលមានប្រយោជន៍នៅក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិនេះ ជំហាននិងវិធានការជាក់លាក់មួយចំនួនត្រូវតែអនុវត្តដោយយកចិត្តទុកដាក់ដើម្បីធានានូវឯករាជ្យភាពរបស់ចៅក្រមខ្មែរ ដែលប្រការនេះមិនមែនសម្រាប់តែសាលាក្តីអន្តរជាតិមួយនេះទេ ប៉ុន្តែគឺសម្រាប់ជាការគ្រប់គ្រងដំណើរការយុត្តិធម៌នៅក្នុងតុលាការសព្វថ្ងៃនេះឲ្យបានសុក្រឹតដែរ ។

មិនតែប៉ុណ្ណោះ រូបមន្តនេះក៏ផ្តល់នូវភាពស្មុគ្រស្មាញសម្រាប់ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងមន្ត្រីរដ្ឋបាលជាន់ខ្ពស់របស់សាលាក្តី ។ ឧទាហរណ៍ថា ចៅក្រមបរទេសមានចេតនាស៊ើបអង្កេតករណី អៀង សារី ប៉ុន្តែចៅក្រមខ្មែរមិនចង់ស៊ើបអង្កេតករណីនេះ ។ ត្រង់នេះជាបញ្ហាដែលកើតចេញពីរូបមន្តខាងលើនេះ ។ មាត្រាទី៥៨នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៣ ចែងថា "ក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថាត្រូវបន្តការស៊ើបអង្កេតណាមួយការស៊ើបអង្កេតនោះត្រូវតែដំណើរការបន្តទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ស្នើសុំនៅក្នុងរយៈពេល៣០ថ្ងៃឲ្យដោះស្រាយការខ្វែងគំនិតនេះ" ។ យើងសន្មតទៀតថា ការខ្វែងគំនិតនេះត្រូវបញ្ជូនទៅដោះស្រាយនៅអង្គបុរេជំនុំជម្រះ ហើយខាងចៅក្រមខ្មែរលើកហេតុផលថាមិនត្រូវចោទប្រកាន់ អៀង សារី ទេ ព្រោះវាផ្ទុយទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងច្បាប់ក្នុងស្រុករបស់ខ្មែរ ពីព្រោះ អៀង សារី បានទទួលការលើកលែងទោសពីព្រះមហាក្សត្ររួចហើយនៅឆ្នាំ១៩៩៦ ។ អៀង សារី មិនអាចត្រូវកាត់ទោសពីរដងក្នុងបទល្មើសតែមួយបានទេ ។ ចុះបើចៅក្រមបរទេសពីររូបមានភស្តុតាងគ្រាប់គ្រាន់ដើម្បីចោទប្រកាន់ អៀង សារី ក្នុងដំណាក់កាលនេះ តើធ្វើយ៉ាងដូចម្តេចទើបបានមតិភាគច្រើន? ដូចនេះរឿងក្តីនេះត្រូវគាំងរហូតទៅឬ?

ចំពោះសមាសភាពចៅក្រមតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មាត្រាទី១២លក្ខន្តិកៈនៃតុលាការពិសេស (២០០២) សាលាដំបូងមានចៅក្រម៣រូប ដែល១រូបតែងតាំងដោយរដ្ឋាភិបាល និង២រូបទៀតតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅសាលាឧទ្ធរណ៍ មានចៅក្រម៥រូប (ដែល២រូបតែងតាំងដោយរដ្ឋាភិបាល) ។

***តើការកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហម ត្រូវការរយៈពេលប៉ុន្មានឆ្នាំយ៉ាងយូរបំផុត? បើអូសបន្លាយពេលទៀតតើមានបញ្ហាអ្វី?***

កាលពីឆ្នាំមុន ពោលគឺឆ្នាំ២០០៣ គេរំពឹងថាសាលាក្តីនេះនឹងលេចចេញជារូបរាងនៅពាក់កណ្តាលឆ្នាំ២០០៤ ហើយនឹងប្រើរយៈពេល៣ឆ្នាំ ។ ក៏ប៉ុន្តែមានបញ្ហាចម្បងពីរដែលមិនអាចធ្វើឲ្យដំណើរការកាត់ទោសប្រព្រឹត្តទៅបានឆាប់ ។ បញ្ហាទីមួយគឺផ្តើមចេញពីការរៃអង្គាសថវិកា ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិមិនទាន់ប្រកាសជាផ្លូវការរកថវិកាស្ម័គ្រចិត្តពីសមាជិកអង្គការសហប្រជាជាតិនិងប្រទេសដែលមានការចាប់អារម្មណ៍មកលើតុលាការនេះនៅឡើយទេ ។ នៅពេលមានថវិកាគ្រប់គ្រាន់ហើយ បុគ្គលិកតុលាការនេះនឹងត្រូវទទួលការបណ្តុះបណ្តាលយ៉ាងហោចណាស់១៨ខែមុននឹងចាប់ផ្តើមដំណើរការអង្គជំនុំជម្រះដោយពេញលេញ ។

ចំពោះការបង្កើតរដ្ឋសភានិងរដ្ឋាភិបាលថ្មីមិនសូវជាបញ្ហាប៉ុន្មានទេ ។ យូរឬឆាប់រដ្ឋសភានឹងចេញជារូបរាង គ្រាន់តែមិនដឹងប្រាកដថាចេញតាមរូបភាពបែបណាតែប៉ុណ្ណោះ ។

ដល់ពេលគាំងបែបនេះ សួរថាមានផលអវិជ្ជមានយ៉ាងណាដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករនិងបងប្អូនជនរួមជាតិខ្មែរយើង? មានបញ្ហាជាច្រើនដែលអាចកើតចេញពីការពន្យារពេលនៃការបង្កើតសាលាក្តីនេះ ។

**បញ្ហាទីមួយគឺ** យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជានិងមនុស្សជាតិទាំងមូលត្រូវមនុស្សជាតិខ្លួនឯងបដិសេធ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានឹងទទួលការរិះគន់យ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិអំពីភាពយឺតយ៉ាវរបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។

**បញ្ហាទីពីរ** មេដឹកនាំខ្មែរក្រហមកាន់តែមានវ័យចំណាស់

ទៅហើយ ភាគច្រើនមានអាយុច្រើនជាង៧០ឆ្នាំ ។ ជនសង្ស័យទាំងនោះនឹងស្លាប់មុនតុលាការកើត ។ ខាតបង់ពេលវេលានិងថវិកា ។

***បញ្ហាទីបី*** ជនរងគ្រោះដែលមិនបានទទួលយុត្តិធម៌នឹងទទួលការឈឺចាប់ជំនួសឲ្យសេចក្តីសង្ឃឹមរបស់គាត់ដែលមានជាង ២០ឆ្នាំមកហើយ ។ គាត់សង្ឃឹមថាគាត់នឹងទទួលបាននូវយុត្តិធម៌ និងសំណងតាមផ្លូវច្បាប់ តែជាលទ្ធផលគាត់ត្រូវខកចិត្ត ហើយត្រាំរស់នៅទាំងអយុត្តិធម៌បន្តទៅទៀត ។ ការមិនផ្តល់យុត្តិធម៌ដល់ជនរងគ្រោះរាប់លាននាក់មិនមែនជាការធម្មតានោះទេសម្រាប់ប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា ។ បញ្ហាចិត្តសាស្ត្រគឺជាចំណុចចម្បងដែលអ្នកជំនាញកំពុងយកចិត្តទុកដាក់ ។ កាលណាជនរងគ្រោះខកចិត្ត ឬបាក់ទឹកចិត្តរហូតមិនអាចស្តារឡើងវិញបាន វានាំឲ្យប៉ះពាល់ដល់ "ផលិតភាព" ដែលជាកត្តាសំខាន់ក្នុងការកសាងជីវភាពគ្រួសាររបស់គាត់ ក៏ដូចជាសេដ្ឋកិច្ចប្រទេសជាតិទាំងមូល ។

***បញ្ហាទីបួន*** ប្រព័ន្ធតុលាការកម្ពុជានឹងមិនអាចធ្វើឲ្យប្រសើរជាងសព្វថ្ងៃនេះទេ ។ បើវិវត្តន៍ទៅមុខក៏ក្នុងល្បឿនមួយយ៉ាងយឺតបំផុត ។

***តើនឹងមានបញ្ហាអ្វីកើតឡើងប្រសិនបើតុលាការអន្តរជាតិបង្កើតបាន មានចៅក្រមធ្វើការ ហើយរាល់ការចោទប្រកាន់លើអតីតមេដឹកនាំខ្មែរក្រហមមិនត្រូវបានរដ្ឋាភិបាលជួយជ្រោមជ្រែង?***

ពិភពលោកអាចទាញសន្និដ្ឋានថា សម័យបច្ចុប្បន្ននេះគឺជាសម័យសកលូបនីយកម្ម ហើយពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងអំពើឧក្រិដ្ឋកម្រិតអន្តរជាតិ ។ ការបង្ការនិងផ្តន្ទាទោសបទឧក្រិដ្ឋអន្តរជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមជាដើម គឺជាកាតព្វកិច្ចរបស់ប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ហើយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិមាត្រាទី២ បានបញ្ជាក់ច្បាស់អំពីគោលការណ៍ "អនុវត្តសន្ធិសញ្ញាដោយសុទ្ធចិត្ត-*pacta sunt servanda* ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩" ។ មាត្រាទី២៦ នៃអនុសញ្ញានេះបញ្ញត្តិថា "រាល់សន្ធិសញ្ញាជាធរមានត្រូវតែមានអានុភាពអនុវត្តចំពោះភាគីដែលជាប់កាតព្វកិច្ច ហើយភាគីទាំងនេះត្រូវតែអនុវត្តសន្ធិសញ្ញានេះដោយសុទ្ធចិត្ត" ។

ចំពោះប្រទេសកម្ពុជា ប្រសិនបើមានករណីនេះកើតឡើង យើងអាចប្រមើលឃើញវិធានការចាស់ដៃពីរ គឺវិធានការផ្នែកនយោបាយនិងវិធានការផ្នែកការទូត ។

***ចំពោះវិធានការនយោបាយ*** ជាទស្សនៈខ្ញុំផ្ទាល់ ខ្ញុំអាចទស្សន៍ទាយបានថាវាមានសភាពធ្ងន់ធ្ងរខ្លាំងណាស់ ។ ប្រទេសមហាអំណាច ប្រទេសផ្តល់ជំនួយមួយចំនួន នឹងផ្លាស់ប្តូរនយោបាយការបរទេសរបស់ខ្លួនជាមិនខាន ។ ប្រទេសទាំងនេះបាននិងកំពុងតែយកចិត្តទុកដាក់ខ្ពស់មកលើការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា និងចង់ឲ្យប្រទេសកម្ពុជាឈានទៅមុខកសាងសេដ្ឋកិច្ចជាតិដោយឈរលើ "នីតិរដ្ឋ" ឬ "ធម្មាធិបតេយ្យ" ។

ម្យ៉ាងវិញទៀត ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នហិរញ្ញវត្ថុនានា នឹងដាក់សម្ពាធនយោបាយនិងហិរញ្ញ-វត្ថុ មកលើរាជរដ្ឋាភិបាលកម្ពុជា ។ សេដ្ឋកិច្ចកម្ពុជានឹងកាន់តែយ៉ាប់យ៉ឺន ។ ក៏ប៉ុន្តែ ប្រសិនបើកម្ពុជាអាចរស់ដោយខ្លួនឯងដោយមិនពឹងជំនួយបរទេសនោះ កម្ពុជាអាចមិនជួយជ្រោមជ្រែងដល់ការនាំខ្លួនជនសង្ស័យឬជនជាប់ចោទជាអន្តរជាតិបាន ។

***ចំពោះវិធានការការទូត*** ខ្ញុំជឿថា សហគមន៍អន្តរជាតិនឹងថ្កោលទោសចំពោះរដ្ឋឬរដ្ឋាភិបាលណាចេញមុខគាំទ្រឬជួយជ្រោមជ្រែងឧក្រិដ្ឋជន ។ ម្យ៉ាងវិញទៀត អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងចាត់វិធានការប្រឆាំងនឹងការបដិសេធយុត្តិធម៌សម្រាប់មនុស្សជាតិបែបនេះតាមរយៈមហាសន្និបាតអង្គការសហប្រជាជាតិដែលមានប្រទេសជាសមាជិកចំនួន១៩១ ។ ប្រទេសជាសមាជិកអង្គការសហប្រជាជាតិនឹងជួយដាក់សម្ពាធថែមពីលើនេះមួយកម្រិតទៀត ។ នៅពេលនោះ ទំនាក់ទំនងការទូតរបស់កម្ពុជានៅលើឆាកអន្តរជាតិនឹងធ្លាក់ចុះជាមិនខាន ។

***តើច្បាប់កាត់ទោសអតីតមេខ្មែរក្រហមគួរបង្កើតឡើងរបៀបណាដើម្បីឲ្យមានការទទួលយកបានទាំងជាតិនិងអន្តរជាតិ?***

ដើម្បីឆ្លើយនឹងសំណួរនេះ ខ្ញុំបាទសូមបញ្ជាក់បន្តិចអំពីពាក្យថា "គំរូយុត្តិធម៌ដែលទទួលស្គាល់ជាអន្តរជាតិ (*Internationally Accepted Standards of Justice*)" និង "គំរូយុត្តិធម៌អន្តរជាតិ



លលាដ៍សពភេទប្រុស អាយុពី៣០ ទៅ៥៥ឆ្នាំ
ស្នាមរបួសៈ គ្រាប់បាញ់ចូលពីផ្នែកខាងលើនៃលលាដ៍ក្បាលសំដៅចុះទៅក្រោមកាត់តាមខួរក្បាលពីឆ្វេងទៅស្តាំរួចធ្លាយចេញតាមសៀតផ្កាខាងស្តាំ ។



លលាដ៍សពភេទប្រុស អាយុពី២០ ទៅ៤០ឆ្នាំ
ស្នាមរបួសៈ គ្រាប់បាញ់ចូលពីផ្នែកខាងលើជ្រុងខាងស្តាំនៃលលាដ៍ក្បាលសំដៅចុះទៅក្រោម ឆ្លងកាត់ខួរក្បាលរួចធ្លាយចេញតាមផ្នែកខាងឆ្វេងនៃគល់កញ្ចឹងក ។



លលាដ៍សពភេទប្រុស អាយុពី៣០ ទៅ៥០ឆ្នាំ
ស្នាមរបួសៈ ស្នាមប្រេះជាច្រើនកន្លែងបណ្តាលពីការវាយដោយឧបករណ៍ទាល ។



លលាដ៍សពភេទប្រុស អាយុពី២០ ទៅ៤០ឆ្នាំ
ស្នាមរបួសៈ ស្នាមកាប់ដោយឧបករណ៍មុតពីរកន្លែងទៅលើផ្នែកខាងក្រោយ ជ្រុងខាងស្តាំនៃលលាដ៍ក្បាល (មិនធ្លាយ) ។



លលាដ៍សពភេទប្រុស អាយុពី២៥ ទៅ៤៥ឆ្នាំ
ស្នាមរបួសៈ គ្រាប់បាញ់ចូលពីផ្នែកខាងមុខជ្រុងខាងឆ្វេងនៃលលាដ៍ក្បាលសំដៅចុះទៅក្រោមតាមមុំ៤៥ដឺក្រេ កាត់តាមខួរក្បាលពីស្តាំទៅឆ្វេង មានសភាពជារន្ធសោ (គ្រាប់បៀម) ។



ក្រុមការងាររដ្ឋបាលអង្គការសហប្រជាជាតិរៀបចំបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (ខាស្តេន ហេវែល)

(International Standards of Justice) ។ យោងតាមការយល់ឃើញរបស់លោក ចន ឆរនីអារី សាស្ត្រាចារ្យច្បាប់នៃសកលវិទ្យាល័យអក់ស៊ឹត គំនិតទាំងពីរនេះមានលក្ខណៈដូចគ្នា ។ វាខុសគ្នាទៅតាមការចូលចិត្តប្រើពាក្យនេះតែប៉ុណ្ណោះ ។ ផ្អែកតាមគំនិតនេះ មានទិដ្ឋភាពពីរសំខាន់ គឺទិដ្ឋភាពនីតិវិធី និង ទិដ្ឋភាពសារធាតុ ។ ជាទូទៅ គេប្រើសម្រាប់និយាយដល់បញ្ហានីតិវិធីច្រើនជាង ។

ក្នុងករណីតុលាការខ្មែរក្រហមដែលនឹងចេញរូបរាងនាឆ្នាំក្រោយនេះពាក្យ "គំរូឬស្តង់ដារអន្តរជាតិ" តែងតែលើកយកមកពិភាក្សាយ៉ាងក្តៅគគុកដើម្បីធានាឲ្យបាននូវការជម្រះក្តីប្រកបដោយយុត្តិធម៌ត្រឹមត្រូវដែលជាការការពារសិទ្ធិចុងចោទនិងសាក្សី ។

ដើម្បីសម្រេចថានីតិអន្តរជាតិអ្វីដែលត្រូវបង្កើតឡើងជាបុព្វលក្ខខណ្ឌសម្រាប់ការជម្រះក្តីប្រកបដោយយុត្តិធម៌ត្រឹមត្រូវ យើងត្រូវតែពិនិត្យមើល "ប្រភព" នៃនីតិអន្តរជាតិដែលមានប្រាំសំខាន់ៗ គឺទំនៀមទម្លាប់និងការអនុវត្តជាក់ស្តែងរបស់រដ្ឋអនុសញ្ញាដែលមិនអាចទុកជាមោឃៈបាន សេចក្តីសម្រេច និង "ច្បាប់ទន់" គោលការណ៍ដែលបង្កើតឡើងដោយអ្នកច្បាប់ឧត្តម ។

ជាទូទៅ បើគេនិយាយដល់បទដ្ឋានយុត្តិធម៌អន្តរជាតិតាមនីតិវិធី យើងនិយាយដល់គោលការណ៍ដែលបង្កើតឡើងតាមរយៈកត្តាចម្រុះទាំង៥÷

១) តើប្រព័ន្ធអនុវត្តច្បាប់ជាក់ស្តែងយ៉ាងដូចម្តេច?

២) តើបទបញ្ញត្តិណាខ្លះនៃអនុសញ្ញាដែលភ្ជាប់កាតព្វកិច្ច?

៣) តើបញ្ញាជននិយាយយ៉ាងដូចម្តេចខ្លះ?

៤) តើតុលាការអន្តរជាតិសំខាន់ៗនិងក្នុងស្រុកដោះស្រាយបញ្ហានីតិវិធីយុត្តិធម៌តាមរបៀបដូចម្តេចខ្លះ?

៥) តើអ្វីជាលក្ខណៈពិសេសនៃនីតិវិធីដែលសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិនិងសេចក្តីប្រកាសទាមទារឲ្យមាន?

ជាការពិតណាស់ថា ដំណើរការសម្រេចថាអ្វីជា "លក្ខណៈអន្តរជាតិ" ឬ "ទទួលស្គាល់ជាអន្តរជាតិ" តម្រូវឲ្យមានការពិភាក្សាវែកញែកជាច្រើន ព្រមទាំងមានផលប្រយោជន៍នយោបាយផង ។ ជាទូទៅ ការក្រឡេកមើលប្រព័ន្ធច្បាប់សំខាន់ៗរបស់លោកខាងលិចនិងតុលាការអន្តរជាតិកន្លងមក នឹងផ្តល់នូវគំនិតថ្មីប្រពៃនៃពាក្យថា"គំរូអន្តរជាតិ" ។ លក្ខណៈពិសេសនៃប្រព័ន្ធច្បាប់លោកខាងលិចបានក្លាយទៅជាលក្ខណៈដែលអាចទទួលបានតាមរយៈសន្ធិសញ្ញា សេចក្តីសម្រេចរបស់តុលាការ និងកិច្ចការជាលក្ខណៈសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលជាផ្នែកមួយនៃច្បាប់អន្តរជាតិ ។ តាមន័យនយោបាយ ប្រទេសដែលមានការអភិវឌ្ឍន៍ខ្ពស់ចង់គ្របសង្កត់ទៅលើអង្គនានាដែលសម្រេចថាអ្វីទៅជា"ការប្រកបដោយយុត្តិធម៌ហើយប្រើខ្នាតគំរូរបស់ខ្លួនមកធ្វើជារង្វាស់" ។

នៅក្នុងបរិបទប្រទេសកម្ពុជា អ្វីដែលពាក្យទាំងពីរនេះហាក់ដូចជាមានន័យនោះគឺថា តុលាការមួយត្រូវមានការធានាការពារឲ្យបានគ្រប់គ្រាន់ ដើម្បីធានាថាការជំនុំជម្រះក្តីនឹងមានលក្ខណៈយុត្តិធម៌ និងការពារដល់សិទ្ធិរបស់បុគ្គល ដូចដែលតុលាការអន្តរជាតិឬតុលាការបរទេសបានអនុវត្ត ដែលមានន័យច្បាស់លាស់ថាជាវេទិកាលោកខាងលិច ឬ"អាទិលោក" មិនមែនគំរូយុត្តិធម៌តាមបែបតតិយលោកនោះទេ ។

ខាងក្រោមនេះជាចំណុចមួយចំនួនដែលត្រូវបញ្ចូលដើម្បីឲ្យច្បាប់នេះកាន់តែប្រសើរឡើង÷

- ◆ បញ្ចូលគោលការណ៍នៃការទទួលខុសត្រូវពីបទព្រហ្មទណ្ឌ និងច្បាប់ស្តីពីការការពារខ្លួន ។ មាត្រាទី២៩មិនអនុញ្ញាតឲ្យមានការការពារខ្លួនដោយសារការទទួលបញ្ជាពីថ្នាក់លើ ។
- ◆ ចែងអំពីការគាំពារជនរងគ្រោះនិងសាក្សីឲ្យបានគ្រប់គ្រាន់ (មានកម្មវិធីជាក់លាក់) ។
- ◆ បញ្ចូលបទបញ្ញត្តិអំពីសំណងជំងឺចិត្ត ។
- ◆ បញ្ចូលនូវទំនាក់ទំនងរវាងនីតិវិធីតុលាការអន្តរជាតិនេះភ្ជាប់ទៅនឹងការកសាងនូវប្រព័ន្ធយុត្តិធម៌កម្ពុជាបច្ចុប្បន្ន ។
- ◆ បញ្ជាក់ឲ្យច្បាស់អំពីការលើកលែងទោសចំពោះ អៀង សារី ។ តើអាចកាត់ទោស អៀង សារី ឬក៏មិនអាច?
- ◆ បញ្ញត្តិអំពីការបើកទូលាយឲ្យមេធាវីបរទេសមានសិទ្ធិតំណាងកូនក្តីរបស់ខ្លួនក្នុងពេលជម្រះក្តី ។

(មាត្រា៥នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបញ្ញត្តិថា "មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅឬ

ដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរ ហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែពុំអាចតំណាងកូនក្តីបានឡើយ») ។

***តើមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់នឹងត្រូវប្រឈមមុខនឹងការកាត់ទោស? ចំណែកមន្ត្រីខ្លះដែលជាអតីតកម្មាភិបាលខ្មែរក្រហមកំពុងធ្វើជាមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលបច្ចុប្បន្ន តើអាចជាប់ទាក់ទិននឹងអតីតកាលឬទេ?***

រឿងនេះជាតួនាទីរបស់ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត ប៉ុន្តែអ្វីដែលយើងអាចមើលឃើញច្បាស់ទាំងអស់គ្នានោះគឺការប្រកាសក្តែងៗរបស់ ខៀវ សំផន ដែលថាគាត់ជាមេដឹកនាំម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ ។ តាមមាត្រាទី១នៃច្បាប់ខ្មែរក្រហម ការអះអាងរបស់ ខៀវ សំផន នឹងបន្ថុលក្ខណៈងាយស្រួលដល់ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត ។ ពីព្រោះថា មុននឹងឈានដល់ការកំណត់ថាជនណាមួយជាថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវការពេលវេលាស៊ើបអង្កេតច្រើន។ ប៉ុន្តែពេលនេះបុគ្គល ខៀវ សំផន បានបញ្ជាក់ច្បាស់ហើយ ។ មិនតែប៉ុណ្ណោះ មាត្រាទី២ វាក្យខ័ណ្ឌទី២នៃច្បាប់ដដែលនេះបញ្ញត្តិថា «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថាជនសង្ស័យ» ។

ថ្មីៗនេះ អ្នកស្រាវជ្រាវជាន់ខ្ពស់ ស៊្វីវ ហេង៉ រ បានចេញផ្សាយសៀវភៅរបស់លោកដែលមានចំណងជើងថា «បេក្ខជន៧រូបប្រឈមមុខនឹងការកាត់ទោស» ។

ទម្រាំតែបញ្ចប់សៀវភៅនេះ លោកខិតខំស្រាវជ្រាវអស់ជាច្រើនឆ្នាំ ប្រមែប្រមូលឯកសារគ្រប់បណ្ណសារ គ្រប់ប្រភពទាំងអស់ ដើម្បីឲ្យប្រាកដថាពត៌មានដែលលោកលើកមកសរសេរមិនមែនជាពត៌មានក្លែងក្លាយ ។

ប្រជាជនកម្ពុជាបានបាត់បង់ជីវិតអស់ជិត២លាននាក់ដោយសារនយោបាយឃោរឃៅយង់ឃ្នងរបស់ខ្មែរក្រហមក្នុងរយៈពេលគិតចាប់តាំងពីខែមេសាឆ្នាំ១៩៧៥ដល់ខែមករាឆ្នាំ១៩៧៩ ។ មកទល់សព្វថ្ងៃពុំមានមេដឹកនាំណាម្នាក់ក្នុងចំណោមថ្នាក់ដឹកនាំនៃរបបនេះដែលជាប់សង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខតុលាការនៅឡើយទេ ។ ២៤ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម អ្នកជំនាញការពីររូបបានសរសេររបាយការណ៍មួយដោយការវាយតម្លៃជាលើកដំបូងបង្អស់ទៅលើពិរុទ្ធភាពរបស់បុគ្គលមួយចំនួនដោយយោងទៅតាមភស្តុតាងដែលមានស្រាប់ ។ របាយការណ៍នេះមានចំណងជើងថា «បុគ្គល៧រូបដែលត្រូវកាត់ទោស ការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម» ត្រូវបានរៀបចំឡើងប្រយោជន៍ដើម្បីជួយផ្តល់ឲ្យប្រជាជនកម្ពុជានូវអ្វីដែលជាឱកាសចុងក្រោយក្នុងការកាត់ទោសថ្នាក់ដឹកនាំរបស់ ប៉ុល ពត ដែលនៅរស់រានមានជីវិតហើយមានវ័យកាន់តែចាស់ទៅហើយ ។

ដោយផ្អែកលើភស្តុតាងឯកសារដែលទើបតែស្រាវជ្រាវរកឃើញថ្មីៗ របាយការណ៍នេះចងក្រងជាសំណុំរឿង «តាមទិដ្ឋភាពដំបូង»សម្រាប់ជំនុំជម្រះទោសអតីតមេដឹកនាំខ្មែរក្រហមដែលមានតួនាទីក្នុងវាលពិឃាត ។ មានកិច្ចខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវពីមុនៗមកបានចងក្រងជាឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់និងពិនិត្យពិច័យយ៉ាងល្អិតល្អន់ទៅលើអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ដោយឡែក របាយការណ៍នេះគឺជាឯកសារទីមួយដែលផ្តោតសំខាន់ទៅលើការទទួលខុសត្រូវពីបទព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនិងទៅលើសមត្ថកិច្ចនៃការដឹកនាំរបស់កម្មា-ភិបាលខ្មែរក្រហមមួយចំនួន ។ របាយការណ៍នេះនឹងចេញផ្សាយដោយការិយាល័យឧក្រិដ្ឋកម្មសង្គ្រាមនៅមហាវិទ្យាល័យច្បាប់វ៉ាស៊ីនតោននៃសាកលវិទ្យាល័យសហរដ្ឋអាមេរិកនិងគណៈកម្មការចម្រុះដើម្បីយុត្តិធម៌អន្តរជាតិ ។ នេះគឺជាស្នាដៃនិពន្ធរួមរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់អំពីកម្ពុជា លោក ស៊្វីវ ហេង៉ រ និងអ្នកជំនាញការច្បាប់សិទ្ធិមនុស្សអន្តរជាតិ, លោក ប្រាយ៉ាន់ ឌីទីម័រ ។ អ្នកនិពន្ធទាំងពីររូបនេះបានធ្វើការវិភាគទៅលើភស្តុតាងដែលកន្លងមកពុំមានអ្នកណាម្នាក់មានឱកាសពិនិត្យមើល ហើយដែលរៀបចំនិងផ្តល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការកម្ពុជាមួយនាំមុខក្នុងបេសកកម្មចងក្រងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនិងចងក្រង

បទឧក្រិដ្ឋកម្មនៃរបបនេះសម្រាប់ការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។

ភស្តុតាងដែលត្រូវបានពិនិត្យរួចហើយនេះមានបញ្ជាក់អំពីនយោបាយមហាឃាតកម្មបង្កើតឡើងដោយថ្នាក់លើដែលមានអំណាចបំផុត និងអនុវត្តតាមរយៈខ្សែសង្វាក់នៃការបញ្ជា ។ របាយ-ការណ៍នេះសង្កត់ធ្ងន់លើការសម្លាប់ជាទ្រង់ទ្រាយធំទៅលើក្រុមដែលជាមុខសញ្ញាចំនួនបី ។ ទីមួយគឺអ្នកដែលជាប់និន្នាការជាមួយអតីតរបបសាធារណរដ្ឋដែលខ្មែរក្រហមផ្ដួលរំលំនៅក្នុងឆ្នាំ ១៩៧៥ ។ ទីពីរគឺបក្ខជន ឬ «កម្មាភិបាល» នៅក្នុងជួរខ្មែរក្រហមដែលត្រូវបានសង្ស័យថាជាជនក្បត់ ។ ទីបីគឺ សមាជិករបស់ក្រុមមិនមែនកុម្មុយនិស្តរបស់ប្រជាជនទូទៅ ។

របាយការណ៍នេះរៀបរាប់អំពីសកម្មភាពរបស់បុគ្គលទាំង ៧រូប ហើយធ្វើការវាយតម្លៃទៅលើអ្វីដែលបុគ្គលម្នាក់ៗ បានដឹងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់ខ្លួន ពោលគឺជាការដឹងឮដែលជនសង្ស័យទាំងនេះមួយចំនួនបានបដិសេធជាយូរណាស់មកហើយ ។

របាយការណ៍នេះចងក្រងជាឯកសារយ៉ាងលម្អិតអំពីតួនាទីដែលបុគ្គលខាងលើបានជំរុញនិងអនុវត្តនូវនយោបាយមនុស្សឃាត មានជាអាទិ៍ដូចជាតាមរយៈការចូលប្រជុំរៀបចំគម្រោងសម្លាប់មនុស្ស ។ ព័ត៌មាននេះរួមជាមួយភស្តុតាងដែលបង្ហាញថាបុគ្គលខាងលើជាអ្នកបានទទួលរបាយការណ៍និងឯកសារផ្សេងៗស្ដីអំពីដំណើរការវិវត្តន៍ទៅមុខនៃអំពើឃោរឃៅ ហើយមិនបានការពារថា ប៉ុល ពត ដែលបានស្លាប់ហើយនោះមិនទទួលខុសត្រូវក្នុងការរៀបចំនិងអនុវត្តនយោបាយឃោរឃៅរបស់ខ្មែរក្រហមឡើយ ។

អ្នកនិពន្ធបានធ្វើការវិភាគតាមផ្នែកនីមួយៗយ៉ាងល្អិតល្អន់ទៅលើភស្តុតាងនានាដែលរួមមានឯកសារទូរសារ កំណត់ហេតុប្រជុំបក្ស របាយការណ៍អំពីកន្លែងសម្លាប់និងគុក ដែលត្រូវបានធ្វើឲ្យជនសង្ស័យដូចដែលបានរៀបរាប់ខាងលើនេះ ថែមទាំងសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមនិងចម្លើយសារភាពរបស់«កម្មាភិបាល»ខ្មែរក្រហមដែលត្រូវបានធ្វើទារុណកម្មនិងសម្លាប់ចោលបន្ទាប់ពីដកចេញពីមុខតំណែង ។ ភស្តុតាងទាំងនេះរួមជាមួយបទសម្ភាសន៍របស់មេដឹកខ្មែរក្រហម ដែលរួមមានកិច្ចសន្ទនារបស់លោក ស៊ីវ ហេង៉រ ជាមួយ អៀង សារី ផងបានបង្ហាញអំពីខ្សែសង្វាក់ដែលមិនមានអ្នកណាស្រាវជ្រាវរកឃើញពីមុនមករវាងអំពើឃោរឃៅនានាដែលប្រព្រឹត្តនៅថ្នាក់ក្រោមជាមួយកម្មាភិបាលដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ ។

ពេលនេះ អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការសម្លាប់ប្រជាជនកម្ពុជាជិតមួយភាគបីនៅក្នុងការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ប្រាកដជាមិនអាចបន្តនិយាយថាខ្លួនមិនដឹងឡើយ ។ ការចេញផ្សាយនូវរបាយការណ៍នេះស្របគ្នាទៅនឹងកិច្ចប្រឹងប្រែងនានាដែលកំពុងបន្តធ្វើដោយអង្គការសហប្រជាជាតិប្រទេសដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជានិងគ្រប់ទិសទី ក្នុងការបង្កើតនូវតុលាការឧក្រិដ្ឋកម្មមួយដើម្បីយកអ្នកដែលទទួលខុសត្រូវមកកាត់ទោសចំពោះមុខច្បាប់ ។ របាយការណ៍នេះអាចជាគ្រឹះសម្រាប់កសាងសំណុំរឿងព្រហ្មទណ្ឌដូចដែលកំពុងតែធ្វើសព្វថ្ងៃនេះ ដើម្បីដាក់បន្ទុកចោទប្រកាន់លើបុគ្គលទាំង៧រូបខាងលើ ព្រមទាំងកម្មាភិបាលខ្មែរក្រហមផ្សេងៗទៀតដែលនៅរស់ ។

របាយការណ៍នេះគឺជាឯកសារប្រវត្តិសាស្ត្រមួយដែលមិនត្រឹមតែកត់ត្រានូវអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់អំពីការដឹងឮរបស់មេដឹកនាំ និងអំពីការទទួលខុសត្រូវលើបទព្រហ្មទណ្ឌជាលក្ខណៈបុគ្គលទៀតផង ដែលសក្ខីកម្មទាំងអស់ត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈវិធីសាស្ត្រដែលខ្មែរក្រហមបានចងក្រងឯកសារទាក់ទងនឹងអំពើដ៏គួរឲ្យព្រឺព្រួច ។

ចំពោះការពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាល យើងខ្ញុំសូមបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលស្រាវជ្រាវនិងចងក្រងឯកសារសម្រាប់គោលបំណងសំខាន់ពីរគឺ «យុត្តិធម៌និងការចងចាំ» ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាវិទ្យាស្ថានច្បាប់ មិនមែនជាមេធាវី ហើយក៏មិនមែនជាតុលាការដែរ ។ ដូចនេះ ឯកសារដែលយើងប្រមូលបានត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ងាយស្រួលក្នុងការស្វែងរកឯកសារពីសំណាក់

មេធាវី ចៅក្រម ព្រះរាជអាជ្ញា ចុងចោទ និងអ្នកដែលមានប្រយោជន៍ក្នុងរឿងក្ដីព្រហ្មទណ្ឌ ព្រមទាំងអ្នកដែលចង់មកសិក្សាស្រាវជ្រាវ ដោយមិនមានការរើសអើង ។ ដើម្បីរក្សាឯកសារកុំឲ្យបាត់បង់ និងតម្រូវទៅនឹង «ភាពចាំបាច់នៃការរក្សាភស្តុតាង» មជ្ឈមណ្ឌលឯកសារកម្ពុជាបានជូនអនុស្សារណៈដល់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាក្នុងការប្រើប្រាស់ឯកសាររបស់យើង ។ មានន័យថា នៅពេលមានតុលាការ អ្នកដែលអាចចូលមកពិនិត្យឯកសាររបស់យើងចាំបាច់ត្រូវមានការបញ្ជាក់ពីតុលាការជាមុនសិន ។ សរុបមក យើងមិនមានសមត្ថភាពអះអាងតាមផ្លូវច្បាប់ថា «ជននេះជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬជននោះជាប់ចោទពីបទទារុណកម្ម...ទេនោះ» ។ ទុកឲ្យចៅក្រមឬព្រះរាជអាជ្ញាជាអ្នកកំណត់និងសម្រេចតាមបច្ចេកទេសច្បាប់ ។

**កាលពីពេលថ្មីៗនេះ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ បានឆ្លើយថា ខ្លួនពុំបានដឹងអំពីការកាប់សម្លាប់រង្គាលទេ ។ តើការឆ្លើយនេះជាការពិតឬក៏ជាការឆ្លើយយករួចខ្លួន?**

មុខតំណែងការបរទេសរបស់ អៀង សារី ជាមុខតំណែងមួយធំណាស់ ។ រដ្ឋាភិបាលមួយមានមុខមាត់ឬទំនាក់ទំនងការបរទេសល្អគឺជាកិត្តិយសរបស់រដ្ឋផង ជាពិសេសកិត្តិយសរបស់រដ្ឋមន្ត្រីការបរទេសនៃរដ្ឋាភិបាលនោះតែម្ដង ។ ក៏ប៉ុន្តែ រដ្ឋមន្ត្រីការបរទេសមិនគួរទទួលយកតែគុណសម្បត្តិ ហើយទាត់ចោលផលអាក្រក់ដែលខ្លួនបានសាងនោះទេ ។ ពោលគឺ ក្នុងនាមជារដ្ឋមន្ត្រីការបរទេស អៀង សារី ត្រូវទទួលខុសត្រូវចំពោះផលអវិជ្ជមាននានាដែលបណ្ដាលមកពីការបំពេញភារកិច្ចរបស់ខ្លួន ។ យ៉ាងណាមិញ នៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ អៀង សារី ធ្វើឲ្យមនុស្សស្លាប់ដោយប្រយោលមិនតិចទេ ។ បញ្ញវន្តជាច្រើនរយនាក់ត្រូវបាត់បង់ជីវិតដោយសារការល្បួងឲ្យចូលស្រុកវិញពីសំណាក់រដ្ឋមន្ត្រីការបរទេសរូបនេះ ។ ឧទាហរណ៍នៅមណ្ឌលអប់រំកែប្រែបឹងត្របែក ។ មុនដំបូង មាននិស្សិតនិងអ្នករដ្ឋការមកពីបរទេសជាច្រើននាក់ដែលមកតាមការអំពាវនាវរបស់ អៀង សារី គឺមិនតិចជាង១០០០នាក់ឡើយ ។ ក្រោយរបបនេះដួលរលំ នៅសល់តែ២៥០នាក់ប៉ុណ្ណោះ ។ ជាផលវិបាកប្រទេសកម្ពុជាបាត់បង់នូវធនធានមនុស្សដ៏មានតម្លៃជាច្រើន នេះមិនទាន់និយាយដល់ការសម្លាប់ក្រៅផ្លូវតុលាការរបស់របបកម្ពុជាប្រជាធិបតេយ្យទាំងមូលផង ។

ឯកសារមួយចំនួនក្នុងចំណោមឯកសាររាប់សែនសន្លឹកតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញអំពីព័ត៌មានទាក់ទងនឹងការចូលរួមឬយ៉ាងហោចណាស់ការដឹងឮរបស់សមមិត្តវ៉ាន់ (អៀង សារី) ព្រមទាំងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រព្រឹត្តឡើងចំពោះអតីតរដ្ឋការលន់ណុល និងសមាជិកបក្សកុម្មុយនិស្តខ្លួនឯងផ្ទាល់ ដែលសូម្បីតែក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិក៏បញ្ជាក់ដែរថា ឧក្រិដ្ឋកម្មទាំងនេះគឺប្រព្រឹត្តឡើងនៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិតេយ្យផ្ទាល់ ។

ខ្ញុំសូមលើកឧទាហរណ៍កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាធ្វើឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ។ របាយការណ៍នេះបានបញ្ជាក់អំពីសេចក្ដីសម្រេច «ដាក់ផែនការ» និង «ការអនុវត្តន៍ជាក់ស្ដែង» ដែល ប៉ុល ពត «ទទួលបន្ទុកយោធានិងសេដ្ឋកិច្ច» នួន ជា «ទទួលបន្ទុកកិច្ចការបក្ស សុខមាលភាពសង្គម វប្បធម៌ ឃោសនាការ និងការអប់រំ» ។ ចំណែកឯ អៀង សារី «ទទួលបន្ទុកទាំងកិច្ចការបក្សទាំងកិច្ចការបរទេស» ។ សុន សេន (ខៀវ-៨៧) «ទទួលបន្ទុកកងកម្លាំងប្រដាប់អាវុធ អគ្គសេនាធិការ និងសន្តិសុខ» ។ វន វ៉ែត «ឧស្សាហកម្ម ផ្លូវអយស្ម័យាន និងនេសាទ» ។

ដូចនេះចម្លើយរបស់ខ្ញុំគឺថា ការឆ្លើយរបស់ អៀង សារី គឺធ្វើឲ្យតែរួចខ្លួនមួយគ្រាតែប៉ុណ្ណោះ ។ ធ្វើជាថ្នាក់ដឹកនាំហើយដឹងឮអំពីឧក្រិដ្ឋហើយ មិនព្រមចាត់វិធានការនោះជាកំហុសធ្ងន់ធ្ងរណាស់ ។

**តើមានភស្តុតាងអ្វីខ្លះក្នុងការចោទប្រកាន់ខ្មែរក្រហមថាបានកាប់សម្លាប់រង្គាល?**

ឯកសារ៦សែនសន្លឹក រូបថតនិងហ្វីលមិនទាន់ផ្ដិត២៩៩៣៤សន្លឹក ខ្សែភាពយន្តឯកសាររាប់រយ លិខិតឆ្លើយឆ្លងនិងទូរលេខ៧៥៤ទំព័រ ព្រមទាំងចំណាររបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ

ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន រួមផ្សំទាំងបទសម្ភាសន៍ជាមួយអតីតកម្មាភិបាល២ពាន់នាក់ដែលជាអ្នកអនុវត្តគោលនយោបាយរបស់បក្សផងនោះ បាននាំឲ្យអ្នកជំនាញការវាយតម្លៃថា «ពត៌មានទាំងនេះអាចជាភ័ស្តុតាងដ៏មានទម្ងន់សម្រាប់ចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យអំពីបទឧក្រិដ្ឋដែលមានលក្ខណៈអន្តរជាតិនិងបទល្មើសព្រហ្មទណ្ឌតាមច្បាប់ជាតិយើង ។

### ការចុះស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៣

១) ទីកប់សាកសព ៣៩១កន្លែង ក្នុងនោះមានរណ្តៅសាកសពរួម ១៩៥២១កន្លែង

២) គុក ១៩៨កន្លែង

៣) បូជនីយដ្ឋាន ៨០កន្លែង

### របៀបនៃការស្លាប់របស់ជនរងគ្រោះ

យោងតាមការធ្វើកោសល្យវិច័យរបស់អ្នកសិក្សាបែបវិទ្យាសាស្ត្រខាងកោសល្យវិច័យមកពីទ្វីបអាមេរិកខាងជើងគឺ បណ្ឌិត ម៉ៃឃើល ប៉ូឡានិន, បណ្ឌិត កាថារីន គ្រូសហ្វើ, និងបណ្ឌិត ក្រេច អេចនេសាន់ និងការចុះសាកសួរសាក្សី និងអ្នកផ្តល់ពត៌មាននៅកន្លែងកើតហេតុនៅតាមមូលដ្ឋានភូមិឃុំស្ទើរតែទូទាំងប្រទេស បានបង្ហាញថា ជនរងគ្រោះមួយចំនួនស្លាប់ដោយសារ÷

- ការវាយសំពងលើក្បាលដោយព្រនង់
- ការបាញ់ចំក្បាល
- ការអារ-ក
- ការវាយចំកញ្ចឹងក (នឹងដែកក្ងោរទេះ)
- ការកប់ទាំងរស់
- ការកាប់សសៃជើង
- ការបោកនឹងគល់ឈើ (កុមារ)
- ការបំផ្ទុះគ្រាប់បែកសម្លាប់ជារួម និងវិធីផ្សេងៗទៀត

### ការផ្សះផ្សាជាតិ ស៊ូហ្សាណា (ដាង៧០០នាក់)

ខ្ញុំយល់ថា ការផ្សះផ្សាជាតិមិនអាចសម្រេចផលល្អទេ ល្គឹកណាអ្នកផ្តើមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មមិនត្រូវបានគេនាំយកទៅជម្រះទោសនៅចំពោះមុខតុលាការដែលមានលក្ខណៈអន្តរជាតិ ហើយមេដឹកនាំទាំងនោះមិនគួរត្រូវបានលើកលែងទោសឬអនុញ្ញាតឲ្យសារភាពចំពោះមុខគណៈកម្មការស្វែងរកការពិតឡើយ ។ មេដឹកនាំទាំងនោះគួរតែឆ្លើយសារភាពកំហុសចំពោះតុលាការដែលមានសមត្ថកិច្ចចាប់បង្ខំនិងផ្តន្ទាទោស ។ គណៈកម្មាធិការស្វែងរកការពិតរៀបចំឡើងសម្រាប់កម្មាភិបាលថ្នាក់កណ្តាលនិងថ្នាក់ក្រោមតែប៉ុណ្ណោះ ពីព្រោះថា ការកាត់ទោសកម្មាភិបាលថ្នាក់ក្រោមអាចនាំឲ្យមានភាពច្របូកច្របល់និងការសងសឹកគ្នានៅក្នុងសហគមន៍នានានិងសង្គមជាតិទាំងមូល ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវមួយដែលនឹងចេញផ្សាយឆាប់ៗខាងមុខនេះ ។ យោងតាមការស្រាវជ្រាវនេះបង្ហាញថា ៨៩ភាគរយនៃអ្នកដែលយើងបានធ្វើសម្ភាសន៍ឆ្លើយថា ខ្លួនបានបាត់បង់សមាជិកគ្រួសារហើយ៥៧ភាគរយឆ្លើយថា ការបាត់បង់ជីវិតសមាជិកនៃក្រុមគ្រួសារពិតជាមានផលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់គាត់ ។ នៅពេលសួរថា តើគាត់នៅតែគិតអំពីបទពិសោធន៍ជូរចត់របស់គាត់ដែរឬទេ ៥៨ភាគរយឆ្លើយថា គាត់នៅតែគិតមកដល់សព្វថ្ងៃ ។ នៅពេលសួរថាតើគាត់អាចអត់ឱនឲ្យកម្មាភិបាលខ្មែរក្រហមដែរឬទេ? មាន២៦ភាគរយឆ្លើយថាអាចអត់ឱនឲ្យបាន ប៉ុន្តែមាន៦៧ភាគរយឆ្លើយថាគាត់មិនអាចអត់ឱនឲ្យបានទេ ។

### មកទល់នឹងថ្ងៃនេះ តើការរៀបចំបង្កើតតុលាការខ្មែរក្រហមវិវត្តន៍ដល់ណាហើយ?

មុននឹងចូលដល់ការវិវត្តន៍ចុងក្រោយ ខ្ញុំសូមជម្រាបជូនត្រួសៗអំពីការចាប់ផ្តើមពីដំបូងមកបន្តិច ។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចលេខ១៩៩៧/៤៩ ដែលស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិតាមរយៈតំណាងពិសេសរបស់លោក ពិនិត្យសំណើសុំជំនួយទាក់ទងនឹងការរំលោភដ៏ធ្ងន់ធ្ងរមកលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា (សម្តេចក្រុមព្រះ នរោត្តម បុណ្ណរិទ្ធិ និងសម្តេច ហ៊ុន សែន) បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ ក្នុងការនាំយកជនទាំងឡាយ

ដែលទទួលខុសត្រូវពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកកាត់ទោស ។ ក្រោយមកទៀត នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំដដែល មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្ដីសម្រេចលេខ៥២,១៣៥ ដែលស្នើឲ្យអគ្គលេខាធិការឆ្លើយតបតាមសំណើរបស់កម្ពុជា ។ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតក្រុមអ្នកជំនាញការមួយក្រុមឲ្យមកសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ចាប់ពីពេលនោះមកមានការចរចាទល់មុខគ្នាដើម្បីរកដំណោះស្រាយមួយសមស្រប ។ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្ដេច ព្រះ នរោត្តម សីហនុ បានឡាយព្រះហស្ដលេខាលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្រោយពីច្បាប់នេះចេញហើយ មានការផ្ដល់យោបល់ពីអង្គការសហប្រជាជាតិក្នុងន័យស្ថាបនាដើម្បីឲ្យច្បាប់នេះកាន់តែប្រសើរឡើង ។ សហគមន៍អន្តរជាតិចង់ឲ្យអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការនេះ ។ អង្គការសហប្រជាជាតិក៏ធ្វើការបន្ថែមទៀតជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីរៀបចំជាផែនការមួយច្បាស់លាស់ដើម្បីសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ក្រោយពីធ្វើការងារនេះមួយរយៈពេលមក អង្គការសហប្រជាជាតិក៏សម្រេចចិត្តដកខ្លួនថយពីការចរចានៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ។

នៅក្នុងលិខិតចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០១ តាមការបង្គាប់ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក ហេន កូរែល បានជម្រាបដំណឹងដល់រាជរដ្ឋាភិបាលកម្ពុជាថា អង្គការសហប្រជាជាតិឈប់ចរចាជាមួយរដ្ឋាភិបាលកម្ពុជាទៀតហើយ ទាក់ទងនឹងការរៀបចំបង្កើតសាលាក្ដីពិសេសសម្រាប់កាត់ទោសមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចំពោះបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ គឺពេលនោះហើយដែលយើងឃើញច្បាស់ទាំងអស់គ្នាថា ទាំងសង្គមប្រជាជាតិ ទាំងមហាអំណាចទាំង៥ លើកលែងតែចិន ទាំងអង្គការអន្តរជាតិនានា និងរដ្ឋាភិបាលកម្ពុជា ព្រមទាំងប្រទេសដែលមានចំណាប់អារម្មណ៍នៅក្នុងការរៀបចំតុលាការនេះដូចជាសហរដ្ឋអាមេរិក បារាំង ជប៉ុន សហភាពអឺរ៉ុប សុទ្ធតែបានសម្ដែងការសោកស្ដាយយ៉ាងខ្លាំង ហើយបានព្យាយាមដាក់សម្ពាធឲ្យអង្គការសហប្រជាជាតិវិលត្រឡប់មកចរចាជាមួយកម្ពុជាវិញ ។ ជាលទ្ធផលនៃភាពអន្ទះសារចង់បាននូវយុត្តិធម៌ជូនមនុស្សជាតិ មហាសន្និបាតបានអនុម័តសេចក្ដីសម្រេចស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជា-ជាតិបន្តការចរចាជាថ្មីដើម្បីបញ្ចប់កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដោយមានសំឡេងគាំទ្រ១៥០ ទល់នឹងសូន្យ និងសំឡេងឆ្នោតអនុប្បវាទ៣០ ។ ទង្វើនេះពិតជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់ការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ជាការគួរឲ្យកត់សម្គាល់ នៅអំឡុងពេលទស្សនៈកិច្ចរបស់លោកនាយករដ្ឋមន្ត្រីឥណ្ឌា អាតាល បីហារី វ៉ាយ៉ាផាយី នៅប្រទេសកម្ពុជា លោកបានថ្លែងថា “ទីក្រុងញូវដេលីសន្យាគាំទ្រតុលាការចម្រុះ ប្រសិនបើអង្គការសហប្រជាជាតិដកខ្លួនថយជារៀងរហូត” ។

ក្រោយពីមានសេចក្ដីសម្រេចរបស់មហាសន្និបាតអ.ស.ប ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជានិងអ្នកជំនាញការរបស់អង្គការសហប្រជាជាតិក៏ចាប់ដៃគ្នាធ្វើការតទៅទៀត ។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤ ក្រុមជំនាញការច្បាប់របស់អង្គការសហប្រជាជាតិបានអញ្ជើញមកដល់ប្រទេសកម្ពុជាដើម្បីពិនិត្យនិងធ្វើការឲ្យបានលម្អិតបំផុតអំពីផែនការរៀបចំអង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមុននឹងខ្លួនដាក់សំណើពេញលេញមួយជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ។ នៅថ្ងៃទី១៨ខែឆ្នាំដដែល ក្រុមជំនាញការនេះបានបញ្ចប់បេសកម្មរបស់ខ្លួនដោយមានការប៉ាន់ស្មានចំណាយមួយដែលមានទឹកប្រាក់ “ជាង ៥០លាន”ដុល្លារ ។ លោក ខាស្ដេន ហេរែល ដែលអមដំណើរដោយមន្ត្រីហិរញ្ញវត្ថុនិងទីប្រឹក្សាផ្នែកភស្តុភារ មិនបានបញ្ជាក់អំពីតួលេខបុក្ខខ្ទង់ចំណាយឡើយ ។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ នេះដែរ សភាតំណាងរបស់សហរដ្ឋអាមេរិកបានចេញសេចក្ដីសម្រេចឲ្យសហសភាអាមេរិក ១) ជំរុញឲ្យប្រធានាធិបតីប៊ូសជំរុញសភាជាតិកម្ពុជាផ្ដល់សច្ចាប័នឲ្យបានឆាប់ទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហ

ប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និង២) ជំរុញឲ្យប្រធានាធិបតីប៊ូស ផ្តល់នូវការគាំទ្ររួមជាមួយថវិកាដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការផ្តល់សច្ចាប័នពីរដ្ឋសភាជាតិកម្ពុជារួចហើយដើម្បីឲ្យស្របទៅនឹងច្បាប់ស្តីពី «យុត្តិធម៌អំពើប្រល័យពូជសាសន៍នៅកម្ពុជា» ដែលអនុម័តដោយសហសភាអាមេរិក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៤ ។

កាលពីពេលថ្មីៗនេះប្រទេសចិនបានសន្យានឹងផ្តល់ថវិកា ១០០លានដុល្លារជាថ្នូរនឹងការពង្រឹងវិស័យច្បាប់នៅកម្ពុជា ប្រសិនបើគ្មានតុលាការខ្មែរក្រហម ។ ខ្ញុំសូមប្រៀបធៀបទង្វើនេះទៅនឹងការទិញសញ្ញាបត្រដោយមិនបានចូលរៀនក្នុងថ្នាក់ ។ យ៉ាងណាមិញ ទោះជាទឹកលុយរបស់ចិនអាចធ្វើឲ្យប្រព័ន្ធយុត្តិធម៌កម្ពុជាប្រសើរឡើងក៏ដោយ ក៏ទង្វើនេះមិនអាចផ្សះរបួសផ្លូវចិត្តរបស់ជនរងគ្រោះភាគច្រើនបានឡើយ ។ ប្រាក់ដែលសន្យានេះមិនទាំងអាចព្យាបាលជំងឺចិត្តវិកលនិងសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះរបស់ខ្មែរក្រហមផង កុំថាឡើយទៅដល់ការស្តារនឹងកែលម្អប្រព័ន្ធយុត្តិធម៌ ។ ក៏ប៉ុន្តែប្រសិនបើចិនផ្តល់លុយនេះដល់សាលាក្តីខ្មែរក្រហមវិញ ពិតជាជួយដល់កម្ពុជាបានច្រើនទាំងវិស័យសុខាភិបាល សង្គមកិច្ច និងវិស័យតុលាការ ។

ចុងបញ្ចប់នេះ ខ្ញុំសូមផ្ញើសារមួយយ៉ាងខ្លីទៅអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា ជនរងគ្រោះ ជនសង្ស័យ សង្គមស៊ីវិល និងអ្នកទាំងឡាយដែលមានប្រយោជន៍នៅក្នុងការទាមទារយុត្តិធម៌ សូមរៀបចំខ្លួនចូលរួមឲ្យបានសកម្មនៅក្នុងដំណើរការកាត់សេចក្តីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនាពេលខាងមុខឆាប់ៗនេះ ។ ការចូលរួមនេះពិតជាមានសារសំខាន់ណាស់បញ្ជាក់អំពីការយកចិត្តទុកដាក់របស់មនុស្សជាតិមកលើការឈឺចាប់និងការទាមទារយុត្តិធម៌របស់មនុស្សជាតិដូចគ្នា និងដើម្បីផលិតបាននូវយុត្តិធម៌តាមផ្លូវច្បាប់និងតម្លៃសីលធម៌ដែលអាចទទួលយកបានទាំងអស់គ្នា ។ ធ្វើដូចនេះ កម្ពុជានឹងមានលទ្ធភាពរើបម្រះខ្លួនពីចំណាប់ខ្មាំងនៃអតីតកាលដែលតែងតែអន្ទោលតាមប្រាណ ហើយកម្ពុជានឹងឈានជើងទៅមុខទៅរកភាពរីកចម្រើនសម្បូររុងរឿង ។

**សួ ប៊ុនស៊ូ**



# ការិយាល័យពត៌មានសាធារណៈ

នៅខណៈពេលដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកិច្ចព្រមព្រៀងរួមគ្នាមួយឈានទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីវិនិច្ឆ័យទោសអតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភដ៏ធ្ងន់ធ្ងរនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រៀមខ្លួនរួចជាស្រេចដើម្បីផ្តល់កិច្ចគាំទ្រដល់ដំណើរការជំនុំជម្រះនេះ ។

យើងបានសហការជាមួយទីប្រឹក្សាផ្នែកច្បាប់របស់យើងដើម្បីបង្កើតប្រព័ន្ធក្រឹតក្រមនិងរបៀបរបបនៃការប្រើប្រាស់ឯកសារនៅពេលដែលតុលាការចាប់ផ្តើមដំណើរការ ។ យើងក៏បានផ្តល់នូវទម្រង់បែបបទនៃក្រឹតក្រមនេះ ដល់ក្រុមការងារពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាហើយដែរ ។ បើនិយាយជាសង្ខេបគឺ មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រៀមខ្លួនផ្តល់ជូនតុលាការនិងមន្ត្រីពាក់ព័ន្ធនូវរាល់ច្បាប់ចម្លងនៃឯកសារដែលយើងមាន ។ ទន្ទឹមនឹងនេះ យើងក៏បានធ្វើសេចក្តីណែនាំដ៏ច្បាស់លាស់មួយស្តីអំពីការផ្តល់សិទ្ធិដល់បុគ្គលដែលគួរមានសិទ្ធិប្រើប្រាស់ឯកសារដើមរបស់យើង ។ ការរៀបចំឲ្យមានសេចក្តីណែនាំនេះគឺធ្វើឡើងក្នុងគោលបំណងផ្តល់ការប្រើប្រាស់ឯកសារ ហើយព្រមពេលជាមួយនោះ ថែរក្សាឯកសារទាំងនោះកុំឲ្យបាត់បង់ឬខូចខាតខុសអំពីសភាពដើម ។

ជំហានបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងសកម្មភាពគាំទ្រតុលាការខ្មែរក្រហម គឺបង្កើតគម្រោងការមួយដែលបង្កើនលទ្ធភាពរបស់សាធារណជនក្នុងការប្រើប្រាស់បណ្ណសារទាំងឡាយដែលយើងមាន ដើម្បីត្រៀមសម្រាប់តុលាការ ទន្ទឹមនឹងនោះថែរក្សាឯកសារទាំងនោះកុំឲ្យបាត់បង់ឬខូចខាតខុសអំពីសភាពដើម ។ យើងនឹងបង្កើតការិយាល័យពត៌មានសាធារណៈមួយដែលបង្កើនការផ្សព្វផ្សាយនូវពត៌មានទាំងឡាយទាក់ទងនឹងរបបខ្មែរក្រហម ។ គោលបំណងរបស់យើងគឺអប់រំសាធារណជនអំពីរឿងរ៉ាវទាំងឡាយរបស់ខ្មែរក្រហម ជាពិសេសគឺបង្កើនការយល់ដឹងជ្រួតជ្រាបរបស់សាធារណជនអំពីការវិវត្តន៍នៃដំណើរការតុលាការខ្មែរក្រហមដែលនឹងកើតមានក្នុងពេលខាងមុខ ។ ផ្អែកតាមការរៀនសូត្រអំពីបទពិសោធន៍តុលាការអន្តរជាតិនៅប្រទេសរ៉្វាន់ដានិងប៊ូស្នៀ យើងបានដឹងថា ការផ្សព្វផ្សាយដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់អំពីដំណើរការទៅនៃតុលាការជាកត្តាមួយដែលចាំបាច់ជាទីបំផុត ។ ការដឹងឮនិងចូលរួមនៅក្នុងដំណើរការនេះ នឹងធ្វើឲ្យដំណើរការនៃអង្គជំនុំជម្រះមិនត្រឹមតែជាកាតាលីករដែលនឹងផ្តល់យុត្តិធម៌ជូនជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញឲ្យមានការផ្សះផ្សារបួសផ្លូវចិត្ត និងបង្រួបបង្រួមជាតិនៅក្នុងប្រទេសកម្ពុជាដែរ ។

ក្នុងអំឡុងពេលវិវត្តន៍ទៅមុខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងនឹងពង្រីកការទាក់ទងជាមួយសាធារណជន ព្រមទាំងបង្កើនការផ្សព្វផ្សាយការងាររបស់យើងឲ្យបានទូលំទូលាយ ។ តម្រូវការនៃការអប់រំដូចបានរៀបរាប់ខាងលើនេះកាន់តែសំខាន់ឡើងនៅពេលដែលតុលាការខ្មែរក្រហមខិតជិតមកដល់ ។ ទន្ទឹមនឹងមានគោលបំណងចម្បងក្នុងការផ្សព្វផ្សាយចំណេះដឹងដល់សាធារណជន ការិយាល័យពត៌មានសាធារណៈរបស់យើងក៏ជាកន្លែងផ្តល់ការអប់រំស្តីអំពីរឿងរ៉ាវជុំវិញបញ្ហាខ្មែរក្រហមដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងថា ការចូលរួមរបស់សាធារណជនក្នុងកម្មវិធីដែលយើងរៀបរៀងមានដូចជា វេទិកាបទខទ្ទេសនាម ការចូលរួមបញ្ចេញយោបល់ ការអាន និងការរៀនសូត្រប្តូរយោបល់គ្នានឹងនាំមកនូវគំនិតថ្មីៗនិងល្អៗ ដែលជំរុញទៅមុខឆ្ពោះទៅរកការសម្រេចបំណងរួមរបស់យើង គឺការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិ ។

**ការិយាល័យពត៌មានសាធារណៈជាទីតាំងនៃក្រុមជំនួយការតុលាការ**

ជាបឋម ការិយាល័យពត៌មានសាធារណៈនឹងប្រើប្រាស់ជាទីតាំងសម្រាប់ក្រុមជំនួយការតុលាការ ។ សមាសភាពនៃក្រុមជំនួយការតុលាការរួមមាន ទីប្រឹក្សាច្បាប់មួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បុគ្គលិកជំនាញផ្នែកទីតាំងឯកសារ និងក្រុមការងារនៃគម្រោង ជំរុញឲ្យមានការទទួលខុសត្រូវ ។ ក្រុមការងារនេះមានភារកិច្ចជាជំនួយការតុលាការនិងមន្ត្រីដែលទទួលការអនុញ្ញាតឲ្យការស្រាវជ្រាវឯកសារតាមតម្រូវការចាំបាច់ ។ ក្រុមបកប្រែរបស់យើងនឹងជួយដល់ការងារបកប្រែឯកសារពីភាសាខ្មែរទៅជាភាសាអង់គ្លេសដើម្បីត្រៀមជាស្រេចមុនពេលតុលាការចាប់ផ្តើម ។

ដើម្បីសុវត្ថិភាពនិងភាពស្ងៀមស្ងាត់ យើងប្រុងប្រៀបរៀបចំការិយាល័យរបស់ក្រុមការងារបម្រើអង្គជំនុំជម្រះនៅជាន់ទីបីនៃការិយាល័យបន្ទប់ពត៌មានសាធារណៈ ។ ការអានឯកសារនៅក្នុងផ្នែកនេះត្រូវធ្វើដោយគោរពតាមបទដ្ឋាននិងសេចក្តីណែនាំដែលរៀបរៀងដោយក្រុមប្រឹក្សាផ្នែកច្បាប់របស់យើង ដើម្បីរក្សាសភាពដើមរបស់ឯកសារនិងទប់ស្កាត់ការបន្ថែមបន្ថយឬបំផ្លាញក្នុងអំឡុងនិងក្រោយពេលអានឯកសារ ។ យើងជឿថា យុត្តិធម៌មិនអាចកើតមានឡើងទេបើឯកសារដើមមិនអាចថែរក្សាបាន ។

ក្រុមការងារនៃ "គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ" នឹងជួយដល់មន្ត្រីដែលទទួលការអនុញ្ញាត ក្នុងការស្វែងយល់អំពីរបាយការណ៍និងឯកសារសំណេរនៃបទសម្ភាសន៍ដែលជាលទ្ធផលការងាររបស់"ក្រុមគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ" ។ ក្នុងករណីមានតម្រូវការបកស្រាយពាក្យពេចន៍ឃ្លាប្រយោគ ក្រុមបកប្រែភាសារបស់យើងនឹងជួយការងារនេះ ។ យើងសង្កេតឃើញថា ភាសាដែលខ្មែរក្រហមប្រើប្រាស់មានលក្ខណៈខុសប្លែកពីភាសាខ្មែរដែលប្រជាជនធម្មតាប្រើប្រាស់ ។ ដូច្នេះដើម្បីរក្សាអត្ថន័យដើមរបស់ឯកសារ ទាមទារអ្នកបកប្រែដែលមានបទពិសោធន៍បកប្រែឯកសារប្រភេទនេះ ។

## ការិយាល័យពត៌មានសាធារណៈជាបណ្ណាល័យ

ព្រមជាមួយនោះ ការិយាល័យពត៌មានសាធារណៈក៏ដើរតួជាបណ្ណាល័យផ្ទុកប្រភេទឯកសារខ្មែរក្រហមដែរ ។ ក្នុងបណ្ណាល័យនេះ យើងមានរៀបចំទុកជូននូវឯកសារចម្លងទាំងឡាយដែលយើងមាននៅមជ្ឈមណ្ឌលឯកសាររបស់យើង ព្រមជាមួយឯកសារទាំងឡាយដែលទាក់ទង ។ ជាពិសេសទៅទៀត យើងក៏មានរៀបចំជូននូវឯកសាទាំងឡាយណាដែលទាក់ទងជុំវិញដំណើរការតុលាការដែលបម្រុងនឹងកើតមានក្នុងពេលខាងមុខ ។ គ្រប់សាធារណជនដែលមានចំណាប់អារម្មណ៍អានឬស្រាវជ្រាវក្តី អាចអញ្ជើញមកប្រើប្រាស់ឯកសារដែលយើងខ្ញុំមានតម្កល់ជូននៅទីនេះ ។ នៅក្នុងបណ្ណាល័យ យើងខ្ញុំក៏មានទុកជូនអាននូវច្បាប់ចម្លងនៃឯកសារទាំងឡាយដែលសព្វថ្ងៃមានតម្កល់ទុកជូននៅសារមន្ទីរទួលស្លែង ។ ការប្រមូលផ្តុំតម្កល់ទុកឯកសារដែលយើងមានរួមជាមួយឯកសារចម្លងរបស់ទួលស្លែង គឺដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ឯកសារក្នុងកិច្ចការស្រាវជ្រាវ ។ សូមបញ្ជាក់បន្ថែមថា យើងប្រើប្រាស់ក្នុងបណ្ណាល័យនេះតែឯកសារចម្លងប៉ុណ្ណោះ គឺក្នុងគោលបំណងថែរក្សាឯកសារដើម ដើម្បីទុកជាភ័ស្តុតាងប្រវត្តិសាស្ត្រក៏ដូចជាភ័ស្តុតាងប្រើក្នុងពេលមានតុលាការ ។ ក្រៅពីប្រភេទឯកសារដូចមានរៀបរាប់ជូនខាងលើនេះ យើងខ្ញុំក៏មានតម្កល់ទុកជូនអាននូវអត្ថបទដែលសសេរដោយបញ្ញាជនក្នុងនិងក្រៅប្រទេស ទស្សនាវដ្តីស្វែងរកការពិត សៀវភៅសសេរ និងសៀវភៅបកប្រែដោយអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងស្នាដៃនិពន្ធទាំងឡាយដែលពាក់ព័ន្ធនិងប្រវត្តិសាស្ត្រទំនើប ច្បាប់ និងនយោបាយ ។ បណ្ណាល័យក៏បានបំពាក់នូវប្រព័ន្ធស្វែងរកទំនើបដែលជួយដល់អ្នកអាននិងអ្នកស្រាវជ្រាវឲ្យមានការងាយស្រួលក្នុងការស្វែងរកទីតាំងឯកសារ សៀវភៅ និងទស្សនាវដ្តី ដែលតម្កល់ទុកក្នុងបណ្ណាល័យនេះ ។ អ្នកដែលមកប្រើប្រាស់សេវាក្នុងបណ្ណាល័យនេះក៏អាចស្រាវជ្រាវនូវប្រព័ន្ធទិន្នន័យដ៏សន្ធឹកសន្ធាប់ដែលយើងបានសហការបង្កើតឡើងជាមួយកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃសកលវិទ្យាល័យយែល និងអ្នកជំនាញការនៃសកលវិទ្យាល័យញូសៅវែល ។ ប្រព័ន្ធទិន្នន័យពត៌មានទាំងនោះរួមមានទិន្នន័យប្រវត្តិរូបអតីតកម្មាភិបាលខ្មែរក្រហម (CBIO) ទិន្នន័យគន្ថនិទ្ទេសអំពីទូរលេខទំនាក់ទំនងផ្ទៃក្នុងរបស់ខ្មែរក្រហម (CBIB) ទិន្នន័យភូមិសាស្ត្រ (CGEO)

ដែលបង្ហាញអំពីទីតាំងរណ្តៅសាកសព មន្ទីរសន្តិសុខ បូជនីយដ្ឋាន និងទិន្នន័យរបស់ក្រុមការងារជំរុញឲ្យមានការទទួលខុសត្រូវ ដែលជាអត្ថបទសម្ភាសន៍របស់អ្នកសិក្សាស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអតីតកម្មាភិបាលខ្មែរក្រហម ។ លើសពីនេះទៀត អ្នកសិក្សាស្រាវជ្រាវក៏អាចស្វែងរកពត៌មាន និងអានឯកសារដោយប្រើប្រាស់ម៉ាស៊ីនមីក្រូហ្វីលរបស់យើងដែរ ។ នៅទីនោះយើងក៏មានរៀបចំបន្ទប់សម្រាប់ស្តាប់ចម្រៀងខ្មែរក្រហម បន្ទប់ទស្សនាខ្សែភាពយន្តឯកសារស្តីអំពីរបបខ្មែរក្រហមដែលជាស្នាដៃផលិតរួមគ្នារវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងផលិតករក្នុងនិងក្រៅប្រទេស ។ ចំណុចចុងក្រោយនៃបន្ទប់ពត៌មានសាធារណៈ គឺការបំពាក់នូវម៉ាស៊ីនកុំព្យូទ័រនិងប្រព័ន្ធអ៊ីនធើនែតដែលសាធា-រណជនអាចសិក្សាស្រាវជ្រាវតាមរយៈគេហទំព័ររបស់យើង ។ ប្រភពពត៌មានដែលទាក់ទងដល់ប្រព័ន្ធច្បាប់ទាំងអស់នឹងត្រូវដាក់បង្ហាញនៅលើគេហទំព័ររបស់យើង ដើម្បីបង្កភាពងាយស្រួលដល់អ្នកសិក្សាស្រាវជ្រាវក្នុងការស្រាវជ្រាវអំពីប្រព័ន្ធច្បាប់ តុលាការនិងប្រវត្តិសាស្ត្រ ។ យើងជឿថា សាធារណជនចូលរួមស្វែងយល់និងពិភាក្សាអំពីដំណើរការជំនុំជម្រះក្តីកាន់តែដុលដុស លទ្ធផលនៃការជំនុំជម្រះកាន់តែមានកម្រិតខ្ពស់ ។

## ការិយាល័យពត៌មានសាធារណៈជាមជ្ឈមណ្ឌលអប់រំ

ដើម្បីបង្កើនចំណេះដឹងដល់សាធារណជន រៀងរាល់ថ្ងៃសៅរ៍សប្តាហ៍ទីពីរនៃខែនីមួយៗ យើងនឹងរៀបចំបទខ្ទេសនាមលើប្រធានបទរបបខ្មែរក្រហមនិងដំណើរការជំនុំជម្រះក្តី ។ ជាមួយគ្នានេះ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានឹងចូលរួមយ៉ាងទៀងទាត់ក្នុងការផ្តល់បទខ្ទេសនាមលើប្រធានបទផ្សេងៗជាច្រើនទៀតដែលទាក់ទងនឹងការងារនីមួយៗរបស់យើង ។ ប្រធានបទនៃបទខ្ទេសនាមនីមួយៗនឹងតម្រូវតាមសំណូមពររបស់អ្នកចូលរួមស្តាប់ ។ ស្របពេលជាមួយគ្នានេះ យើងក៏មានផែនការអញ្ជើញអ្នកប្រវត្តិសាស្ត្រ មេធាវី អ្នកវិទ្យាសាស្ត្រនយោបាយ និងអ្នកសិក្សាជាន់ខ្ពស់ជាតិនិងអន្តរជាតិ ឲ្យមកចូលរួមធ្វើបទខ្ទេសនាមនិងចែករំលែកចំណេះដឹង ជាពិសេសបទពិសោធន៍ផ្ទាល់ខ្លួនជាមួយបុគ្គលិកមជ្ឈមណ្ឌលកម្ពុជានិងសាធារណជនទូទៅ ។ យើងជឿថា ការងារនេះមិនត្រឹមតែធ្វើឲ្យសាធារណជនមានឱកាសសិក្សាស្វែងយល់កាន់តែច្បាស់អំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញឲ្យមានកិច្ចពិភាក្សាអំពីដំណើរការជំនុំជម្រះកាន់តែដុលដុសដែរ ។

បន្ទាប់ពីបទខ្ទេសនាម យើងនឹងមានរៀបចំការប្រជុំពិភាក្សាជាក្រុមដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមបានបញ្ចេញយោបល់និងស្តាប់ការបកស្រាយពន្យល់ហេតុផលផ្សេងៗពីសមាជិកក្រុមនីមួយៗ ។ កិច្ចប្រជុំពិភាក្សានេះនឹងបន្ថែមចំណេះដឹងអំពីរបបខ្មែរក្រហមដល់អ្នកចូលរួម ជាមួយគ្នានេះក៏នឹងជួយឲ្យមានគំនិតថ្មីៗបន្ថែមទៀតទាក់ទងដល់ដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនិងការផ្សះផ្សាបង្រួបបង្រួមជាតិនៅកម្ពុជា ។ នៅក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅរកការបង្កើតអង្គជំនុំជម្រះក្តី ការបង្កើតឱកាសឲ្យសាធារណជនបានចូលរួមពិភាក្សាបញ្ចេញយោបល់គឺជាការសំខាន់បំផុតលើមាគ៌ាស្វែងរកការពិតនិងដាក់ឲ្យមានការទទួលខុសត្រូវ ។

## ការិយាល័យពត៌មានសាធារណៈជាទីតាំងជួបជុំ

យើងមានបំណងរៀបចំទីកន្លែងនិងបរិយាកាសដែលផ្តល់ភាពងាយស្រួលជូនសាធារណជននិងអ្នកសិក្សាស្រាវជ្រាវដែលមកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងការិយាល័យពត៌មានសាធា-រណៈរបស់យើង ។ យើងបម្រុងទុកទីតាំងស្អាតបាតមួយកន្លែងរួមជាមួយបន្លែម ផ្លែឈើ និងទឹក សម្រាប់បម្រើសាធារណជនដើម្បីបន្ធូរបន្ថយបរិយាកាសតានតឹងដែលបណ្តាលមកពីការអានឯកសារ ។ បុគ្គលិកយើងនឹងមកចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍ជាមួយសាធារណជន ដើម្បីបន្ថយអារម្មណ៍ឈឺចាប់និងទុក្ខសោកដោយសារការនឹកឃើញរឿងរ៉ាវអតីតកាល ។ បុគ្គលិកចំនួនប្រាំរូបនឹងបម្រើការងារនៅក្នុងការិយាល័យពត៌មានសាធារណៈ ។ ក្នុងចំណោមនោះ បុគ្គលិកពីររូបជាបណ្ណារក្សទទួលខុសត្រូវផ្នែកឯកសារ មួយរូបទទួលខុសត្រូវផ្នែកកុំព្យូទ័រអ៊ីនធើនែត និងប្រព័ន្ធសំឡេង និងពីររូបទៀតទទួលខុសត្រូវការងារទូទៅ ។

**សុខា អ៊ីរ៉ែន**

# ស្រមោលបង

(ជ័យលាភីលេខ១ក្នុង "វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ" លើកទី១ ឆ្នាំ២០០៤)

### *សោកនាដកម្មថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

ចន្លោះពីឆ្នាំ១៩៧០ដល់១៩៧៥ នាងខ្ញុំបានរៀបការជាមួយបុរសម្នាក់ ហើយបានកូនប្រុសម្នាក់អាយុ៣ឆ្នាំនិងកូនស្រីម្នាក់អាយុ២ឆ្នាំ ។ នាងខ្ញុំជាគិលានុបដ្ឋាយិកាយោធានៅមន្ទីរពេទ្យព្រះមុនីវង្ស ។ កាលណោះ ប្រធានពេទ្យគឺលោកវេជ្ជបណ្ឌិត ថៅង បូយ៉ាន, លោកវេជ្ជបណ្ឌិត ទា គីមហ៊ី ផ្នែក Radio, លោកសាស្ត្រាចារ្យ ទិត្យ ម៉ម ផ្នែកសួត, ហើយចៅហ្វាយរបស់ខ្ញុំគឺលោកវេជ្ជបណ្ឌិត អ៊ឹង ប៉ូឡេង ដែលមានជំនាញផ្នែកជំងឺក្រពះនិងជំងឺទូទៅ ។ នៅមានអស់លោកជាច្រើនទៀត ប៉ុន្តែនាងខ្ញុំភ្លេចអស់ទៅហើយ ពុំដឹងជាពេលនេះអស់លោកទាំងនោះទៅដល់ណាហើយទេ ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃខ្មៅនៃកម្ពុជា ។ សមមិត្តអាវខ្មៅក្មេងៗប្រកបដោយមុខមាំគួរឲ្យខ្លាច បានបញ្ជាយ៉ាងដាច់ណាត់ឲ្យប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញចាកចេញពីលំនៅឋានជាប្រញាប់ ដោយមិនបាច់យកអីវ៉ាន់ទៅច្រើនទេ ព្រោះចេញតែ៣ថ្ងៃប៉ុណ្ណោះនឹងត្រឡប់មកផ្ទះវិញហើយ ។ នាងខ្ញុំនិងប្ដីព្រមទាំងកូនភ័ក្ត្រនិងស្រីស្រស់កូនពៅខ្ញុំក៏ចេញដំណើរដូចគេឯងដែរ ។ យើងទាំងអស់គ្នាយកចានស្រាក់មួយ ឆ្នាំងដាំបាយមួយ ឆ្នាំងសម្លមួយ ធុងទឹកកក និងសម្លៀកបំពាក់រៀងៗខ្លួនម្នាក់បន្តិចបន្តួច ។ ខ្ញុំយកសម្លៀកបំពាក់របស់ម្ដាយក្មេកខ្ញុំ៤-៥បាវដែលគាត់បានយកមកផ្ញើនៅផ្ទះខ្ញុំ ។ លោកឪពុកក្មេកខ្ញុំដែលគាត់មកសម្រាន្តលេងនៅផ្ទះខ្ញុំ៤-១០ថ្ងៃហើយ បានទៅចម្ការរបស់គាត់មុននេះបន្តិច ព្រោះគាត់យល់ថាស្រុកសាន្តត្រាណហើយលែងខ្វល់អីហើយ ។ ក្រោយមកគាត់ក៏បាត់ស្រមោលរហូត ។ យើងទាំងអស់គ្នារង់ចាំមើលផ្លូវគាត់យ៉ាងយូរទម្រាំដាច់ចិត្តចាកចេញ ។ មុនចេញដំណើរ ប្ដីខ្ញុំបានយកកាត កាំភ្លើងនិងគ្រឿងប្រាក់ខ្លះៗ ទៅកប់នៅដីក្រោយផ្ទះខ្ញុំដោយមានកូនឈរមើលគាត់ផង ។ គាត់ដឹកដៃបណ្ដើរនិយាយប្រាប់ខ្ញុំបណ្ដើរថា "អាបារាំង (គាត់តែងហៅខ្ញុំដូច្នេះ) ជួយចាំគ្នាណា ខ្ញុំវាស់១០ជំហានពីរបងខ្ញុំកប់អីវ៉ាន់" ។ ខ្ញុំឆ្លើយថា "ចាំតែខ្លួនឯងអ្នកកប់ទៅ ៣ថ្ងៃក្រោយគង់តែមកយកខ្លួនឯងវិញទេ" ។ ពុទ្ធោ! ខ្ញុំពុំនឹកស្មានសោះថាគាត់គ្មានវាសនាវិលមកយកអីវ៉ាន់ហ្នឹងវិញទេ ។

ខ្ញុំនិងក្រុមគ្រួសារបានចេញដំណើរទៅតាមផ្លូវត្រសក់ផ្អែមដោយយកឡានម៉ាក់វ៉ុលវ៉ាហ្គែនបីបាំងមួយគ្រឿងទៅជាមួយផង ។ យើងធ្វើដំណើរទៅដល់ស្ពានក្បាលថ្នល់ ហើយនៅកកស្ទះនៅទីនោះរាល់ល្ងាចដោយពុំអាចឆ្លងរួច ។ នៅទីនោះ អ្នកជម្លៀសខ្លះក៏ឈឺពោះឆ្លងទន្លេដាប់នៅលើស្ពានក៏មាន ។ ខ្ញុំឈប់នៅវត្តមូលក្បាលថ្នល់ជិតឃ្លាំងអង្ករមួយ មនុស្សម្នាចូលទៅទាញយកបាវអង្ករស្រេចតែចិត្ត ។ ខ្លះក៏ត្រូវបាវអង្ករសង្កត់លើស្លាប់ខ្លះលោភលន់លើកយកមកគរត្រួតលើគ្នា៤-៥បាវនៅលើផ្លូវទីបំផុតយកតែ១បាវមិនចង់រួច ។ ប្ដីខ្ញុំក៏ចាំយកបន្តពីគេមកដាក់ក្នុងឡាន ។ ស្អែកឡើងខ្ញុំឆ្លងផុតស្ពានមុនីវង្សដោយលំបាក ព្រោះមនុស្សច្រើនពេក ។ ពេលនោះមនុស្សមិនដឹងមកពីណាទៅណាទេ កូនខ្លះវង្វេងម៉ែឪ បងប្អូន ចាស់ៗខ្លះត្រូវចៅប្ដូកូនអៀវ ឬដាក់លើរទេះឈើអូស ឬដាក់លើស៊ីក្លូដែលមិនដឹងជារកបានពីណា ។ ពេញមួយថ្ងៃយើងធ្វើដំណើរមិនបានមួយគីឡូម៉ែត្រផង ។ យប់នេះ គ្រួសារខ្ញុំមកដល់មុខវត្តនិរោធរង្សី ប្ដីខ្ញុំប្រាប់ថា យើងត្រូវសម្រាកក្នុងឡាននៅលើចិញ្ចើមថ្នល់នេះហើយ ។ កណ្ដាលយប់ឡានហ្ស៊ីប២-៣គ្រឿងបើកពីទិសខាងកើតមកវិញ បន្ទឺស៊ីផ្លេយ៉ាងញាប់រន្ថើន ហាក់ដូចជាមានការបន្ទាន់ណាស់ ។ ពួកយោធាក្មេងៗឈរនៅលើឡានអត់ដំបូលស្រែកគំហកដោយទឹកមុខមាំឲ្យអ្នកធ្វើដំណើរចៀសពីផ្លូវឲ្យឆាប់ ។ អ្នកដំណើរ៤-៥នាក់ដែលនៅពាំងផ្លូវ ត្រូវយោធាក្មេងៗនោះលើកកាំភ្លើងបាញ់រះទាំងកំហឹង ។ យើងទាំងអស់គ្នាញ័ររន្ធត់ដូចកូនសត្វ ព្រោះពុំដែល

ឃើញទស្សនីយភាពដូច្នេះសោះពីមុនមក ។

បីថ្ងៃក្រោយមក យើងបានទៅឈប់សម្រាកនៅចម្ការល្ហុតជិតមាត់ទន្លេម្តុំកៀនស្វាយ ។ ខ្ញុំដើរមើលប្រជាជនជម្លៀសទាំងអស់ ខ្លះបោះតង់ ខ្លះក៏ចងក្រណាត់កៅស៊ូក្រោមដើមល្ហុត ខ្លះហាក់ដូចជាឈឺទើបនឹងចេញពីពេទ្យ ។ គ្រួសារខ្លះមានទឹកមុខរីករាយ ហើយអង្គុយដកង់ហូបបាយដូចជាទៅដើរកម្សាន្ត ។ ម្នាក់ៗពោរពេញដោយក្តីសង្ឃឹមយ៉ាងមុតមាំថា បីថ្ងៃទៀតបានត្រឡប់ទៅផ្ទះវិញ ។ ពេលល្ងាច ស្រីៗបោមពុងសារុងបញ្ចេញសាច់ទ្រូងសខ្ចីកាន់ដបសាប៊ូកក់សក់ដើរទៅមាត់ទន្លេងូតទឹកយ៉ាងរំភើយ ។ ក្រមុំកម្លោះខ្លះមានតែខោអាវមួយកំប្លេ ខ្លះមានតែសារុងឬក្រមា បណ្តើរគ្នាទៅងូតទឹក តែទឹកមុខគេគ្មានព្រួយបារម្ភអ្វីបន្តិចណាសោះ ។ ក្មេងៗអស់នេះប្រហែលជាទៅដើរលេងហើយពេលខ្មែរក្រហមបណ្តេញចេញពីទីក្រុងក៏ចេញតែម្តងទៅ ។ យើងសម្រាកនៅទីនោះបានប្រហែល១០ថ្ងៃ ស្រាប់តែមានយោធាក្មេងៗ៤-៥នាក់ដៃកាន់កាំភ្លើងអាកាស្តាយសម្ពារសឹក ពាក់មួកកន្តិប អាវខ្មៅ ខោខ្មៅ ស្បែកជើងកង់ឡាន ដើរប្រកាសប្រាប់ថា បងប្អូន អ៊ំ ពូ មីងណាធ្វើការអីអាចទៅចុះឈ្មោះចូលធ្វើការវិញបាន ។ កន្លះខែក្រោយមក កន្លែងដែលខ្ញុំសម្រាកក៏ស្ងាត់មនុស្សនៅសល់តែ៣-៤គ្រួសារប៉ុណ្ណោះ ។ មានអ៊ំម្នាក់សម្រាកនៅជិតខ្ញុំប្រាប់ថា គាត់ចាំគ្រួសាររបស់គាត់ដើម្បីត្រឡប់ទៅស្រុកកំណើតនៅថ្ងៃស្អែកនេះហើយ ព្រោះគេមិនទាន់ឲ្យចូលទីក្រុងភ្នំពេញវិញទេ ខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក ។

គ្រួសារខ្ញុំក៏សម្រេចចិត្តទៅឃុំតានីទូកមាសដែលជាស្រុកកំណើតរបស់ប្តីខ្ញុំ ដើម្បីជួបឪពុកក្មេកម្តាយក្មេកខ្ញុំ និងយកអីវ៉ាន់ដែលគាត់ផ្ញើទៅជូនគាត់វិញ ។ ស្អែកឡើងយើងក៏ធ្វើដំណើរបកក្រោយមកមាត់ទន្លេវិញ តែយើងមិនអាចឆ្លងស្ពានព្រះមុនីវង្សវិញបានទេ ។ យើងនាំគ្នាបើកឡានសសៀរតាមមាត់ទន្លេ ហើយឆ្លងទូកដទៅត្រើយម្ខាងដោយនិយាយដោះដូរឡានជាមួយនឹងឡាំប្រិតាបងប្រុសម្នាក់ដែលចង់ឆ្លងមកត្រើយខាងខ្ញុំវិញ ។ ខ្ញុំបានយកអង្ករខ្លះដូរបានត្រីរ៉ស់គ្រាន់ហូបមួយពេលដែរ ។

ឆ្លងទៅដល់ត្រើយម្ខាង យើងក៏ធ្វើដំណើរទៅតាមផ្លូវតូចៗដោយគ្មានដឹងទិសតំបន់អ្វីទាំងអស់ ។ យូរៗម្តង ក្រុមគ្រួសារយើងឈប់សួរប្រជាជនរកផ្លូវទៅតានីទូកមាស ។ នៅតាមផ្លូវយើងបានជួបនឹងយោធាក្មេងៗចងអង្រឹងយាមក្រោមដើមឈើបានហៅឡាំប្រិតាខ្ញុំឈប់ហើយឆែកឆេរអីវ៉ាន់ ។ ពេលរើទៅឃើញកំប៉ុងត្រីខដែលមានរាងទ្រវែង សមមិត្តអស់នោះចង់ខ្លាចព្រោះស្មានស្មានថាជាតែគ្រាប់បែក ។ តាមមើលសមមិត្តអស់នោះចង់រើរកនាឡិកាដៃតែប៉ុណ្ណោះ ។ ខ្ញុំបានលាក់ថ្នាំពេទ្យនិងសឺរ៉ាំងចាក់ថ្នាំក្នុងបាវអង្ករ ។ យើងបន្តដំណើរទៅមុខទៀតតាមការចង្អុលបង្ហាញរបស់អ្នកស្រុក ។ ផ្លូវលំក្រហេងក្រហូងដែលតាមស្មានគឺគ្មានការថែរក្សាដោយមូលហេតុសង្គ្រាម ធ្វើឲ្យឡាំប្រិតាវារគើមៗទៅមុខដោយលំបាក ។ ថ្ងៃត្រង់ហើយ យើងទាំងអស់គ្នាមកដល់ភូមិមួយឈ្មោះភូមិក្រាំងយ៉ូវ ។ ទីនោះស្ងាត់ជ្រងំដូចគ្មានមនុស្សរស់នៅ ។ នៅមុខផ្ទះនីមួយៗសុទ្ធតែគូររូបក្បាលខ្មោចនៅរបងផ្ទះ ។ ប្តីនាងខ្ញុំនិយាយថា “ស្ងាត់យ៉ាងណាក៏ត្រូវតែឈប់ដាំបាយសិនដែរ ព្រោះហេវខ្លាំងណាស់ ទៅមុខទៀតពុំរួចទេ” ។ មួយរយៈតូចដែលយើងឈប់ដាំបាយពុំទាន់ឆ្អិនស្រួលបួលផង ខ្ញុំឃើញយោធាសែងខ្មោចយកទៅកប់ប្រហែលជា៤-៥នាក់ ហើយអ្នកស្រុកម្នាក់បានខ្សឹបប្រាប់ថាកុំនៅទីនេះយូរពេក កន្លែងនេះមានមនុស្សស្លាប់ដោយជំងឺអាសន្នរោគច្រើនណាស់ ។ យើងក៏រូតរះទៅមុខទៀតដោយពុំហ៊ានទាំងហូបបាយនៅទីនោះផង ។

ដំណើររបស់យើងពីដំបូងហាក់ដូចសប្បាយណាស់ ។ ខ្ញុំស្រម័យថាជាការដើរកម្សាន្តមួយលុះយូរៗទៅ យើងមានការហេវហត់រកកម្លាំងកំហែងគ្មាន ។ កូនប្រុសច្បងខ្ញុំអាយុ៣ឆ្នាំ និងកូនស្រីទីពីរអាយុ២ឆ្នាំមុខក្រៀមជាប់ សាច់ក្តៅស្ពេញលែងចង់និយាយស្តីអ្វីទាំងអស់ ។

ព្រឹកនេះនៅតាមផ្លូវខ្ញុំបានជួបស្រីក្រមុំពីរនាក់បងប្អូន នាងបងរាងខ្ពស់បន្តិចតែខ្ញុំភ្លេចឈ្មោះទៅហើយ (សុំទោស) នាងប្អូនអាយុប្រហែល១៨ឆ្នាំ សាច់សម៉ដ្ឋខែសម្តីរួសរាយរាក់ទាក់ជាងនាងបង ។ នាងឈ្មោះ អាជា (ដែលសព្វថ្ងៃនាងជាអ្នកស្រី មា ឆដា ពិធីការិនីប្រចាំទូរទស្សន៍ជាតិកម្ពុជា) ។ បងប្អូនទាំងពីរបានសុំ

គ្រួសារនាងខ្ញុំរួមដំណើរជាមួយផង ព្រោះនាងបែកពីឪពុកម្ដាយអស់ហើយ ។ ពួកខ្ញុំក៏យល់ព្រមដោយចិត្តរីករាយ ព្រោះយើងចង់តែបានគ្នាច្រើនប៉ុណ្ណោះ ។

ល្ងាចម៉ោង៥ទៅហើយ ក្រុមគ្រួសារនាងខ្ញុំបានមកដល់មុខវត្តមួយឈ្មោះវត្តអង្គរសិង្ហដែលពុំដឹងក្នុងភូមិស្រុកអ្វី ដឹងតែថានៅក្នុងខេត្តតាកែវ ។ យោធា៤-៥នាក់ឈរពាំងផ្លូវ ដៃកាន់កាំភ្លើងវែងទឹកមុខមាំកាចគួរឲ្យខ្លាច បានស្ដីឲ្យយើងថា "នៅធ្វើដំណើរដល់ណាទៀត គេរវល់ធ្វើស្រែគ្រប់គ្នា ឯឯងគិតតែដើរសេរី ។ ឥឡូវយប់ហ្នឹងនៅសម្រាកក្នុងវត្តនេះហើយ ចាំស្អែកគេនាំទៅនៅក្នុងស្រុកភូមិនឹងគេ ឈប់ឲ្យដើរទៀតហើយ" ។ យប់នេះ កូនប្រុសខ្ញុំក្ដៅខ្លួនរើរវាយស្រែកតែផ្ដេសផ្ដាស ។ ខ្ញុំលួចយកថ្នាំក្នុងបាវអង្ករឲ្យកូនលេបទម្រាំតែបាន ។ អ្នកជិតខាងប្រាប់ ឲ្យខ្ញុំបន់ទៅ ក្រែងខុសបារមីវត្តនេះ ។

ព្រឹកនេះខ្ញុំបើកភ្នែកឡើងឃើញឡានសណ្ដោង៣-៤គ្រឿងចតរង់ចាំយើងទាំងអស់គ្នារួចជាស្រេចនៅមុខសាលាឆាន់ ។ យោធាម្នាក់ស្ពាយកាំភ្លើងវែងស្រែកប្រាប់ឲ្យយើងរៀបអីវ៉ាន់ឡើងលើឡានថ្មី ។

យោធាក្មេងម្នាក់សម្បុរខ្មៅមុខមាំនិយាយដោយសំឡេងដាច់ខាតថា "មិត្តទាំងអស់គ្នានៅជួយធ្វើស្រែនៅទីនេះមួយឆ្នាំសិនហើយ ចាំឆ្នាំក្រោយសឹមទៅស្រុកកំណើតវិញ" ។

ខ្ញុំត្រេកអរណាស់គ្រាន់តែឮដូច្នេះ ព្រោះនឹកថាបានស្គាល់ស្រុកទេសគេដែរ ។ គិតទៅយើងទាំងអស់គ្នាត្រូវគេភរដោយពុំដឹងខ្លួនតាំងពីដំបូងទីមកម្ល៉េះ ។ ឡាំប្រឺតាខ្ញុំចោលនៅទីនេះទុកដាំខ្ទឹមទៅ ។ ម្នាក់ៗស្ពាយតែបង្វេចរៀងៗខ្លួនឡើងលើឡានថ្មី ។ ខ្ញុំជិះលើឡានមែរសឺដែសកង់ដប់ថ្មីសប្បាយចិត្តណាស់ ព្រោះបានស្រូបខ្យល់អាកាសថ្មី ទោះបីរលាក់ចង់ធ្លាក់ថ្លើមប្រមាត់ក៏ដោយ ។ ពេលនោះនាងខ្ញុំហាក់ដូចជាមានក្ដីពិភាល់មួយក្នុងចិត្តអំពីអនាគតរបស់យើងទាំងអស់គ្នា ។

## ភូមិព្រៃតាំ

ក្រុមយោធាទគេបានដឹកយើងទាំងអស់គ្នាមកដល់ភូមិមួយឈ្មោះភូមិព្រៃតាំ ។ គេឲ្យផ្ទះឈើមួយខ្នងធំនៅជុំគ្នាប្រាំគ្រួសាររួមទាំងបងប្អូន អាដា ដែរ ហើយខ្ញុំក៏ទើបបានជួបប្អូនប្រុសទីពីរនៅតាមផ្លូវដែលវាបែកពីប៉ាម៉ាក់ខ្ញុំព្រោះវារវល់នៅរៀនផ្ទះពួកម៉ាក ។ រួមទាំងបងប្អូនខាងប្ដីខ្ញុំបីគ្រួសារទៀតក៏នៅជួបជុំគ្នាក្នុងផ្ទះនោះ ។

យើងទាំងអស់គ្នាស្រឡាញ់រាប់អានគ្នាណាស់ ចេះជួយគ្នាទៅវិញទៅមក ជាពិសេសប្អូនស្រី ដា ស្រឡាញ់ក្មេងណាស់ជួយមើលកូនខ្ញុំពេលខ្ញុំរវល់ ។ នេះជាអនុស្សាវរីយ៍មួយនៅដក់ជាប់ក្នុងបេះដូងរបស់នាងខ្ញុំដែលខ្ញុំមិនអាចបំភ្លេចបានទាល់តែសោះ ។

ក្នុងផ្ទះនោះមានជង្រុកស្រូវធំមួយដាក់នៅជ្រុងផ្ទះ តែគ្មានអ្នកណាយកចិត្តទុកដាក់ស្រូវនេះទេ ព្រោះយើងសុទ្ធតែនៅមានអង្ករហូបបរិបូណ៌នៅឡើយ ។ ភូមិព្រៃតាំមានប្រជាជនចាស់ឬអ្នកមូលដ្ឋានប្រហែល៣០គ្រួសារ ហើយយើងជាប្រជាជន១៧មេសាប្រហែល១០គ្រួសារ ។ ប្រជាជនចាស់ៗទាំងនេះមានសម្លៀកបំពាក់រហែកប៉ះជាច្រើនបំណះ ព្រោះគេថាធ្វើបដិវត្តន៍មុនប្រជាជន១៧មេសាយូរឆ្នាំមកហើយ ។ ពេលយើងទៅដល់ដំបូងប្រជាជនមូលដ្ឋានសម្លក់សម្លឹងមើលសម្លៀកបំពាក់របស់យើងដោយក្ដីចង់បាន ។ មានអ្នកលួចខ្សឹបសួរនាងខ្ញុំ រកសារុងថ្មីប្ដូរអាវដៃវែង ។ ដូច្នេះមានតែខោអាវម្ដាយក្មេកឪពុកក្មេកខ្ញុំទេដែលត្រូវប៉ាន់អាចដោះដូរបានជាមាន់ ជាត្រី ឬជួនកាលក៏ដូរយកបន្លែដែលគេដាំក្នុងភូមិ ដូចជា ត្រឡាច ល្ពៅជាដើម ។ ជួនកាលថ្នាំគ្រុន ថ្នាំផ្សះរបស់ខ្ញុំ ក៏មានគេត្រូវការដែរ ។

## ឈ្លើងកន្ធាស់មិត្តដ៏ស្និទ្ធស្នាលរបស់ខ្ញុំ

យើងទាំងអស់គ្នានៅទីនោះប្រមាណ៣ខែ ពេលព្រឹកយើងត្រូវចេញទៅដកសំណាបនៅឯវាលស្រែដ៏ធំល្វឹងល្វើយ ។ អ្នកណាក៏សើចនឹងនាងខ្ញុំដែរ ព្រោះទម្រាំដើរទៅដល់វាលស្រែនាងខ្ញុំរអិលដួលច្រវាប់ច្រវិលប្រឡាក់សុទ្ធតែភក់ឲ្យស្រមកទាំងមិនទាន់បានធ្វើការអ្វីបន្តិចផង ។ អ្នកមូលដ្ឋានទាំងអស់តែងតែសើចចំអកឲ្យខ្ញុំថា នៅភ្នំពេញតើរកស៊ីអីទៅ បើគ្រាន់តែដើរក៏ដួលដែរនោះ មិត្តណាង អើយ ។ នៅពេលចុះស្ទូងខ្ញុំមិនដែលស្ទូងទាន់គេទេ ជួនកាលគេក៏ស្ទូងបិទមុខខ្ញុំក៏មាន ។ នៅក្នុងទឹកមានសត្វអ្វីតូចៗនៅជាប់នឹងជើងខ្ញុំ ខ្ញុំបេះចេញធ្វើមិនដឹង ។ អ្នកមូលដ្ឋានម្នាក់សួរខ្ញុំថា "មិត្តឯងម៉េចក៏មិនខ្លាចឈ្លើងអីចឹង?" ខ្ញុំឆ្លើយ

ធ្វើព្រងើយថា ព្រោះខ្ញុំនៅតែក្នុងស្រែតាំងពីបាតជើងក្រហមមក ម្ល៉េះ ។ ក្នុងពោះខ្ញុំញ័រដែរ អូហ៎អាហ្នឹងទេដែលគេហៅថាឈ្លើង? ហេតុនេះឈ្លើងក៏ក្លាយជាមិត្តសម្លាញ់ខ្ញុំតាំងពីពេលនោះមក ។ ពេលខ្លះមានអ្នកមូលដ្ឋានដែលត្រូវឈ្លើងទាមស្រែកយ៉ៃហើយ រត់មករកខ្ញុំឲ្យជួយបេះឲ្យ ខ្ញុំយកសំណាបបូតឈ្លើងចេញ ។ ស្រីអ្នកមូលដ្ឋាននោះប្រាប់ខ្ញុំថា "មិត្តណាងអើយ ខ្ញុំអ្នកស្រែមែន តែមិនដែលស្គាល់ស្រែយ៉ាងម៉េចទេ" ។ ប្រជាជននៅទីនោះមិនសូវប្រកាន់ការល្ងិតល្ងង់របស់យើងទេ គេមានតែជួយពន្យល់ប្រាប់យើងថែមទៀត ។

## មន្ទីរពេទ្យរបស់អង្គការ

ប៉ុន្មានថ្ងៃនេះកូនស្រីទីពីររបស់ខ្ញុំចេះតែក្អួត បាយក៏មិនហូប ទឹកក៏មិនផឹកដែរ ។ ខ្ញុំសុំច្បាប់គេឈប់សម្រាកនៅផ្ទះមើលកូន គេក៏អនុញ្ញាតឲ្យ ។ ១០ថ្ងៃកន្លងផុតទៅហើយ ជំងឺរបស់កូនស្រីស្រស់ខ្ញុំមិនបានស្រាកស្រាន្តសោះ ។ ប្រធានភូមិបានឲ្យខ្ញុំយកកូនទៅដេកពេទ្យឃុំដែលមានចម្ងាយពីភូមិខ្ញុំប្រហែលពីរគីឡូម៉ែត្រ ។ ពេទ្យនោះគ្មានថ្នាំសង្កូវអ្វីទេ មានតែគ្រែឈើសម្រាប់ដេកតែប៉ុណ្ណោះ បើអ្នកជំងឺល្មមៗមកដេកក៏ស្លាប់ដែរ ដោយសារសង្កើចខាំ ។

វេលាយប់នោះកូនស្រីខ្ញុំយំទើសភ្លឺ ។ ក្មេងប្រុសពេទ្យម្នាក់បានប្រាប់ខ្ញុំ ឲ្យសុំប្រធានពេទ្យយកកូនទៅសម្រាកនៅពេទ្យស្រុក ទៅព្រោះនៅទីនោះសម្បូរថ្នាំ ។ ខ្ញុំក៏ទៅសុំប្រធានពេទ្យនារីដោយយកសារុងខ្ញុំមួយឲ្យគាត់ជាថ្នូរនូវការដឹងគុណ នារីប្រធានពេទ្យនោះទទួលយកដោយភ្នែកក្រឡេកក្រឡាប់មើលឆ្វេងស្តាំ ។ ប្រធានពេទ្យនោះក៏ចិត្តបានដែរ គាត់ប្រាប់ខ្ញុំថា ចាំស្អែកឲ្យសម-មិត្តក្មេងម្នាក់បររទេះគោជូនខ្ញុំនិងកូនទៅពេទ្យ ។ ប្តីខ្ញុំក៏សុំទៅជាមួយដែរ ។ ព្រលឹមស្រាងៗ យើងក៏ចេញដំណើរតាមរទេះគោ ។ ដោយរទេះរលាក់ពេក ខ្ញុំនិងប្តីមិនជិះរទេះគោទេ ព្រោះអាណិតកូន សុខចិត្តយកអង្រឹងស្នែងសែងកូន ។ ពេទ្យស្រុកពុំដឹងនៅទីណាព្រោះខ្ញុំពុំហ៊ានសួរគេ គ្រាន់តែដឹងថាយើងត្រូវដើរកាត់ស្រុកជាច្រើន ។ ទៅដល់ស្រុកមួយនោះ អ្នកបររទេះគោចង្អុលប្រាប់ថា ទីនេះគឺស្រុកសៃវ៉ា មានកប់ខ្មោចទាហានពលីច្រើនណាស់ ។ យើងទៅដល់ពេទ្យស្រុក ពេលថ្ងៃជ្រេបន្តិចហើយ ។ ពេទ្យនោះគឺយកវត្តធ្វើតែម្តង ។ ទាំងអស់គ្នាចង់ទន់ជង្គង់ព្រោះតែឃ្លានបាយពេក ។ ខាងមន្ទីរពេទ្យអនុញ្ញាតឲ្យប្តីខ្ញុំនិងសមមិត្តបររទេះហូបបាយនៅរោងបាយពិសេសព្រោះទីនោះមានបាយម្ហូបឆ្ងាញ់ៗសម្រាប់ឲ្យអ្នកជូនអ្នកជំងឺមកពេទ្យហូបគ្រប់ពេលវេលា ។ ចំណែកខ្ញុំគេឲ្យហូបបបរពរនិងអំបិលម្រេច តែទោះយ៉ាងណាក៏ឆ្ងាញ់ដែរ ព្រោះខ្ញុំមិនបានហូបអ្វីតាំងពីព្រឹកមកម្ល៉េះ ។ ក្រោយពេលហូបបាយរួច ប្តីខ្ញុំត្រឡប់ទៅវិញភ្លាមជាមួយមិត្តបររទេះ ក្រោយពីលួចថើបថ្ពាសកូនស្រីបន្តិច ។ ចំណែកនាងខ្ញុំនិងកូនគេឲ្យចូលសម្រាកកន្លែងរួមជាមួយអ្នកជំងឺ៦ទៀតដែលមានគ្រែរនាបធំៗអាចសម្រាកបានពីរនាក់ ។ ព្រឹកឡើងមានពេទ្យស្រីក្មេងៗ២-៣នាក់កាន់ថាសដាក់ប្រអប់ថ្នាំគ្រាប់ដើរចែកថ្នាំ ។ គេសួរខ្ញុំថាកូនឈឺអី ហើយក៏លូកយកថ្នាំគ្រាប់ឲ្យលេបដោយមិនចាំបាច់ពិនិត្យយូរ ។ ពេទ្យក្មេងៗទាំងនោះហាក់ដូចជាជំនាញខ្លាំងណាស់ ជួនកាលមានអ្នកជំងឺខ្លះត្រូវចាក់ថ្នាំ គេដណ្តើមគ្នាចាក់ ។ ខ្លះរត់ចេញពីចង្ក្រានបាយដៃសុទ្ធតែខ្លាញ់ ព្រោះទើបតែលាងចានហើយ យកដៃជូតខោខ្លាកៗហើយស្រែកថាទុកឲ្យខ្ញុំចាក់វិញ ។ ៤-៥ថ្ងៃក្រោយមកកូនខ្ញុំបានធូរស្រាលបន្តិចទោះជាថ្នាំដែលគេឲ្យលេបមិនដឹងជាថ្នាំអ្វីខ្លះក៏ដោយព្រោះសុទ្ធតែអក្សរចិនហើយខ្លះជាថ្នាំសូន្យដូចអាចម៍ទន្សាយ ។ ទីនោះប្រៀបដូចជានៅក្នុងឋាននរក សំឡេងស្រែកថ្ងូរយំញ័ររន្ធត់ស្រែកសម្លុតជេរបញ្ឆោរយ៉ាងម៉េចក៏មានគ្រប់បែបយ៉ាងទាំងអស់ ។

ថ្ងៃនេះពេទ្យអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅភូមិវិញ ។ ខ្ញុំឡេឡឺពុំដឹងទៅតាមផ្លូវណាជាមួយអ្នកណា ។ ចៃដន្យថ្ងៃបន្តិចមានរទេះអ៊ំម្នាក់មកទទួលប្រពន្ធកូនគាត់ទៅផ្ទះវិញ ខ្ញុំក៏សុំដោយសារជាមួយបានតែពាក់កណ្តាលផ្លូវ គាត់ក៏បែកផ្លូវទៅទៀត ។ គាត់ប្រាប់ខ្ញុំឲ្យស្រូតដំណើរទៅផ្លូវខាងមុខនេះទៅកុំឲ្យយប់ទាន់ដើរប្រហែល១០គីឡូម៉ែត្រទៀតប៉ុណ្ណោះដល់ផ្ទះហើយ ។ ពុទ្ធោអើយ ខ្ញុំត្រូវពកូននិងមានបង្វេចខោអាវទៀត តែសំណាងល្អខ្ញុំចេះតែជួបរទេះសុំដោយសារទៅដល់ពេទ្យឃុំក៏យប់ល្មម ។ ពួកពេទ្យឃុំដែលស្គាល់ខ្ញុំគេត្រេកអរណាស់ពេលឃើញខ្ញុំនិងកូនត្រឡប់មកវិញ ។ គេឃាត់ខ្ញុំឲ្យសម្រាកនៅទីនោះមួយយប់ តែខ្ញុំ

មិនព្រមព្រោះខ្លាចបងសង្កើច ។ ខ្ញុំផ្ញើបង្កេចនឹងពេទ្យហើយពកូនដើរលើទំនប់ដែលគេទើបនឹងលើកហើយថ្មីៗ ។ នៅវាលដុបខាងឆ្វេងដៃខ្ញុំសុទ្ធតែផ្នូរខ្មោចដែលគេកប់ទាំងស្នែងបុស្សី ឃើញឈើស្នែងនោះច្បាស់ ពេលចាំងនឹងពន្លឺព្រះច័ន្ទ ធ្វើឲ្យខ្ញុំព្រឺក្បាលខ្លាចដូចជាមានគេដេញតាមពីក្រោយ ។ ខ្ញុំដើរកាន់តែលឿនទៅៗ ។ ត្រចៀកខ្ញុំឡើងហ៊ឹង ខ្ញុំទន្ទេញញាប់មាត់ថា "កុំខ្លាចៗ" ហើយស្រែកច្រៀងពុៗ ដើម្បីបន្ធូរការខ្លាច ។ ខ្ញុំមកដល់ភូមិទឹកលិចជុំវិញភូមិ ។ ខ្ញុំដើរស្ទាបៗ ព្រោះដឹងថាមុំនេះមានអន្លង់ធំមួយ ។ ម៉ោងប្រមាណ៨-៩យប់ យើងបានជួបជុំគ្នាសប្បាយរីករាយណាស់ រួមទាំងមិត្តទាំងអស់ដែលនៅផ្ទះជាមួយគ្នា ។ ឥឡូវនេះយើងស្បើយអង្ករហូប ប្រធានភូមិចែកមិនបានគ្រប់គ្រាន់ទេ គាត់ប្រាប់យើងថាត្រូវហូបឲ្យសន្សំសំចៃ ត្រូវបបរក៏បបរខ្លះទៅ ។ យើងចាប់ផ្តើមសម្លឹងមើលជង្រុកស្រូវដែលនៅក្នុងផ្ទះយើង ហើយក៏លួចកិនហូបទាល់តែអស់ ។

យើងទទួលបញ្ជាឲ្យរៀបចំខ្លួនដើម្បីចេញដំណើរទៅរស់នៅខេត្តបាត់ដំបង ។ ម្នាក់ៗសប្បាយរីករាយណាស់ ព្រោះល្បីថាខេត្តនេះសម្បូរស្រូវ ។ ខ្លះលួចនិយាយគ្នាថាគេឲ្យយើងត្រឡប់ទៅភ្នំពេញវិញហើយ តែគេករយើង ។ ចំណែកអ្នកមូលដ្ឋានគេមិនឲ្យទៅទេ ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ហាក់មានអាថ៌កំបាំងអ្វីមួយ ។

ព្រឹកនេះយើងលាអ្នកមូលដ្ឋានទាំងអស់ ខ្លះក៏យំព្រោះអាឡោះអាល័យយើងដែរ ។ យើងត្រូវជិះរថភ្លើង ។ ក្នុងទូរថភ្លើងនីមួយៗ គេញាត់យើងឲ្យណែនដូចកាត់ ។ មិត្តភក្តិនិងបងប្អូនខាងប្តីខ្ញុំដែលនៅក្នុងផ្ទះជាមួយគ្នាក៏បែកគ្នាតាំងពីពេលនោះជារៀងរហូត ។ ជិះរថភ្លើងបានមួយស្របក់ ខ្ញុំចាប់ផ្តើមចុកពោះ ។ ពេទ្យអង្គការប្រុសចំណាស់ម្នាក់ស្ពាយកាបូបដើរចុះឡើងៗ មើលខ្ញុំ តែគ្មានឲ្យថ្នាំអ្វីមួយគ្រាប់ទេ ។ មួយម៉ោងក្រោយគ្រូពេទ្យដែលក៏មកអើតម្តងទៀត ឃើញមុខខ្ញុំឡើងស្លេកមែនទែន ទើបបើកកាបូបយកថ្នាំគ្រាប់ហុចខ្ញុំលេប ហើយនិយាយថា "មិត្តនេះឈឺមែនទែនមិនមែនលេងៗទេ" ។ ព្រះអើយ! ខ្ញុំឈឺចង់ងាប់គេនៅចាំតាមដានមើលទៀត ។ លើរថភ្លើង គេចែកនំប៉័ងឲ្យម្នាក់ពីរ ទោះមានកូនតូចធំក៏ឲ្យដូចគ្នា ហើយចែកស្ករសនិងទឹកស៊ីអ៊ីវឲ្យជ្រលក់ ។

ខ្ញុំហូបអ្វីក៏មិនបានអង្គុយសង្កត់តែពោះ ។ ប្តីខ្ញុំបានយកដែកកេះមួយដូរជាមួយអ្នកជិតខាងម្នាក់យកប្រេងកូឡាបស្វាមួយប្រអប់មកលាបពោះឲ្យខ្ញុំ ។ ម៉ោង៥ល្ងាចរថភ្លើងឈប់ឲ្យបត់ជើងធំនិងដាំបាយនៅកន្លែងមួយ ។ ខ្ញុំពុំដឹងកន្លែងណាទេ តែអ្នកខ្លះថាជិតដល់ភ្នំពេញហើយ ខ្លះចូលទៅភូមិជិតនោះយកមុងឬខោអាវល្អៗដូរយកដំឡូង៤-៥ដុំហូបព្រោះតែឃ្លានពេក ។ គេនិយាយថាចាំយើងចូលភ្នំពេញវិញចាំទិញថ្មីក៏បាន ។ យប់ងងឹតហើយ រថភ្លើងបន្លឺស៊ីរ៉ែនឲ្យយើងទាំងអស់គ្នាឡើងវិញដើម្បីបន្តដំណើរទៅមុខទៀត ។ រថភ្លើងបរកាត់ទីក្រុងភ្នំពេញដែលមានចង្កៀងអគ្គិសនីមិនសូវភ្លឺប៉ុន្មានទេក្រោមតំណក់ទឹកភ្នែករលីងរលោងរបស់យើងគ្រប់ៗគ្នា ។ ខ្លះក៏ស្រែកទ្រហោយំ លាហើយភ្នំពេញអើយ លាហើយផ្ទះជាទីស្រឡាញ់ លាហើយមិត្តទាំងអស់គ្នា លាអ្វីៗគ្រប់យ៉ាងហើយគ្មានសង្ឃឹមជួបអ្នកទៀតទេ ។

### ស្វាយស៊ីសុផុន

ពីរថ្ងៃកន្លង រថភ្លើងបាននាំយើងទៅដល់ស្វាយស៊ីសុផុន ។ យើងចុះពីលើរថភ្លើងដោយដៃជើងរឹងក្រញង់ស្ទើរកម្រើកពុំបាន ។ ផ្ទះឈើខ្លះថ្មនៅទំនេរទាំងអស់ពុំដឹងម្ចាស់ទៅណា ។ គេឲ្យយើងសម្រាកនៅផ្ទះណាក៏បានស្រេចតែចិត្ត ។ ក្នុងផ្ទះនីមួយៗមាន២-៣គ្រួសារនៅជុំគ្នា ។ ពួកយើងអាចយកតុ ទូ កៅអី នៅក្នុងផ្ទះអស់នោះពុះដុតស្រេចចិត្តដើម្បីដាំបាយហូបស្រេចនឹងចិត្ត ។

ក្នុងមួយថ្ងៃគេចែកអង្ករម្នាក់ពីរកំប៉ុង ចំណែកម្ហូបយើងត្រូវដោះស្រាយដោយខ្លួនឯង ។ ពួកយើងបានយកអង្ករឬអំបិលទៅដូរជាមួយប្រហុក ត្រីស្រស់ ឬត្រីងៀត នៅតាមភូមិអ្នកស្រុក ។ សម្រាកបានប្រហែលមួយអាទិត្យ អង្គការបានដើរប្រកាសប្រាប់យើងថា អ្នកណាជាជនជាតិវៀតណាមអង្គការអនុញ្ញាតឲ្យទៅស្រុកយួនវិញបាន តែត្រូវមានប្រវត្តិច្បាស់លាស់ ។ ប្តីខ្ញុំជំនុំគ្នានឹងខ្ញុំថា យើងគិតធ្វើជាវៀតណាមទៅឲ្យ តែស្រុកចាយលុយទៅណាក៏យើងមិនស្គាល់ដែរ ។ ហើយខ្ញុំបានសុំយាយយួនម្នាក់ធ្វើជាម្តាយដោយឲ្យខោអាវ២-៣កំប្លេទៅគាត់ ។

៣-៤ថ្ងៃក្រោយ គេហៅពួកខ្ញុំទៅសួរម្តងទៀត ។ គេសួរម្តាយយួនខ្ញុំថាហេតុអីនាងខ្ញុំនិយាយខ្មែរច្បាស់ម្ល៉េះ ហើយមុខមិន

ដូចម្តាយសោះ? (ខ្ញុំត្រូវធ្វើជាកូនស្រីគាត់បង្កើត) ម្តាយខ្ញុំឆ្លើយថាព្រោះខ្ញុំកើតនៅស្រុកខ្មែរ ហើយមុខមាត់កាត់តាមឪពុក តែតាមមើលគេមិនសូវជឿទេ។ ចំណែកអ្នកដែលមិនបានចុះឈ្មោះជាវៀតណាម គេដឹកយកទៅដាក់តាមភូមិស្រុកអស់ហើយ នៅសល់ក្រុមយួនប្រហែល៣០ទៅ៤០គ្រួសារតែប៉ុណ្ណោះ។ ពួកយើងនៅទីនោះប្រហែល២ខែហើយ កន្ទុះខែគេហៅសួរម្តង ហើយរបបអង្ករគេចែកតាមធម្មតាគ្រាន់តែពុំសូវសម្បូរម្ហូប។ យប់មួយខ្ញុំគេងយល់សប្តិឃើញថា ខ្ញុំដើរទៅភូមិមួយជិតជើងភ្នំសងខាងមានសុទ្ធតែដើមត្នោតទេសភាពត្រជាក់ល្អមជាទីសប្បាយរីករាយណាស់។

## ភូមិស្រែះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបងឬបន្ទាយមានជ័យ

ព្រឹកឡើងខ្ញុំមិនទាន់ទាំងចេញពីមុងផង ខ្ញុំឮខ្មែរក្រហមស្រែកមេក្រូខាងមុខផ្ទះថា «បងប្អូនក្រុមយួនទាំងអស់គ្នារៀបចំអីវ៉ាន់ឆាប់ឡើងឡានមកយកហើយ»។ យើងសប្បាយរីករាយណាស់រៀបចំអីវ៉ាន់លឿនៗចោលខ្លះយកខ្លះឲ្យតែបានទៅ។ ឡានសណ្តោងធំៗ៣-៤បួនបានដឹកពួកយើងកាត់តាមវាលស្រែពណ៌មាសដាច់កន្ទុយភ្នែក។ យើងទាំងអស់គ្នានៅលើឡានខ្លះស្រែកច្រៀង ហើយខ្លះជាជនជាតិវៀតណាមពិតប្រាកដស្រែកច្រៀងចម្រៀងយួនយ៉ាងសប្បាយរីករាយ។ រថយន្តដឹកយើងចូលតាមផ្លូវដីក្រហមចូលទៅក្នុងរហូតយើងឃើញភ្នំមួយ ហើយដាក់ចុះតាមភូមិខ្លះៗរហូតដល់ចុងភូមិក្រោយគឺនៅសល់ប្រមាណតែដប់គ្រួសារប៉ុណ្ណោះរាប់ទាំងគ្រួសារខ្ញុំផង។ គេឲ្យយើងចុះពីលើឡាន។ មានសមមិត្ត២-៣នាក់ឈរចាំទទួលពួកយើង។ សមមិត្តម្នាក់ចាស់ជាងគេ ប្រហែលជាធំជាងគេបាននិយាយប្រាប់យើងថា «ក្រុមបងប្អូនយួនទាំងអស់នៅជួយធ្វើស្រែនៅទីនេះមួយឆ្នាំសិនហើយ ចាំឆ្នាំក្រោយសឹមទៅស្រុកកំណើតវិញគង់តែជួបទេបងប្អូននោះ»។ យើងធ្លាក់ទឹកមុខគ្រប់ៗគ្នា ខ្លះចង់ពេបបន្តិចអីបន្តិច ខ្លះនិយាយមិនចេញ។

ភូមិដែលខ្ញុំនៅនោះឈ្មោះភូមិស្រែះខាងជើង មានទេស-ភាពដូចដែលខ្ញុំយល់សប្តិពីយប់មិញ។ ភូមិនោះស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (សព្វថ្ងៃស្ថិតក្នុងខេត្តបន្ទាយមាន-ជ័យ)។ ពីសង្គមចាស់ អ្នកស្រុករកស៊ីដាប់ថ្មភ្នំធ្វើត្បាល់កិនត្បាល់បុក។ ខ្មែរក្រហមយកពួកយើងទៅដាក់នៅវត្តមួយក្បែរជើងភ្នំ មិនទាន់ឲ្យចូលភូមិភ្លាមទេ។ គេប្រាប់ថាត្រាំនៅទីនេះ៨-១០ថ្ងៃសិនទៅចាំគេរកកន្លែងឲ្យនៅ។ ពួកយើងលួចទៅមើលព្រះពុទ្ធរូបធំៗដែលត្រូវវាយកម្ទេចចោលនៅក្នុងព្រះវិហារ ហើយលួចថ្វាយបង្គំទាំងភ្នែកនៅកញ្ចឹងក។

ព្រឹកនេះមានសមមិត្ត២-៣នាក់ស្លៀកពាក់ខោអាវខ្មៅបង់កក្រមា ពាក់ស្បែកជើងកង់ឡាន មានស្ពាយថង់យាមម្នាក់មួយ ដើរចូលមកកន្លែងយើងសម្រាក។ ក្នុងចំណោមនោះខ្ញុំស្គាល់លោកម្នាក់ពីសង្គម លន់ ណុល ពាក់សក្តិ២។ គាត់ធ្លាប់ទៅសម្រាកពេទ្យនៅកន្លែងខ្ញុំ គាត់ឈ្មោះ លោក លី។ គ្រាន់តែក្រឡេកឃើញខ្ញុំ គាត់មិចភ្នែកជាសញ្ញាកុំឲ្យខ្ញុំធ្វើស្គាល់គាត់។ គាត់ដើរជាមួយអ្នកមូលដ្ឋានដែលក្នុងថង់យាមមានថ្នាំបុស្សីជាច្រើនយកទៅចែកក្រុមយួនឲ្យដាំទឹកហូបដើម្បីការពារកុំឲ្យចាញ់ទឹកចាញ់ដីក្នុងព្រៃភ្នំនេះ។ លោក លី ធ្វើជាដើរមកជិតខ្ញុំ និយាយពន្យល់ពីថ្នាំបុសឈើនេះ ហើយខ្សឹបប្រាប់ខ្ញុំថា «កុំធ្វើស្គាល់ខ្ញុំឲ្យសោះណា៎» ខ្ញុំក៏ងក់ក្បាលអរគុណគាត់។ រំលងបានមួយអាទិត្យ អង្គការចែកដីឲ្យយើងធ្វើកូនខ្ទមនៅរៀងៗខ្លួន។ យើងជួយគ្នាធ្វើផ្ទះទៅវិញទៅមកទាំងលំបាកទម្រាំបានកូនខ្ទមនៅ។

## ទៅរៀនសូត្រ ឬ ទៅបរលោក?

អង្គការមិនទាន់បញ្ជាឲ្យក្រុមយួនយើងទៅធ្វើការអ្វីទេ ប្រហែលជាគេឲ្យសម្រាកយកកម្លាំងសិនក៏មិនដឹង។ តាមពិតក្នុងចំណោមក្រុមយួនមានសុទ្ធតែចិន ចំណែកយួនពិតប្រាកដមានតែ២-៣គ្រួសារប៉ុណ្ណោះ។

ព្រឹកនេះ សមមិត្តស្រីប្រុសក្មេងៗមុខប្លែកៗ៤-៥នាក់កាន់សៀវភៅម្នាក់មួយដើរកត់ឈ្មោះក្មេងកម្លោះក្រមុំដែលនៅរៀននៅឡើយហើយចង់រៀនបន្តទៀត អង្គការអនុញ្ញាតឲ្យទៅរៀនសូត្រវិញ។ ប្អូនស្រីទីពីររបស់ខ្ញុំដែលកំពុងកាប់ដីនៅក្រោយផ្ទះ រត់មកដោយអំណរស្ម័គ្រចិត្តទៅភ្លាម។ ក្រោយកត់ឈ្មោះហើយ វាក៏រៀបចំខោអាវដែលមានតែ២-៣កំប្លេ។ ខ្ញុំលួចខ្សឹបប្រាប់វាថា «កុំទៅអីប្អូននៅជាមួយបងឯហ្នឹងហើយ» វាឆ្លើយថា «អត់ទេ ខ្ញុំចង់រៀន បងស្រីឃើញទេ ខ្ញុំថាទោះយ៉ាងណាក៏គេមិនបិទសាលារៀនដែរ»។ វាហុចសាប៊ូក្រអូបម៉ាកលុច្សមិនទាន់ប្រើ

មួយដុំមកឲ្យខ្ញុំហើយប្រាប់ថា "បងទុកឲ្យភ័ក្ត្រនិងស្រីស្រស់ប្រើទៅ ខ្ញុំលាហើយ"។ រួចហើយវាក៏ឡើងរថយន្តការ៉ាមីញ៉ុងមួយដែលចតចាំ និងមានយុវជនជំទង់ស្រីប្រុសប្រហែល១០នាក់រង់ចាំនៅលើនោះជាស្រេច។ តាំងពីថ្ងៃនោះមកក៏បាត់ដំណឹងវារហូតទៅពុំដឹងថាទៅរៀននៅមហាវិទ្យាល័យណាទេ។

ដោយនៅទំនេរពុំទាន់ទៅធ្វើការអ្វី ប្តីនាងខ្ញុំក៏កាប់ដីនៅក្រោយផ្ទះដាំដំឡូង ជី ស្លឹកគ្រៃ ដែលយើងដើរសុំពីអ្នកមូលដ្ឋាន។ នាងខ្ញុំត្រូវប្រធានកងស្រីហៅឲ្យទៅជួយកិនស្រូវ។ នាងខ្ញុំមានភារកិច្ចអុំអង្ករ។ ខ្ញុំត្រូវប្រធានកងស្តីបន្ទោសពីមុខស្តីពីក្រោយ ព្រោះអុំអង្ករកំពប់អស់ជាច្រើន ហើយគេបញ្ជាឲ្យរើសទាល់តែអស់ទើបអាចទៅហូបបាយបាន។ ទោះគេថាឲ្យយ៉ាងម៉េចក៏ខ្ញុំមិនតបតនឹងគេឡើយ ហេតុនេះថ្ងៃក្រោយទៅពួកគេក៏អាណិតស្រឡាញ់ខ្ញុំគ្រប់គ្នា។ ពេលរួចពីការងារពេលព្រលប់ប្តីប្រពន្ធនាងខ្ញុំនិងកូនតូចៗទាំងពីរតែងតែនាំគ្នាទៅងូតទឹកនៅស្រះជិតវត្ត។ ប្តីខ្ញុំបានខ្ចីធុងអ្នកជិតខាងយកទៅរែកទឹកទុកប្រើផង។ ស្អែកល្ងាច ស្រាប់តែមានការប្រជុំ។ ក្រោយពីសមមិត្តប្រធានភូមិឡើងគោរពអ៊ំ ពូ មីង បងប្អូនក្រុមយួនទាំងអស់គ្នារួចមក គាត់ណែនាំឲ្យយើងខំធ្វើការ ថ្ងៃក្រោយនឹងបានហូបគ្រប់គ្រាន់បរិបូរណ៍។ អស់ពីនិយាយរឿងធ្វើការគាត់ចាប់ផ្តើមទិតៀនពីរឿងសីលធម៌វិញម្តង។ គាត់និយាយថា "អ្នកខ្លះមិនបោះបង់របៀបរបបចក្រពត្តិអាសអាភាស សូម្បីតែទៅងូតទឹកក៏បណ្តើរគ្នាឲ្យត្រសងសប្បាយរីករាយណាស់ ក្នុងពេលដែលយុទ្ធជនយើងនៅកំពុងប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាជាមួយពួកអាមេរិកនៅឡើយ"។ និយាយដល់ត្រង់នេះ គ្រប់គ្នាងាកមើលស្រមកប្តីប្រពន្ធខ្ញុំ។ តាំងពីថ្ងៃនោះមកពួកយើងលែងហ៊ានបណ្តើរគ្នាទៅងូតទឹកទៀត។

ព្រឹកនេះ ប្រធានក្រុមដើរហៅពួកក្រុមយួនយើងទៅធ្វើការគឺទៅលើកទំនប់នៅខាងក្រោយភូមិចម្ងាយប្រហែលមួយគីឡូម៉ែត្រ។ គិតទៅក្រុមយួនខ្ញុំមកក្រោយគេតែពីរខែសោះ ប៉ុន្តែអ្នកមកដល់មុនគេប្រៀបដូចអ្នកមូលដ្ឋាន ចំណែកពួកខ្ញុំប្រៀបដូចអ្នក១៧មេសា។ ពួកគេតែងលួចសើចពួកខ្ញុំដែលពុំសូវចេះធ្វើអ្វីដូចជារែកទឹក ពុះអុស កាប់ដីជាដើម ព្រោះយើងធ្វើពុំសូវសមដូចអ្នកមូលដ្ឋាន។ ពេលត្រឡប់មកពីលើទំនប់វិញ ម្នាក់ៗទូលអុសមួយបាច់ធំៗ ចំណែកខ្ញុំទូលសុទ្ធតែស្លឹកគ្រោតសំពីងសំពោងពេញផ្លូវទើសគេទើសឯង មើលទៅដូចជាសម្បើមណាស់ តែដាំទឹកស្ងោរមិនបានមួយកំសៀវផង។ នៅពេលបាយគេឲ្យយើងទៅហូបនៅរោងបាយជុំគ្នានឹងប្រជាជនចាស់ដែរ។ ពួកយើងហូបយកមួយឆ្អែត ជួនកាលក៏បបរវាវជាមួយទឹកសម្ល ចំណែកអ្នកមូលដ្ឋានវិញ គេហូបតែពីរបីម៉ាត់ក៏កាន់ចានបាយដើរសំដៅទៅផ្ទះរៀងៗខ្លួន ព្រោះគេមានម្ហូបពិសេសនៅផ្ទះ។

យូរៗខ្ញុំជួប លោកលី ម្តង។ គាត់និយាយអ្វីនឹងខ្ញុំក៏ខ្សឹបដែរ ហើយភ្នែកក្រឡេកក្រឡាប់មើលឆ្វេងស្តាំជានិច្ច។ រំលងពីរខែក្រោយមក ព្រឹកមួយខ្ញុំនៅធ្វើចម្ការនៅជើងភ្នំ ខ្ញុំបានឮគេនិយាយខ្សឹបខ្សៀវគ្នាថា លោកលី ត្រូវគេនាំយកទៅបាត់យប់មិញហើយ។ កាលនោះខ្ញុំពុំដឹងហើយពុំជឿថាគេនាំមនុស្សទៅសម្លាប់ទេ។ ខ្ញុំនឹកអាណិតប្រពន្ធ លោកលី ដែលកំពុងមានផ្ទៃពោះប្រាំខែ ហើយនិងកូនស្រីម្នាក់អាយុប្រហែល៥-៦ឆ្នាំ។ ប្រពន្ធលោកលីត្រូវគេចាត់ឲ្យទៅធ្វើស្មៅចម្ការជាមួយក្រុមខ្ញុំដែរ តែគ្មានអ្នកណាហ៊ាននិយាយរកគាត់ទេ។

ប្រមាណមួយខែក្រោយ ខ្ញុំពុំឃើញប្រពន្ធលោកលី ទៅធ្វើការទេ។ ខ្ញុំឮគេថាគាត់ឈឺនៅផ្ទះ។ ពេលត្រឡប់មកពីចម្ការវិញនាពេលល្ងាច ខ្ញុំដើរកាត់ខ្ទមរបស់គាត់ ចង់ចូលសួរសុខទុក្ខគាត់ តែពុំហ៊ាន។ ខ្ញុំឮសំឡេងថ្ងូរអ៊ូយៗចុកពោះណាស់ពីក្នុងខ្ទមកម្សត់របស់គាត់។ សម្រែកនោះធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក តែពុំដឹងធ្វើយ៉ាងម៉េចអាចជួយគាត់បាន។ ស្អែកឡើងប្រពន្ធលោកលីទទួលមរណភាព។ ពួកឈ្លបក្មេងៗ២-៣នាក់បានសែងគាត់យកទៅកប់ក្នុងព្រៃជ្រៅ។ គេនិយាយប្រាប់ពួកយើងនៅចម្ការថា មុនកប់សពលោកស្រីលី គេបានវះពោះយកកូនក្នុងផ្ទៃចេញកប់ដោយខ្លួន ព្រោះកុំឲ្យរាតត្បាតក្នុងភូមិ។ នេះជាទំនៀមទម្លាប់របស់ប្រជាជនក្នុងភូមិនេះ។ កូនស្រីរបស់លោកលីត្រូវអ្នកមូលដ្ឋានយកទៅចិញ្ចឹម ហើយតាំងពីថ្ងៃនោះមកគ្រួសារលីក៏រលាយបាត់ឈ្មោះទៅ។

នៅក្នុងចម្ការដែលខ្ញុំទៅធ្វើស្មៅ ខ្ញុំបានជួបតាចាស់ម្នាក់ដែលជាទាហានជំនាន់ លន់ ណុល ដែរ។ កាលណោះគាត់ពាក់

សក្តិប្រាំ តែឥឡូវគាត់ជាតាចាស់សក់ស្កូវម្នាក់យ៉ាងគគ្រិច ។ ថ្ងៃមួយគាត់លួចខ្សឹបប្រាប់ខ្ញុំថា គាត់មានខ្នុរធំមួយ ល្ងាចនេះឲ្យប្តីខ្ញុំទៅរែកទឹកនៅស្រះជិតចូលទៅយកខ្នុរនោះមកបន្ទុំទុកចែកគ្នាហូប ។ ប្តីខ្ញុំជីកដីក្នុងផ្ទះកប់ខ្នុរទុកឲ្យទុំ ។ ពីរថ្ងៃកន្លងទៅ ព្រឹកនេះពេលភ្ញាក់ពីព្រលឹម ក្លិនខ្នុរក្រអូបឈ្ងុយដល់ផ្លូវដើរមុខផ្ទះ ។ ប្តីខ្ញុំញញើរញញ័រជីកយកចេញ ហើយពុះជា៤-៥ចំណែកយកទៅផ្ញើតាចាំចម្ការផង ។ ខ្ញុំពិតជាស្មានពុំដល់សោះថាក្លិនខ្នុរក្រអូបបានឆ្ងាយដូច្នេះ ។

## ប្តីប្រពន្ធក្លែងក្លាយ

ក្នុងភូមិស្រែះនេះ ខ្មែរក្រហមកំពុងតាមដានប្តីប្រពន្ធមួយគូដែលពុំសូវសមគ្នាជាប្តីប្រពន្ធសោះ ។ អាគា អាយុប្រហែល ១៨ឆ្នាំ ហើយប្តីវាអាយុ២០ឆ្នាំ ។ តាមពិតវាទាំងពីរនាក់នេះពុំមែនជាប្តីប្រពន្ធគ្នាពិតប្រាកដទេ ។ វាជាបងប្អូនជីដូនមួយនឹងគ្នា ហើយពេលវាមកនៅក្នុងភូមិនេះក៏ប្រាប់អង្គការថាប្តីប្រពន្ធទៅ ដើម្បីកុំឲ្យអង្គការបញ្ជូនទៅកងចល័ត ។ អាទី ដែលជាប្តីបានលួចខ្សឹបប្រាប់ប្តីខ្ញុំថា យប់ណាក៏វាដេកពុំដែលបានស្កប់ស្កល់ដែរ ព្រោះមានឈ្លបនៅចាំលួចស្តាប់យកការណ៍ពីវាទាំងពីរនាក់នោះ ។ ប្តីខ្ញុំដែលមានមាត់រប៉ិលរប៉ូចផងក៏ប្រាប់វាថា "ម៉េចឯងមិនបើកប្រតិបត្តិការសឹកមែនទែនតែម្តងទៅ កុំឲ្យគេសង្ស័យ" អាទីវាស្រែកឡើងថា "អូ មិនបានទេ អាមួយគាកាចណាស់ យប់ណាក៏វាស្លៀកខោ៣-៤ជាន់ដែរ" ។ ប្តីខ្ញុំថា "គំរាមវាទៅណាប្រាប់អង្គការទៅ" ។ អាទី ថា "បើដូច្នោះខ្ញុំក៏ស្លាប់ដែរ" ។ ដូច្នេះពួកវាទាំងពីរក៏ត្រូវចំលាក់អាថ៌កំបាំងនេះរៀងៗខ្លួន ទោះឈ្លោះគ្នាជេរគ្នាក៏មិនហ៊ានឲ្យអ្នកដទៃឮដែរ ។ នេះគឺចំណេះជិះកឯង ។ បច្ចុប្បន្ននេះ អាមួយគា ជាចៅកែកាណូតភ្នំពេញ-ក្រចេះ ។ វាមានកូនពីរនាក់ហើយ ប៉ុន្តែប្តីវាមិនមែនជាអាទីទេ ។

## ស្និតសិតចៃ របស់ដែលមានតម្លៃ

ក្នុងរបបអាវខ្មៅ ក្រៅពីអង្ករ ត្រីងៀត ប្រហុក ស្និតសិតចៃគឺជារបស់ដែលមានតម្លៃបំផុត ។ ក្នុងសម័យនោះ យើងម្នាក់ៗពុំអាចកម្ចាត់ចៃឲ្យអស់ពីក្បាលបានឡើយទោះជាកាត់សក់ខ្លីក៏ដោយ ព្រោះគ្មានសាប៊ូកក់សក់ ។ ម្ល៉ោះហើយអ្នកដែលមានស្និតសិតចៃគឺដូចជាមានដងសន្ទូចស្ទូចត្រីដែរ ។ ចែអេង គាត់មានគំនិតចេះយកស្និតសិតចៃមកតាមខ្លួនបាន២-៣ ។ អ្នកណាក៏ខ្ចីរបស់គាត់ដែរ ជួនកាលគាត់ឲ្យដោយទឹកមុខរីករាយ ជួនកាលក៏ឲ្យទាំងទើសទាល់ ។ យូរៗគាត់បែកប្រាជ្ញា បើអ្នកមកខ្ចីទាល់តែមានត្រីងៀត ប្រហុកចំហុយ ឬស្ករផ្សេងទៀតក៏បានឲ្យតែជារបស់ញ៉ាំ ទើបអាចខ្ចីបាន ។ បើអ្នកមូលដ្ឋានខ្ចីគាត់ពុំឲ្យទេ ។ ថ្ងៃមួយអង្គការនាំគាត់ទៅរៀនសូត្របាត់ទៅ ។ គេថាខួរក្បាលគាត់នៅជាប់កម្អែលនាយទុនច្រើនណាស់ ។

## យាយធំដាច់ខាត

ថ្ងៃមួយ ប្តីខ្ញុំបានប្រាប់ខ្ញុំថាគាត់ឧស្សាហ៍ទៅសុំទឹកត្នោតហូបនៅកន្លែងម្ចាស់ស្ករចម្ងាយពីភូមិខ្ញុំប្រហែលមួយគីឡូម៉ែត្រប៉ុណ្ណោះ ។ កន្លែងនោះគឺសុទ្ធតែអ្នកមកពីខាងតាកែវ មកធ្វើស្ករនៅទីនេះ ហើយគេធ្វើផ្ទះស្រាស់របងនៅតែក្រុមរបស់គេប្រហែល២០គ្រួសារប៉ុណ្ណោះ ប្រៀបដូចជាបន្ទាយទាហាន ។ គេហូបតែគ្នាគេគ្មានឡូកឡំជាមួយអ្នកមូលដ្ឋានឬអ្នកថ្មីអីទេ គេហៅថាក្រុមដាច់ខាត ។ ប្តីខ្ញុំប្រាប់ថាគេសម្បូរថ្នាំពេទ្យណាស់ គេចង់រកពេទ្យដើម្បីចាក់ថ្នាំឲ្យក្រុមគេ ។

ស្អែកឡើងកណ្តាលថ្ងៃត្រង់ចែស ខ្ញុំលួចដើរតាមទំនប់ក្រោយផ្ទះសំដៅទៅក្រុមដាច់ខាត ។ យាយធំដែលជាប្រធានគេមានមុខមាំ សក់ស្កូវពេញក្បាល តែសាច់ឈាមគាត់ល្អណាស់បង្ហាញថាគាត់ហូបចុកបរិបូរណ៍ ។ យាយធំបានយកថ្នាំ២-៣ប្រអប់ធំៗមកបង្ហាញខ្ញុំហើយសួរថា នេះថ្នាំអី នេះថ្នាំអីខ្លះ ។ ថ្នាំមានគ្រប់មុខតាំងពីថ្នាំគ្រុនចាញ់ ថ្នាំកម្លាំង វិតាមីនសេ ថ្នាំផ្សះជាដើម ។ កូនចៅយាយធំចូលចិត្តឲ្យខ្ញុំចាក់ថ្នាំណាដែលមានពណ៌ស្រស់ៗ ។ ខ្ញុំមានតែសឺរ៉ាំងកែវមួយនិងម្ជុលចាក់៣-៤ ប៉ុណ្ណោះ ចំណែកប្រដាប់ប្រដាពេទ្យដែលខ្ញុំយកទៅពីភ្នំពេញត្រូវអង្គការឆែកយកអស់តាំងពីពេលចុះពីរថភ្លើងមកម្ល៉េះ ។ ខ្ញុំដាក់ស្ងោរសឺរ៉ាំងនិងម្ជុលក្នុងផ្តិលមួយ ហើយទឹកក្តៅជំនួសអាល់កុល ។ ក្រោយពេលចាក់ថ្នាំរួច យាយធំបញ្ជាឲ្យកូនចៅគាត់រៀបបាយសម្លឲ្យខ្ញុំហូប ។ បាយអង្ករកិនម៉ាស៊ីនឡើងសស្គុសដូចកាកដូង ។ ខ្ញុំឱនមើលបាយចង់ដល់ចាន ព្រោះខានឃើញយូរហើយ ។ សម្លស្ងោរស្ពៃខៀវជាមួយត្រីងៀតធំៗជាប្រភេទត្រីរ៉ស់មកពីបឹងទន្លេសាបឆ្ងាញ់ម្ល៉េះទេលោកអើយ ។ ខ្ញុំហូបចង់បែកពោះ

ទោះឆ្អែតពីភូមិហើយក៏ដោយ ។ យាយធំហាមមិនឲ្យខ្ញុំយកបាយមកផ្ទះទេ ខ្លាចអង្គការដឹង ។ ទោះជាយាយធំហាមក៏ខ្ញុំនៅតែលួចយកត្រីងៀតនឹងបាយតូចដុំៗចងជាយក្រមាទុកផ្ញើកូននិងប្តី ។ មិត្តអ្នកអានពិតជាមិនជឿនឹងខ្ញុំទេមែនទេ? នៅកន្លែងដាច់ខាតនោះមួយអាទិត្យគេធ្វើបង្អែមម្តង ជួនកាលចេកខ្ទិះ ជួនកាលនំបាញ់ឆុកធំៗប៉ុនផ្លែក្រូច ។ ខ្ញុំតែងលួចចងនៅជាយក្រមាយកមកផ្ញើកូននិងប្តីជានិច្ច ទោះគ្មានទឹកស្ករក៏ហូបឆ្ងាញ់ដែរ ។ យាយធំស្រលាញ់ខ្ញុំណាស់ ប៉ុន្តែគាត់ពុំសូវហ៊ានឲ្យអីខ្ញុំទេ ខ្លាចអង្គការផែកមានឃើញរឿងដល់គាត់ ។

## កណ្តុរស្រែ ម្ហូបពិសេស

នៅស្រុកនោះ សត្វកណ្តុរជាម្ហូបយ៉ាងឆ្ងាញ់របស់យើងទាំងអស់ ។ ពេលថ្ងៃត្រង់សម្រាកពីការងារ យើងតែងលីចបមួយម្នាក់ដើរទៅកណ្តាលវាលស្រែដែលច្រូតហើយដើម្បីរករន្ធកណ្តុរ ។ រន្ធកណ្តុរមានទំហំល្មមតែដៃកូនក្មេងលូកបាន ។ យើងត្រូវឱនមើលសិនរន្ធនោះមានជាប់ពេបសៗឬអត់ ហើយត្រូវរករន្ធហុយរបស់វាមួយទៀតដែលនៅជិតនោះ ។ ពេលកាប់រន្ធកណ្តុរយើងត្រូវប្រយ័ត្នវារត់ចេញតាមរន្ធហុយ ។ ហើយពេលវារត់ចេញទាល់តែរហ័សណាស់ទើបអាចវាយវាបាន ។ ខ្ញុំពុំដែលចាប់កណ្តុរបាននឹងគេទេ ព្រោះវារត់លឿនណាស់ ក្មេងៗបេះតែឲ្យខ្ញុំម្នាក់ពីរ-បីៗ ឲ្យតែខ្ញុំដើរតាមវា ។ កណ្តុរអាំងមានរសជាតិឆ្ងាញ់ណាស់ ឆ្ងាញ់ជាងជ្រូកខ្វៃទៅទៀតសម័យនោះ ។ ប្តីខ្ញុំខស្សរាហ៍ត្រូវពិន័យឲ្យលើកដីជាច្រើនដង ព្រោះគាត់គេចទៅរកកណ្តុរពុំព្រមទៅធ្វើការ ។ កាលនោះក៏មានអ្នកខ្លះត្រូវបាត់ខ្លួនដោយសារតែរឿងទៅរកម្ហូបកណ្តុរពិសេសនេះដែរ ។

អ៊ំស្រីសយ ជាអ្នក១៧មេសាដូចពួកខ្ញុំដែរ ។ គាត់ប៉ុនដឹងរឿងច្រើនណាស់ព្រោះប្តីគាត់ជាអ្នកបររទេះគោខស្សរាហ៍ទៅនេះទៅនោះ ។ ព្រឹកនេះពេលបោចស្ទូងចម្ការ គាត់ខ្សឹបប្រាប់ខ្ញុំថា «យប់មិញប្តីគាត់ប្រាប់គាត់ថា ពេលទៅដឹកស្រូវនៅជើងវត្តគាត់ឮគេនិយាយពីមនុស្សម្នាក់ដែលគាត់ធ្លាប់ស្គាល់ដែរ ។ លោកនោះឈ្មោះ សឹង ភឿកថ ជាចាងហ្វាងកាសែតមាតុភូមិ ។ កាលគាត់ទៅដល់ភូមិនោះពីដំបូងគាត់ជាអ្នកមានសិទ្ធិអំណាចណាស់ ហើយមានកង់ជិះទៀត (សម័យនោះអ្នកមានកង់ជិះគឺសម្បើមណាស់) តែក្រោយមកគេដឹកគាត់និងគ្រួសារតាមឡានយកទៅបាត់ ពុំដឹងយកទៅណា ។

## ពេលរាត្រីរឭកស្នេហ៍វ័យក្មេង

ពេលរាត្រីជាឋានសួគ៌របស់ប្តីប្រពន្ធខ្ញុំ ព្រោះមានតែពេលយប់ទើបយើងនអាចរំឭកពីអនុស្សាវរីយ៍ចាស់ៗបាន ។ ក្រោមពន្លឺដួងច័ន្ទ ក្រោមដំបូលស្លឹកដែលប្រក់ដោយដៃមិនសូវប៉ិនប្រសប់របស់ប្តីសម្លាញ់ ខ្ញុំផ្អែកកាយលើស្មាគាត់ គាត់នាំខ្ញុំរំឭកពីគ្រាមួយដែលយើងស្គាល់គ្នាគ្រាដំបូង គឺពេលលេងអង្គញ់ក្នុងសាលារៀនក្នុងពេលបញ្ចប់វិស្សមកាល ។ ប្តីខ្ញុំហ៊ានណាស់មុខផ្ទះខ្ញុំត្រូវក្រហូងដោយម៉ូតូរបស់គាត់ ។ ទម្រាំយើងបានជួបគ្នាត្រូវចំណាយពេលរហូតបីឆ្នាំឯណោះ ។ ប្តីខ្ញុំរអ៊ូថាប៉ាខ្ញុំកាចណាស់ ។ ខ្ញុំនាំប្តីខ្ញុំនិយាយពីរឿងឆ្ងាញ់ម្តង ។ ខ្ញុំប្រាប់គាត់ថាខ្ញុំឃ្លាននំអាកោខ្ទិះនៅក្រោយវាំងដែលកាលណោះពេលគាត់មកពីដើរលេងជាមួយពួកម៉ាកវិញ គាត់តែងទិញផ្ញើខ្ញុំ ហើយបើត្រូវចិត្តខ្ញុំក៏ញ៉ាំ បើមិនត្រូវចិត្តខ្ញុំដាក់ចោលទាំងអស់ ។ ខ្ញុំប្រាប់គាត់ថា «ខ្ញុំស្តាយអាកោដែលចាក់ចោលពីពេលនោះណាស់បង» ។ ប្តីខ្ញុំអង្អែលក្បាលខ្ញុំហើយគាត់ថា «ចាំស្អែកបងរើសត្នោតទុំធ្វើអាកោត្នោតឲ្យញ៉ាំ» ។ ប្តីខ្ញុំនិយាយអ៊ីក៏ធូរដែរ គាត់ធ្វើមើលតែទីនោះមានសព្វគ្រប់អីចឹង ។ តែប៉ុណ្ណឹងខ្ញុំក៏ឆ្អែតដែរ ។ មានតែពេលយប់ទេដែលយើងអាចនិយាយពាក្យផ្អែមល្ហែមរកគ្នាបាន ។ ប្តីខ្ញុំតែងតែរើសស្លឹកត្នោតដាក់ជុំវិញខ្ទមនៅពេលយប់ បង្ការក្រែងបើមានអ្នកណាដើរមកលបស្តាប់យើងនឹងឮ ។

## មរណភាពកូនស្រីខ្ញុំ

កន្លះឆ្នាំកន្លងទៅ កូនស្រីទីពីររបស់ខ្ញុំឈឺជាទម្ងន់ វាញ៉ាំអីក៏ពុំបាន បេះតែក្អួត ។ នៅយប់មួយនោះជាយប់ដែលខ្ញុំពុំអាចបំភ្លេចបាន ដែលមានផ្គរលាន់ រន្ទះបាញ់ ផ្លេកបន្ទោរឆេះឆ្វាចគួរឲ្យខ្លាច កូនស្រីខ្ញុំក៏ទទួលមរណភាពទៅ ។ ខ្ញុំស្រែកទ្រហោយំប្រណាំងនឹងទឹកភ្លៀង «កូនស្រីមាសម្តាយ បើនៅផ្ទះយើងវិញម្តាយមិនឲ្យកូនស្លាប់បានទេ» ។ ប្តីខ្ញុំយកដៃក្តោបមាត់ខ្ញុំមិនឲ្យនិយាយទៀត ទាំងទឹកមុខភ័យខ្លាចលាយនឹងទឹកភ្នែក ។ គាត់ក៏ឈឺចាប់ណាស់ដែរ ប៉ុន្តែគាត់តាំងស្មារតីបានល្អជាងខ្ញុំ ។ ស្អែកឡើងអ្នកជិតខាងបានមកជួយយកសពកូនស្រីខ្ញុំទៅបញ្ចុះ ហើយពេល

ត្រឡប់មកវិញយើងក៏ត្រូវរកមាន់មួយមកកាប់ធ្វើបាយឲ្យគេហូបដើម្បីជាការដឹងគុណ ។ កូនស្រីខ្ញុំស្លាប់បានបីខែ ខ្ញុំដឹងថាខ្ញុំមានផ្ទៃពោះមួយទៀត ។ ពុទ្ធោកូនម្ដាយខំមកចាប់កំណើតអីនៅក្នុងឋាននរកហ្នឹង ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពោះរបស់ខ្ញុំចេះតែធំទៅៗ ប្រធានកងប្រធានក្រុមចេះតែដេញខ្ញុំមិនឲ្យទៅធ្វើការអស់ ។ គេថាពោះខ្ញុំជិតគ្រប់ខែហើយឈប់នៅផ្ទះចុះ តែខ្ញុំដឹងខ្លួនថាខ្ញុំ ទើបតែបានប្រាំបីខែប៉ុណ្ណោះ ។ ដោយនៅទំនេរពេកពេលគេចេញទៅធ្វើការ ខ្ញុំក៏ចេញទៅរកត្រកួនឈ្លក់ទឹកជាមួយក្មេងៗ ។ ត្រកួនឈ្លក់នៅក្នុងទឹកប្រហែលមួយម៉ែត្រ ចេញចុងតែស្លឹកបន្តិចប៉ុណ្ណោះ នៅលើទឹក ទាល់តែយើងជ្រមុជចូលក្នុងទឹកបន្តិចទើបអាចបេះវាបាន ។ ល្ងាចឡើង ខ្ញុំទូលត្រកួនមួយបាច់ធំមកផ្ទះរាល់ថ្ងៃ តែក៏ត្រូវដើរដោយប្រយ័ត្នប្រយែងដែរ ។ ខ្ញុំតែងតែរអ៊ូដាក់ប្ដីខ្ញុំដែលគាត់ឲ្យត្រកួនគេច្រើនៗពេក ។ ប្ដីខ្ញុំនិយាយថា យើងធ្វើចិត្តល្អទៅ ថ្ងៃក្រោយបើឯងមេម៉ាយវិញឯងក៏ប៉ះគេចិត្តល្អដូច្នេះដែរ ។ មិនស្មានថាពាក្យសម្ដីរបស់គាត់ក្លាយជាការពិតសោះ ។

## ឆ្លងទន្លេដោយគ្មានឆ្មប

យប់នេះខ្ញុំចាប់ផ្ដើមឈឺពោះតិចៗពីក្បាលព្រលប់ ដល់កណ្ដាលយប់ខ្ញុំឈឺខ្លាំងមែនទែន ។ ប្ដីខ្ញុំរវៀសរវៃរត់ទៅហៅឆ្មប ។ ថ្ងៃនោះទេសកាលអីមានបងស្រីម្នាក់មកស្នងនៅជិតភូមិខ្ញុំគាត់សុំផ្ទះខ្ញុំសម្រាកពេលយប់ ។ គឺគាត់នេះហើយជាអ្នកជួយអង្អែលពោះខ្ញុំ ។ កូនប្រុសខ្ញុំអង្គុយធ្វើមុខជូរហួញនៅជិតខ្ញុំព្រោះថាពុំដឹងជួយយ៉ាងម៉េច ។ មានម៉ែសយម្នាក់ទៀតដែលនៅជិតផ្ទះខ្ញុំ មកជួយបង្កាត់ភ្លើងដាំទឹកឲ្យខ្ញុំ ។ មួយស្របក់ធំប្ដីខ្ញុំត្រឡប់មកវិញតែម្នាក់ឯង ។ គាត់និយាយដូចចង់យំ យាយហួបគេមិនមកមើលយើងទេ ព្រោះប្រពន្ធប្រធានភូមិហៅគាត់ទៅដែរ ព្រោះចុកពោះ (ចុកពោះធម្មតា) ។ គេទៅមើលខាងណោះហើយ ហើយគេថា ប្ដីខ្ញុំទៅនិមន្តគេដែទទេ ដូច្នេះខុសត្រណមគេ បើគេមកក៏អ្នកឆ្លងទន្លេត្រូវស្លាប់ដែរ ។ ម៉ែសយលួចជេរដោយកំហឹង ។ គាត់យកកន្ត្រៃមួយដែលយកមកពីផ្ទះរបស់គាត់ដាក់ស្ងោរ ហើយគាត់និយាយលើកទឹកចិត្តខ្ញុំថា “កុំភ័យម៉ែអាភ័ក្ត្រ ចាំខ្ញុំបង្កើតឲ្យ ខ្ញុំក៏ចេះធ្វើឆ្មបដែរ” ។ យប់នោះពេលជិតភ្លឺខ្ញុំក៏ឆ្លងទន្លេបានកូនប្រុសមួយដោយសុខសប្បាយ ។ កូនខ្ញុំថ្លោសណាស់ ប្រហែលវាត្រូវមាត់រសជាតិត្រកួនក៏មិនដឹង ។ ព្រឹកឡើង ប្ដីខ្ញុំធ្វើបបរមាន់ជប់លៀង ម៉ែសយ និងបងស្រីម្នាក់ទៀតដែលជួយខ្ញុំ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ ម៉ែសយ និងបងស្រីម្នាក់ទៀត ដែលពេលនេះពុំដឹងគាត់ទៅដល់ទីណាហើយទេ ។ ក្នុងផ្ទះខ្ញុំហុយផ្សែងទ្រលោម ព្រោះខ្ញុំអាំងភ្លើង ។ ទាំងកូនទាំងប្ដីខ្ញុំហើមភ្នែកគ្រប់ៗគ្នា ។ ព្រឹកស្អែក ប្ដីខ្ញុំសុំច្បាប់បានបីថ្ងៃដើម្បីមើលថែខ្ញុំ ។ ល្ងាចនេះមិនដឹងជាចង្រៃអីខ្ញុំនឹកឃ្លានកាហ្វេដែលខ្ញុំពីដើមមកមិនចេះញ៉ាំផង ។ ខ្ញុំប្រាប់ប្ដីខ្ញុំទាំងអួលដើមកថាៈ

- បងអើយ ខ្ញុំឃ្លានកាហ្វេណាស់ ។

ប្ដីខ្ញុំមុខជូរហួញហើយដើរចេញទៅក្រៅបាត់ប្រហែលមួយម៉ោង ។ គាត់ត្រឡប់មកវិញដោយទឹកមុខញញឹមញញែម ។ គាត់ចាប់ផ្ដើមបង្កាត់ភ្លើងហើយយកបាយក្រៀមដែលមានសល់ប្រហែលពីរក្ដាប់ដាក់លីងចង់ខ្លោចបន្តិច ។ គាត់ចាក់ទឹកចូលដាំឲ្យពុះជាមួយបាយក្រៀមនោះ រួចដាក់ស្ករត្នោតមួយស្លាបព្រាចូល ។ ហើយគាត់ដកបានមើមស្មៅក្រវាញជ្រូកបួនប្រាំមើមលាងឲ្យស្អាតដំដាក់ចូលក្នុងទឹកពុះនោះ ។ ប្ដីខ្ញុំចាក់កាហ្វេដ៏ឆ្ងាញ់នោះចូលក្នុងត្រឡោក ហើយយកមកឲ្យខ្ញុំញ៉ាំ ដោយនិយាយថា÷

- អាបារាំងអើយ នេះហើយកាហ្វេដ៏ឆ្ងាញ់របស់យើងញ៉ាំទៅប្រពន្ធសម្លាញ់ ។

ខ្ញុំញ៉ាំហើយមានកម្លាំងប្រើស ។ ពុំដឹងគាត់បានមេតូតពីណាមក ។ កូនប្រុសភ័ក្ត្រខ្ញុំក៏ដណ្ដើមពីខ្ញុំញ៉ាំដែរ ។ យើងហាក់ភ្លេចខ្លួនថានៅក្នុងឋាននរក ។

ស្អែកឡើង ភ្លៀងធ្លាក់ខ្លាំងពេកក៏ហូរចូលរណ្ដៅខ្ញុំអាំងភ្លើងរលត់ភ្លើងខសរបស់ខ្ញុំអស់រលីង ។ ខ្ញុំអរណាស់ ព្រោះកំពុងតែផ្សាភ្នែកបើកពុំចង់រួចផង ។ ខ្ញុំគ្មានថ្នាំអ៊ីហូប គ្មានស្រាសសម្រាប់ផឹកកម្ដៅសរសៃខ្ទើរបស់ខ្ញុំទេ ។ ប្ដីខ្ញុំដាំទឹកថ្នាំឫសឈើដែលមិនដឹងថ្នាំអ៊ីខ្លះឲ្យខ្ញុំញ៉ាំ ។

រំលងបានបីខែ កូនប្រុសតូចខ្ញុំក៏ស្លាប់ទៅទៀត ព្រោះខ្ញុំគ្មានទឹកដោះឲ្យវាបៅ ។ ប្ដីខ្ញុំហួសពីគិត គាត់អង្គុយតែឱបកូនភ័ក្ត្រខ្ញុំខ្លាចបាត់បង់វាទៀត ។ **(នៅមានត)** **ហេង សុខផាន់ណា**

# ទឹកភ្នែកម៉ែ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បដិវត្តន៍របស់ខ្មែរក្រហម បានបណ្តេញប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជននានា ។ ក្នុងអំឡុងពេលនោះអំពើហិង្សានិងការកាប់សម្លាប់បានចាប់ផ្តើមកើតឡើងក្នុងគោលបំណងបង្កើតសង្គមបរិសុទ្ធមួយដែលហៅថា «បោសសម្អាតវណ្ណៈសក្តិភូមិ មូលធននាយទុន» ចេញឲ្យអស់ពីទឹកដីកម្ពុជា ហើយបង្កើតសង្គមថ្មីមួយ «ពីបាតដៃទទេ» ។ សិទ្ធិសេរីភាពគ្រប់បែបយ៉ាងត្រូវកាត់ផ្តាច់ ។ សូម្បីតែសិទ្ធិយំនិងសើចដែលធម្មជាតិបានផ្តល់ឲ្យមនុស្សក៏ត្រូវអង្គការកាត់ផ្តាច់យកដែរ ។ ការវែងភាពបរិសុទ្ធរបស់វណ្ណៈត្រូវបានធ្វើឡើងតាមរយៈទ្រព្យសម្បត្តិ ពាក្យសម្តី និងការងារ ។ ការសង្ស័យការតាមដានចាប់កំហុសពីម្នាក់ទៅម្នាក់កើតមានគ្រប់ទីកន្លែងទូទាំងប្រទេសហើយឈានដល់ការចាប់សម្លាប់ដើម្បីបំបាត់ធាតុសក្តិភូមិមូលធននាយទុន ។


ម្តាយរបស់ អែម សុខឃីម

ក្រុមគ្រួសាររបស់ខ្ញុំត្រូវបង្ខំចិត្តទុកជីតាចាស់ជរាចោលនៅក្នុងក្រុងភ្នំពេញ ហើយធ្វើដំណើរទៅគោកត្រប់ដែលជាភូមិកំណើតខាងម្តាយរបស់ខ្ញុំ ដោយសង្ឃឹមថានឹងមានការទំនុកបម្រុងពីបងប្អូននិងអ្នកស្រុកដែលស្គាល់នៅទីនោះ ។ ក្តីសង្ឃឹមរបស់គាត់ត្រូវរលាយអស់ពីព្រោះគាត់បែរជាត្រូវអង្គការចោទថាជា «វណ្ណៈមូលធន» ដែលជិះជាន់អ្នកក្រទៅវិញ ។ គ្មានសាច់ញាតិ និងអ្នកភូមិណាម្នាក់ហ៊ានរាប់អានម្តាយខ្ញុំឡើយ ដោយសារតែខ្លាចជាប់ពាក់ព័ន្ធជាមួយវណ្ណៈមូលធន ។ ទ្រព្យសម្បត្តិដែលម្តាយខ្ញុំមានទាំងប៉ុន្មានត្រូវរាយការណ៍ជូននិងប្រគល់ជូនអង្គការទុកជាសម្បត្តិទ្រព្យសម្បត្តិរួម ។ ម្តាយរបស់ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះទ្រព្យសម្បត្តិដែលគាត់ខិតខំប្រឹងប្រែងស្ទើរតែពេញមួយជីវិតរបស់គាត់ ។ ដើម្បីបង្ហាញពីភាពស្មោះត្រង់ម្តាយរបស់ខ្ញុំបានបង្ខំចិត្តយកទ្រព្យសម្បត្តិ និងគ្រឿងអលង្ការទាំងអស់ទៅប្រគល់ជូនអង្គការ ប៉ុន្តែបងស្រីរបស់ខ្ញុំបានសុំអង្វរម្តាយឲ្យរក្សាទុកចំណែករបស់គាត់ ។ ម្តាយរបស់ខ្ញុំបានយល់ព្រម ហើយក៏ជីកដីកប់ទុកនៅជិតសសរផ្ទះដោយសម្ងាត់ ។ ក្រោយពីការបោសសម្អាតធាតុមូលធន ប្រជាជនស្ទើរតែគ្មានសល់អ្វីទាំងអស់ សូម្បីតែចានឆ្នាំងក៏គ្មានសិទ្ធិទុកជាកម្មសិទ្ធិផ្ទាល់ខ្លួនដែរ ។ អ្វីៗដែលនៅសេសសល់ហើយមានធាតុសក្តិភូមិនាយទុន ត្រូវបំផ្លែងឲ្យស្របតាមសង្គមបដិវត្តន៍ ។ សូម្បីតែការរស់នៅរបស់ប្រជាជនក៏ត្រូវបំផ្លែងឲ្យស្របតាមជីវភាពសង្គមបដិវត្តន៍ដែរ បើមិនដូច្នេះទេនឹងត្រូវបោសសម្អាត ។ ទង្វើទាំងនេះបានធ្វើឲ្យជីវិតប្រជាជនបាត់បង់ជារៀងរាល់ថ្ងៃ ។

ម្តាយរបស់ខ្ញុំបានយកសម្លៀកបំពាក់ពណ៌ទាំងអស់ទៅជ្រលក់ពណ៌ខ្មៅដើម្បីឲ្យស្របតាមសន្តមបដិវត្តន៍បរិសុទ្ធ ។ ទោះបីគាត់ខំប្រតិបត្តិតាមវិន័យអង្គការយ៉ាងណាក៏គាត់នៅតែមានឈ្មោះថាពួកមូលធនដែរ ហើយត្រូវដានតាមយ៉ាងប្រយ័ត្នប្រយែងពី «កម្មាភិបាលភូមិ» ។ គាត់ទទួលការទិតៀននិងអប់រំពីអង្គការជារៀងរាល់យប់ឲ្យលះបង់ធាតុមូលធន ។ បងប្អូនស្រីប្រុសទាំង៦នាក់របស់ខ្ញុំដែលគ្រប់អាយុពលកម្ម ត្រូវអង្គការបង្ខំឲ្យទៅរស់នៅក្នុងជំរំកុមារដើម្បីបំពេញពលកម្មជូនអង្គការ ។ ខ្ញុំជាក្មេងស្រីម្នាក់ដែលមានសំណាងជាងគេក្នុងចំណោមបងប្អូនរបស់ខ្ញុំ ព្រោះខ្ញុំមិនទាន់គ្រប់អាយុត្រូវបញ្ជូនទៅជំរំកុមារ ហើយត្រូវរស់នៅក្នុងបន្ទុកឪពុកម្តាយ ប៉ុន្តែស្ថិតនៅក្រោមការមើលថែពីប្រជាជនមូលដ្ឋានដែលមានវ័យចំណាស់ ។ ក្រោយពីបញ្ជូនបងប្អូនខ្ញុំទៅជំរំកុមារបានប៉ុន្មានខែ ម្តាយរបស់ខ្ញុំកើតទុក្ខយ៉ាងខ្លាំងដោយឮដំណឹងថា បងប្រុសទី៤របស់ខ្ញុំត្រូវប្រធានកងកុមារវាយនិងចងបណ្តើរស្លាបសេកបណ្តើរអាក្រោសតាមផ្លូវបទលួចដំឡូងអង្គការបរិភោគ ។ ចំណែកបងស្រីទី៣របស់ខ្ញុំត្រូវប្រធានកងកុមារីធ្វើបាបនិងទិតៀនយ៉ាងខ្លាំងពីបទឈឺច្រើនធ្វើការមិនកើត ។ ម្តាយរបស់ខ្ញុំមិនហ៊ានយំនិងកើតទុក្ខឲ្យកម្មាភិបាលឃើញឡើយ បើមិនដូច្នេះទេ គាត់នឹងត្រូវចោទថា «ក្បត់បដិវត្តន៍» នៅមានធាតុមូលធន ហើយអាចមានគ្រោះថ្នាក់ដល់ខ្លួន ។

ម្តាយខ្ញុំបានប្រាប់ខ្ញុំថា ដោយសារតែរូបខ្ញុំគាត់ហៀបតែនឹងបាត់បង់ជីវិត ពីព្រោះខ្ញុំជាក្មេងស្រីដែលម្នាក់ចូលចិត្តដើរមិននៅផ្ទះ ហើយខ្ញុំត្រូវកូនអ្នកមូលដ្ឋានធ្វើបាបជាញឹកញាប់ ។ ថ្ងៃមួយ ម្តាយរបស់ខ្ញុំបានច្បាប់ឈប់សម្រាកក្រោយពីគាត់ឆ្លងទន្លេប្អូនប្រុសខ្ញុំបានប៉ុន្មានថ្ងៃ គាត់បានឮសំឡេងខ្ញុំស្រែកយំយ៉ាងខ្លាំង ។ គាត់បានចេញមកមើល ឃើញក្មេងប្រុសម្នាក់កំពុងវាយធ្វើបាបខ្ញុំ ។ ក្មេងប្រុសនោះឈ្មោះ អុល ជាកូនប្រធានភូមិ ។ ម្តាយរបស់ខ្ញុំបានហៅខ្ញុំឲ្យចូលផ្ទះហើយនិយាយប្រាប់ខ្ញុំថា «កុំយំកូន ចាំម៉ែប្រាប់ តាសុក ឲ្យចាប់វា» ។ ម្តាយរបស់ខ្ញុំនិយាយដូច្នេះដើម្បីលួងខ្ញុំឲ្យឈប់យំតែប៉ុណ្ណោះ ។ គាត់និយាយមិនទាន់ផុតពីមាត់ផង ស្រាប់តែមានសំឡេងស្ត្រីម្នាក់ស្រែកទាំងកំហឹងចេញពីផ្ទះប្រធានភូមិមក ។ ស្ត្រីនោះឈ្មោះ ពុយ ជាម្តាយរបស់ក្មេងប្រុសដែលធ្វើបាបខ្ញុំ និងជាប្រពន្ធរបស់ប្រធានភូមិឈ្មោះ អ៊ឹម ។ នៅសម័យនោះ ប្រពន្ធកម្មាភិបាលមិនសូវទៅធ្វើពលកម្មនៅតាមការដ្ឋានទេ ភាគច្រើននៅផ្ទះដើម្បីចាំឈ្លបយកការណ៍ពីប្រជាជន១៧មេសាដែលមិនទៅធ្វើការ ។

យាយពុយ ក៏ជាអ្នកភូមិដែលធ្លាប់ស្គាល់ម្តាយខ្ញុំយ៉ាងច្បាស់តាំងពីកុមារភាពមកម្ល៉េះ ។ ម្តាយខ្ញុំទើបតែផ្លាស់មកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧១ នៅពេលដែលភូមិកំណើតម្តាយខ្ញុំទទួលរងនូវការទម្លាក់គ្រាប់បែក ។ អ្នកភូមិដែលគ្មានបងប្អូនសាច់ញាតិនៅទីក្រុងភ្នំពេញត្រូវបង្ខំចិត្តរស់នៅ ក្រោមការដឹកនាំរបស់ខ្មែរក្រហម រហូតដល់ឆ្នាំ១៩៧៥ ។ ដោយសារ យាយពុយមិនដែលភៀសខ្លួនចេញពីភូមិស្រុកនិងធ្លាប់មានប្រវត្តិតស៊ូ អង្គការក៏បានតែងតាំងប្តីរបស់គាត់ជាប្រធានភូមិ ។ ឆ្លៀតឱកាសនោះ យាយពុយ បានថ្កោលទោសម្តាយរបស់ខ្ញុំនៅក្នុងអង្គប្រជុំ ហើយទាមទារឲ្យគាត់លះបង់ធាតុ «មូលធន» ចេញ ។ ទោះបីអង្គការបានប្រជុំស៊ុយទិតៀនម្តាយខ្ញុំយ៉ាងណាក៏ដោយ ក៏យាយពុយនៅតែមិនអស់ចិត្ត ហើយបានដើរប្រកូកប្រកាសប្រាប់ប្រជាជនទូទាំងភូមិក្រាំងធៃ ។ គាត់ធ្វើដំណើរដល់ទីណា គាត់និយាយរិះគន់អំពីម្តាយខ្ញុំនៅទីនោះ ។ ម្តាយរបស់ខ្ញុំមានការព្រួយបារម្ភជាខ្លាំង ។ គាត់តែងតែដើរគេចមុខពីយាយពុយជានិច្ច ។ ជាភ័ព្វសំណាងល្អដែលកម្មាភិបាលមួយចំនួននៅក្នុងភូមិធ្លាប់ស្គាល់ពីអត្តចរិតម្តាយរបស់ខ្ញុំតែងតែមានការយោគយល់ចំពោះគាត់ខ្លះ ហើយចេះតែធ្វើមិនដឹងមិនឮចំពោះការបរិហារកេរ្តិ៍របស់យាយពុយ ។ ប្រជាជន១៧មេសា ដែលត្រូវកម្មាភិបាលចោទប្រកាន់ដូច្នេះមានភាគតិចណាស់ដែលគេចរួចពីសេចក្តីស្លាប់ដោយការចោទប្រកាន់នេះ ។

ឆ្នាំ១៩៧៦ជាឆ្នាំដែលយុទ្ធនាការបោសសម្អាតកណ្តុរបានធ្វើឡើងគ្រប់ភូមិទាំងអស់ ។ យុទ្ធនាការនេះត្រូវបានដាក់កំហិតឲ្យប្រជាជនម្នាក់សម្លាប់កណ្តុរយ៉ាងតិច៥ក្នុងមួយថ្ងៃនៅក្រៅពីម៉ោងធ្វើការ ។ ដើម្បីបំពេញផែនការរបស់អង្គការ ប្រជាជនម្នាក់ៗខំប្រឹងប្រែងស្វែងរកកណ្តុរពីផ្ទះមួយទៅផ្ទះមួយ ។ ចៃដន្យអាក្រក់ កណ្តុរបានធ្វើរូងជិតជើងសសរចំកន្លែងដែលម្តាយខ្ញុំកប់មាសទុក ។ ប្រជាជនមូលដ្ឋានម្នាក់បានជីកឃើញកំប៉ុងមាសដែល

ម្តាយខ្ញុំកប់ ហើយបានយកមាសនោះទៅឲ្យរាយការណ៍ឲ្យប្រធានក្រុម ។ សំឡេងខ្សឹបខ្សៀវពីមាត់មួយទៅមាត់មួយបានលេចឮសុសសាយពេញទាំងភូមិ ។ ភាពភ័យរន្ធត់ចេះតែកើតមានជាបន្តបន្ទាប់ចំពោះម្តាយខ្ញុំ ។ ម្តាយខ្ញុំមានការព្រួយបារម្ភកាន់តែទ្វេឡើងអំពីទោសកំហុសរបស់គាត់ដែលមិនស្មោះត្រង់ជាមួយអង្គការ ។ ម្តងនេះតើគាត់អាចគេចរួចពីសេចក្តីស្លាប់ឬទេ? ក្នុងឆ្នាំនោះក៏ជាឆ្នាំដែលអង្គការថ្នាក់លើមានការសង្ស័យលើកម្មាភិបាលគ្រប់ជាន់ថ្នាក់ ហើយកម្មាភិបាលមួយចំនួនត្រូវចាប់ខ្លួន ។ តាអ៊ឹម ជាប្រធានភូមិក្រាំងដៃ និងជាប្តីរបស់ យាយពុយ ត្រូវអង្គការហៅទៅរៀនសូត្រមិនឃើញវិលត្រឡប់មកវិញ ។ គាត់ហាក់បីដូចជាដឹងកំហុសដែលធ្វើចំពោះម្តាយរបស់ខ្ញុំ ។ គាត់បានជួយនិយាយលាក់បំពួនទោសកំហុសរបស់ម្តាយខ្ញុំ ដោយមិនបញ្ជូនមាសទៅអង្គការថ្នាក់លើឡើយ ។ គាត់បានប្រគល់មាសនោះឲ្យមកម្តាយខ្ញុំវិញដោយគ្រាន់តែនិយាយថា “កុំធ្វេសប្រហែសដូច្នេះទៀត” ។ កន្លះខែក្រោយមក យាយពុយ ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនទៅគុកសង់នៅទន្លេបាទីជាមួយប្តីរបស់គាត់ ។

ក្រោយឆ្នាំ១៩៧៩ យាយពុយ និងកូនប្រុសឈ្មោះ អុល នៅរស់រានមានជីវិត ហើយបានត្រឡប់មកស្រុកកំណើតវិញ ។ គាត់បានរៀបរាប់ប្រាប់អ្នកភូមិអំពីជីវិតរបស់គាត់និងប្តីគាត់នៅក្នុងគុកសង់ ។ អ្នកភូមិដែលធ្លាប់ធ្វើការនៅក្នុងគុកសង់បានឲ្យដឹងថា តាអ៊ឹម ត្រូវអង្គការធ្វើទារុណកម្មយ៉ាងខ្លាំងហើយបង្ខំឲ្យឆ្លើយសារភាពពីបក្ខពួកក្បត់ ។ នៅក្នុងចម្លើយសារភាពរបស់គាត់មានរាយឈ្មោះមនុស្សជាច្រើនក្នុងបញ្ជីក្បត់ ។ ក្នុងបណ្តាឈ្មោះអ្នកទាំងនោះ មានមួយចំនួនត្រូវអង្គការចាប់យកទៅសម្លាប់ ។

ក្នុងនាមជាពុទ្ធសាសនិកម្នាក់ ម្តាយខ្ញុំមិនដែលមានគំនិតចងគំនុំជាមួយ យាយពុយ ម្តងណាឡើយ ។ គាត់កាន់តែមានការអាណិតអាសូរចំពោះ យាយពុយ ដែលក្លាយជាស្ត្រីមេម៉ាយនិងមានកូន៤នាក់ក្នុងបន្ទុក ។ គាត់មិនដែលរំឭករឿងអតីតកាលចំពោះមុខ យាយពុយទេ ដើម្បីកុំឲ្យយាយពុយមានការអៀនខ្មាសចំពោះទង្វើរបស់គាត់ក្នុងរបបខ្មែរក្រហម ផ្ទុយទៅវិញ យាយពុយ នៅតែប្រើអាកប្បកិរិយាឆេវឆាវ ។ គាត់បានមកព្រមានម្តាយខ្ញុំជាលើកទី២ពេលដែលខ្ញុំវាយ អុល ក្នុងពេលដែលលេងជាមួយគ្នាកាលពីទសវត្សរ៍ឆ្នាំ១៩៨០ ។ ម្តាយរបស់ខ្ញុំមិនប្រកាន់ចំពោះគាត់ឡើយ ព្រោះម្តាយខ្ញុំយល់ថាខ្ញុំធ្វើខុស ហើយសន្យាថាគាត់នឹងប្រដៅខ្ញុំឲ្យឈប់ធ្វើដូច្នេះទៀត ។

ជាការសងសឹកនិងនឹកឃើញរឿងអតីតកាលដែល អុល តែងតែធ្វើបាបខ្ញុំជារៀងរាល់ថ្ងៃនៅក្នុងរបបខ្មែរក្រហមនោះ ខ្ញុំបានវាយ អុល នឹងផាងត្នោតដែលមានបន្លា ធ្វើឲ្យ អុល ឈឺយ៉ាងខ្លាំង ។ អុល បានយំរៀបរាប់ប្រាប់ម្តាយតាមនិស្ស័យក្មេងក្នុងគោលបំណងឲ្យម្តាយសងសឹកជំនួសវិញ ។ វាជារឿងឆ្កួតលេលា ណាស់ ដែលខ្ញុំសងសឹកចំពោះ អុល វិញដោយមិនដឹងថាអ្វីត្រូវអ្វីខុសនោះ ។

អស់រយៈពេល២៥ឆ្នាំមកហើយ ដែលរឿងរ៉ាវក្នុងរបបខ្មែរក្រហមបានកើតឡើងចំពោះម្តាយរបស់ខ្ញុំនិងប្រជាជនកម្ពុជាទាំងអស់ ។ ខ្ញុំនៅតែនឹកឃើញដំណក់ទឹកភ្នែកម្តាយខ្ញុំ ដោយសារគាត់បានបោះបង់ចោលជីតាចាស់ជរារបស់ខ្ញុំនៅទីក្រុងភ្នំពេញកាលពីឆ្នាំ១៩៧៥ ។ គាត់តែងតែបង្ហូរទឹកភ្នែកនៅពេលដែលគាត់ឃើញឪពុកជរាហើយមានជំងឺមិនអាចងើបរួចពីកន្ទេល ។ ម៉ែបានប្រាប់ខ្ញុំថា គាត់មិនអាចបំភ្លេចនូវការឈឺចាប់ទាំងអស់នេះបានឡើយក្នុងមួយជីវិតរបស់គាត់ ។ ឥឡូវម៉ែបានលាចាកលោកនេះទៅទាំងមិនបានទទួលភាពយុត្តិធម៌ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលគាត់ខំរង់ចាំអស់រយៈ ពេលជាង២០ឆ្នាំមកនេះ ។ ម៉ែបានស្លាប់ទាំងបិទភ្នែកមិនជិតកាលពីឆ្នាំ២០០៣កន្លងទៅដោយបន្សល់ទុកការឈឺចាប់នេះដល់កូនៗជំនួសវិញ ។

**វ៉អែម សុខឃីម**

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# សេចក្តីប្រកាសរកប្អូនពីរនាក់

នាងខ្ញុំឈ្មោះ ទេស ស្រេង អាយុ៥២ឆ្នាំ ឪពុកឈ្មោះ ទេស (ស្លាប់) និងម្តាយឈ្មោះ ម៉ម វ៉ិន (ស្លាប់) មានស្រុកកំណើតនៅភូមិក្រាំងយ៉ុក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ។ បច្ចុប្បន្ននេះរស់នៅក្នុងភូមិពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ។

សូមសួររកប្អូនពីរនាក់ឈ្មោះ

១) ទេស ទុយ ភេទប្រុស ចេញពីផ្ទះនៅក្នុងឆ្នាំ១៩៧២ ចូលធ្វើជាយោធា ។

២) ទេស តែម ចេញពីផ្ទះនៅក្នុងឆ្នាំ១៩៧២ ដើម្បីចូលកងកុមារ ។

កាលពីឆ្នាំមុនធ្លាប់មានដំណឹងថាឈ្មោះទាំងពីរនេះរស់នៅអន្លង់វែង ។

ប្រសិនបើអស់លោកលោកស្រីបានដឹងពីពត៌មានដែលទាក់ទងនឹងឈ្មោះខាងលើ សូមផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកក្មួយៗ

នាងខ្ញុំឈ្មោះ អ៊ុក សាអែម (បច្ចុប្បន្នហៅ សាជៀប) ភេទស្រី កើតឆ្នាំរោង (១៩៥០) នៅភូមិមហាសៀកក្រោម ឃុំក្រញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សូមសួររកក្មួយៗឈ្មោះ

១) អ៊ុក សំរិត ភេទប្រុស ។ ម្តាយឈ្មោះ អ៊ុយ ឌីម ឪពុកឈ្មោះ អ៊ុក សេន ។ កើតនៅភូមិមហាសៀកក្រោម ឃុំក្រញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ជាកងទ័ពរណសិរ្សបាត់ខ្លួនតាំងពីឆ្នាំ១៩៧៣ កាលនោះអាយុ១៦-១៧ឆ្នាំ ។

២) អ៊ុក ធារិទ្ធ ភេទប្រុស និង អ៊ុក ស្រីមុំ ហៅ ធានី ភេទស្រី ។ ទាំងពីរនាក់នេះអាយុ១២និង១៣ឆ្នាំ ។ កាលបាត់ខ្លួននៅខេត្តពោធិសាត់ឆ្នាំ១៩៧៩ ។ ពេលបាត់ខ្លួននោះម្តាយទៅស្ទូង ឪពុកទៅរកត្រី ។ ម្តាយឪពុកស្រុកកំណើតនៅភូមិមហាសៀក តែកូនទាំងពីរធំដឹងក្តីនៅពោធិចិនតុង ។

បើបងប្អូនណាបានទទួលដំណឹងពីឈ្មោះទាំងបីខាងលើ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬតាមប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។ សូមអរគុណ ។






ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១ ០ ០ ០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ៧ ០ ០ ០រៀល

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 52, April 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**